រាជបណ្ឌិត្យសភាកម្ពុជា

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

នាយកដ្ឋាន ធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ

# បច្ចុប្បន្នភាពនៃយេនឌ័រនិងតួនាទីយេនឌ័រនៅកម្ពុជា



ស្រាវជ្រាវនិងចងក្រងដោយ **បណ្ឌិត ជា វណ្ណី**

ឆ្នាំ២០២៤

# មាតិកា

**ចំណងជើងអត្ថបទ** **ទំព័រ**


អារម្ភកថា.....................................................................................១
បច្ចុប្បន្នភាពនៃយេនឌ័រនិងតួនាទីយេនឌ័រនៅកម្ពុជា.......................................២
ន័យនៃពាក្យយេនឌ័រ.........................................................................៧
ន័យនៃតួនាទីយេនឌ័រ.......................................................................១២
យេនឌ័រនិងការងារ.........................................................................១៦
យេនឌ័រនិងការស្វែងរកការគាំទ្រ..........................................................២១
បច្ចុប្បន្នភាពនៃការលើកកម្ពស់តួនាទីយេនឌ័រ.......................................២៧
សិទ្ធិស្មើភាពរវាងស្ត្រី-បុរសជាអន្តរជាតិ.............................................៤៦
ការលើកកម្ពស់យេនឌ័រក្នុងសង្គមខ្មែរ...............................................៥៥
ប្រវត្តិទិវានារីអន្តរជាតិ និងសង្គមខ្មែរ...............................................៦៥
តួនាទីស្ត្រីខ្មែរតាមសម័យកាលនីមួយៗ.................................................៨៦
ស្ត្រីក្នុងតួនាទីធ្វើសេចក្ដីសម្រេច.......................................................១៣៥
តួនាទីស្ត្រី និងច្បាប់.......................................................................១៣៩
តម្លៃអប់រំស្ត្រីតាមទស្សនៈព្រះពុទ្ធសាសនា.........................................១៤១
តម្លៃអប់រំស្ត្រីខ្មែរតាមរយៈច្បាប់ស្រី.................................................១៥២
ស្ត្រី និងច្បាប់សម័យទំនើប.............................................................១៩៣
ការអប់រំឥរិយាបថ...........................................................................២០២
គន្ថនិទ្ទេស...................................................................................២១៣
ឧបសម្ព័ន្ធ....................................................................................២១៥
ជីវប្រវត្តិអ្នកនិពន្ធ...........................................................................២១៨

# អារម្ភកថា

សៀវភៅ ស្តីពី **បច្ចុប្បន្នភាពនៃយេនឌ័រនិងតួនាទីយេនឌ័រនៅកម្ពុជា** គឺមានសារៈសំខាន់ណាស់ ដ្បិតវាជាគោលសម្រាប់បង្ហាញឱ្យឃើញពីតួនាទីបុរស និងស្ត្រីក្នុងការចូលរួមចំណែកក្នុងសង្គមជាតិលើគ្រប់វិស័យ ជាពិសេសគឺស្ត្រីដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ សង្គម និងគ្រួសារ ប៉ុន្តែជាញឹកញយស្ត្រីត្រូវបានសង្គម និងគ្រួសារបំភ្លេចចោល ហើយចាត់ទុកការចូលរួមនៅក្នុងសង្គមរបស់ស្ត្រី គឺជារឿងធម្មតាទៅវិញ។ បច្ចុប្បន្នមានបុរសជាស្វាមី ឬក្រុមគ្រួសារមួយចំនួនបានលើកឡើងនូវពំនោលថា ភរិយា ម្តាយ ឬបងប្អូនស្រីរបស់ខ្លួន មិនមានធ្វើអ្វីទេ គឺនៅតែផ្ទះ។ តែទន្ទឹមនឹងពំនោលស្ត្រីនៅតែផ្ទះនេះ គឺការងារ ១០០ជំពូកស្ថិតកំពុងស្ថិតក្នុងកណ្តាប់ដៃស្ត្រីដែលជាអ្នកនៅផ្ទះនោះ គឺស្ត្រីជាកម្មករក្នុងគ្រួសារ ស្ត្រីជាអ្នកបោសជូតបោកគក់ ស្ត្រីជាចុងភៅ ស្ត្រីជាអ្នកមើលថែកុមារនិងមនុស្សចាស់ជរា ក៏ដូចជាការមើលការខុសត្រូវនូវរាល់ការងាររាក់ជ្រៅសព្វយ៉ាង ដែលស្ត្រីមិនដែលបានទទួលកម្រៃថ្លៃឈ្នួលពីការងារទាំងនោះទេ។ បើនិយាយពីស្ត្រីដែលជាមន្ត្រីរាជការ ជាគ្រូបង្រៀន ជាកម្មករ ជាអាជីវករ ...ដែលចេញទៅធ្វើការនៅតាមស្ថាប័ន ក្រសួង មន្ទីរ រោងចក្រ សហគ្រាស ឬតាមកន្លែង អាជីវកម្មនានា គឺស្ត្រីត្រូវធ្វើការទាំងនោះបន្ថែមមួយជំពូកទៀត។ ដូច្នេះ «*ក្នុងនាមយើងជាស្ត្រី និងក្នុងនាមយើងជាមនុស្សនៅក្នុងសង្គម យើងត្រូវដឹងឱ្យបានច្បាស់ថា ស្ត្រីជាកម្លាំងចលករ ស្ត្រីជាឆ្អឹងខ្នងដ៏សំខាន់នៃសេដ្ឋកិច្ច ស្ត្រីជាផ្នែកមួយដ៏សំខាន់ដែលធ្វើឱ្យសង្គមជាតិ សង្គមគ្រួសាររឹងមាំ ស្ត្រីមិនមែនជាជនរងគ្រោះ ឬជាជនទន់ខ្សោយនោះឡើយ*»។

ទន្ទឹមនឹងការយកចិត្តទុកដាក់ពីសង្គមនេះ បុរសនិងស្ត្រីខ្លួនឯងក៏គួរតែត្រូវខិតខំពង្រីកចំណេះដឹងពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីជម្នះរាល់ការលំបាកក៏ដូចជាឧបសគ្គនានា ឈានទៅរកភាពជោគជ័យក្នុងតួនាទីនិងភារកិច្ចរបស់ខ្លួនជាបន្ត។ បើយោងតាមការអង្កេតជាទូទៅ ស្ត្រីជាផ្នែកមួយនៃដំណើរការរបស់យុទ្ធនាការសិទ្ធិស្ត្រី ក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាព និងសមធម៌ជាមួយបុរស។ យើងទាំងអស់គ្នាបានដឹងហើយថា ការបង្កើនភាពអង់អាចដល់ស្ត្រី គឺជាកត្តាចាំបាច់ក្នុងការផ្លាស់ប្ដូរផ្នត់គំនិតនៃការគិតគូសម្រាប់ការអភិវឌ្ឍនិងកសាងប្រទេសក្នុងភាពជាយេនឌ័រនៃកម្ពុជា។

ក្នុងសៀវភៅនេះក៏បានបង្ហាញផងដែរពីតួនាទីយេនឌ័រ ដែលជាការរៀបរាប់ពីអ្វីដែលបុរសនិងស្ត្រីរំពឹងថានឹងធ្វើអ្វីមួយបាន។ បុរសត្រូវបានគេរំពឹងទុកថា ជាអ្នកទទួលបន្ទុកចេញទៅធ្វើការងារខាងក្រៅដូចជា ធ្វើជារាជការ ធ្វើជាអ្នកជំនួញ ធ្វើស្រែចម្ការ កាប់អុស រកត្រី រីឯស្ត្រីវិញគឺជាអ្នកចម្អិនអាហារមើលថៃកូន។ ចាប់តាំងពីបានបង្កើតតួនាទីយេនឌ័រ ធ្វើឱ្យមានការផ្លាស់ប្ដូរការទទួលខុសត្រូវការងាររបស់បុរស និងស្ត្រីក្នុងជីវិតរស់នៅ និងការយល់ដឹងពីឥទ្ធិពលនៃយេនឌ័រ ទៅលើការអនុវត្តឱ្យបានល្អសម្រាប់បុរសនិងស្ត្រី។ វាអាចមានភាពលម្អៀងនៃយេនឌ័រ ដែលមានដែនកំណត់សម្រាប់អ្វីដែលបុរសនិងស្ត្រីក្នុងការធ្វើសកម្មភាពនានាទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ ប៉ុន្តែនៅក្នុងការរស់នៅជាក់ស្ដែង ភាគច្រើនគឺបុរសជាអ្នកគ្រប់គ្រងក៏ពិតមែន តែស្ត្រីជាអ្នកចាត់ចែងគ្រប់យ៉ាង។ តួនាទីយេនឌ័រ មានសារៈសំខាន់ណាស់ក្នុងការចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពរបស់គ្រួសារ និងសហគមន៍ ក្នុងការចែករំលែកការទទួលខុសត្រូវដោយផ្អែកលើសមភាពយេនឌ័រ។

# បច្ចុប្បន្នភាពនៃយេនឌ័រ និងតួនាទីយេនឌ័រនៅកម្ពុជា

នាពេលបច្ចុប្បន្ននេះ កម្ពុជាជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ខ្លួនពីប្រទេសកំពុងអភិវឌ្ឍន៍ឆ្ពោះទៅជាប្រទេសអភិវឌ្ឍន៍មួយឱ្យដូចបណ្តាប្រទេសនានានៅលើពិភពលោកដែរ។ នៅក្នុងការប្រតិបត្តិលើគ្រប់វិស័យនោះ កម្ពុជាបាននឹងកំពុងតែធ្វើការលើកកម្ពស់ការយល់ដឹងសង្គមដល់ប្រជាពលរដ្ឋទាំងពីរភេទ ក្នុងការផ្តល់នូវភាពក្លាហានដល់យេនឌ័រក្នុងការបំពេញភារកិច្ចរបស់ខ្លួន គឺមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងជាទីមោទនៈ។ យ៉ាងណាមិញ ការផ្តល់ភាពក្លាហានចំពោះស្ត្រីនៅក្នុងប្រទេសកម្ពុជាយើង ក៏មានការយកចិត្តទុកដាក់ជាពិសេសផងដែរ  គឺស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសង្គមស្ទើរគ្រប់វិស័យ។ ស្ត្រីពិតជាមានភារកិច្ចយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការជួយបង្កើនសេដ្ឋកិច្ចគ្រួសារ ហើយស្ត្រីក៏ជាឆ្អឹងខ្នងដ៏សំខាន់ក្នុងការជួយបង្កើនសេដ្ឋកិច្ចសង្គមកម្ពុជាដែលមិនអាចខ្វះបាន។

ប៉ុន្តែបើយើងធ្វើការសង្កេតជាទូទៅឃើញថា ទាំងអង្គការសង្គមស៊ីវិលក៏ដូចជាក្រសួង មន្ទីរ និងស្ថាប័នមួយចំនួន ដែលមានទាំងក្រសួងកិច្ចនារី បានកត់សម្គាល់ឃើញថា បើទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តនូវគោលនយោបាយលើកកម្ពស់ភាពអង់អាចក្លាហានរបស់ស្ត្រីក្នុងសង្គមយ៉ាងណាក៏ដោយ ក៏គេនៅតែសង្កេតឃើញថា បញ្ហាយេនឌ័រ ជាពិសេសស្ត្រីនៅតែជួបបញ្ហាប្រឈមមួយចំនួន ក្នុងការរួមចំណែកអភិវឌ្ឍន៍គ្រួសារក៏ដូចជាសង្គម

ជាតិខ្លួន ដែលបញ្ហាទាំងនេះ រាជរដ្ឋាភិបាលបាននឹងកំពុងពង្រឹង និងពង្រីកការយកចិត្តទុកដាក់បន្ថែមទៀតចំពោះស្ត្រី។

ទន្ទឹមនឹងការយកចិត្តទុកដាក់ពីសង្គមនេះ ស្ត្រីខ្លួនឯងក៏គួរតែត្រូវខិតខំពង្រីកចំណេះដឹងពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីជម្នះរាល់ឧបសគ្គ ឈានទៅរកភាពជោគជ័យក្នុងតួនាទីនិងភារកិច្ចរបស់ខ្លួនជាស្ត្រី។ បើយោងតាមការអង្កេតជាទូទៅ ស្ត្រីជាផ្នែកមួយនៃដំណើរការរបស់យុទ្ធនាការសិទ្ធិស្ត្រី ក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាព និងសមធម៌។ ស្ត្រីគឺជាឆ្អឹងខ្នងសេដ្ឋកិច្ចជាតិ សង្គម និងគ្រួសារ ប៉ុន្តែជាញឹកញយស្ត្រីត្រូវបានសង្គម និងគ្រួសារបំភ្លេចចោល ហើយយកការចូលរួមនៅក្នុងសង្គមរបស់ស្ត្រី គឺជារឿងធម្មតាទៅវិញ។ បច្ចុប្បន្នមានបុរសជាស្វាមី ឬក្រុមគ្រួសារមួយចំនួនបានលើកឡើងនូវពំនោលថា ***ភរិយា ម្តាយ ឬបងប្អូនស្រីរបស់ខ្លួន មិនមានធ្វើអ្វីទេ គឺនៅតែផ្ទះ។*** តែទន្ទឹមនឹងពំនោល ស្ត្រីនៅតែផ្ទះនេះ គឺការងារ១០០ជំពូកស្ថិតក្នុងកណ្តាប់ដៃស្ត្រីដែលជាអ្នកនៅផ្ទះនោះ គឺស្ត្រីជាកម្មករក្នុងគ្រួសារ ស្ត្រីជាអ្នកបោសជូតបោកគក់ ស្ត្រីជាចុងភៅ ស្ត្រីជាអ្នកមើលថៃកុមារនិងមនុស្សចាស់ជរាក៏ដូចជាការមើលការខុសត្រូវនូវរាល់ការងាររាក់ជ្រៅសព្វយ៉ាង ដែលស្ត្រីមិនដែលបានទទួលកម្រៃថ្លៃឈ្នួលពីការងារទាំងនោះទេ។ ដូច្នេះ ក្នុងនាមយើងជាស្ត្រី និងក្នុងនាមយើងជាមនុស្សនៅក្នុងសង្គម យើងត្រូវដឹងឱ្យបានច្បាស់ថាស្ត្រីជាកម្លាំងចលករ ស្ត្រីជាឆ្អឹងខ្នងដ៏សំខាន់នៃសេដ្ឋកិច្ច ស្ត្រីជាផ្នែកមួយដ៏សំខាន់ដែលធ្វើឱ្យសង្គមជាតិ សង្គមគ្រួសាររឹងមាំ ដោយស្ត្រីមិនមែនជាជនរងគ្រោះ ឬជាជនទន់ខ្សោយនោះឡើយ។

ពាក់ព័ន្ធនឹងការផ្តល់ភាពអង់អាចក្លាហាន ក៏ដូចជាការលើកកម្ពស់ចំពោះស្ត្រី ការផ្តល់ភាពអង់អាចក្លាហានផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅលើពិភពលោកនាពេលបច្ចុប្បន្ននេះ ត្រូវបានគេចាត់ទុកថា វាជាយុទ្ធសាស្ត្រចាំបាច់ ក្នុងការផ្លាស់ប្តូរផ្នត់គំនិត នៃការគិតគូអំពីគម្លាតយេនឌ័រនៃសេដ្ឋកិច្ច។ យ៉ាងណាមិញ ប្រទេសកម្ពុជា គឺជាសង្គមសមូហភាពមួយដែលអាចបង្កើនសក្តានុពលភាពនៃធនធានស្ត្រីឱ្យក្លាយទៅជាធនធានដែលមានតម្លៃនៅក្នុងសេដ្ឋកិច្ច និងសង្គមផងដែរ គឺតាមរយៈការលើកកម្ពស់សិទ្ធិស្ត្រី។ តែទោះជាយ៉ាងណាក៏ដោយ ក៏ស្ត្រីនៅតែជួបបញ្ហាប្រឈមមួយចំនួនផងដែរក្នុងការលើកស្ទួយ ជួយពង្រឹងសេដ្ឋកិច្ចក្នុងគ្រួសាររបស់ខ្លួន។ បញ្ហាប្រឈមទាំងនោះមានដូចជា ស្ត្រីនៅតែប្រឈមនូវបញ្ហាក្នុងការចាប់ផ្តើមដំណើរការពង្រីកនិងពង្រឹងអាជីវកម្មរបស់ខ្លួន ស្ត្រីជាទូទៅនៅតែទទួលបានឱកាស និងការគ្រប់គ្រងចំណូលសេដ្ឋកិច្ចតិចតួចជាងបុរស ហើយមិនតែប៉ុណ្ណោះ ស្ត្រីថែមទាំងទទួលបន្ទុកគ្រួសារ ជាពិសេសសមាជិកចាស់ជរាក្នុងគ្រួសារ និងការងារគ្មានប្រាក់កម្រៃ ក៏ដូចជាការងារដែលងាយរងគ្រោះជាច្រើន។

យើងទាំងអស់គ្នាបានដឹងហើយថា ការបង្កើនភាពអង់អាចដល់ស្ត្រី គឺជាកត្តាចាំបាច់ក្នុងការផ្លាស់ប្តូរផ្នត់គំនិតនៃការគិតគូសម្រាប់ការអភិវឌ្ឍ និងការកសាងប្រទេស។ មានស្ត្រីមួយចំនួនដែលជាអ្នកធ្វើការតាមរោងចក្រនិងសហគ្រាសនានា បានយកកម្រៃថវិកាដែលនាងទទួលបានពីការធ្វើការតាមរោងចក្រ និងសហគ្រាសទាំងនោះ ទៅជួយផ្គត់ផ្គង់ដល់សាច់ញាតិរបស់ខ្លួន ជាពិសេសគឺជួយដល់មាតាបិតាដែលចាស់ជរា និងផ្គត់ផ្គង់ដល់បងប្អូនកូនក្មួយដែលកំពុងបន្តការសិក្សានៅតាមភូមិសិក្សានានាផងដែរ។ ដូច្នេះការងារ

តាមរោងចក្រនិងសហគ្រាស ក៏បានរួមចំណែកយ៉ាងសំខាន់ជាមួយរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គមកម្ពុជា ហើយរដ្ឋាភិបាលក៏បាននិងកំពុងតែបង្កើន ពង្រឹង និងពង្រីកការយកចិត្តទុកដាក់លើកកម្ពស់សិទ្ធិស្ត្រីឱ្យបានច្រើនថែមទៀត ដើម្បីផ្តល់នូវតម្លៃដល់ស្ត្រីដែលបម្រើការងារតាមរោងចក្រទាំងនោះបន្ថែមទៀតផងដែរ ដ្បិតសព្វថ្ងៃនេះ ការឱ្យតម្លៃរបស់សង្គមទៅលើស្ត្រីនៅមានកម្រិតនៅឡើយ។ នាពេលកន្លងមក ស្ត្រីដែលបម្រើការនៅតាមរោងចក្រ និងសហគ្រាសទាំងនោះ តែងតែបានស្នើឱ្យរាជរដ្ឋាភិបាលលើកស្ទួយស្ត្រីឱ្យបានច្រើន ហើយត្រូវផ្តល់តម្លៃស្ត្រីឱ្យបានកាន់តែច្រើន ដ្បិតស្ត្រីអាចធ្វើអ្វីៗបានគ្រប់យ៉ាងទាំងអស់ ដែលមានការងារខ្លះ បុរសមិនអាចធ្វើបានទៀតផង ប៉ុន្តែស្ត្រីអាចធ្វើបានដូចជា ការពពោះ ការបង្កើតកូន ការចិញ្ចឹមកូនដោយទឹកដោះម្តាយ ក៏ដូចជាការមើលថែបីបាច់សមាជិកក្នុងគ្រួសារ និងការចិញ្ចឹមបីបាច់ថែរក្សាកូនដោយមានទំនួលខុសត្រូវ»។

សព្វថ្ងៃក្រៅពីវិស័យសេដ្ឋកិច្ច ស្ត្រីខ្មែរក៏បានចូលប្រឡូកស្ទើរគ្រប់វិស័យទាំងវិស័យសង្គមកិច្ច សេដ្ឋកិច្ច និងនយោបាយផងដែរ ដែលបានបង្ហាញតាមរយៈការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់កន្លងមក គឺគណបក្សនយោបាយនីមួយៗបានចាប់អារម្មណ៍និងផ្តល់ឱកាសឱ្យស្ត្រីក្លាយជាបេក្ខជន ហើយរដ្ឋាភិបាលសព្វថ្ងៃក៏បានលើកបង្ហាញពីតម្លៃ ពីប្រភព និងការចូលរួមចំណែករបស់ស្ត្រី។ ជាក់ស្តែងដូចជាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ កន្លងទៅ អតីតប្រមុខរដ្ឋាភិបាល គឺសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានលើកឡើងពី

បច្ចុប្បន្នភាព ស្ត្រីបានចូលរួមចំណែកក្នុងកិច្ចការងារជាច្រើនវិស័យ[១] រួមទាំងបញ្ហាដែលស្ត្រីជួបប្រទះក្នុងវិស័យសេដ្ឋកិច្ចទាំងក្នុងគ្រួសារនិងសង្គម និងលើកឡើងពីតម្រូវការរបស់ស្ត្រី ក្នុងការទទួលបានសេវាសង្គមជាមូលដ្ឋានប្រកបដោយគុណភាព សមធម៌ ក៏ដូចជាការពង្រឹងនិងពង្រីកនូវសាមគ្គីភាពនៃចលនាស្ត្រីនៅកម្ពុជា ប៉ុន្តែវាហាក់បីដូចជានៅមានកម្រិតនៅឡើយ។

*តើនាពេលបច្ចុប្បន្ននេះ យេនឌ័របានចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិយ៉ាងដូចម្តេចខ្លះ?*

ដូច្នេះមុននឹងយើងធ្វើការសិក្សានិងវិភាគឱ្យបានស៊ីជម្រៅចំពោះបញ្ហានេះ យើងគួរស្វែងយល់នូវពាក្យ **យេនឌ័រ** ជាមុនសិន។

## ១- ន័យនៃពាក្យយេនឌ័រ

នាពេលបច្ចុប្បន្ន ពាក្យ **យេនឌ័រ** តែងតែត្រូវគេប្រើជំនួសឱ្យពាក្យ **ភេទ** របស់មនុស្សម្នាក់(ប្រុស ឬ ស្រី) និងមានការឱ្យនិយមន័យផ្សេងៗគ្នានូវពាក្យ **យេនឌ័រ** និង **ភេទ** នៅខាងផ្នែកវិទ្យាសាស្ត្រសង្គម ដែលមានលក្ខណៈខុសគ្នាដូចជា៖

. ពាក្យ «**ភេទ**» សំដៅទៅលើខ្លួនប្រាណរបស់នរណាម្នាក់។ វាបង្ហាញពីភាពជាស្រី ឬប្រុស របស់ខ្លួនប្រាណខាងក្រៅរបស់នរណាម្នាក់។

---

[១] https://www.srpostnews.com/article/42981.

ពាក្យ " **យេនឌ័រ** " គឺជាលក្ខណៈទំនាក់ទំនងតួនាទីរបស់បុរសនិងស្ត្រី ដែលមាននិងត្រូវបានកំណត់ដោយគ្រប់ទិដ្ឋភាពសង្គម ហើយមិនមែនកំណត់ដោយកត្តាជីវសាស្ត្រទេ។[២]

. ពាក្យ " **យេនឌ័រ**( Gender )" គឺជាភាពស្មើគ្នារវាងបុរសនិងស្ត្រី ស្តីអំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ ការសម្រេចចិត្ត ឧបសគ្គ ឱកាស និងតម្រូវការរបស់បុរសនិងស្ត្រី នៅគ្រប់បរិបទ គ្រប់វិស័យ និងគ្រប់មជ្ឈដ្ឋានទាំងអស់ ដែលកំណត់ដោយសង្គមវប្បធម៌ ហើយអាចផ្លាស់ប្តូរបានទៅតាមពេលវេលា និងស្ថានភាពជាក់ស្តែង ឬអាចនិយាយថា ជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គមក្នុងការវិភាគលើតួនាទី និងទំនួលខុសត្រូវ។ យេនឌ័រក៏ជាការកំណត់របស់គ្រួសារ សហគមន៍ និងសង្គមពាក់ព័ន្ធនឹងការបែងចែកការងារ ការអប់រំ សិទ្ធិអំណាចឋានៈ និងតួនាទី ដល់កូនស្រី កូនប្រុស ស្ត្រី និងបុរស។ យេនឌ័រអាចផ្លាស់ប្តូរកែប្រែបាន ព្រោះវាជាលក្ខខណ្ឌសង្គមមិនមែនមានពីកំណើតនោះទេ។

. ពាក្យ «**យេនឌ័រ**» គឺសំដៅទៅលើបុគ្គលិកលក្ខណៈ និងអត្តចរិតរបស់នរណាម្នាក់ដែលបង្ហាញអំពីអារម្មណ៍ឬកាយវិការរបស់មនុស្សម្នាក់ ថាតើគេដូចមនុស្សស្រី ឬដូចមនុស្សប្រុស។

---

[២] ក្រុមប្រឹក្សាជាតិភាសាខ្មែរ **វចនានុក្រមខ្មែរ** ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា បោះពុម្ពលើកទី១ ឆ្នាំ២០២២ ទំព័រ៨៩០។

. **យេនឌ័រ** គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គមក្នុងការវិភាគលើតួនាទីទំនួលខុសត្រូវ ឧបសគ្គ ឱកាស និងតម្រូវការរបស់បុរសនិងស្ត្រីនៅគ្រប់បរិបទគ្រប់វិស័យ គ្រប់មជ្ឈដ្ឋាន។ ឧទាហរណ៍៖ ស្ត្រី និងបុរសអាចធ្វើជាគ្រូបង្រៀន វិស្វករ កម្មករ... ហើយស្ត្រី និងបុរសអាចមើលថែកូន និងមនុស្សចាស់ជាដើម។

. **យេនឌ័រ** សំដៅលើភាពខុសគ្នារវាងបុរសនិងស្ត្រីដែលកំណត់ដោយសង្គម ហើយដែលគេបានរៀនសូត្រ និងមានការប្រែប្រួលពីពេលមួយទៅពេលមួយ។ យេនឌ័រមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរស និងស្ត្រីទៅតាមវប្បធម៌មួយទៅវប្បធម៌មួយ។

. **យេនឌ័រ** គឺជាគោលគំនិតផ្នែកសេដ្ឋកិច្ច និងសង្គម ក្នុងការធ្វើការវិភាគនៃតួនាទីទទួលខុសត្រូវ ឧបសគ្គ និងតម្រូវការរបស់បុរសនិងស្ត្រីនៅគ្រប់បរិបទទាំងអស់។ ដោយសារយេនឌ័រត្រូវបានបង្កើតឡើងដោយសង្គម ទើបការកំណត់អំពីតួនាទីតម្រូវការអាទិភាព និងសកម្មភាពរបស់ស្ត្រីមានទំនាក់ទំនងទៅនឹងបរិបទជាក់ស្តែងនៃវប្បធម៌ សាសនា និងសេដ្ឋកិច្ចសង្គម។

. **យេនឌ័រ** ជាភាពស្មើគ្នារវាងបុរសនិងស្ត្រី អំពីសិទ្ធិ តួនាទី ការទទួលខុសត្រូវ និងការសម្រេចចិត្តដែលកំណត់ដោយសង្គមវប្បធម៌ ហើយអាចផ្លាស់ប្តូរបានតាមពេលវេលា និងស្ថានភាពជាក់ស្តែង។[៣]

---

៣ https://rhac.org.kh/km

នៅពេលទារកម្នាក់កើតមក គេដឹងថា ជាស្រី ឬប្រុស គឺគេសម្គាល់លើប្រដាប់ភេទរបស់ទារកនោះដែលជាផ្នែកមួយនៃជីវសាស្ត្រ។ ប៉ុន្តែយេនឌ័រ គឺខុសគ្នា។ វប្បធម៌ ទំនៀមទម្លាប់ និងច្បាប់របស់យើង បានកំណត់នូវតួនាទីយេនឌ័រសម្រាប់បុរសនិងស្ត្រី។ តួនាទីនេះចែងថា ស្ត្រីត្រូវធ្វើការងារផ្ទះ ហើយបុរសជាអ្នកសម្រេចចិត្តសំខាន់ៗនៅក្នុងសហគមន៍។ យើងច្រើនតែយល់ច្រឡំរវាងតួនាទីយេនឌ័រ ជាមួយនិងតួនាទីភេទ ហើយគិតថា វាជារឿងធម្មជាតិ ឬមិនអាចផ្លាស់ប្តូរបាន។

**តើយេនឌ័រមានន័យដូចម្តេច? យេនឌ័រចាប់កំណើតពីពេលណាមក?**

**យេនឌ័រ** តាមវចនានុក្រម Learner's Dictionary ជាភាសាអង់គ្លេសខ្មែរ បានពន្យល់ថា **ជាលិង្គ**។ លិង្គនេះមិនមែនសំដៅលើប្រដាប់ភេទបុរសទេ តែវាសំដៅលើភេទ(នបុំសកលិង្គ និងឥត្ថីលិង្គ)។[៤] **យេនឌ័រ ឬជេនឌ័រ** គឺសំដៅលើរូបសាស្ត្រ ជីវសាស្ត្រ ចិត្ត ឥរិយាបថ ទាក់ទងនឹងភាពប្លែកគ្នារវាងនបុំសក-លិង្គ និងបុំលិង្គ។ យោងតាមបរិបទវាក្យសព្ទសំដៅដល់ជីវសាស្ត្រភេទ (ឱ. ថ្លែងដល់ភេទប្រុសនិងស្រី ឬក៏អន្តរភេទ) ភេទដែលផ្អែកទៅលើរចនាសម្ព័ន្ធសង្គម (រួមបញ្ចូលទាំងតួនាទីភេទ និងតួនាទីសង្គមដទៃទៀត) ឬអត្តសញ្ញាណភេទ។

អ្នកភេទវិទ្យា លោក John Money បានបែងចែកវាក្យសព្ទរវាងជីវសាស្ត្រភេទនិងយេនឌ័រ ជាច្បាប់មួយនៅឆ្នាំ១៩៥៥។ មុនពេលចាប់ផ្តើមការងាររបស់គាត់ វាជារឿងមិនធម្មតាមួយ ដើម្បីប្រើប្រាស់ពាក្យ **យេនឌ័រ** សំដៅ

---

[៤] សេរីវុធ Learner's Dictionary បោះពុម្ពលើកទី១ ព.ស.២៥៤១ គ.ស១៩៩៧ ទំព័រ១៩៥។

លើអ្វីមួយ ដូចការបែងចែកក្នុងវេយ្យាករណ៍នោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ អត្ថន័យរបស់លោក Money ទៅលើពាក្យនេះ មិនមានលក្ខណៈសកលទូទៅទេ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលអ្នកទ្រឹស្ដីស្ត្រីបានក្រសោបទស្សនៈទៅលើការបែងចែករវាងជីវសាស្ត្រភេទ និងរចនាសម្ព័ន្ធសង្គមនៃយេនឌ័រ។ សព្វថ្ងៃ ការបែងចែកបានដើរតាមយ៉ាងជាក់ច្បាស់នៅក្នុងបរិបទសង្គម ជាពិសេសក្នុងវិទ្យាសាស្ត្រសង្គម និងឯកសារដែលបានសរសេរឡើងដោយអង្គការសុខភាពពិភពលោក(WHO)។ ទោះបីជានៅក្នុងបរិបទដទៃទៀត នៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គម អត្ថន័យនៃពាក្យថា **យេនឌ័រ** បានទទួលនូវរបៀបប្រើប្រាស់ផ្លាស់គ្នា រួមទាំងភេទ(Sex) ទោះបីជាដាក់ជំនួសនៅពីក្រោយពាក្យផ្សេង។ ទោះបីជាការបញ្ចប់នូវការផ្លាស់ប្ដូរនេះនៅក្នុងអត្ថន័យនៃពាក្យ **យេនឌ័រ** ដែលអាចធ្វើឱ្យអូសបន្លាយមកទល់នឹងទសវត្សរ៍១៩៨០ ក៏ការពន្លឿនដ៏តូចនៃដំណើរការក្នុងវិទ្យាសាស្ត្រអក្សរសាស្ត្រ ត្រូវបានសង្កេតនៅពេលមួយក្នុងឆ្នាំ១៩៩៣ ដោយរដ្ឋបាលអាហារ និងឱសថ បានចាប់ផ្ដើមប្រើប្រាស់ពាក្យ **យេនឌ័រ** ជំនួសឱ្យពាក្យភេទ។ **យេនឌ័រ** គឺឥឡូវត្រូវបានគេប្រើប្រាស់ជាធម្មតាដែលថែមទាំងមិនមែនជាមនុស្ស និងសត្វ ដោយមិនឱ្យជាប់ទាក់ទិនទៅនឹងតួនាទីយេនឌ័រក្នុងសង្គម។

ចំណែកឯនៅក្នុងអក្សរសាស្ត្រអង់គ្លេសវិញ មានការបែងចែកជាបីរវាងជីវសាស្ត្រភេទ ចិត្តសាស្ត្រភេទ និងតួនាទីសង្គមភេទ ដែលដំបូងបានលេចចេញក្នុងកាសែតស្ត្រីមួយ ចំពោះការនិយមប្ដូរភេទនៅឆ្នាំ១៩៧៨។ វប្បធម៌មួយចំនួនកំណត់តួនាទីជាយថាភេទ(ច្បាស់) ពាក់ពន្ធ័នឹងតួនាទីសង្គម ដូចជាពួក **ហ៊ីជ្រះ**(Hijra) នៃប្រទេស**ឥណ្ឌា** និង **ប៉ាគីស្ថាន** ជាដើម។

## ២- ន័យនៃតួនាទីយេនឌ័រ

តួនាទីយេនឌ័រ គឺជាការរៀបរាប់ពីអ្វីដែលបុរសនិងស្ត្រី រំពឹងថានឹងធ្វើអ្វីមួយបាន។ ឧទាហរណ៍៖ បុរសត្រូវបានគេរំពឹងទុកថា ជាអ្នកទទួលបន្ទុកចេញទៅធ្វើការងារខាងក្រៅដូចជា ធ្វើជារាជការ ធ្វើជាអ្នកជំនួញ ធ្វើស្រែចម្ការ កាប់អុស រកត្រី រីឯស្ត្រីវិញគឺជាអ្នកចម្អិនអាហារ មើលថែកូន។ ចាប់តាំងពីបានបង្កើតតួនាទីយេនឌ័រ ធ្វើឱ្យមានការផ្លាស់ប្ដូរការទទួលខុសត្រូវការងាររបស់បុរស និងស្ត្រីក្នុងជីវិតរស់នៅ និងការយល់ដឹងពីឥទ្ធិពលនៃយេនឌ័រទៅលើការអនុវត្តឱ្យបានល្អសម្រាប់បុរសនិងស្ត្រី។ ស្ត្រីមានការជឿជាក់ថា ពួកគេមិនអាចចចេសរឹងរូស និងមានតែបុរសប៉ុណ្ណោះជាអ្នកគ្រប់គ្រងគ្រួសារ។ ដូច្នេះ បើយោងទៅលើការគិតនេះ វាអាចមានភាពលម្អៀងនៃយេនឌ័រ ដែលមានដែនកំណត់សម្រាប់អ្វីដែលបុរសនិងស្ត្រីក្នុងការធ្វើសកម្មភាពនានាទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ។ តួនាទីយេនឌ័រ មានសារៈសំខាន់ណាស់ក្នុងការចូលរួមយ៉ាងសកម្ម ក្នុងសកម្មភាពទាំងឡាយរបស់គ្រួសារ និងសហគមន៍ ដើម្បីអភិវឌ្ឍន៍គ្រួសារនិងសហគមន៍ គប្បីបង្កើតឱ្យមានការពិភាក្សាអំពីវិធីផ្សេងៗ ក្នុងការចែករំលែកការទទួលខុសត្រូវផ្អែកលើសមភាពយេនឌ័រ។[៥]

ក្នុងពេលបច្ចុប្បន្ននៅលើពិភពលោកយើងនេះ ទំនៀមទម្លាប់យេនឌ័រគឺកំពុងតែមានការផ្លាស់ប្ដូរផងដែរ ដ្បិតមានមនុស្សវ័យក្មេងជាច្រើនដែលធ្វើការដើម្បីសមភាព និងយុត្តិធម៌កំពុងតែជួយឱ្យមានការផ្លាស់ប្ដូរនេះ។ យេនឌ័រពេលក៏ខ្លះអាចជះឥទ្ធិពលដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ហើយចាំបាច់

---

[៥] https://rhac.org.kh/km

ត្រូវធ្វើការផ្លាស់ប្តូរ។ ឧទាហរណ៍៖ ស្ត្រីបង្ខិលចង្រ្កានមិនជុំ គឺជាពំនោលមួយដែលធ្វើឱ្យស្ត្រីបាត់បង់សេរីភាព និងឱកាសនៃការចូលរួមក្នុងសកម្មភាពនានាក្នុងសង្គមដែលទាក់ទងនឹងការអប់រំ ការទទួលបានពត៌មាន និងការបញ្ចេញមតិយោបល់ជាដើម។

ជាទូទៅនៅក្នុងសង្គមខ្មែរ បុរសគឺជាមេគ្រួសារក្នុងគ្រួសារ បុរសមានអំណាច បុរសមានសិទ្ធិ បុរសជាអ្នកសម្រេចកិច្ចការក្នុងគ្រួសារ ដូច្នេះស្ត្រីត្រូវតែស្តាប់បង្គាប់បុរស ត្រូវតែគោរពបុរស ទោះបីជាគំនិតរបស់បុរសទាំងនោះអាចបង្កជាបញ្ហាក៏ដោយ ហើយតួនាទីយេនឌ័រដែលគេរំពឹងទុកនោះ គឺត្រូវបានគេមើលឃើញជាក់ច្បាស់នៅក្នុងទិដ្ឋភាពជាច្រើននៃគ្រួសារ។ គ្រួសារខ្លះបានប្រព្រឹត្តចំពោះក្មេងស្រី និងក្មេងប្រុសស្មើភាពគ្នា តែក៏មានគ្រួសារជាច្រើនទៀតដែលមិនបានប្រព្រឹត្តចំពោះក្មេងប្រុសនិងក្មេងស្រីឱ្យបានស្មើភាពគ្នានោះទេ។ ដូច្នេះគ្រួសារ និងសហគមន៍ គួរគប្បីបង្កើតឱ្យមានការពិភាក្សាអំពីវិធីផ្សេងៗក្នុងការបែករំលែក ការទទួលខុសត្រូវ ដោយផ្អែកលើសមភាពយេនឌ័រ។ ការធ្វើដូច្នេះ ពួកគេអាចមានលទ្ធភាពក្នុងការស្វែងរកវិធីដ៏ល្អប្រសើរសម្រាប់ពួកគេបែករំលែកនូវតួនាទីដែលអាចធ្វើឱ្យយុវវ័យមានការសប្បាយរីករាយ ដើម្បីភាពសុខដុមរមនានៅក្នុងគ្រួសារ។

តួនាទីយេនឌ័រ បានបង្កើតឱ្យមានការរំពឹងទុកផ្សេងៗនូវអ្វីដែលគេហៅថា "បុរសពេញលក្ខណៈ" និង "ស្ត្រីពេញលក្ខណៈ"។ នៅពេលដែលការរំពឹងទុករបស់យេនឌ័របានរួមបញ្ចូលនូវការគោរពនិងការសរសើរចំពោះតួនាទីរបស់ភេទផ្សេងៗគ្នា នោះស្ត្រីនិងបុរសអាចមានដំណើរជីវិតមួយដែលប្រកបទៅ

ដោយភាពពេញចិត្ត ការរួមផ្លូងគ្នា និងសមិទ្ធផលផ្សេង។ ប៉ុន្តែជារឿយៗ តួនាទីរបស់ស្ត្រី មានឋានៈទាបជាងយ៉ាងខ្លាំង បើធៀបនឹងតួនាទីរបស់បុរស។ ឋានៈមិនស្មើគ្នានៅក្នុងយេនឌ័រនេះ រឹតតែបណ្តាលឱ្យមានគ្រោះថ្នាក់ថែមទៀត នៅពេលដែលមានការរំពឹងទុកពីសង្គមថា បុរសមានការគ្រប់គ្រងលើស្ត្រី ឬនរណាម្នាក់ដែលមានរូបរាង ឬគំនិតដូចស្ត្រី។ វិធីមួយដើម្បីមើលឃើញពីភាពខុសគ្នារវាងឋានៈបុរសនិងស្ត្រី គឺតាមរយៈការឆ្លុះបញ្ចាំងពីបុគ្គលិកលក្ខណៈនៃភាពជាបុរសនិងភាពជាស្ត្រីដែលមនុស្សទូទៅកោតសរសើរ។ ធ្វើបែបនេះអាចជួយឱ្យមនុស្សគិតថា តើបុគ្គលិកលក្ខណៈណាខ្លះដែលសហគមន៍ទទួលស្គាល់។ ការឆ្លុះបញ្ចាំងបែបនេះក៏ជួយឱ្យក្រុមស្វែងយល់ថា តើបុរសនិងស្ត្រីទូទៅប្រព្រឹត្តបែបណា ដើម្បីលើកកម្ពស់ការរំពឹងទុកក្នុងយេនឌ័រ ហើយតើនឹងមានអ្វីកើតឡើងបើមនុស្សម្នាក់ប្រព្រឹត្តខុសគេ។ ស្ត្រីៗច្រើនតែជជែកគ្នាស្វាត់ៗអំពីបទពិសោធន៍និងអារម្មណ៍របស់ពួកគេ ហើយការរៀបរាប់ពីភាពលំបាកផ្សេងៗក្នុងជីវិត ជាពិសេសអំពីការប្រាស្រ័យទាក់ទងដ៏លំបាកជាមួយបុរស ជួយឱ្យស្ត្រីមានអារម្មណ៍ថា មិនសូវឯកា។ ប៉ុន្តែការជជែកគ្នារបស់ពួកគេ ជាទូទៅមិនសូវលើកយកសំណួរដែលស្វែងរកមូលហេតុនៃភាពលំបាករបស់ពួកគេ ឬអំពីដំណោះស្រាយនៃបញ្ហានោះទេ។ សកម្មភាពឆ្លុះបញ្ចាំងនិងចែករំលែកអាចផ្តល់នូវទីកន្លែងមួយដែលមានសុវត្ថិភាព និងភាពងាយស្រួលដល់ស្ត្រី ដើម្បីឱ្យពួកគាត់ពិភាក្សាអំពីបទពិសោធន៍របស់ខ្លួន ព្រមទាំងប្រៀបធៀបតួនាទីរបស់ពួកគាត់ជាមួយនឹងតួនាទីរបស់បុរស។ នៅគ្រប់សហគមន៍ទាំងអស់ មានការងារខ្លះត្រូវបានចាត់ទុកថាជា "ការងារបុរស" ហើយការងារខ្លះទៀតជា "ការងារស្ត្រី។ ភាពខុសគ្នានៃការរំពឹងទុកទាំងនេះ គឺជាផ្នែកមួយនៃតួនាទីយេនឌ័រ។

ការងារដែលស្ត្រីជាច្រើនធ្វើ ដូចជាមើលថែកូន និងតម្រូវការប្រចាំថ្ងៃរបស់គ្រួសារ ច្រើនតែមិនទទួលបានតម្លៃខ្ពស់ទេ ឬថែមទាំងមិនត្រូវបានគិតថាជាការងារទៀតផង។ នេះគឺជាមូលហេតុមួយដែលធ្វើឱ្យស្ត្រីមានឋានៈទាប និងមានការងារច្រើនដែលមិនស្មើភាព។ ការពិភាក្សាអំពីតួនាទីយេនឌ័រនិងការងារអាចជួយឱ្យមនុស្សគិតអំពីការផ្លាស់ប្តូរផ្សេងៗដែលអាចនាំឱ្យសុខភាពរបស់ស្ត្រីបានប្រសើរឡើង។ ការរៀបរាប់អំពីសកម្មភាពទាំងឡាយដែលបុរសនិងស្ត្រីធ្វើរៀងរាល់ថ្ងៃ អាចផ្តល់ជាមូលដ្ឋានសម្រាប់ការពិភាក្សាអំពីការងារ និងយេនឌ័រ។ ជួនកាលបុរស ឬស្ត្រី មិនបានដឹងទេថា តើស្ត្រីឬបុរសធ្វើអ្វីខ្លះក្នុងមួយថ្ងៃៗ។

ពេលខ្លះស្ត្រីមិនដែលគិតថា អ្វីដែលស្ត្រីធ្វើនៅផ្ទះ ជាការងារទេ ទោះបីជាស្ត្រីមានការងារពេញមួយថ្ងៃក៏ដោយ ក៏ស្ត្រីនៅតែត្រូវធ្វើការងារផ្ទះដែរ ហើយមិនដែលបានសម្រាកអ្វីឡើយ។ ស្ត្រីតែងតែគិតថា បុរសត្រូវការអាហារ និងការសម្រាកច្រើនជាង ព្រោះពួកគេធ្វើការងារនឿយហត់ជាង តែជាក់ស្តែងស្ត្រីធ្វើការនឿយហត់ដែរ តែហូបនិងសម្រាកបានតិចទៅវិញ។ ស្ត្រីហាក់ដូចជាធ្វើការងារច្រើនម៉ោងជាង តែសម្រាកបានតិចជាង។

តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា។ ជាញឹកញាប់តួនាទីយេនឌ័រតែងតែកំណត់ឋានៈស្ត្រីឱ្យនៅទាប ដែលមានន័យថា មិនសូវទទួលបានការថែទាំសុខភាព មិនអាចគ្រប់គ្រងរាងកាយខ្លួនឯងឱ្យពេញលេញ ធ្វើការងារច្រើនម៉ោង និងមិនសូវមានអំណាចក្នុងការសម្រេចចិត្តនោះទេ។ ដើម្បីឱ្យសហគមន៍អាចកែលម្អសុខភាពរបស់ស្ត្រីបាន ពួកគេចាំបាច់ត្រូវកែប្រែតួនាទីយេនឌ័រ ជាពិសេសចំណុចដែលធ្វើឱ្យស្ត្រីងាយរងគ្រោះពីបុរស។ ត្រង់

នេះហាក់ដូចជាពិបាកកែប្រែខ្លាំងណាស់ ប៉ុន្តែវាមិនសូវជាពិបាកទេ នៅពេលដែលយើងយល់ដឹងថា យេនឌ័រមិនមែនជាបញ្ហាជីវសាស្ត្រនោះ មានន័យថា អ្វីៗដែលយើងគិតថាស័ក្តិសមជាបុរស និងស័ក្តិសមជាស្ត្រី គឺជាការយល់ឃើញរបស់យើងតែប៉ុណ្ណោះ វាមិនមែនកើតចេញពីធម្មជាតិនោះទេ។ ម្យ៉ាងទៀតគួរចាំថា នៅគ្រប់តំបន់នៅទូទាំងសកលលោក តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា។ ការពិភាក្សាអំពីខ្សែជីវិតរបស់ស្ត្រីក្នុងអតីតកាលធៀបនឹងបច្ចុប្បន្នកាល អាចជួយឱ្យមនុស្សមើលឃើញថា តួនាទីយេនឌ័រពិតជាផ្លាស់ប្តូរមែន និងឃើញថាការផ្លាស់ប្តូរទាំងនេះបានធ្វើឱ្យសុខភាពរបស់ស្ត្រីកាន់តែប្រសើរ។

## ៣- យេនឌ័រនិងការងារ

តាមការសង្កេតជាទូទៅ មានការងារខ្លះត្រូវបានចាត់ទុកថាជា "ការងារបុរស" ហើយការងារខ្លះទៀតជា "ការងារស្ត្រី។ ភាពខុសគ្នានៃការរំពឹងទុកទាំងនេះ គឺជាផ្នែកមួយនៃតួនាទីយេនឌ័រ។ ការងារដែលស្ត្រីជាច្រើនធ្វើ មានដូចជាការមើលថែកូន និងការបំពេញតម្រូវការប្រចាំថ្ងៃរបស់គ្រួសារ ដែលការងារទាំងនោះ ច្រើនតែមិនទទួលបានតម្លៃខ្ពស់ហើយថែមទាំងមិនត្រូវបានគិតថាជាការងារទៀតផង។ ទាំងនេះគឺជាមូលហេតុមួយដែលធ្វើឱ្យស្ត្រីមានឋានៈទាប និងមានការងារច្រើនដែលមិនស្មើភាព។

បើយើងធ្វើការជជែកពិភាក្សាអំពីតួនាទីយេនឌ័រនិងការងារ គឺយើងនឹងអាចជួយឱ្យមនុស្សគិតអំពីការផ្លាស់ប្តូរផ្សេងៗដែលអាចនាំឱ្យស្ត្រីមានតម្លៃក្នុងការងាររបស់ខ្លួន ក៏ដូចជានាំឱ្យសុខភាពរបស់ស្ត្រីបានប្រសើរឡើងផងដែរ។

ការរៀបរាប់អំពីសកម្មភាពទាំងឡាយដែលបុរសនិងស្ត្រីធ្វើរៀងរាល់ថ្ងៃ អាចផ្តល់ជាមូលដ្ឋានសម្រាប់ការពិភាក្សាអំពីការងារ និងយេនឌ័រ។ ជួនកាលបុរសឬស្ត្រី មិនបានដឹងទេថា តើស្ត្រីឬបុរសធ្វើអ្វីខ្លះក្នុងមួយថ្ងៃៗ។ យើងអាចកែច្នៃសកម្មភាពនេះ ដើម្បីយកមកប្រើជាមួយក្រុមដែលមានតែស្ត្រី ដើម្បីបង្កើនការយល់ដឹងរបស់ពួកគេ ថាការងារផ្ទះ ក៏ជាការងារដែលមានតម្លៃដែរ។ តើបុរសឬស្ត្រីណាខ្លះដែលធ្វើការងារមួយចំនួនរបស់អ្នកមានភេទផ្ទុយពីខ្លួន (បុរសធ្វើការងារស្ត្រីឬស្ត្រីធ្វើការងារបុរស)។ ហេតុអ្វីអ្នកទាំងនេះធ្វើការងារដែលគេរំពឹងថាជារបស់អ្នកដែលមានភេទផ្ទុយពីគាត់ទៅវិញ? តើពួកគេទទួលបានការគោរពថយចុះឬក៏កើនឡើងដែរឬទេនៅពេលធ្វើការងារទាំងនោះ?

## . តួនាទីយេនឌ័រ តែងតែប្រែប្រួលទៅតាមពេលវេលា

តួនាទីយេនឌ័រតែងតែកំណត់ឋានៈស្ត្រីឱ្យនៅទាប ដែលមានន័យថា មិនសូវទទួលបានការថែទាំសុខភាព មិនអាចគ្រប់គ្រងរាងកាយខ្លួនឯងឱ្យពេញលេញ ធ្វើការងារច្រើនម៉ោង និងមិនសូវមានអំណាចក្នុងការសម្រេចចិត្តនោះទេ។ ដើម្បីឱ្យសហគមន៍អាចកែលម្អសុខភាពរបស់ស្ត្រីបាន ពួកគេចាំបាច់ត្រូវកែប្រែតួនាទីយេនឌ័រ ជាពិសេសចំណុចដែលធ្វើឱ្យស្ត្រីងាយរងគ្រោះពីបុរស។ ត្រង់នេះហាក់ដូចជាពិបាកកែប្រែខ្លាំងណាស់ ប៉ុន្តែវាមិនសូវជាពិបាកទេ នៅពេលដែលយើងយល់ដឹងថា យេនឌ័រមិនមែនជាបញ្ហាជីវសាស្ត្រនោះ មានន័យថា អ្វីៗដែលយើងគិតថាស័ក្តិសមជាបុរស និងស័ក្តិសមជាស្ត្រី គឺជាការយល់ឃើញរបស់យើងតែប៉ុណ្ណោះ វាមិនមែនកើតចេញពីធម្មជាតិនោះទេ។ ម្យ៉ាងទៀតគួរចងចាំថា នៅគ្រប់តំបន់នៅទូទាំងសកលលោក តួនាទីយេនឌ័រ

តែងតែប្រែប្រួលទៅតាមពេលវេលា។ ការពិភាក្សាអំពីខ្សែជីវិតរបស់ស្ត្រីក្នុង អតីតកាល ធៀបនឹងបច្ចុប្បន្នកាល អាចជួយឱ្យមនុស្សមើលឃើញថា តួនាទី យេនឌ័រពិតជាផ្លាស់ប្តូរមែន ហើយការផ្លាស់ប្តូរទាំងនេះ បានធ្វើឱ្យសុខភាព របស់ស្ត្រីកាន់តែប្រសើរដូចម្តេចខ្លះ?

ការស្វែងយល់អំពីយេនឌ័រ គឺជាផ្នែកមួយនៅក្នុងការស្វែងយល់ពីឆាក ជីវិតរបស់យើង។ តួនាទីនិងការរំពឹងទុកក្នុងយេនឌ័រ មានភាពខុសៗគ្នាទៅ តាមសហគមន៍ ដោយអាស្រ័យទៅលើទំនៀមទម្លាប់ ប្រពៃណី ច្បាប់ និង សាសនារបស់ពួកគេ។ នៅតំបន់ជាច្រើន ក្មេងប្រុសនិងបុរសមានឋានៈខ្ពស់ ជាង។ ពួកគេមានសិទ្ធិមូលដ្ឋាន និងសិទ្ធិពិសេសមួយចំនួនដែលស្ត្រីមិនមាន។ នៅពេលដែលស្ត្រីមានឋានៈទាបជាងបុរសខ្លាំងពេក ពួកគេច្រើនតែទទួលរងនូវ អំពើហិង្សា ទទួលបាននូវការថែទាំសុខភាពតិចតួច និងមិនសូវមានអំណាច ក្នុងការសម្រេចចិត្តអំពីសុខភាពរបស់ពួកគេទេ។ ហេតុដូច្នេះហើយ ការត្រិះរិះ ពិចារណាអំពីក្បួនច្បាប់យេនឌ័រ និងការធ្វើការងារដើម្បីសមភាពយេនឌ័រ គឺជា ផ្នែកដ៏សំខាន់ក្នុងការទ្រទ្រង់សុខភាពរបស់ក្មេងស្រីនិងស្ត្រី។ ការផ្លាស់ប្តូរ គឺ មានការពិបាកក្នុងការផ្លាស់ប្តូរ ដ្បិតមនុស្សខ្លះគាំទ្រតួនាទីយេនឌ័រដែលមិនស្មើ ភាពគ្នានេះ គឺមានន័យថា ពួកគេចង់រក្សាអ្វីៗឱ្យនៅដដែល។ អ្នកខ្លះទៀតអាច នឹងមិនគាំទ្រវិសមភាពយេនឌ័រ ប៉ុន្តែពួកគេគិតថា មិនអាចកែប្រែវាបានទេ គឺ ដូចជាបញ្ហាអាកាសធាតុដូច្នេះដែរ ហើយក៏ពុំគួរបាត់បង់ទឹកចិត្តដោយសារពួក គេនោះដែរ។ ការចូលរួមជាមួយអ្នករៀបចំ អ្នកអប់រំសុខភាព និងអ្នកដទៃទៀត ជាច្រើនដែលកំពុងតែប្រើប្រាស់អំណាចនិងភាពច្នៃប្រឌិតរបស់ខ្លួន ដើម្បីនាំ មកនូវការផ្លាស់ប្តូរនានាដែលធានាឱ្យមានការកែលម្អសុខភាពរបស់ស្ត្រី។

បុគ្គលិកលក្ខណៈពីបុរាណមួយនៃភាពជាបុរស គឺការមានអំណាច។ ជាទូទៅនៅក្នុងសហគមន៍មួយ ឋានៈ ឬតំណែងដែលមានអំណាចធំបំផុតត្រូវបានកាន់កាប់ដោយបុរស។ ឧទាហរណ៍ អ្នកដឹកនាំសហគមន៍និងមន្ត្រីរដ្ឋាភិបាលភាគច្រើនជាបុរស។ ជាញឹកញាប់បុរសធ្វើការសម្រេចចិត្តដោយមិនប្រឹក្សាជាមួយស្ត្រី ឬសម្រេចចិត្តដោយមិនគិតពីផលប៉ះពាល់លើស្ត្រីឡើយ។ នៅក្នុងគ្រួសារមួយ ជាធម្មតាគេរំពឹងថា បុរសគឺជាអ្នកដឹកនាំគ្រួសារ និងជាអ្នកសម្រេចពីវិធីរកប្រាក់និងការចំណាយប្រាក់។ ក្នុងជីវិតប្តីប្រពន្ធ ជាញឹកញាប់បុរសច្រើនតែជាអ្នកសម្រេចថា តើការរួមភេទរវាងស្វាមីនិងភរិយា ឬការប្រើប្រាស់ផែនការគ្រួសារ គួរធ្វើឡើងនៅពេលណា និងបែបណា? ដែលវិសមភាពអំណាចទាំងនេះហើយដែលជាឫសគល់នៃបញ្ហាសុខភាពជាច្រើនដែលកើតឡើងញឹកញាប់ចំពោះស្ត្រី។

អំណាចលើអ្វីមួយ គឺជាប្រភេទអំណាចដែលមានគ្រោះថ្នាក់បំផុត។ ជាទូទៅអំណាចប្រភេទនេះមានដូចជា ការគំរាមកំហែង ការចាត់ចែងព្រឹត្តិការណ៍អ្វីមួយ ការប្រើហិង្សាឬទណ្ឌកម្ម ដើម្បីបង្ខំមនុស្សម្នាក់ឬមួយក្រុម ឱ្យធ្វើអ្វីមួយដែលពួកគេមិនពេញចិត្ត។

ជាញឹកញាប់ ជនមានអំណាចខ្លាំងតែងតែប្រើបទបញ្ញត្តិ ទំនៀមទម្លាប់ និងច្បាប់ផ្សេងៗដើម្បីរក្សាអំណាចរបស់ខ្លួន និងដើម្បីគ្រប់គ្រងមនុស្សដទៃព្រមទាំងសកម្មភាពរបស់ពួកគេ។ អ្នកមានអំណាចតិចដូចជាស្ត្រីជាដើម ជាធម្មតាត្រូវបានផ្តាច់ចេញពីការប្រើប្រាស់បទបញ្ញត្តិ ទំនៀមទម្លាប់និងច្បាប់ដែលគ្រប់គ្រងជីវិតរបស់ពួកគេ រួមទាំងការទទួលបានសេវាថែទាំសុខភាព

ជាដើម។ ការប្រើអំណាចតាមរបៀបនេះ ជួនកាលហៅថា ការគាបសង្កត់ដែលធ្វើឱ្យជនមានអំណាចតិចទទួលយកថា វិសមភាពគឺជារឿងធម្មតា។ នៅពេលដែលរឿងបែបនេះកើតឡើង គេប្រហែលជាមិនជឿឡើយថា ខ្លួននៅមានជម្រើសឬមានឱកាសធ្វើការផ្លាស់ប្តូរ ហើយអាចនឹងបញ្ជូនទស្សនៈនេះបន្តទៅឱ្យអ្នកដទៃទៀតផង។ សកម្មភាពនេះអាចជួយឱ្យក្រុមស្វែងយល់ថា តើភាពខុសគ្នារវាងអំណាច និងការរំពឹងទុកពីបុរសនិងស្ត្រី ធ្វើឱ្យមានវិសមភាពនៃបន្ទុកដែលប៉ះពាល់ដល់សុខភាពរបស់ស្ត្រីដូចម្តេចខ្លះ?

មូលហេតុទាំងនោះបណ្តាលមកពីឋានៈទាបរបស់ស្ត្រី ឬការរំពឹងទុកក្នុងយេនឌ័រ ហើយផលប៉ះពាល់ គឺជាស្ថានភាពដែលនាំឱ្យមានបញ្ហាសុខភាព។ កង្វះអំណាចដើម្បីធ្វើការសម្រេចចិត្ត គឺជាមូលហេតុមួយដែលត្រូវគ្នានឹងផលប៉ះពាល់។ ការផ្តល់តម្លៃដល់មនុស្សជាធនធានដែលសំខាន់បំផុត ដោយផ្តោតលើការគោរពគំនិត ប្រពៃណី និងការសម្រេចចិត្តរបស់គ្នាទៅវិញទៅមក ជាពិសេស គឺការជួយស្ត្រីឱ្យចេះជួយខ្លួនឯង ដោយស្តាប់ក្តីកង្វល់ តម្រូវការក៏ដូចជាទស្សនៈរបស់ស្ត្រី និងជួយស្ត្រីឱ្យស្វែងរកដំណោះស្រាយផ្ទាល់ខ្លួនរបស់គេ ពោលគឺការរៀបចំផែនការជាមួយគ្នានិងមិនមែនសម្រាប់គ្នា ដោយមិនយកគំនិតណាមួយទៅគ្របលើគំនិតអ្នកដទៃនោះឡើយ។ យ៉ាងណាមិញ ការចែករំលែកចំណេះដឹង ក៏ដូចជាការរៀនសូត្រពីមនុស្សដែលអ្នកបានជួយ និងចែករំលែកចំណេះដឹងដែលអ្នកមាន ដោយជួយអ្នកដទៃស្វែងរកព័ត៌មានដែលពួកគេត្រូវការ ដើម្បីដោះស្រាយបញ្ហា។

## ៤- យេនឌ័រនិងការស្វែងរកការគាំទ្រ

ការគាំទ្រ មានន័យការគាំពារ ការទទួលស្គាល់ ការជួយឧបត្ថម្ភ... ដូច្នេះ ការស្វែងរកការគាំទ្រពីសម្ព័ន្ធមិត្ត ដែលរួមមានទាំងបុរស ទាំងយុវវ័យ មេដឹកនាំសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល(NGOs) និងទីភ្នាក់ងាររដ្ឋាភិបាល គឺត្រូវបានរៀបចំឡើង ដើម្បីបង្ហាញថា ជីវិតមនុស្សគ្រប់រូបអាចល្អប្រសើរឡើងតាមរយៈការធ្វើការជាមួយគ្នាឆ្ពោះទៅសម្រេចគោលដៅរួម។ ការផ្លាស់ប្តូរដែលបានចាប់ផ្តើមជាមួយនឹងសហគមន៍មួយក៏អាចផ្សព្វផ្សាយ និងជំរុញទឹកចិត្តដល់សហគមន៍ដទៃដែលនៅឆ្ងាយផងដែរ។ នៅពេលខ្លះ ការខិតខំប្រឹងប្រែងរបស់ក្រុមតូចមួយ បានធំលូតលាស់និងប្រែក្លាយជាចលនាមួយដែលនាំឱ្យមានការផ្លាស់ប្តូរធំៗនៅក្នុងសាកលលោក។

ជាទូទៅបុគ្គលិកលក្ខណៈមួយដែលគេច្រើនតែគិតថាជារបស់ស្ត្រី គឺភាពអសកម្មនិងការស្តាប់ឱវាទ។ គេមិនរំពឹងថា ស្ត្រីនិងក្មេងស្រីគួរតែជជែកវែកញែក ឬប្រឆាំងនឹងពាក្យសម្តីរបស់បុរសទេ។ ពេលខ្លះយោបល់របស់ពួកគេត្រូវបានផាត់ចោល ហើយអាចនឹងត្រូវបានស្តីបន្ទោស ដោយទុកឱ្យគេនៅម្នាក់ឯង ឬពិន័យចំពោះការនិយាយជាសាធារណៈ ឬគ្រាន់តែបញ្ចេញយោបល់ពីអ្វីដែលពួកគេត្រូវការឬចង់បាន។ ការផ្លាស់ប្តូរផ្នត់គំនិតមួយនេះ ត្រូវការភាពក្លាហានជាខ្លាំង ប៉ុន្តែលទ្ធភាពដែលអាចបញ្ចេញយោបល់ជាសាធារណៈ គឺជាទម្រង់មួយនៃអំណាច។

ការស្វែងរកការគាំទ្រឬកាគាំពារតាមរយៈការប្រាស្រ័យទាក់ទង វាតែងតែបង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយដែលក្នុងនោះមាន៖

. **ការប្រាស្រ័យទាក់ទងបែបទន់ខ្សោយឬអសកម្ម** គឺសំដៅដល់ការធ្វើតាមអ្វីដែលអ្នកដទៃចង់បាន គិតអំពីអ្នកដទៃជាមុនដែលធ្វើឱ្យលំបាកដល់ខ្លួនឯង ការរក្សាភាពស្ងៀមស្ងាត់នៅពេលមានអ្វីមករំខាន ការនិយាយសុំទោសជាញឹកញាប់ ការយំជាញឹកញាប់ ការលាក់ពីអារម្មណ៍របស់ខ្លួន និងការមិនធ្វើអ្វីមួយដើម្បីការពារសិទ្ធិរបស់ខ្លួន។ល។[៦]

. **ការប្រាស្រ័យទាក់ទងបែបបង្ខំឬជម្លោះ៖** ស្ត្រីធ្វើអ្វីតាមតែគាត់ចង់បាន ហើយស្ត្រីមួយចំនួនមានគិតតិចតួចឬមិនគិតទាល់តែសោះពីអ្នកដទៃ ដែលពេលខ្លះស្ត្រីអាចនិយាយគំរាមឬទាមទារ ស្ត្រីមិនចង់ស្តាប់អ្នកដទៃ ឆាប់ខឹងនៅពេលដែលអ្នកដទៃមិនយល់ស្របជាមួយខ្លួន ស្រែកចំអកឬមើលងាយអ្នកដទៃ។ គាត់ខឹងនឹងស្ត្រីទាំងនោះ ព្រមទាំងស្តីបន្ទោសឱ្យពួកគេថាមិនគួរទៅពាក់ព័ន្ធនឹងអ្វីដែលមិនមានប្រយោជន៍សម្រាប់ខ្លួននោះឡើយ។

. **ការប្រាស្រ័យទាក់ទងបែបមាំមួនឬជឿជាក់** គឺសំដៅដល់ការគោរពខ្លួនឯងនិងអ្នកដទៃ ការក្រោកឈរទាមទារសិទ្ធិរបស់ខ្លួន ការស្តាប់និងការនិយាយតាមសម្រួល ការចេះបង្ហាញគំនិតយោបល់ ការចេះបំពេញនិងបង្ហាញនូវតម្រូវការនៃអារម្មណ៍របស់ខ្លួនយ៉ាងច្បាស់លាស់ ការចេះនិយាយថាទេដោយគ្មានអារម្មណ៍ខុសឆ្គង ការចេះស្វែងរកជំនួយនៅពេលដែលខ្លួនត្រូវការ និងការបង្ហាញភាពជឿជាក់នៅពេលនិយាយ។ល។ ឧទាហរណ៍៖ ស្ត្រីហ៊ានពន្យល់ប្រាប់បុរសជាស្វាមីអំពីមូលហេតុដែលគាត់ចាប់អារម្មណ៍នឹងការងារណាមួយ

[៦] https://km.hesperian.org/hhg/Health_Actions_for_Women

ហើយស្ត្រីហ៊ាននិយាយនិងពន្យល់ប្រាប់ប្ដីថា *"ការងារនោះធ្វើឡើងយ៉ាងដូចម្ដេច? ធ្វើប៉ុន្មានដង? ម្ដងឬពីរដង? ក្នុងរយៈពេលប៉ុន្មាន?* ហើយនាងពិតជាចង់ចូលរួមខ្លាំងណាស់ក្នុងការងារនោះ ដោយនាងនៅតែអាចធ្វើការងារផ្ទះឱ្យបានរួចរាល់ដដែល ឬក៏ស្ត្រីនោះអាចនិយាយទៅកាន់ស្វាមីថា តើយើងអាចជជែកគ្នាបានទេ ថាយើងគួរធ្វើបែបណាដើម្បីអាចឱ្យនាងទៅចូលរួមការងារនោះបាននឹងគេជាដើម។

ដូច្នេះការជួយគាំទ្រស្ត្រីឱ្យក្លាយជាអ្នកប្រាស្រ័យទាក់ទងដ៏ល្អ មានន័យថា អ្នកជាអ្នកប្រាស្រ័យទាក់ទងដ៏ល្អខ្លួនឯងដែរ។ មនុស្សគ្រប់គ្នាដែលធ្វើការងារនេះ សុទ្ធតែត្រូវការការជួយគាំទ្រ។ យើងត្រៀមលក្ខណៈជាមុន មុននឹងយើងចាប់ផ្ដើមអនុវត្តសកម្មភាពណាមួយ។ យើងគួរសាកល្បងឬនិយាយជាមួយនរណាម្នាក់ជាមុន ដើម្បីឱ្យមានចិត្តស្ងប់ នៅពេលយើងដឹកនាំអនុវត្តសកម្មភាពណាមួយ។ យើងត្រូវប្រាកដថា អ្នកដែលស្ដាប់នោះ អាចធ្វើការឆ្លុះបញ្ចាំងឡើងវិញក្រោយសកម្មភាពបានបញ្ចប់។ ឧទាហរណ៍៖ ស្ត្រីតែងតែ និងនៅតែជាកម្លាំងរុញច្រានដ៏សំខាន់មួយឆ្ពោះទៅកាន់សមភាពយេនឌ័រ។

ដូច្នេះការប្រាស្រ័យទាក់ទងគឺជាសិល្បៈនៃការនិយាយពិភាក្សា ឬជាការបញ្ជូនការយល់ដឹងរវាងមនុស្សម្នាក់ទៅកាន់មនុស្សម្នាក់ទៀត ឬជាច្រើននាក់ ដោយមានដំណាក់កាលនៃការចាប់ផ្ដើមទំនាក់ទំនង ដែលមានដូចជា ការស្វាគមន៍ ការស្វែងរកកន្លែងសមរម្យដើម្បីចាប់ផ្ដើមទំនាក់ទំនង ការណែនាំឈ្មោះនិងតួនាទី ការទទួលខុសត្រូវនិងលទ្ធភាពដែលខ្លួនអាចធ្វើបាន ការប្រាប់ពីគោលបំណងនិងពេលវេលានៃការធ្វើទំនាក់ទំនង ការរក្សាការសម្ងាត់ ការកត់

គ្រាអាចប្រព្រឹត្តទៅបានដោយការសុំអនុញ្ញាតិឬប្រាប់ពីហេតុផលច្បាស់លាស់ថា ហេតុអ្វីទើបមានការកត់ត្រានេះ? ជាដើម។

នៅក្នុងការធ្វើទំនាក់ទំនងត្រូវស្វែងយល់ថា ហេតុអ្វីបានជាគាត់ស្វែងរកជំនួយ ឬត្រូវការឱ្យគេជួយ? តើការស្វែងរកជំនួយនេះដោយស្ម័គ្រចិត្តដែរឬទេ? តើការបង្កើតការសន្ទនា និងបង្កើតបរិយាកាសទុកចិត្ត និងយល់ចិត្តគ្នាទៅវិញទៅមកកម្រិតណា?

បន្ទាប់ពីដំណាក់កាលនៃការចាប់ផ្តើម គឺជាដំណាក់កាលនៃការធ្វើការជាមួយគ្នា ដោយត្រូវចេះធ្វើការស្វែងយល់ និងការបញ្ចេញបញ្ហា ដែលមាននៅក្នុងចិត្ត ការផ្តោះប្តូយោបល់ ដើម្បីស្វែងរកដំណោះស្រាយសមស្រប។ ចំណែកដំណាក់កាលចុងក្រោយនៃការប្រាស្រ័យទាក់ទង និងធ្វើទំនាក់ទំនងនោះគឺការមានអារម្មណ៍ធូស្រាលឬអាចនៅតឹងតែង តែក៏មានដំណោះស្រាយថ្មីៗសម្រាប់យកទៅវិភាគពិចារណា ការប្រើវិធីដោះស្រាយថ្មីទៅនិងបញ្ហាដែលមាន ហើយបានទទួលការថែទាំព្យាបាល ឬអន្តរាគមន៍តាមគោលបំណងនិងផែនការការណាត់ជួបនៅពេលក្រោយទៀតបើសិនជាមានការថ្លែងអំណរគុណចំពោះការសហការ។

ទោះជាយ៉ាងណា ក្នុងការប្រាស្រ័យទាក់ទង ក៏តែងតែមានឧបសគ្គផងដែរនៅក្នុងការធ្វើទំនាក់ទំនងដែលមានដូចជា ភាសា(រួមបញ្ចូលទាំងភាសាបច្ចេកទេសដែលអ្នកទទួលមិនយល់) ស្ថានភាពឬឋានៈ ទីកន្លែងពិបាក(អ៊ូអរបញ្ហាសុវត្ថិភាព) មិនមានពេលវេលាគ្រប់គ្រាន់ បញ្ហាភេទ(មានការពិបាកសម្រាប់នារីឬបុរសក្នុងការពិភាក្សារឿងរ៉ាវផ្សេងៗ) បរិយាកាសមិនអំណោយ

ផល ប្រពៃណីផ្សេងគ្នា មិនមានមធ្យោបាយទំនាក់ទំនងឬមិនសមស្រប(វិទ្យុទាក់ទង) សំពាធនយោបាយ ឥរិយាបថមិនល្អ មិនយកចិត្តទុកដាក់ គ្មានចិត្តចង់ ពត៌មានមិនច្បាស់លាស់ មិនមែនជាប្រធានបទដែលគាត់ចង់ពិភាក្សា គោលបំណងនិងការសង្ឃឹមទុកមិនត្រូវគ្នា ភាសាកាយវិការ មិនមានលទ្ធភាពក្នុងការនិយាយឬទទួលពត៌មានដោយមានជម្រើស ស្ថានភាពនៃការអប់រំ ចំណេះដឹង ស្ថានភាពអារម្មណ៍ ស្ថានភាពសុខភាព និងការនិយាយជាដើម។

វាជាការលំបាកសម្រាប់បុរសមួយចំនួន ក្នុងការទទួលយកនូវគំនិតមួយដែលជំរុញឱ្យចែករំលែកអំណាច និងសិទ្ធិពិសេសយ៉ាងស្មើគ្នាជាមួយស្ត្រី។ មានបុរសជាច្រើនមិនព្រមទទួលយកការផ្លាស់ប្តូរណាមួយក្នុងតួនាទីយេនឌ័រ ដែលអនុញ្ញាតឱ្យស្ត្រីអាចគ្រប់គ្រងជីវិតផ្ទាល់ខ្លួនរបស់ពួកគេឡើយ។ ទោះជាយ៉ាងនេះក្តី ក៏មានបុរសកាន់តែច្រើនឡើងៗដែលព្រមទទួលយក និងគាំទ្រដល់ការផ្លាស់ប្តូរនានា ដែលលើកកម្ពស់ឋានៈរបស់ស្ត្រី ពីព្រោះពួកគេយល់ដឹងថា សមភាពយេនឌ័រអាចកែលម្អគុណភាពជីវិតរបស់មនុស្សគ្រប់គ្នា។

ជាញឹកញាប់បុរសត្រូវបានជំរុញទឹកចិត្តក្នុងការងារដើម្បីសមភាពនៃយេនឌ័រ ព្រោះពួកគេយល់ថា វាជាផ្នែកមួយដ៏សំខាន់នៃការតស៊ូផ្សេងទៀតដើម្បីយុត្តិធម៌ ដូចជាការគ្រប់គ្រងដីធ្លីនិងធនធាន ការទទួលបានការអប់រំនិងការថែទាំសុខភាពនិងសេរីភាពពីហិង្សា។ សកម្មភាពផ្សេងៗទៀតដូចជាការងារក្នុងមួយថ្ងៃអាចជួយឱ្យបុរសស្វែងយល់ និងមានក្តីអាណិតអាសូរដល់ភាពលំបាកវេទនាផ្សេងៗដែលស្ត្រីជួបប្រទះដោយសារតែវិសមភាពយេនឌ័រ។ ប្រហែលជាមានបុរសមួយចំនួនកំពុងតែរិះរកវិធីរួចទៅហើយ អំពីថាតើការ

ផ្លាស់ប្តូរ ការរំពឹងទុកក្នុងយេនឌ័រ អាចផ្តល់ផលប្រយោជន៍អ្វីខ្លះដល់បុរសនិងស្ត្រី?

មិនមែនបុរសទាំងអស់សុទ្ធតែមើលឃើញពីគ្រោះថ្នាក់ដែលបង្កឡើងដោយសារវិសមភាពយេនឌ័រ ជាពិសេសទំហំនៃភាពឈឺចាប់ដែលស្ត្រីទទួលបានដោយសារបញ្ហានេះ។ ភាពជោគជ័យអាចកើតឡើង គឺអាស្រ័យលើការជួយឱ្យបុរសមើលឃើញពីភាពលំបាកទាំងនេះ និងយល់ពីតួនាទីរបស់បុរសនៅក្នុងការដោះស្រាយបញ្ហា ដោយមិនធ្វើឱ្យពួកគេទទួលនូវភាពអាម៉ាសដោយសារកង្វះខាតការយល់ដឹងរបស់ពួកគេនោះទេ។

ដូច្នេះដើម្បីជួយឱ្យបុរសមិនមានអារម្មណ៍ទើសទាល់ ជាដំបូង បុរសត្រូវមានចិត្តអាណិតអាសូរដល់ភាពលំបាករបស់ស្ត្រី យល់ពីភាពឈឺចាប់របស់ស្ត្រី និងស្វែងយល់ពីដំណើរជីវិតនិងការប្រាស្រ័យទាក់ទងរបស់ស្ត្រី ដោយប្រើប្រាស់នូវរាល់អ្វីដែលបង្ហាញពីរឿងរ៉ាវ និងហេតុការណ៍ផ្សេងៗ ដូចជារបៀបដែលស្ត្រីជាច្រើនត្រូវបានរើសអើងនៅក្នុងការងារ ស្ត្រីទទួលរងនូវអំពើហិង្សា និងភាពឈឺចាប់របស់ស្ត្រីដោយសារតែមានឋានៈទាបនៅក្នុងយេនឌ័រ ដែលនៅផ្នែកនៃការបង្ហាញ បានធ្វើឱ្យបុរសពិចារណាទៅលើសកម្មភាព និងឥរិយាបថរបស់ខ្លួនចំពោះបញ្ហាដែលបានកើតឡើង។

មានបុរសជាច្រើនបានយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហានានាដែលស្ត្រីប្រឈម ប៉ុន្តែមានខ្លះទៀតនៅតែមិនសូវយល់ ឬមិនយកចិត្តទុកដាក់នឹងបញ្ហាវិសមភាពយេនឌ័រនេះនៅឡើយទេ។ ដូច្នេះដើម្បីជំរុញការយល់ដឹងបន្ថែមយើងអាចបង្កើតជាសកម្មភាពដែលមានការប្រកួតប្រជែងគ្នា ហើយត្រូវ

ព្យាយាមធ្វើការពន្យល់ឱ្យបានល្អបំផុតអំពីមូលហេតុដែលបណ្តាលឱ្យមានវិសមភាពយេនឌ័រ។ ជាមួយនឹងការយល់ដឹង សេចក្តីមេត្តា និងការបារម្ភអំពីស្ត្រីដែលនៅជិតខ្លួន អាចធ្វើឱ្យបុរសចាប់ផ្តើមពិចារណាអំពីការផ្លាស់ប្តូរ ដោយមើលទៅលើភាពអយុត្តិធម៌ ឬក្តីអស់សង្ឃឹមរបស់ស្ត្រី រួចក៏អាចធ្វើការផ្លាស់ប្តូរដែលវាជួយឱ្យបុរសគិតអំពីរបៀបផ្លាស់ប្តូរនៅក្នុងឆាកជីវិត ក្នុងការប្រាស្រ័យទាក់ទង និងក្នុងសហគមន៍របស់ពួកគេផ្ទាល់។

## ៥- បច្ចុប្បន្នភាពនៃការលើកកម្ពស់តួនាទីយេនឌ័រ

បើកាលណាយើងនិយាយពីការលើកកម្ពស់យេនឌ័រ ក៏យើងត្រូវផ្តោតទៅលើតួនាទីយេនឌ័រផងដែរ ថាតើតួនាទីយេនឌ័រមានសារៈសំខាន់យ៉ាងណាខ្លះក្នុងការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងឡាយរបស់គ្រួសារ ក៏ដូចជាសហគមន៍ ដើម្បីអភិវឌ្ឍន៍គ្រួសារ និងសហគមន៍?

តួនាទីយេនឌ័រ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពទាំងឡាយរបស់គ្រួសារ និងសហគមន៍ ដើម្បីអភិវឌ្ឍន៍គ្រួសារនិងសហគមន៍ ដូច្នេះយើងគប្បីបង្កើតឱ្យមានការពិភាក្សាអំពីវិធីផ្សេងៗក្នុងការបែករំលែកការទទួលខុសត្រូវផ្អែកលើសមភាពយេនឌ័រ។ បើបុរសអាចធ្វើការងារអ្វីបាន ស្ត្រីក៏អាចធ្វើការងារនោះបានដូចគ្នា ពោលគឺស្ត្រីនិងបុរសអាចធ្វើគ្រប់យ៉ាងដូចជា គ្រូបង្រៀន គ្រូពេទ្យ តុលាការ វិស្វករ ... (នេះបើនិយាយពីការចូលរួមការងារក្នុងសង្គម) និងស្ត្រីនិងបុរសអាចធ្វើការងារផ្ទះគ្រប់យ៉ាងបានដូចគ្នា ដូចជាការមើលថែចិញ្ចឹមបីបាច់កូន ការមើលថែមនុស្សចាស់...(នេះបើនិយាយពីការចូលរួមការងារក្នុងសង្គមគ្រួសារ) គឺបានដូចគ្នា។ បើនិយាយឱ្យ

សាមញ្ញងាយយល់ តួនាទីយេនឌ័រ គឺជាការរៀបរាប់ពីអ្វីដែលបុរសនិងស្ត្រីរំពឹងថា នឹងធ្វើអ្វីមួយបាន។ ឧទាហរណ៍៖ បុរសត្រូវបានគេរំពឹងទុកថា ជាអ្នកទទួលបន្ទុកការងារកាប់ឱស រកត្រី រីឯស្ត្រីវិញគឺជាអ្នកចម្អិនចំណីអាហារជាដើម។

ចាប់តាំងពីយើងបានបង្កើតឱ្យមានតួនាទីយេនឌ័រ យើងសង្កេតឃើញថា បច្ចុប្បន្ននេះ សង្គមកម្ពុជាមានការផ្លាស់ប្តូរការទទួលខុសត្រូវការងាររបស់បុរសនិងស្ត្រីនៅក្នុងជីវិតរស់នៅ និងការយល់ដឹងពីឥទ្ធិពលនៃយេនឌ័របានច្រើន ជាពិសេសទៅលើការអនុវត្តបានល្អសម្រាប់លើកកម្ពស់យេនឌ័រ ទាំងបុរសទាំងស្ត្រី។ កាលពីមុន ជាទូទៅស្ត្រីខ្មែរត្រូវបានគេមិនឱ្យទៅរៀនសូត្របានខ្ពស់ខ្ពស់ទេ ឬក៏ស្ត្រីមិនត្រូវបានឱ្យចេញទៅធ្វើការក្រៅផ្ទះដូចបុរសនោះដែរ ដែលវាផ្ទុយស្រឡះពីបច្ចុប្បន្នភាព ដែលស្ត្រីអាចចូលប្រឡូកគ្រប់ការងារទាំងអស់ ទាំងការងារក្នុងផ្ទះ និងការងារក្រៅផ្ទះ។

ដោយមើលឃើញពីសារៈសំខាន់នៃការចូលរួមចំណែករបស់យេនឌ័រ ទើបនាពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់យេនឌ័រ ធ្វើយ៉ាងណាឱ្យមានសមភាពរវាងបុរសនិងស្ត្រី ដើម្បីស្ត្រីនាពេលបច្ចុប្បន្នមានសិទ្ធិ និងកាតព្វកិច្ចចូលរួមក្នុងកិច្ចការនយោបាយដូចបុរសដែរ ពោលគឺ ***ស្ត្រីជាឆ្អឹងខ្នងរបស់ប្រទេសជាតិ ជាកោសិកានៃសង្គម និងជាមាតានៃពិភពលោក***។ ដើម្បីលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីលុបបំបាត់រាល់ការរើសអើងលើស្ត្រីភេទ ដើម្បីភាពសុខសាន្តក្នុងសង្គមនិងភាពរីកចម្រើននៃសង្គមជាតិ យើងត្រូវរួមគ្នាលើកកម្ពស់យេនឌ័រ។ ដូច្នេះសមភាពយេនឌ័រ គឺមានន័យថា គ្មានការរើសអើងរវាងបុរសនិងស្ត្រី មានលក្ខខណ្ឌនិងទទួលបាន

នូវសិទ្ធិស្មើៗគ្នា ជាការឱ្យតម្លៃដោយសង្គមទៅលើភាពដូចគ្នា និងភាពខុសគ្នា ដូចជា ភេទទាំងពីរត្រូវបានគេផ្តល់ឱកាសឱ្យស្មើគ្នា ហើយភេទទាំងពីរក៏ត្រូវបានទទួលផលប្រយោជន៍ស្មើគ្នា ទោះបីជាមានភាពខុសគ្នាផ្នែកជីវសាស្ត្រយ៉ាងណាក៏ដោយ ពោលគឺយើងមិនត្រូវឱ្យមានភាពលម្អៀងនៃយេនឌ័រឡើយ។ បើកាលណាមានភាពលម្អៀងយេនឌ័រនោះ នោះតួនាទីបុរសនិងស្ត្រីក៏មានភាពលម្អៀង។ កាលពីមុន បុរសនិងស្ត្រី ជានិច្ចកាលបានបង្ហាញពីតួនាទីរបស់ខ្លួន ដូចជា ស្ត្រីជាអ្នកចម្អិនអាហារ ចំណែកបុរសចេញទៅធ្វើការក្រៅផ្ទះ ឬឆ្ងាយផ្ទះ ហើយស្ត្រីមានការជឿជាក់ថា ពួកគេមិនអាចចចេសរឹងរូសបានទេ មានតែបុរសប៉ុណ្ណោះដែលជាអ្នកគ្រប់គ្រងក្រុមគ្រួសាររបស់គេ។ ដូច្នេះការលម្អៀងនៃយេនឌ័រ គឺមានដែនកំណត់សម្រាប់អ្វីដែលបុរសនិងស្ត្រីមាន ក្នុងការធ្វើសកម្មភាពនានាទាក់ទងនឹងការរស់នៅ។ ដោយហេតុនេះ ក្នុងពេលបច្ចុប្បន្ននៅលើពិភពលោកនេះ ទំនៀមទម្លាប់នៃយេនឌ័រកាលពីមុន គឺកំពុងមានការផ្លាស់ប្តូរ ព្រោះមានមនុស្សវ័យក្មេងជាច្រើនដែលធ្វើការដើម្បីសមភាព និងយុត្តិធម៌ ដែលកំពុងតែជួយឱ្យមានការផ្លាស់ប្តូរនេះ ហើយយេនឌ័រខ្លះអាចជះឥទ្ធិពលដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ដែលជាការចាំបាច់ត្រូវតែធ្វើការផ្លាស់ប្តូរ។ ពាក្យ ***ស្ត្រីបង្វិលចង្ក្រានមិនជុំ*** ធ្វើឱ្យស្ត្រីបាត់បង់សេរីភាព និងឱកាសនៃការចូលរួមសកម្មភាពក្នុងសង្គមដែលទាក់ទងនឹងការអប់រំ ការទទួលបានព័ត៌មាននិងការបញ្ចេញមតិយោបល់( ជាទូទៅ បុរសគឺជាមេគ្រួសារ ហើយក្នុងគ្រួសារ បុរសមានអំណាច បុរសមានសិទ្ធិជាអ្នកសម្រេចកិច្ចការក្នុងគ្រួសារទាំងអស់ ដូច្នេះស្ត្រីត្រូវតែស្តាប់បង្គាប់បុរស ទោះបីជាគំនិតរបស់បុរសទាំងនោះអាចបង្កបញ្ហាក៏ដោយ )។ ប៉ុន្តែបច្ចុប្បន្ននេះ ស្ត្រីបង្វិលចង្ក្រានមិនជុំ គឺមិនមែនសំដៅ

ទៅលើភាពអសមត្ថភាពរបស់ស្ត្រីទេ គឺសំដៅទៅលើទំហំការងារច្រើនដែលស្ត្រីធ្វើយ៉ាងណាក៏មិនចេះអស់ និងមិនចេះហើយ ***ជាមាតាដៃមួយរយ*** ដែលទាមទារពីការជួយចូលរួមនិងជ្រោមជ្រែងពីបុរស ហើយម្យ៉ាងទៀត បច្ចុប្បន្ននេះស្ត្រីមានឱកាសចូលប្រឡូកគ្រប់សកម្មភាពការងារក្រៅផ្ទះក្នុងសង្គម ស្ទើរតែគ្រប់វិស័យ សូម្បីតែវិស័យនយោបាយ ពោលគឺទន្ទឹមនឹងការចេញទៅបំពេញការងារខាងក្រៅផ្ទះ ក៏ស្ត្រីមិនដែលបោះបង់ចោលការងារនៅក្នុងផ្ទះដែរ តើស្ត្រីធ្វើដូចម្តេចនឹងវិលចង្ក្រានបានជុំនោះ?

បើសិនជាយើងធ្វើការអង្កេតទៅលើតួនាទីយេនឌ័រដែលគេរំពឹងទុកនោះ គឺត្រូវមើលឱ្យឃើញជាក់ច្បាស់នៅក្នុងទិដ្ឋភាពជាច្រើននៃគ្រួសារ ដែលគ្រួសារខ្លះបានប្រព្រឹត្តចំពោះក្មេងស្រី និងក្មេងប្រុសស្មើភាពគ្នា។ ប៉ុន្តែទោះជាយ៉ាងណា ក៏មានគ្រួសារមួយចំនួន មិនទាន់បានប្រព្រឹត្តចំពោះក្មេងប្រុសនិងក្មេងស្រីឱ្យបានស្មើភាពគ្នានោះទេ បើទោះបីជាមានភាពខុសគ្នាខាងវប្បធម៌ក៏ដោយ ក៏ក្មេងប្រុសជំទង់ៗមានអារម្មណ៍ថា រងសម្ពាធពីគ្រួសារនិងសង្គម អំពីតួនាទីយេនឌ័រផងដែរ។ គ្រួសារនិងសហគមន៍ គប្បីបង្កើតឱ្យមានការពិភាក្សាអំពីវិធីផ្សេងៗក្នុងការចែករំលែក ការទទួលខុសត្រូវផ្អែកលើសមភាពយេនឌ័រ។ ការធ្វើដូច្នេះពួកគេអាចមានលទ្ធភាពក្នុងការស្វែងរកវិធីដ៏ល្អប្រសើរសម្រាប់ពួកគេចែករំលែកនូវតួនាទីដែលអាចធ្វើឱ្យយុវវ័យមានការសប្បាយរីករាយ ដើម្បីភាពសុខដុមរមនានៅក្នុងគ្រួសារ។

ការលើកម្ពស់យេនឌ័រជាផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនាពេលបច្ចុប្បន្ន គឺដើម្បីចូលរួមចំណែកពង្រីកចំណេះដឹងពង្រឹងសមត្ថភាពមន្ត្រីរាជការ

គ្រប់ស្ថាប័ន គ្រប់កម្រិត ស្តីពីចំណេះដឹងយេនឌ័រ ដើម្បីបន្តផ្តល់ឱកាសដល់មន្ត្រីជាស្ត្រីក្នុងការទទួលបានតួនាទីធ្វើសេចក្តីសម្រេច ដោយបង្កើនការបញ្ជ្រាបយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានមនុស្ស ធានាថាគ្រប់សេវាកម្មទាំងអស់នៅគ្រប់វិស័យបានផ្តល់ផលប្រយោជន៍កាន់តែច្រើនដល់ស្ត្រី បង្កើននូវកិច្ចសហការ និងភាពជាដៃគូល្អរបស់ស្ថាប័ននីមួយៗ ដើម្បីរួមចំណែកបង្កើននូវប្រសិទ្ធភាពការងារ។

**ការលើកកម្ពស់យេនឌ័រក្នុងវិស័យអប់រំ** ទោះបីជាមានការអភិវឌ្ឍលើវិស័យអប់រំ និងសង្គមបានដើរទៅមុខយ៉ាងលឿនក៏ដោយ តែកូនស្រីនៅកម្ពុជាក៏នៅតែមានបញ្ហាវិសមភាពលើវិស័យអប់រំដដែល ជាពិសេសក្មេងស្រីនៅតំបន់ជនបទ។ ក្មេងស្រីមានឱកាសអប់រំតិចជាងក្មេងប្រុស ថ្វីត្បិតតែការអប់រំនៅកម្រិតបឋមសិក្សាបានបង្ហាញ និងផ្តល់អត្ថប្រយោជន៍ដល់ក្មេងទាំងពីរភេទមានចំនួនស្មើគ្នា។

បញ្ហាទាំងនេះ បានជំរុញឱ្យមានការតស៊ូមតិក្នុងចំណោមភាគីពាក់ព័ន្ធនានា ធ្វើយ៉ាងណាឱ្យការលើកកម្ពស់ស្ត្រីកម្ពុជាឱ្យមានលទ្ធភាពគ្រប់គ្រាន់ដើម្បីសិក្សាឱ្យស្មើនឹងបុរស។ បច្ចុប្បន្នក្រសួងអប់រំ យុវជននិងកីឡា បាននិងកំពុងគាំទ្រឱ្យមានការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យពាក់ព័ន្ធនានា។ ជាក់ស្តែងការជួយមន្ត្រីរាជការស៊ីវិលជាស្ត្រី គឺហាក់បីដូចជាយើងកំពុងជួយខ្លួនឯង និងសង្គមជាតិទាំងមូល ព្រោះស្ត្រីជាចលករដ៏សំខាន់មួយក្នុងការអភិវឌ្ឍសម្រាប់សង្គមជាតិ។ ស្ត្រីជាធនធានមនុស្សដ៏មានតម្លៃសម្រាប់សង្គម។ ការកសាងបណ្តាញភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី គឺជាការចូលរួមក្នុងការកសាង

ផែនការយុទ្ធសាស្ត្រអប់រំ ការចែករំលែកចំណេះដឹងនិងបទពិសោធទៅវិញទៅមកដល់យុវជននៅតាមគ្រឹះស្ថានអប់រំនានា ក៏បានចូលរួមដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងស្ត្រី។ បណ្តាញអ្នកដឹកនាំស្ត្រីនឹងប្រមូលផ្តុំស្ត្រីដែលមានតួនាទីចាប់ពីអនុប្រធានការិយាល័យរហូតដល់ថ្នាក់ក្រសួង ក្នុងការគាំទ្រ និងលើកទឹកចិត្តគ្នា ដើម្បីលើកកម្ពស់វិស័យអប់រំសម្រាប់ស្ត្រី។ តាមរយៈសកម្មភាពនេះ ស្ត្រីមកពីក្រសួងនានា នឹងបានចែករំលែកបទពិសោធចំណេះដឹង និងដំណោះស្រាយសង្គមសម្រាប់អភិវឌ្ឍសង្គម។

ពាក់ព័ន្ធនឹងការបង្ហាញការគាំទ្រលើគម្រោងនេះ ក្រសួងអប់រំគួរបន្ថែមគ្រូបង្រៀនដែលជាស្ត្រី គួរសាងសង់អន្តេវាសិកដ្ឋាន និងគួរផ្តល់អាហារូបករណ៍ដល់សិស្សនារីឱ្យបានច្រើន ដើម្បីសមភាពយេនឌ័រក្នុងវិស័យអប់រំ ដោយបង្កើនការផ្សព្វផ្សាយអប់រំ និងពន្យល់ដល់អាណាព្យាបាលមួយចំនួនឱ្យពួកគាត់ប្តូរឥរិយាបថ ឬគំនិតអវិជ្ជមានលើកូនស្រី ដើម្បីផ្តល់ឱកាសដល់កូនស្រីឱ្យបានរៀនសូត្រដូចកូនប្រុសដែរ។ ម្យ៉ាងវិញទៀតការលើកកម្ពស់យេនឌ័រនៅក្នុងវិស័យអប់រំ មិនមែនមានន័យថា ត្រឹមតែកុមារា កុមារី និងយុវជន មានសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ( ទាំងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ) ប៉ុណ្ណោះទេ យើងក៏ត្រូវការបង្កើនចំនួនស្ត្រីជាគ្រូបង្រៀន និងជានាយិកា ឬសកលវិទ្យាធិការនៅតាមបណ្តាសាលារៀន សាកលវិទ្យាល័យ ក៏ដូចជានៅតាមមជ្ឈមណ្ឌលអប់រំផងដែរ។ ក្រៅពីការសម្រេចបាននូវសមភាពក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត ការលើកកម្ពស់រវាងបុរសនិងស្ត្រី ត្រូវតែជាផ្នែកមួយនៃកម្មវិធីសិក្សានៅកម្រិតបឋមសិក្សានិងអនុវិទ្យាល័យ។ គ្រូបង្រៀននិងកម្មវិធីសិក្សា ត្រូវតែលើកទឹកចិត្តឱ្យកុមារី និងក្មេងស្រីត្រូវខិតខំពង្រីកចំណេះ

ដឹង ពង្រឹងសមត្ថភាព ដើម្បីអភិវឌ្ឍសក្តានុពលពេញលេញរបស់គេ។ ការអប់រំក្នុងប្រព័ន្ធក៏ត្រូវតែផ្តល់នូវវិធីសាស្ត្រសម្រាប់យុវជន ដើម្បីឆ្លើយតបទៅនឹងបទដ្ឋានសង្គមនានាដែលជាប់ទាក់ទងនឹងយេនឌ័រ។

**ការលើកកម្ពស់យេនឌ័រក្នុងវិស័យនយោបាយ** ការលើកកម្ពស់យេនឌ័រក្នុងវិស័យនយោបាយ ក៏អាចធានាបាននូវសមភាពយេនឌ័រ ការឆ្លើយតបនឹងបញ្ហាយេនឌ័រដែលជាកិច្ចការដ៏សំខាន់ក្នុងការជំរុញ និងបង្កើននូវតួនាទីនយោបាយសង្គមរបស់ស្ត្រីនិងបុរស។ ការធ្វើឱ្យប្រសើរឡើងនូវសមភាពយេនឌ័រ ជាពិសេសការធានាឱ្យមានលទ្ធផល និងការចូលរួមរវាងស្ត្រី និងបុរសឱ្យទទួលបាននូវភាពថ្លៃថ្នូរ និងបង្កលក្ខណៈឱ្យស្ត្រី និងបុរសចូលប្រឡូកក្នុងកិច្ចការនយោបាយ ដើម្បីទទួលបាននូវការអភិវឌ្ឍជីវភាពរស់នៅឱ្យកាន់តែមានភាពប្រសើរឡើងទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

នៅក្នុងការលើកកម្ពស់យេនឌ័រក្នុងវិស័យនយោបាយ ក៏មានបណ្តាញដែលបម្រើខាងស្ត្រីនិងនយោបាយនេះដែរ គឺ**គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ**(CPWP)[៧] ជាចលនាស្ត្រីដែលធ្វើការតស៊ូមតិនិងបញ្ចុះបញ្ចូលគណបក្សនយោបាយ ដើម្បីជំរុញភាពជាអ្នកដឹកនាំរបស់ស្ត្រី។ CPWP កំពុងធ្វើការនៅថ្នាក់ជាតិដើម្បីតស៊ូមតិ ដើម្បីភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងដើម្បីធ្វើការស្រាវជ្រាវនៅក្នុងតំបន់ ដែលបានបង្កើតឡើងនៅឆ្នាំ២០០៥ ហើយគោលដៅនៃ CPWP គឺដើម្បីបង្កើនលទ្ធភាពទទួលបានវត្តមាន និងឥទ្ធិពល

[៧] The Committee for Participation of Women in Politics

របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនយោបាយនៅគ្រប់កម្រិត។ CPWP មានបំណងសម្រេចបាននូវគោលដៅរបស់ខ្លួនតាមរយៈបេសកកម្មពីរ។ ទីមួយ គឺលើកកម្ពស់និងតស៊ូមតិ ដើម្បីចូលរួមដោយស្មើភាពតំណាងស្ត្រី និងបុរសក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពនៅក្នុងការិយាល័យ និងទី២ គឺប្តេជ្ញាពង្រឹងការយល់ដឹងរបស់ស្ត្រីនិងសំឡេងសមត្ថភាព និងសកម្មភាពរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនយោបាយ។ អាទិភាពជាយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ CPWP រួមមាន បណ្តាញដែលមានប្រសិទ្ធភាពនិងសមូហភាព ការអភិវឌ្ឍសមត្ថភាពឥទ្ធិពលលើការកំណត់របៀបវារៈនិងគោលនយោបាយ និងបានជួយដល់ការដឹកនាំរបស់យុវនារី។

ក្រៅពីបណ្តាញខាងលើ នៅមានបណ្តាញពីរទៀតគឺ **បណ្តាញយេនឌ័រនិងការអភិវឌ្ឍ** (GADNet)[៨] គឺជាតំណាងមួយដែលតំណាងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិនិងស្ថាប័នរដ្ឋចំនួន៦២ ដែលគាំទ្រការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងប្រទេសកម្ពុជា និង**បណ្តាញបុរសកម្ពុជា** (CMN)[៩] មានសមាជិកប្រុសចំនួន៦០០នាក់ មកពីក្រុមការងារសង្គមផ្សេងៗគ្នា ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រីនិងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីដោយធ្វើការជាមួយបុរសគ្រប់កម្រិតនៅកម្ពុជា។ ក្រុមបុរសបានសហការជាមួយបណ្តាញបុរសក្នុងតំបន់ដើម្បីចែករំលែក

[៨] Gender And Development Network

[៩] Cambodian Men's Network

បទពិសោធន៍និងការកសាងសមត្ថភាពស្ដីពីការយល់ដឹងអំពីភេទ និងភាពជាបុរស។

ដោយហេតុផលមួយចំនួនទាំងវប្បធម៌ នយោបាយ សេដ្ឋកិច្ច សង្គម និងប្រវត្តិសាស្ត្រ អត្រាចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយកម្ពុជានៅមានកម្រិតទាបនៅឡើយ។ ក្រសួងកិច្ចការនារី អង្គការសង្គមស៊ីវិលនិងភាគីពាក់ព័ន្ធបាននឹងកំពុងជំរុញស្ត្រីឱ្យចូលប្រឡូកក្នុងវិស័យនយោបាយ ដើម្បីដោះស្រាយបញ្ហាដែលស្ត្រីជួបប្រទះ និងជំរុញឱ្យមានសមភាពយេនឌ័រ និងការលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ។ តែទោះបីយ៉ាងណាក៏មានការលើកឡើងផ្សេងថា ស្ត្រីគួរកុំទាន់ឆាប់ប្រឡូកក្នុងវិស័យនយោបាយ ប៉ុន្តែស្ត្រីគួរតែយកចិត្តទុកដាក់លើសហគ្រិនខ្នាតតូចនិងមធ្យម ព្រោះវាក៏អាចចូលរួមចំណែកក្នុងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចរបស់ប្រទេសជាតិផងដែរ។

យើងដឹងហើយថា ប្រជាពលរដ្ឋទាំងពីរភេទ ត្រូវរួមគ្នាដើម្បីអភិវឌ្ឍន៍ជាតិ គឺសិទ្ធស្មើគ្នាចំពោះមុខច្បាប់ សិទ្ធិចូលរួមក្នុងការងារនយោបាយ សិទ្ធិជ្រើសរើសមុខរបរសមស្រប ការងារដូចគ្នា ប្រាក់ខែដូចគ្នា លុបបំបាត់នូវការរើសអើង ចូលរួមគ្រប់សកម្មភាពរបស់រាជរដ្ឋាភិបាលរួមមាន ការអប់រំផ្សព្វផ្សាយនិងការសម្រេចចិត្តនានា ប៉ុន្តែប្រការទាំងនេះ យើងអាចធ្វើបាននៅក្នុងកម្រិតមួយនៅឡើយ ជាពិសេសការចូលរួមក្នុងវិស័យនយោបាយនេះ។

**ការលើកកម្ពស់យេនឌ័រក្នុងវិស័យសេដ្ឋកិច្ច** នាពេលបច្ចុប្បន្ន ការងារស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ជាពិសេសកិច្ចការងារពាណិជ្ជកម្ម គឺបានដើរតួនាទីដ៏សំខាន់ណាស់ ព្រោះស្ត្រីបានបំពេញនិងបង្កើនសមត្ថភាព ដែលកំពុងបម្រើ

ការងារក្នុងវិស័យពាណិជ្ជកម្មនៅតាមមូលដ្ឋាន បានក្លាយជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ តម្លៃរបស់ស្ត្រីខ្មែរក្នុងគ្រួសារ ក្នុងសង្គមនិងប្រទេសជាតិ គឺតម្រូវឱ្យយើងរួមគ្នាប្រឹងប្រែងចាត់វិធានការរកដំណោះស្រាយឱ្យបានទាន់ពេលវេលា និងតាមគ្រប់រូបភាព។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ដោយមានការដឹកនាំប្រកបដោយទស្សនវិស័យវែងឆ្ងាយ និងយុទ្ធសាស្ត្រស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** កម្ពុជាសម្រេចបាននូវវឌ្ឍនភាពនិងជោគជ័យគួរជាទីមោទនៈ គឺកម្ពុជាអាចរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាមធ្យម ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២០ឆ្នាំជាប់ៗគ្នា ចំណែកអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយប្រហែល១% ក្នុង១ឆ្នាំ។ កំណើនសេដ្ឋកិច្ចដ៏រឹងមាំនេះបានមកពីការរីកចម្រើននៃវិស័យឧស្សាហកម្ម កម្មន្តសាល កសិកម្ម សំណង់ និងសេវាកម្មដែលក្នុងនោះ មានស្ត្រីចូលរួមក្នុងកម្លាំងពលកម្មចំនួនជាង៧០ភាគរយ។[១០] ជាលទ្ធផល កម្ពុជាសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រ និងប្រែក្លាយពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយអនុវត្តដោយជោគជ័យនូវគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាពជាច្រើន សំដៅលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី។ ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលបានបង្ហាញឱ្យឃើញថា កម្ពុជាមានវឌ្ឍនភាពក្នុងការកាត់បន្ថយគម្លាតយេនឌ័រ ដែលបាន

[១០] https://opendevelopmentcambodia.net/km/topics/industries/

បញ្ជាក់ក្នុងរបាយការណ៍វេទិកាសេដ្ឋកិច្ចពិភពលោក ពីចំណាត់ថ្នាក់លេខ១១២ នៅឆ្នាំ២០១៦ មកត្រឹមចំណាត់ថ្នាក់លេខ៩៩ ក្នុងចំណោម១៤៤ប្រទេស នៅឆ្នាំ២០១៧។[១១] ការបង្កើនការយល់ដឹងអំពីសេវាអភិវឌ្ឍអាជីវកម្មសំខាន់ៗសម្រាប់សហគ្រាសស្ត្រី ខ្នាតមីក្រូខ្នាតតូចនិងមធ្យម ការបង្កើតនូវកម្មវិធីនានាដើម្បីជួយឱ្យស្ត្រីទទួលបាននូវជំនាញបច្ចេកទេស សហគ្រិនភាព និងសេវាហិរញ្ញវត្ថុគាំទ្រស្ត្រីក្នុងការធ្វើពិពិធកម្ម និងពាណិជ្ជកម្មលើវិស័យកសិកម្ម ព្រមទាំងកិច្ចសហការជាមួយភាគីពាក់ព័ន្ធនានានៅក្នុងទីផ្សារការងារ ដើម្បីលុបបំបាត់ការរើសអើងស្ត្រីនៅកន្លែងការងារ រៀបចំស្តង់ដាពលកម្មសម្រាប់ស្ត្រីផ្តល់ការគាំពារសង្គម និងជួយដោះស្រាយវិវាទជាដើម។ល។ ដូច្នេះនៅក្នុងការលើកម្ពស់យេនឌ័រក្នុងវិស័យសេដ្ឋកិច្ច យើងឃើញថា បងប្អូនស្ត្រីក្នុងវិស័យការងារកិច្ចការនារី ពិតជាបានចូលរួមចំណែកដ៏សំខាន់លើការងារអភិវឌ្ឍន៍កំណើនសេដ្ឋកិច្ចសង្គម និងការងារអភិវឌ្ឍន៍សមត្ថភាពស្ត្រីបានយ៉ាងល្អប្រសើរ ថ្វីត្បិតតែវិស័យកិច្ចការនារីមានការរីកចម្រើនក្តី ក៏ប៉ុន្តែស្ត្រីជាថ្នាក់ដឹកនាំនៅតែជួបបញ្ហាប្រឈមនៅឡើយ ដូចជាការមាក់ងាយពីបុរស ពីអ្នកមានអំណាចតាមការបោកបញ្ឆោត ការរើសអើង ភាពក្រីក្រនិងការមានសុខភាពទន់ខ្សោយជាដើម។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់កាន់តែខ្លាំងឡើងនូវតម្រូវការឆ្លើយតបនឹងបញ្ហាយេនឌ័រ ដោយសារតែបញ្ហានេះ មិនត្រឹមតែជួយដល់ការបង្កើន និងធានានិរន្តរភាពនៃសេដ្ឋកិច្ចគ្រួសារប៉ុណ្ណោះទេ ថែមទាំងជួយដល់ការអភិវឌ្ឍជាតិ និងការរីកចម្រើននៃសេដ្ឋកិច្ចផងដែរ។

[១១] http://freshnewsasia.com/index.php/en/localnews/82578-2018-03-28-11-10-46.html

**ការលើកកម្ពស់យេនឌ័រក្នុងវិស័យសិទ្ធិមនុស្ស** ការលើកកម្ពស់យេនឌ័រក្នុងវិស័យសិទ្ធិមនុស្សអាចសម្រេចបានជោគជ័យ លុះត្រាតែស្ត្រីនិងបុរសទទួលសិទ្ធិមនុស្ស សិទ្ធិការងារដូចគ្នា និងជាពិសេសការទទួលខុសត្រូវនិងឱកាសក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាដែលអាចមានឥទ្ធិពលមកលើពួកគេ។ យេនឌ័រនិងសិទ្ធិមនុស្ស គឺជាគុណតម្លៃនិងជាគោលការណ៍មូលដ្ឋាននៃមនុស្សជាតិដែលបានអនុម័តដោយមេដឹកនាំពិភពលោកនៅក្នុងឆ្នាំ១៩៤៥ គឺ "**សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី**" ហើយកិច្ចការពារ និងការលើកកម្ពស់សិទ្ធិស្ត្រី គឺជាទំនួលខុសត្រូវរបស់រដ្ឋទាំងអស់។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ស្ត្រីរាប់លាននាក់នៅជុំវិញពិភពលោកបន្តជួបប្រទះការរើសអើងនៅឡើយ។ ស្ត្រីមួយចំនួនត្រូវបានរើសអើងដោយច្បាប់ និងគោលនយោបាយមួយចំនួនដែលហាមឃាត់ស្ត្រីពីការទទួលបានស្មើភាពនូវដីធ្លី ទ្រព្យសម្បត្តិ និងលំនៅ។ ការរើសអើងផ្នែកសេដ្ឋកិច្ច និងសង្គម បណ្តាលឱ្យមានជម្រើសជីវិតសម្រាប់ស្ត្រីកាន់តែតិចទៅតិចទៅនិងក្រីក្រទៅៗ ដែលធ្វើឱ្យស្ត្រីទាំងនោះងាយរងគ្រោះនឹងការជួញដូរ។ អំពើហិង្សាកើតចេញពីយេនឌ័រ ប៉ះពាល់យ៉ាងហោចណាស់៣០%នៃស្ត្រីនៅទូទាំងពិភពលោក។ ស្ត្រីត្រូវបានបដិសេធនូវសិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពបន្តពូជ។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីក៏ធ្លាប់បានគេបដិសេធមិនទទួលយកដោយសហគមន៍របស់គេ និងបានមើលឃើញថា ជាការគំរាមកំហែងដល់សាសនា កិត្តិយស ឬវប្បធម៌។ តួនាទីយ៉ាងសំខាន់របស់ស្ត្រីចំពោះសន្តិភាព និងសន្តិសុខ ជាញឹកញយត្រូវបានមើលរំលង ដូចជាពេលមានហានិភ័យជាក់លាក់ដែលពួកគេប្រឈមនឹងស្ថានភាពជម្លោះជាដើម។

ជាងនេះទៅទៀត ក្រុមស្ត្រីមួយចំនួនប្រឈមនឹងទម្រង់នៃការរើសអើងនានាដែលកាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើងៗ ដោយសារតែកត្តានានា ដូចជាអាយុរបស់ពួកគេ ជាតិពិន្ទុ ពិការភាព ឬស្ថានភាពសេដ្ឋកិច្ចសង្គម ដែលបន្ថែមលើការរើសអើងយេនឌ័រ។ ដើម្បីធានាឱ្យមានប្រសិទ្ធភាពនូវសិទ្ធិមនុស្សរបស់ស្ត្រី ជាបឋមតម្រូវឱ្យមានការយល់ដឹងទូលំទូលាយនូវរចនាសម្ព័ន្ធសង្គម និងទំនាក់ទំនងអំណាចដែលនៅជុំវិញរឿងនេះ មិនត្រឹមតែច្បាប់និងនយោបាយប៉ុណ្ណោះទេ ថែមទាំងសេដ្ឋកិច្ច សក្ដានុពលសង្គម និងគ្រួសារ ព្រមទាំងជីវិតសហគមន៍ផងដែរ។ ផ្នត់គំនិតយេនឌ័រ ត្រូវតែផ្លាស់ប្តូរចេញ ដើម្បីឱ្យស្ត្រីលែងត្រូវបានគេចាត់ទុកថា អ្វីដែលស្ត្រីមិនគួរ ហើយជំនួសមកវិញនូវការមើលឃើញថា ពួកគេជាអ្នកណា?

សម្រាប់បរិបទក្នុងប្រទេសកម្ពុជា វិសមភាពយេនឌ័រនៅតែបន្តកើតមានស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត មានជាអាទិ៍ដូចជា សេដ្ឋកិច្ច ការអប់រំ នយោបាយ សុខភាព អាពាហ៍ពិពាហ៍និងសន្តិសុខ។ ឧទាហរណ៍ ផ្នែកសេដ្ឋកិច្ច ភាពខុសគ្នារវាងយេនឌ័រ នៅតែបន្តកើតមានក្នុងក្រុមការងារស្ត្រីគ្របដណ្តប់លើសលុបលើវិស័យកាត់ដេរ ហើយបុរសគ្របដណ្តប់លើសលុបលើវិស័យសំណង់។ ស្ត្រីចូលរួមក្នុងការងារដែលងាយរងគ្រោះ ស្ត្រីមានតំណាងមិនគ្រប់គ្រាន់ក្នុងវិស័យសាធារណៈ និងមានតិចតួចអ្នកធ្វើសេចក្តីសម្រេចចិត្ត៉។ ការអប់រំស្ត្រី ៤០%មានអាយុចន្លោះពី២៥ដល់៤៤ឆ្នាំជាអនក្ខរជន បើធៀបទៅនឹងបុរសនៅក្នុងក្រុមអាយុដូចគ្នាអត្រាអនក្ខរជនមានចំនួន២២%។[១២] ដូច្នេះ

[១២] https://www.rfa.org/khmer/program/women/gender_and_education

ក្មេងស្រីមានឱកាសអប់រំតិចជាងក្មេងប្រុស។ ក្នុងវិស័យនយោបាយ រដ្ឋសភានៅតែបន្តគាំទ្រលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិអំណាចស្រ្តី ដើម្បីកាត់បន្ថយការរើសអើងស្រ្តីភេទ អំពើហិង្សាលើស្រ្តីនិងកុមារី ប៉ុន្តែចំនួនស្រ្តីក្នុងវិស័យនេះនៅមានកម្រិត។ ចំពោះផ្នែកសន្តិសុខ ក្នុងការអង្កេតមួយនាឆ្នាំ២០១៥ មានស្រ្តី១នាក់ ក្នុងចំណោមស្រ្តី៥នាក់ ត្រូវបានរាយការណ៍ថា បានទទួលរងការរំលោភបំពានរាងកាយនិងផ្លូវភេទ និងតាមការអង្កេតឆ្នាំ២០១៣ មានបុរសជាង៣៥%ដែលកំពុងមាននិងបានមានទំនាក់ទំនងរឿងស្នេហា ហើយត្រូវបានគេរាយការណ៍ថា ពួកគេបានប្រើអំពើហិង្សាលើរាងកាយ ឬអំពើហិង្សាផ្លូវភេទលើដៃគូរបស់ពួកគេ ហើយបុរសចំនួន២០%ដែលគេបានធ្វើការអង្កេតនិងរាយការណ៍ថាបានប្រព្រឹត្តិអំពើសេពសន្ធវៈ។

ដូច្នេះតាមការលើកជាឧទាហរណ៍ខាងលើ យើងឃើញថា បច្ចុប្បន្នភាពនៃការលើកកម្ពស់យេនឌ័រនៅកម្ពុជានៅមានកម្រិតនៅឡើយ ហើយរាជរដ្ឋាភិបាលក៏គួរតែកែលម្អនូវភាពខ្វះចន្លោះនៃគោលនយោបាយ និងការពាក់ព័ន្ធនានា សំដៅធានាការពារសិទ្ធិ និងលើកកម្ពស់ការចូលរួមរបស់ស្រ្តីនៅក្នុងសង្គម សេដ្ឋកិច្ច និងអភិបាលកិច្ច ព្រមទាំងផ្តល់ឱកាសបន្ថែមទៀតដល់ស្រ្តី ជាពិសេសយុវវ័យ នៅក្នុងតួនាទីធ្វើការសម្រេចចិត្តទាំងនៅក្នុងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាបន្តកសាងនិងលើកកម្ពស់ស្រ្តីនិងកុមារ ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងភាពជាអ្នកដឹកនាំ ក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីបង្ហាញពីកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ស្រ្តីចូលរួមក្នុងភាពជាអ្នកដឹកនាំ និងទ្រទ្រង់សេដ្ឋកិច្ច សង្គម ពិសេសធ្វើឱ្យប្រសើរឡើងនូវស្ថានភាពជីវភាព សិទ្ធិឋានៈ និងតួនាទីស្រ្តីក្នុងគ្រប់វិស័យ។ ការដែលនិយាយនេះ មិនមែនមានន័យ

ថា រាជរដ្ឋាភិបាលកម្ពុជាមិនបានដាក់ចេញគោលនយោបាយយុទ្ធសាស្ត្រ ដោយជំរុញឱ្យមានសមធម៌យេនឌ័រ និងដំណើរឆ្ពោះទៅរកការលើកកម្ពស់យេនឌ័រពិតប្រាកដនោះទេ គឺគ្រាន់តែសុំឱ្យរាជរដ្ឋាភិបាលបង្កើនការយកចិត្តទុកដាក់ឱ្យដល់កម្រិតខ្ពស់ក្នុងការលើកកម្ពស់យេនឌ័រឱ្យសក្តិសមនឹងការចាត់ទុកថា«**ស្ត្រីគឺជាឆ្អឹងខ្នង នៃសេដ្ឋកិច្ចនិងសង្គមជាតិ**» ដែលជាអ្នកចូលរួមយ៉ាងសកម្មក្នុងការប្រែក្លាយប្រទេសកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០ តាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ យើងខ្ញុំក៏សុំឱ្យបង្កើនការគាំទ្របន្ថែម និងជាបន្តទៀតក្នុងការលើកកម្ពស់ស្ថានភាព ឋានៈនិងតួនាទីស្ត្រី តាមរយៈការផ្តល់ឱកាសឱ្យស្ត្រីបានចូលទៅក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តគ្រប់ជាន់ថ្នាក់ពោលគឺតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋានផងដែរ។

ដូច្នេះគោលគំនិតនៃបញ្ចូលបញ្ហាយេនឌ័រទៅក្នុងចរន្តចរិតលក្ខណៈសង្គម ត្រូវបានបង្កើតយ៉ាងច្បាស់ជាយុទ្ធសាស្ត្រសកលមួយសម្រាប់លើកកម្ពស់សមភាពយេនឌ័រនៅក្នុងវេទិកាសកម្មភាពដែលបានអនុម័តនៅសន្និសីទពិភពលោកលើកទី៤របស់អង្គការសហប្រជាជាតិស្តីពីស្ត្រីដែលបានធ្វើឡើងនៅក្នុងទីក្រុងប៉េកាំងប្រទេសចិនក្នុងឆ្នាំ១៩៩៥។ ភាពចាំបាច់ដើម្បីធានាថាសមភាពយេនឌ័រគឺជាគោលដៅចម្បងនៅក្នុងគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។

នៅខែកក្កដា ឆ្នាំ១៩៩៧ ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ(ECOSOC)បានកំណត់និយមន័យនៃការបញ្ជ្រាបយេនឌ័រថា៖

*ការបញ្ជ្រាបទស្សនវិស័យយេនឌ័រ គឺជាដំណើរការនៃការវាយតម្លៃផលប៉ះពាល់ចំពោះស្ត្រី និងបុរសចំពោះសកម្មភាពដែលបានគ្រោងទុក រួមទាំងច្បាប់ គោលនយោបាយឬកម្មវិធីនៅគ្រប់ទីកន្លែងនិងគ្រប់កម្រិតទាំងអស់។ វាជាយុទ្ធសាស្ត្រសម្រាប់ធ្វើឱ្យក្ដីកង្វល់ និងបទពិសោធន៍របស់ស្ត្រីនិងបុរស ជាផ្នែកសំខាន់ដែលត្រូវប្រែបាច់បញ្ចូលគ្នាក្នុងការរៀបចំគម្រោង ការត្រួតពិនិត្យនិងវាយតម្លៃលើគោលនយោបាយ និងកម្មវិធីនៅក្នុងគ្រប់វិស័យនយោបាយ សេដ្ឋកិច្ចនិងសង្គម ដើម្បីឱ្យស្ត្រីនិងបុរសទទួលបានអត្ថប្រយោជន៍ស្មើៗគ្នា ហើយវិសមភាពនឹងត្រូវលុបបំបាត់ចោលរហូត។ គោលដៅចុងក្រោយបំផុតនៃការបញ្ជ្រាប គឺការធ្វើឱ្យមានសមភាពយេនឌ័រ។ ការបញ្ជ្រាបយេនឌ័ររួមមានទាំងសកម្មភាពយេនឌ័រជាក់លាក់ និងសកម្មភាពចាំបាច់ផ្សេងៗទៀត ដែលកើតឡើងចំពោះស្ត្រី ឬបុរសស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ។ អន្តរាគមន៍យេនឌ័រជាក់លាក់ អាចកំណត់គោលដៅលើផ្នែកស្ត្រី បុរស និងស្ត្រីរួមគ្នា ឬតែផ្នែកបុរសប៉ុណ្ណោះ ដើម្បីជួយពួកគេឱ្យចូលរួម និងទទួលបានផលប្រយោជន៍ស្មើៗគ្នាពីកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍។ ទាំងនេះគឺជាវិធានការបណ្ដោះអាសន្នដែលចាំបាច់ត្រូវបង្កើតដើម្បីប្រឆាំងនឹងផលវិបាកដោយផ្ទាល់និងដោយប្រយោលដែលបន្សល់ទុកដោយការរើសអើងកាលពីអតីតកាល។*

## . ការឆ្លុះបញ្ចាំងទិន្នន័យនៃការរំលោភសិទ្ធិស្ត្រី

ព្រឹត្តិការណ៍សកលដែលមនុស្សទូទៅជុំវិញពិភពលោក ជាពិសេសគឺស្ត្រីបាននាំគ្នាប្រារព្ធឡើងដើម្បីរំលឹកដល់វីរៈភាពនៃការតស៊ូទាមទារសិទ្ធិសេរីភាពរបស់ស្ត្រី ប្រឆាំងនឹងការរើសអើងភេទ ព្រមទាំងភាពអសមភាពទាំងអស់

រវាងបុរសនិងស្រ្តីគឺព្រឹត្តិការណ៍៨មីនា។ មុននឹងមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិរហូតសព្វថ្ងៃនេះ គឺមានការតស៊ូប្រឹងប្រែងអស់ប្រមាណមួយសតវត្សពីសំណាក់សកម្មជនស្ត្រី ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតសង្គមក្នុងការទទួលស្គាល់សិទ្ធិរបស់ស្ត្រី។ បើយើងប្រៀបធៀបប្រវត្តិអន្តរជាតិនារី ៨មីនាទៅនឹងកំណើតនៃអង្គការសហប្រជាជាតិឃើញថា ប្រវត្តិទិវាសិទ្ធិអន្តរជាតិនារី ៨មីនា មានកំណើតមុនអង្គការសហប្រជាជាតិ និងទិវាសិទ្ធិមនុស្សអន្តរជាតិ។

នៅក្នុងប្រទេសកម្ពុជា ទិវានេះត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំស្ទើរតែគ្រប់ស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិលដែលធ្វើការងារពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិស្ត្រី និងកុមារក្រោមប្រធានបទផ្សេងៗគ្នា ក្នុងគោលបំណងដើម្បីអំពាវនាវនិងផ្សព្វផ្សាយដល់មនុស្សគ្រប់រូប ទាំងបុរសស្ត្រីនិងភេទដទៃទៀត ជាពិសេសអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចូលរួមទប់ស្កាត់និងលុបបំបាត់នូវបញ្ហា និងការរើសអើងគ្រប់រូបភាពដែលមានចំពោះស្ត្រីនិងកុមារី។ ស្របពេលដែលកំពុងស្ថិតក្នុងកាលៈទេសៈមួយដែលនៅតែបន្តការរើសអើង ការរំលោភសិទ្ធិសេរីភាព ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច អំពើហិង្សា និងការចាប់ដាក់ពន្ធនាគារសម្រាប់ស្ត្រីនិងគ្រួសាររបស់ពួកគេ ជាពិសេសនៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ចាប់តាំងពីចុងឆ្នាំ២០១៩។

បច្ចុប្បន្នយើងឃើញថា កម្ពុជាមានលិខិតបទដ្ឋានគតិយុត្តិទាំងច្បាប់ជាតិនិងច្បាប់អន្តរជាតិជាច្រើន រួមមានដូចជា រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ អនុសញ្ញាស្តីការ

លប់បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សជាដើម ដែលធានាដល់ការលើកកម្ពស់សិទ្ធិស្ត្រី សមភាពយេនឌ័រ ភាពស្មើគ្នារវាងបុរសនិងស្ត្រី និងការបញ្ឈប់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី។ល។ ប៉ុន្តែជាក់ស្តែង បន្ថែមពីអ្វីដែលបានលើកឡើងខាងលើ សមាគមអាដហុកបានរកឃើញថា ជារឿយៗស្ត្រីនៅតែទទួលរងគ្រោះពីការរំលោភសិទ្ធិតាមរូបភាពផ្សេងៗដូចជា អំពើរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារនិងការជួញដូរមនុស្ស(ការជួញដូរភេទនិងកម្លាំងពលកម្ម)ជាដើម។

ករណីរំលោភសេពសន្ថវៈ ក្នុងរយៈពេល២ឆ្នាំ(២០២០-២០២១) **សមាគមអាដហុក**ទទួលបានពាក្យបណ្តឹងចំនួន២៤៣ករណី ដែលនៅក្នុងចំណោមករណីទាំងនេះភាគច្រើនគឺកើតនៅក្នុងខេត្តបាត់ដំបង កំពត កំពង់ធំ និងបន្ទាយមានជ័យ។ ការដែលគួរឱ្យព្រួយបារម្ភទៀតនោះគឺ ជនប្រព្រឹត្ត៩% ជាឪពុកបង្កើត ៤%ជាជីតាបង្កើត និង១២%ជាឪពុកចុង ក្រៅពីនោះគឺជាអ្នកជិតខាង សាច់ញាតិ មិត្តភក្តិ។ រីឯមូលហេតុចម្បងៗនៃអំពើនេះគឺបណ្តាលមកពីវិសមភាពយេនឌ័រ បុរសនៅតែបន្តការមើលងាយស្ត្រីនិងក្មេងស្រី ការចុះខ្សោយនៃសីលធម៌សង្គម ឥទ្ធិពលនៃគ្រឿងញៀន បញ្ហាសន្តិសុខសង្គម ឪពុកម្តាយចំណាកស្រុកទៅធ្វើការងារឆ្ងាយផ្ទះ ការរីកចម្រើននៃបច្ចេកវិទ្យា និងប្រព័ន្ធផ្សព្វផ្សាយ រួមទាំងបញ្ហានិទណ្ឌភាព។ ដូចគ្នានេះដែរ ចំពោះករណីហិង្សាក្នុងគ្រួសារ សមាគមអាដហុក ទទួលបានពាក្យបណ្តឹងសុំអន្តរាគមន៍ ចំនួន១៧៣ករណី ហើយដែលក្នុងនោះយើងបានរកឃើញថា ៥៨%ជនប្រព្រឹត្តគឺជាបុរស(ប្តី)។ តាមការកត់សម្គាល់ មូលហេតុចម្បងដែលបណ្តាលឱ្យមានអំពើហិង្សាគឺដោយសារបុរសជាប្តីមិនយល់ មិនឱ្យតម្លៃ គិតថាស្ត្រីជាភេទទន់ខ្សោយ មាន

តម្លៃទាបជាងបុរស ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញពីអតុល្យភាពនៃអំណាចរវាងបុរសនិងស្ត្រី។ បន្ថែមពីនេះដោយសារតែស្ថានភាពជីវភាពក្រីក្រ បាត់បង់ដីធ្លី សេដ្ឋកិច្ចធ្លាក់ចុះ ជំពាក់បំណុល ជាពិសេសការធ្លាក់ចុះនៃសីលធម៌សង្គម ទស្សនៈសង្គម និងការអនុវត្តច្បាប់នៅមានកម្រិតផងដែរ។ [១៣]

ជាមួយនេះដែរចំពោះអំពើជួញដូរមនុស្សក៏មិនខុសប៉ុន្មានពីករណីទាំងពីរខាងលើដែរ គឺពីរឆ្នាំនេះ **សមាគមអាដហុក**ទទួលបានពាក្យបណ្តឹងសរុប ១១៥ករណី ដែលក្នុងនោះការជួញដូរភេទមាន៨០ករណី និងការជួញដូរកម្លាំងពលកម្មមាន៣៥ករណី។ រីឯមូលហេតុចម្បងៗនោះគឺបណ្តាលមកពីបញ្ហាអត់ការងារធ្វើ ខ្វះខាតជីវភាព មិនមានដីធ្លីគ្រប់គ្រាន់ ផលិតផលកសិកម្មមិនសូវបានថ្លៃ គ្មានទីផ្សារ ជំពាក់បំណុលគេ ហិង្សាក្នុងគ្រួសារ ទស្សនៈសង្គម ភាពជឿនលឿននៃបច្ចេកវិទ្យា មេខ្យល់មានល្បិចកលខ្ពស់ មានបណ្តាញជាពិសេសការធូរលុងនៅតាមព្រំដែន។

តាមរយៈទិន្នន័យខាងលើបានបង្ហាញឱ្យយើងឃើញថា បច្ចុប្បន្ននេះស្ត្រីនៅតែបន្តរងគ្រោះពីការរំលោភបំពាន ទាំងផ្លូវកាយ ផ្លូវភេទនិងផ្លូវចិត្ត បើទោះបីជាកន្លងមកមានកិច្ចខំប្រឹងប្រែងជាច្រើនពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសពីក្រុមអង្គការសង្គមស៊ីវិលមួយចំនួន តួយ៉ាងដូចជាសមាគមអាដហុក ដែលកន្លងមកបានខិតខំប្រឹងប្រែងតាមរយៈសកម្មភាពមួយចំនួនដូចជា ការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី សមភាពយេនឌ័រ និង

---

[១៣] https://www.adhoccambodia.org/km/khmer

ច្បាប់ពាក់ព័ន្ធផ្សេងៗ ក៏ដូចជាការផ្តល់ការការពារតាមរយៈការអង្កេត អន្តរាគមន៍និងការផ្តល់មេធាវី ដើម្បីធ្វើយ៉ាងណាធានាថាជនរងគ្រោះទទួលបានយុត្តិធម៌ ហើយជនប្រព្រឹត្តត្រូវតែទទួលទោសទណ្ឌទៅតាមអំពើដែលខ្លួនបានប្រព្រឹត្ត និងពិសេសជាងនេះទៅទៀតគឺការបញ្ឈប់អំពើនិទណ្ឌភាពនៅក្នុងប្រទេសកម្ពុជា។

ដូច្នេះគ្រប់ភាគីពាក់ព័ន្ធជាពិសេសអាជ្ញាធរដ្ឋត្រូវពង្រឹងបន្ថែមចំពោះកិច្ចគាំពារដល់ស្ត្រីនិងកុមារ ឆ្លើយតបតម្រូវការរបស់ស្ត្រី ពង្រឹងការអនុវត្តច្បាប់ជាពិសេសការស្តែងចេញជាសកម្មភាព និងផែនការជាក់ស្តែង។ ផ្តល់ឱកាសស្ត្រីឱ្យបានចូលរួមអនុវត្តនូវសិទ្ធិរបស់ខ្លួនបានពេញលេញ។ ទន្ទឹមនឹងនេះផងដែរ ស្ត្រីត្រូវតែចាប់ផ្តើមពីថ្ងៃនេះក្នុងការពង្រីកចំណេះដឹង ពង្រឹងសមត្ថភាពជំនាញនិងជំនឿចិត្តលើខ្លួនឯង ហើយចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការងារនានាគ្រប់កម្រិត ត្រូវហ៊ានលើកឡើងពីបញ្ហានិងតម្រូវការជាក់លាក់របស់ខ្លួន។

## ៦- សិទ្ធិស្មើភាពរវាងស្ត្រី-បុរសជាអន្តរជាតិ

នៅពេលអង្គការសហប្រជាជាតិបង្កើតឡើងនាឆ្នាំ១៩៤៥ គឺគេបានបង្កើតលក្ខន្តិកៈមួយដែលទាមទារនូវសិទ្ធិស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រី។ ក្នុងពេលដែលលក្ខន្តិកៈនេះត្រូវបានសរសេរឡើង គឺក្នុងចំណោម៥១ប្រទេសដែលចូលរួម មានតែ៣០ប្រទេសប៉ុណ្ណោះ ដែលមានច្បាប់អនុញ្ញាតឱ្យស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរសក្នុងការបោះឆ្នោត។ ទោះបីជាលក្ខន្តិកៈអង្គការសហប្រជាជាតិបានអំពាវនាវឱ្យមានសិទ្ធិយេនឌ័រស្មើភាពគ្នាក្តី តែការរៀបចំជាអន្តរជាតិដើម្បីជជែកអំពីបញ្ហានេះ ធ្វើឡើងនាច្រើនទសវត្សរ៍ក្រោយ។ លុះដល់ឆ្នាំ១៩៧៥ គេ

ឃើញមានស្ត្រីមកពីស្ទើរគ្រប់ប្រទេសទាំងអស់ក្នុងសាកលលោក បានមកជួបជុំនៅក្នុងទីក្រុង**ម៉ិកស៊ីកូ** ដើម្បីពិភាក្សាពីសិទ្ធិរបស់ស្ត្រី និងបានស្នើសុំឱ្យធ្វើការកែប្រែច្បាប់ដែលមិនមានភាពស្មើគ្នាផ្អែកលើការរំពឹងទុកក្នុងផ្នែកយេនឌ័រ។ កិច្ចប្រជុំលើកដំបូងនេះ បានអំពាវនាវឱ្យមានការលុបបំបាត់ការរើសអើងក្នុងយេនឌ័រ ព្រមទាំងបញ្ចូលបញ្ហាស្ត្រីទៅក្នុងផែនការអភិវឌ្ឍ។ កិច្ចប្រជុំបន្តបន្ទាប់ទៀត បានបង្កើតជានិយាមអន្តរជាតិកាន់តែជាក់លាក់ ដូចជាការផ្តល់ជូននូវសេវាផែនការគ្រួសារឱ្យដល់គ្រប់ស្ត្រីទាំងអស់ ការចិញ្ចឹមបីបាច់កូនស្រីឱ្យស្មើភាពគ្នានឹងកូនប្រុស ព្រមទាំងបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងជួររដ្ឋាភិបាលនៅទូទាំងពិភពលោកផងដែរ។

រដ្ឋាភិបាលស្ទើរតែគ្រប់ប្រទេសបានឯកភាពជាគោលការណ៍ទៅនឹងសំណើរបស់ស្ត្រី ប៉ុន្តែក្រុមស្ត្រីក្នុងស្រុក ជាពិសេសអ្នកលើកកម្ពស់សុខភាព និងដៃគូរបស់ពួកគេ នៅតែចាំបាច់ត្រូវធ្វើការរៀបចំ និងតស៊ូជាច្រើនទៀត ដើម្បីលុបបំបាត់ច្បាប់ដ៏គ្រោះថ្នាក់នានា ក៏ដូចជាធ្វើការអនុវត្តនូវច្បាប់ដែលមានយុត្តិធម៌ និងការផ្លាស់ប្តូរការគិតរបស់ប្រជាជនអំពីតួនាទីយេនឌ័រ និងសិទ្ធិមនុស្សដែលនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ។

ការផ្លាស់ប្តូរនូវសិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស គឺទាមទារនូវភាពមោះមុត និងពេលវេលា ដ្បិតថានៅពេលមនុស្សបានគិតពីរបៀបដែលតួនាទីយេនឌ័របានបង្កើតជាភាពអយុត្តិធម៌ និងបង្កគ្រោះថ្នាក់ដល់ទាំងស្ត្រីនិងបុរសនោះ ពួកគេអាចចាប់ផ្តើមពិចារណាអំពីការផ្លាស់ប្តូរនានាដែលពួកគេអាចជ្រើសរើស។ សម្រាប់មនុស្សទូទៅ វាមានន័យថា ធ្វើការផ្លាស់ប្តូរឥរិយាបថ និងការរំពឹងទុក

របស់ពួកគេផ្ទាល់ ក៏ដូចជាធ្វើកិច្ចការ ដើម្បីផ្លាស់ប្តូរទំនៀមទម្លាប់ ស្ថានភាព និងក្បួនច្បាប់នៅក្នុងសហគមន៍របស់ពួកគេ។

យ៉ាងណាមិញ វិសមភាពយេនឌ័រ ក៏ជាមូលហេតុនិងជាឫសគល់នៃបញ្ហាសុខភាពរបស់ស្ត្រីផងដែរ ជាពិសេសការស្វែងយល់អំពីសុខភាពផ្លូវភេទ។ ដូច្នេះការធ្វើឱ្យមានសិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស គឺដើម្បីសមភាពយេនឌ័រ និងដើម្បីសុខភាពរបស់ស្ត្រីផង។

បើនិយាយពីសុខភាព គឺយើងតែងនិយាយពីសុខភាពទូទៅ ហើយនៅពេលអ្នកគិតដល់សុខភាពទូទៅ គេក៏ផ្តោតទៅលើសុខភាពផ្លូវភេទ សុខភាពបន្តពូជ ឬការជៀសវាងការឆ្លងជំងឺកាមរោគ ដែលវាជាទិដ្ឋភាពដ៏សំខាន់នៅក្នុងសុខភាពផ្លូវភេទ។

ដូច្នេះដើម្បីស្ត្រីកាន់តែមានភាពជឿជាក់ទៅលើសិទ្ធិស្មើភាពគ្នារបស់ស្ត្រីនិងបុរស គឺស្ត្រីត្រូវតែមានភាពក្លាហានក្នុងការជជែកអំពីសុខភាព ជាពិសេសបញ្ហាផ្លូវភេទ និងពីចំណុចផ្សេងៗទៀតដែលធ្វើឱ្យសម្ព័ន្ធផ្លូវភេទរបស់ស្ត្រីកាន់តែមានភាពប្រសើរឡើង ហើយដែលគេអាចកែសម្រួលសកម្មភាពទាំងនេះធ្វើយ៉ាងណាឱ្យសក្តិសមទៅនឹងវ័យរបស់អ្នកចូលរួម ត្រូវនឹងយេនឌ័រ ជំនឿ និងប្រពៃណី។ សូមចងចាំថា ការជជែកដោយបើកចំហរអំពីបញ្ហាសុខភាព ជាពិសេសផ្លូវភេទ គឺដើម្បីជួយដល់ស្ត្រីដែលមានលទ្ធភាពទទួលបានសេវាថែទាំសុខភាពតិចតួចបំផុតចំពោះស្ត្រីដែលមិនហ៊ាននិយាយពីបញ្ហាសុខភាពបន្តពូជដោយមានភាពអៀនខ្មាស ដែលមិនអាចយករឿងនេះមកពិភាក្សាបាន។

សុខភាពជាតម្រូវការរបស់មនុស្សគ្រប់រូប មានសុខភាពទើបមានអ្វីៗគ្រប់យ៉ាង យ៉ាងណាមិញ សុខភាពផ្លូវភេទក៏ដូចគ្នា។ បើនិយាយពីសុខភាពផ្លូវភេទ គឺសំដៅទៅលើការរួមភេទ។ ការរួមភេទគឺជារបៀបដែលបុរសនិងស្ត្រីបង្កើតកូនជាមួយគ្នា។ ការរួមភេទ គឺជាផ្នែកមួយក្នុងចំណោមតួនាទីជាប្រពន្ធ ហើយដែលបុរសមិនអាចគិតតែពីបំពេញចំណង់ចំណូលចិត្តរបស់ខ្លួននោះទេ។

## . អត្តសញ្ញាណយេនឌ័រ

មនុស្សគ្រប់ជាតិសាសន៍ទាំងអស់ក្នុងលោក តែងតែមានសេចក្តីស្នេហា ដែលជាសេចក្តីស្នេហានៃការចងសម្ព័ន្ធមេត្រី នៃការស្រឡាញ់រវាងមនុស្សប្រុស និងមនុស្សស្រីក្នុងគោលបំណងបំពេញតម្រូវការផ្លូវភេទ និងការបង្កកំណើតនៃមនុស្សថ្មី ដើម្បីបន្តពូជពង្សវង្សត្រកូលផង។ ប៉ុន្តែទន្ទឹមនឹងនេះក៏មានមនុស្សស្រឡាញ់ភេទដូចគ្នា និងមនុស្សប្រភេទភេទទី៣។ នៅតំបន់ខ្លះ ពួកគេត្រូវបានទទួលស្គាល់ និងផ្តល់កិត្តិយសស្មើគ្នាតាមធម្មតា។ ប៉ុន្តែនៅតំបន់ខ្លះទៀត អ្នកដឹកនាំសាសនា អ្នកនយោបាយ និងអ្នកមានអំណាចមួយចំនួន មិនគាំទ្រអ្នកស្រឡាញ់ភេទដូចគ្នានោះទេ ដែលនាំឱ្យពួកគេជាច្រើននាក់ តែងតែលាក់បាំងនូវការប្រតិព័ទ្ធផ្លូវភេទរបស់ខ្លួន ដោយសារច្បាប់ប្រឆាំងនឹងការស្រឡាញ់ភេទដូចគ្នានិងបុរេវិនិច្ឆ័យផ្សេង។ ភាពអាម៉ាស់និងការភ័យខ្លាចពីការបដិសេធរបស់សង្គម អាចបណ្តាលឱ្យពួកគេមានបញ្ហាផ្លូវកាយនិងផ្លូវចិត្ត។ អ្នកស្រឡាញ់ភេទដូចគ្នា អាចត្រូវបង្ខំចិត្តរស់នៅដាច់ដោយឡែកពីគេ ដែលអាចនាំឱ្យមានការធ្លាក់ទឹកចិត្តនិងបញ្ហាសុខភាពផ្សេងៗ។ ពួកគេអាចនឹងមិនស្វែងរកការថែទាំសុខភាពជាមូលដ្ឋានទេ ដោយហេតុតែភ័យខ្លាចគេដឹងពីការប្រតិព័ទ្ធផ្លូវភេទ

របស់ខ្លួន។ ដូច្នេះការប្រតិព័ទ្ធក្នុងផ្លូវភេទរួមមាន ការស្រឡាញ់ភេទដូចគ្នា ការស្រឡាញ់ភេទផ្ទុយគ្នា និងការស្រឡាញ់ភេទទាំង២។ ចំណែកពាក្យថា "**ខ្ទើយ**" ឬ "ភេទទី៣" សំដៅលើមនុស្សដែលមានអត្តសញ្ញាណយេនឌ័រ ខុសពីជីវភេទរបស់ខ្លួន។ ឧទាហរណ៍ មនុស្សម្នាក់ដែលមានរាងកាយជាប្រុស ប៉ុន្តែមានអារម្មណ៍ជាស្រីឬមនុស្សដែលមានរាងកាយជាស្រី ប៉ុន្តែមានអារម្មណ៍ជាប្រុស។ ជាធម្មតាអារម្មណ៍ទាំងនេះ ចាប់ផ្តើមតាំងពីពេលដែលបុគ្គលនោះមាន វ័យនៅក្មេងមកម៉្លេះ ហើយចាប់ផ្តើមមើលមកខ្លួនឯងថាស្ថិតក្នុងភេទណាមួយ ប៉ុន្តែអារម្មណ៍នេះក៏អាចចាប់ផ្តើមមាននៅក្នុងវ័យជំទង់ផងដែរ។ អ្នកខ្លះមានអារម្មណ៍ថា មិនស្ថិតក្នុងភេទណាមួយទាំងស្រុងនោះទេ ប៉ុន្តែគឺទាំង២ ឬជួនកាលមានអារម្មណ៍ថា ខ្លួនស្ថិតក្នុងភេទមួយច្រើនជាងភេទមួយទៀត។

**អត្តសញ្ញាណភេទ** កើតឡើងពីការរួមផ្សំនូវចំណុច៤យ៉ាង៖ **ជីវភេទ** (ការមានរាងកាយជាមនុស្សប្រុសឬមនុស្សស្រី) **អត្តសញ្ញាណយេនឌ័រ**(ការមានអារម្មណ៍ឬអាកប្បកិរិយាជាបុរសឬស្ត្រី ឬទាំង២) **តួនាទីយេនឌ័រ**(ការអនុវត្តតាមនូវអ្វីដែលសង្គមគិតថាជាលក្ខណៈរបស់មនុស្សប្រុស ឬមនុស្សស្រី) និង**ការប្រតិព័ទ្ធក្នុងផ្លូវភេទ**(ការចាប់អារម្មណ៍លើបុរសឬស្ត្រី ឬទាំង២)។

ការប្រតិព័ទ្ធក្នុងផ្លូវភេទនិងអត្តសញ្ញាណយេនឌ័រ អាចជាផ្នែកមួយដ៏ពិបាកបំផុតក្នុងការពិភាក្សាអំពីចំណូលចិត្តផ្លូវភេទ ដែលមានអ្នកខ្លះមិនចង់ពិភាក្សាពីការស្រឡាញ់ភេទដូចគ្នាទេ ហើយក៏បានចាប់ផ្តើមដោយការជជែកអំពីភាពអាម៉ាស់។ គ្រប់គ្នាបានយល់ថា ការធ្វើឱ្យអ្នកដទៃមានភាពអាម៉ាស់ គឺ

ជាទង្វើមិនសមរម្យ និងអយុត្តិធម៌ ប៉ុន្តែប្រហែលជាអាចនៅពេលណាមួយនាពេលអនាគត មនុស្សនឹងអាចជជែកអំពីការប្រតិព័ទ្ធក្នុងផ្លូវភេទនេះបាន។

ពាក់ព័ន្ធនឹងបញ្ហានេះ អង្គការសិទ្ធិមនុស្សនៅទូទាំងពិភពលោកក៏កំពុងប្រឹងប្រែងផ្តល់ការអប់រំដល់សហគមន៍ ដើម្បីបញ្ចប់ការរើសអើង និងលើកកម្ពស់ការយល់ដឹង និងទទួលស្គាល់នូវប្រភេទផ្សេងៗនៃភេទក្នុងសម្ព័ន្ធនេះ។

## . ការបញ្ចប់ការរើសអើងភេទ គឺជាការលើកកម្ពស់សុខភាពយេនឌ័រ

នៅលើពិភពលោកយើងនេះ ការរើសអើងភេទដែលជាផ្នែកមួយនៃការលើកកម្ពស់យេនឌ័រ គឺនៅតែកំពុងបន្តកើតមាន តួយ៉ាងដូចជា ប្រទេស**គូយ៉ាណា** ស្ថិតក្នុង**ទ្វីបអាមេរិកខាងត្បូង** ដែលប្រទេសនេះមានរដ្ឋធម្មនុញ្ញមួយដែលចែងថា ស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នា ហើយរាល់ពលរដ្ឋទាំងអស់មានសិទ្ធិទទួលបានការអប់រំ ឱកាសការងារ និងការថែទាំសុខភាពស្មើៗគ្នា។ រដ្ឋធម្មនុញ្ញហាមឃាត់ការរើសអើងជាតិសាសន៍ ពណ៌សម្បុរ និន្នាការនយោបាយ ក៏ដូចជាជំនឿសាសនា។ ប៉ុន្តែសិទ្ធិទាំងនេះ មិនទាន់ត្រូវបានផ្តល់ជូនចំពោះអ្នកដែលស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទទាំង២ ឬអ្នកមានភេទទី៣ឡើយ។ ស្ត្រីនិងបុរសដែលតុបតែងខ្លួនផ្ទុយពីភេទរបស់ខ្លួន គឺជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ ហើយពួកគេមានការពិបាកក្នុងការស្វែងរកការងារធ្វើ។

អង្គការប្រឆាំងនឹងការរើសអើងផ្លូវភេទក្នុងសង្គម( SASOD )[១៤] ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ មានយុទ្ធនាការទាមទារឱ្យបញ្ចូលការប្រតិព័ទ្ធផ្លូវភេទទៅក្នុងសិទ្ធិមូលដ្ឋានរបស់ពលរដ្ឋ ហើយដែលនឹងត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃប្រទេស**គូយ៉ាណា**។ ចាប់ពីពេលនោះមក ពួកគេបាននឹងកំពុងធ្វើការងារដើម្បីបញ្ចប់ការធ្វើទុក្ខមុខម្នេញ និងការរើសអើងលើជនស្រឡាញ់ភេទដូចគ្នា និងអ្នកមានភេទទី៣ ហើយពួកគេអំពាវនាវឱ្យលុបចោលនូវច្បាប់ដែលដាក់ទោសទណ្ឌទៅលើក្រុមស្រឡាញ់ភេទដូចគ្នា និងអ្នកតុបតែងខ្លួនផ្ទុយពីភេទរបស់ខ្លួន។

អង្គការ SASOD បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយភាពច្នៃប្រឌិតខ្ពស់។ ជារៀងរាល់ឆ្នាំ គេតែងរៀបចំពិធីបញ្ចាំងកុនមួយដែលបង្ហាញពីសហគមន៍ក្រុមស្រឡាញ់ភេទដូចគ្នា និងអ្នកមានភេទទី៣ ដែលកុនទាំងនោះឆ្លុះបញ្ចាំងពីភាពលំបាកផ្សេងៗ និងរបៀបតស៊ូរស់នៅរបស់ជនស្រឡាញ់ភេទដូចគ្នា និងអ្នកមានភេទទី៣ ដែលរស់នៅជាមួយនឹងសេរីភាពសង្គមក្បិតក្បៀត ព្រមទាំងបង្ហាញថាភាពចម្រុះនៃភេទនិងយេនឌ័រ គឺជាទិដ្ឋភាពដ៏សំខាន់មួយនៅក្នុងផ្នែកមនុស្សធម៌។ SASOD បានសហការជាមួយក្រសួងសុខាភិបាល និងអង្គការដទៃទៀត ដើម្បីប្រកាសចាប់ផ្តើមគម្រោងសុខភាពវិសាលគម

[១៤] Society Against Sexual Orientation Discrimination

( Spectrum Health Project )[១៥] ដែលផ្ដល់ព័ត៌មានអំពីសុខភាពផ្លូវភេទ រួមទាំងធនធាន ជាពិសេសសម្រាប់ក្រុមស្រឡាញ់ភេទដូចគ្នា និងភេទទី៣។

## . ការជួយប្ដីប្រពន្ធឱ្យមានសម្ព័ន្ធផ្លូវភេទកាន់តែប្រសើរជាការរួមចំណែកខ្ពស់ក្នុងសុខុមាលភាពសង្គម

មជ្ឈមណ្ឌលអន្តរជាតិសម្រាប់សុខភាពបន្តពូជនិងសិទ្ធិផ្លូវភេទ ឬហៅកាត់ថា INCRESE ( International Centre for Reproductive Health and Sexual Rights )[១៦] គឺជាអង្គការសហគមន៍មួយនៅប្រទេស**នីហ្សេរីយ៉ា** ដែលធ្វើការងារជាមួយនឹងប្ដីប្រពន្ធនៅតាមសហគមន៍អំពីបញ្ហាផ្លូវភេទ។ ពួកគេបានចាប់ផ្ដើមការងារនេះបន្ទាប់ពីការស្ទង់មតិនៅក្នុងតំបន់នេះបង្ហាញថា ប្រជាជនមានការព្រួយបារម្ភអំពីកង្វះភាពសុខដុមរវាងប្ដីប្រពន្ធ និងអំពីអត្រាលែងលះគ្នាខ្ពស់។ អង្គការ INCRESE មានការភ្ញាក់ផ្អើលនៅពេលរកឃើញថា ប្រជាជននៅទីនោះមានចំណាប់អារម្មណ៍ពិភាក្សាអំពីបញ្ហាផ្លូវភេទ។

តាមរយៈការធ្វើការងារជាមួយគូស្វាមីភរិយា បានជួយឱ្យស្ត្រីបញ្ចេញយោបល់ក្នុងសម្ព័ន្ធមេត្រីភាពរបស់ពួកគេ។ មិនយូរប៉ុន្មាន គូស្វាមីភរិយាខ្លះសម្រេចបានសម្ព័ន្ធដែលស្មើភាព ដែលមិនមែនត្រឹមតែក្នុងផ្លូវភេទ ប៉ុន្តែក្នុងផ្នែកផ្សេងៗទៀតនៃជីវិតរបស់ពួកគេ។

---

[១៥] https://www.google.com/search?q=Spectrum+Health+Project&sxsrf

[១៦] https://www.mhtf.org/organization/international-center-for-reproductive-health-and-sexual-rights-increse/

នៅពេលអង្គការ INCRESE សួរអ្នកចូលរួមថា តើការបណ្តុះបណ្តាល បានផ្លាស់ប្តូរទំនាក់ទំនងរបស់ពួកគេដូចម្តេចខ្លះ? គូស្វាមីភរិយាមួយចំនួន និយាយថា ស្ត្រីអាចនិយាយពីអារម្មណ៍របស់ខ្លួនបានកាន់តែច្រើន។ គូខ្លះ និយាយថាពួកគេកាន់តែយកចិត្តទុកដាក់ក្នុងការបង្ការការមានផ្ទៃពោះដែលមិន ចង់បាន ហើយខ្លះទៀតនិយាយថា ពួកគេមិនសូវមានអំពើហិង្សាដូចមុនទេ។ ជារួម គូស្វាមីភរិយាដែលបានចូលរួមក្នុងការបណ្តុះបណ្តាល និយាយថាពួកគេ មានអារម្មណ៍កាន់តែស្និតស្នាលជាមួយគ្នា។

## . សិទ្ធិក្នុងផ្លូវភេទនិងការទទួលខុសត្រូវ

តួនាទីយេនឌ័ររបស់ស្ត្រីដែលមានលក្ខណៈសាមញ្ញបំផុត គឺតួនាទីបន្ត ពូជ ពោលគឺការរំពឹងទុកថា គាត់នឹងមានកូនយ៉ាងតិច១នាក់។ នៅក្នុងសង្គម ជាច្រើន តួនាទីនេះធ្វើឱ្យស្ត្រីមានការទទួលខុសត្រូវជាច្រើនក្នុងផ្លូវភេទ និង មានសិទ្ធិក្នុងផ្លូវភេទតិចតួច។ ជំនឿដ៏គ្រោះថ្នាក់បំផុតមួយអំពីស្ត្រីនិងសុខភាព ផ្លូវភេទ គឺគំនិតដែលថា ស្ត្រីជាអ្នកទទួលខុសត្រូវលើបញ្ហាសុខភាពផ្លូវភេទភាគ ច្រើន។ ជាញឹកញាប់ស្ត្រីត្រូវបានស្តីបន្ទោសដោយបានឆ្លងជំងឺកាមរោគ មាន ភាពអារនិងការខ្វះសមត្ថភាពរបស់បុរស។ បញ្ហាទាំងនេះអាចមានមូលហេតុជា ច្រើនផ្សេងៗ ហើយវាជារឿងអយុត្តិធម៌ដែលតែងតែបន្ទោសលើស្ត្រី ឬធ្វើឱ្យស្ត្រី មានអារម្មណ៍អាម៉ាស់នៅពេលខ្លួនគាត់ឬប្តីមានបញ្ហាសុខភាពផ្លូវភេទ។

ការកែលម្អសុខភាពផ្លូវភេទ វាទាមទារឱ្យមានការផ្លាស់ប្តូរនូវតួនាទី យេនឌ័រដ៏គ្រោះថ្នាក់ ដើម្បីឱ្យស្ត្រីគ្រប់គ្នាអាចទទួលបាននូវការរួមភេទទៅតាម ចំណូលចិត្តរបស់គាត់ ដោយមិនមានភាពអាម៉ាស់ ឬភ័យខ្លាចអំពើហិង្សា។ ការ

ផ្លាស់ប្តូរទាំងនេះ គឺជាដំណើរការដ៏វែងឆ្ងាយមួយ។ វិធីមួយដើម្បីចាប់ផ្តើម គឺតាមរយៈការជួបប្រជុំគ្នា ដើម្បីធ្វើការឆ្លុះបញ្ចាំង និងជជែកអំពីបញ្ហាទាំងនេះជាមួយស្ត្រីនៅក្នុងសហគមន៍។ នៅពេលដែលស្ត្រីម្នាក់មិនចាំបាច់លាក់ពីចំណូលចិត្តផ្លូវភេទរបស់ខ្លួន នោះគាត់អាចជជែកជាមួយប្តីអំពីបញ្ហាផ្លូវភេទដោយភាពជឿជាក់។ បើស្ត្រីត្រូវមានភាពអាម៉ាស់ដោយសារការយល់ដឹងអំពីផ្លូវភេទ ឬការរីករាយក្នុងផ្លូវភេទ នោះវានឹងពិបាកក្នុងការណែនាំអំពីវិធីសុវត្ថិភាពផ្សេងៗ ដើម្បីឱ្យពួកគេរីករាយក្នុងការរួមភេទ ហើយដែលបង្ការជំងឺកាមរោគ ឬការមានផ្ទៃពោះមិនចង់បាន។ ដូច្នេះការពិភាក្សាអំពីការរំពឹងទុករបស់បុរសនិងស្ត្រីចំពោះការរួមភេទ គឺជាមធ្យោបាយដ៏ល្អមួយដើម្បីបង្ហាញថា ***តើតួនាទីយេនឌ័រមានឥទ្ធិពលបែបណាខ្លះទៅលើទំនាក់ទំនងផ្លូវភេទ?***

## ៧- ការលើកកម្ពស់យេនឌ័រក្នុងសង្គមខ្មែរ

ប្រវត្តិនៃការលើកកម្ពស់ស្ត្រី និយាយឱ្យខ្លីគឺសិទ្ធិនារីផ្តើមចេញពីចលនាតស៊ូរបស់ស្ត្រីនៅលើពិភពលោក កាលពីចុងសតវត្សទី១៩ ក្នុងការរំដោះខ្លួនចេញពីការកេងប្រវ័ញ្ចនានានៅក្នុងវិស័យឧស្សាហកម្ម ហើយស្ត្រីក៏ត្រូវបានគេទទួលស្គាល់ និងផ្តល់សិទ្ធិពេញលេញនៅក្នុងការងារ និងសង្គមជាបន្តបន្ទាប់។ ដូច្នេះថ្ងៃ៨មីនា ជាថ្ងៃមហាសាមគ្គីតស៊ូរបស់ស្ត្រីពលករទូទាំងពិភពលោក ដើម្បីសេរីភាព ប្រជាធិបតេយ្យ ដោយភ្ជាប់នូវពាក្យស្លោកថា ***«មួយថ្ងៃធ្វើការប្រាំបីម៉ោង ធ្វើការស្មើគ្នា បៀវត្សរ៍ស្មើគ្នា ការពារសុខភាពមាតា និងទារក»*** ។

ការប្រារព្ធពិធីនេះក្នុងអត្ថន័យរួម គឺការគោរពស្រឡាញ់ស្ត្រី លើកកម្ពស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច ការងារ នយោបាយ និងការចូលរួមកិច្ចការសង្គមជាតិ រហូតគេបានចាត់ទុកស្ត្រីជាមាតារបស់ពិភពលោក។ យ៉ាងណាមិញ ទិវាសិទ្ធិ

នារីអន្តរជាតិថ្ងៃ៨មីនានេះ ក៏ត្រូវបានប្រារព្ធធ្វើឡើងយ៉ាងទូលំទូលាយនៅទូទាំងប្រទេសកម្ពុជាផងដែរ ដែលព្រឹត្តិការណ៍នេះសបញ្ជាក់ឱ្យឃើញថាកម្ពុជាជាប្រទេសមួយដែលចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកស្ទួយសិទ្ធិសេរីភាពរបស់ស្ត្រី។ លទ្ធផលជាក់ស្តែង ស្ត្រីខ្មែរបានទទួលសេរីភាពច្រើនជាងមុននៅក្នុងគ្រប់សកម្មភាព រាប់ទាំងនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច។ ស្ត្រីខ្មែរកាន់តែមានសេចក្តីក្លាហានក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ និងគ្រួសារ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ស្ត្រីនៅតែមានចំនួនតិចតួចនៅក្នុងឆាកនយោបាយក៏ដូចជានៅក្នុងសកម្មភាពសង្គមផ្សេងទៀតដែរ។ តើស្ថានភាពស្ត្រីខ្មែរកំពុងវិវត្តបែបណាខ្លះ?

ពីសង្គមមួយដែលកូនស្រីរស់ក្នុងគំនាបប្រពៃណីយ៉ាងតឹងរ៉ឹង ស្ត្រីខ្មែរបច្ចុប្បន្នបានស្គាល់ការផ្លាស់ប្តូរមួយគួរឱ្យកត់សម្គាល់។ ស្ត្រីខ្មែរដែលកាលពីមុនធ្លាប់តែតោងកន្ទុយក្បិនឪពុកម្តាយ និងរស់ក្រោមឥទ្ធិពលរបស់ស្វាមី ឥឡូវនេះបានបង្ហាញវត្តមាននៅគ្រប់សកម្មភាពសង្គម និងនយោបាយចាប់តាំងពីថ្នាក់កំពូលរហូតដល់ថ្នាក់មូលដ្ឋាន។

## *តើយេនឌ័រមានន័យដូចម្តេច? យេនឌ័របានចាប់កំណើតពីពេលណា?*

យេនឌ័រ តាមវចនានុក្រម Learner's Dictionary ជាភាសាអង់គ្លេសខ្មែរ ដែលរៀបរៀងឡើងដោយ លោក **សេរីវ៉ុធ** បោះពុម្ពលើកទី១ ព.ស.២៥៤១ គ.ស១៩៩៧ ទំព័រ១៩៥ បានពន្យល់ថា ជាលិង្គ។ លិង្គ មិនមែនសំដៅលើប្រដាប់ភេទបុរសទេ តែវាសំដៅលើភេទ(នបុំសលិង្គ និងឥត្ថីលិង្គ)។ យេនឌ័រគឺសំដៅលើរូបសាស្ត្រ ជីវសាស្ត្រ ចិត្ត ឥរិយាបថ ទាក់ទងនឹងភាពប្លែកគ្នារវាង

នបុំសកលិង្គ និងបុំលិង្គ។ យោងតាមបរិបទវាក្យសព្ទសំដៅដល់ជីវសាស្ត្រភេទ (ថ្លែងដល់ភេទប្រុសនិងស្រី ឬក៏អន្តរភេទ) ភេទដែលផ្អែកទៅលើរចនាសម្ព័ន្ធសង្គម(រួមបញ្ចូលទាំងតួនាទីភេទ និងតួនាទីសង្គមដទៃទៀត) ឬអត្តសញ្ញាណភេទ។

អ្នកភេទវិទ្យា លោក **John Money** បានបែងចែកវាក្យសព្ទរវាងជីវសាស្ត្រភេទ និងយេនឌ័រ ជាច្បាប់មួយ នៅឆ្នាំ១៩៥៥។ មុនពេលចាប់ផ្តើមការងាររបស់គាត់ វាជារឿងមិនធម្មតាមួយ ដើម្បីប្រើប្រាស់ពាក្យ យេនឌ័រ សំដៅលើអ្វីមួយ ដូចការបែងចែកក្នុងវេយ្យាករណ៍នោះទេ។ ទោះបីជាយ៉ាងនេះក៏ដោយ អត្ថន័យរបស់លោក Money ទៅលើពាក្យនេះ មិនមានលក្ខណៈសកលទូទៅទេ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលអ្នកទ្រឹស្តីស្ត្រីបានក្រសោបទស្សនៈទៅលើការបែងចែករវាងជីវសាស្ត្រភេទ និងរចនាសម្ពន្ធសង្គមនៃយេនឌ័រ។ សព្វថ្ងៃនេះការបែងចែកបានដើរតាមយ៉ាងច្បាស់នៅក្នុងបរិបទសង្គម ជាពិសេសក្នុងវិទ្យាសាស្ត្រសង្គម និងឯកសារដែលបានសរសេរឡើងដោយអង្គការសុខភាពពិភពលោក(WHO)។ ទោះបីជានៅក្នុងបរិបទដទៃទៀត នៅក្នុងផ្នែកវិទ្យាសាស្ត្រសង្គម អត្ថន័យនៃពាក្យថា **យេនឌ័រ** បានទទួលនូវរបៀបប្រើប្រាស់ផ្លាស់គ្នា រួមទាំងភេទ(Sex) ទោះបីជាដាក់ជំនួសនៅពីក្រោយពាក្យផ្សេង។ ការពន្លឿនដ៏តូចនៃដំណើរការក្នុងវិទ្យាសាស្ត្រអក្សរសាស្ត្រត្រូវបានសង្កេតនៅពេលមួយក្នុងឆ្នាំ១៩៩៣ ដោយរដ្ឋបាលអាហារ និងឱសថបានចាប់ផ្តើមប្រើប្រាស់ពាក្យ **យេនឌ័រ** ជំនួសឱ្យពាក្យ **ភេទ**។ យេនឌ័រ គឺឥឡូវត្រូវបានគេប្រើប្រាស់ជាធម្មតាដែលថែមទាំងមិនមែនជាមនុស្ស និងសត្វ ដោយមិនឱ្យជាប់ទាក់ទិនទៅនឹងតួនាទីយេនឌ័រក្នុងសង្គម។

## ៧.១- នារីជាស្ត្រីខ្មែរ

នៅលើពិភពលោក គ្រប់បណ្ដាប្រទេសទាំងអស់ភាគច្រើនតែងតែឱ្យតម្លៃទៅលើស្ត្រីភេទ ទាំងប្រទេសនៅ *ទ្វីបអឺរ៉ុប អាស៊ី អាមេរិក អាហ្វ្រិក* ... ជាដើម។ ជាក់ស្ដែងនៅក្នុងសង្គមខ្មែរយើងក៏ដូចគ្នានឹងបណ្ដាប្រទេសទាំងអស់នោះដែរ។

សង្គមខ្មែរយើងបានចាត់ទុកថា ស្ត្រីដែលកើតមកតែងតែមានជាប់មកជាមួយនឹងពន្លកនៃអធិបតីភាព និងសិរីមង្គលដល់ក្រុមគ្រួសារ សង្គម ក៏ដូចជាប្រទេសជាតិទាំងមូល។ មានសុភាសិតពោលថា "***ស្ត្រីជាមាតានៃពិភពលោក***" "***សំណាបយោងដី ស្រីយោងបុរស***"... ដែលបានបន្តអប់រំដល់ស្ត្រីខ្មែរ កុលបុត្រ កុលធីតា យុវជន យុវនារីខ្មែរជំនាន់ក្រោយ ឱ្យយល់ពីអត្ថន័យនៃសុភាសិតដ៏មានតម្លៃនោះ ហើយលក្ខណៈសំខាន់ៗដែលស្ត្រីខ្មែរត្រូវមានគឺ៖

. កូនល្អ សិស្សល្អ មិត្តល្អ

. ប្រពន្ធល្អ អ្នកជិតខាងល្អ អ្នកគ្រប់គ្រងល្អ

. ម្ដាយល្អ អ្នកអប់រំល្អ ទីប្រឹក្សាល្អ ។

កាលពីសម័យអាណាចក្រនគរភ្នំ ប្រទេសកម្ពុជានៅសម័យនោះបានប្រកាន់របបមាតាធិបតេយ្យ គឺយកស្ត្រីជាធំ និងអ្នកគ្រប់គ្រងប្រទេសជាស្ត្រីភេទ (ព្រះនាងលីវយី) ប៉ុន្តែមកដល់សម័យក្រោយ ការវិវត្តនៃរបបគ្រប់គ្រងប្រទេសត្រូវបានផ្លាស់ប្ដូរមកជារបបបិតាធិបតេយ្យវិញ គឺប្រកាន់យកបុរសជាធំ និងអ្នកគ្រប់គ្រងប្រទេសជាតិក៏បានប្ដូរមកជាបុរសវិញ។

ដោយសារតែប្រទេសកម្ពុជាសម័យមុនប្រកាន់របបមាតាធិបតេយ្យ គេតែងតែនិយមយកពាក្យ "*មេ*" ជាធំ នៅក្នុងការប្រើប្រាស់ពាក្យប្រចាំថ្ងៃដូចជា

*មេទ័ព មេឃុំ មេស្រុក មេភូមិ មេប្រយោគ ...* ដែលភ្ជាប់ជាមួយពាក្យ*មេ* នេះ សុទ្ធតែតំណាងឱ្យអ្នកដឹកនាំ។ ក្រៅពីនេះ ដើម្បីជួយបំពេញបំណងខាងលើនេះ បុព្វបុរសខ្មែរយើងបានចងក្រងកាព្យឧបទេស និងរឿងតំណាលកថាមួយចំនួន ដើម្បីអប់រំទូន្មានប្រៀនប្រដៅដល់កូនស្រីខ្មែរគ្រប់រូបនៅជំនាន់ក្រោយ ឱ្យស្ថិតនៅក្នុងក្រមសីលធម៌ និងគោរពប្រតិបត្តិ តាមលក្ខណៈសម្បត្តិដែលស្ត្រីត្រូវមានជាប់ជាមួយខ្លួន។ ចំពោះច្បាប់ឧបទេសកាលដែលយើងឃើញមកដល់បច្ចុប្បន្ននេះមានដូចជា៖ *ច្បាប់ស្រីនៃព្រះបាទ**អង្គឌួង** ច្បាប់ស្រីនៃបណ្ឌិត**ម៉ឺនមៃ** និងសុភាសិតច្បាប់ស្រីនៃឧកញ៉ា**សុត្តន្តប្រីជាឥន្ទ***។ ចំណែករឿងតំណាលមានដូចជា *រឿងស្រីពិត រឿងសម្លាញ់ពីរនាក់ រឿងភ្នំប្រុសភ្នំស្រី រឿងមាយើង រឿងមាយាស្ត្រី រឿងបុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍ ជាដើម។*

តាមរយៈការបង្ហាញនូវគុណតម្លៃនៃស្ត្រីខ្មែរតាមរយៈស្នាដៃដែលបានលើកឡើងមក មានន័យថា ស្ត្រីខ្មែរគឺជាមាតាដ៏ល្អរបស់កូន ស្ត្រីខ្មែរគឺជាអ្នកជំនួញដ៏ឆ្លាតវៃ ស្ត្រីខ្មែរគឺជាភរិយាដ៏ល្អរបស់ស្វាមី ស្ត្រីខ្មែរគឺជាអ្នកប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌របស់ព្រះពុទ្ធសាសនា ស្ត្រីខ្មែរគឺជាកងជីវពលដ៏ក្លាហានរបស់ជាតិ ស្ត្រីខ្មែរគឺជាអ្នកទាមទារសេរីភាពដ៏សកម្មរបស់ជាតិ ស្ត្រីខ្មែរគឺជាក្តីសង្ឃឹមរបស់បុរស ស្ត្រីខ្មែរគឺជាកម្លាំងដ៏មុតស្រួចរបស់សហគមន៍ក៏ដូចជាប្រទេសជាតិ ស្ត្រីខ្មែរគឺជាគ្រូបង្រៀនរបស់ជាតិ ស្ត្រីខ្មែរគឺជាមនុស្សស័ក្តិសមទីមួយនៅក្នុងវិស័យអប់រំជាពិសេសនៅថ្នាក់បឋមសិក្សា ស្ត្រីខ្មែរជាអ្នកឈានមុខគេនៅក្នុងកិច្ចថែរក្សាវប្បធម៌ ជាដើម។ សរុបមកស្ត្រីគឺពិតជាមានតម្លៃដ៏ធំធេងសម្រាប់សង្គម ប្រទេសជាតិក៏ដូចជាពិភពលោកទាំងមូល។ ដូច្នេះយើងទាំងអស់គ្នាគួរតែនាំគ្នាលើកស្ទួយតម្លៃស្ត្រីឱ្យបានខ្ពស់ស្មើនឹងបុរស យើងគួរតែយល់

ដឹងឱ្យច្បាស់ពីសុខទុក្ខរបស់ស្ត្រី និងចេះផ្តល់ឱកាសឱ្យស្ត្រីមានលទ្ធភាពនៅក្នុងការកសាងសង្គមជាតិនិងពិភពលោក។

## ៧.២- ស្ត្រីខ្មែរ និងពាក្យទំនៀម«ស្ត្រីបង្វិលចង្ក្រានមិនជុំ»

***ស្ត្រីបង្វិលចង្ក្រានមិនជុំ*** ជាទស្សនៈនៃពាក្យទំនៀមរបស់ខ្មែរ ដែលតែងតែនិយាយពីមាត់មួយទៅមាត់មួយតាំងពីបុរាណកាលមក។ អ្នកខ្លះយល់ថាទស្សនៈនេះជាទស្សនៈអវិជ្ជមានចំពោះស្ត្រី ដោយសំដៅថា ស្ត្រីមិនអាចធ្វើការអ្វីធំដុំក្រៅពីការងារផ្ទះបាយនោះទេ។ ឯអ្នកខ្លះទៀតយល់ថា ជាទស្សនៈវិជ្ជមានចំពោះស្ត្រី ដោយចង់បញ្ជាក់ថា ការងារផ្ទះសម្បែងនេះជាការងាររយជំពូកដែលទោះបីជាស្ត្រីមានដៃ១០០ក៏ធ្វើមិនអស់ដែរ ហើយក្នុងសម័យបច្ចុប្បន្ន ទស្សនៈមួយនេះ គឺពិតជាវិជ្ជមានសម្រាប់ស្ត្រី រហូតដល់មានអ្នកខ្លះនិយាយបកស្រាយបែបជាលក្ខណៈប្រយោលថា ***តើឱ្យស្ត្រីបង្វិលចង្ក្រានម្តេចជុំ បើការងារតូចធំក្នុងសង្គមកំពុងរង់ចាំការចូលរួមពីស្ត្រី*** ។ បច្ចុប្បន្នមានមនុស្សស្រីជាច្រើនដែលមានសមត្ថភាពខ្ពស់អាចបំពេញការងារដូចបុរស មិនថាកិច្ចការងារក្នុងផ្ទះ ឬកិច្ចការងារសង្គមនោះឡើយ គឺស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច ស្ត្រីមិនត្រឹមតែបំពេញការងារក្នុងផ្ទះនោះទេ ស្ត្រីអាចធ្វើជាអ្នកជំនួញដួញដូរដូចបុរស ស្ត្រីអាចជាអ្នកដឹកនាំកំពូលៗនិងខ្លាំងពូកែដូចបុរសៗផងដែរ។ ជាក់ស្តែងដូចជា កាលពីសម័យបុរាណមាន ព្រះនាង**សោមា** ព្រះនាង**ឥន្ទ្រទេវី** ព្រះនាង**ជ័យទេវី** ជំទាវ**ស្រែន** ជាដើម រីឯសម័យបច្ចុប្បន្នមានដូចជា **សម្តេចម៉ែ** លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** លោកជំទាវ **ពេជ្រ ចន្ទមុនី ហ៊ុន ម៉ាណែត** លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** លោកជំទាវ **ឃួង សុដារី** និងលោកជំទាវ **ជាសិរី** ជាដើម ដែលសុទ្ធសឹងតែជាស្ត្រីឆ្នើមនិងមានកេរ្តិ៍ឈ្មោះល្បីល្បាញ។

ក្រៅពីថ្នាក់ដឹកនាំកំពូលជាស្ត្រីខាងលើ ជាទូទៅយើងសង្កេតឃើញថា នៅក្នុងសង្គមកម្ពុជាយើងបច្ចុប្បន្ន ស្ត្រីមិនមែនត្រឹមតែជាស្ត្រីមេផ្ទះមួយមុខតែប៉ុណ្ណោះទេ ថែមទាំងជាបុគ្គលស្វែងរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ជាអ្នកបណ្តុះបណ្តាល និងជាអ្នកចូលរួមការអភិវឌ្ឍសង្គមជាតិថែមទៀតផង បើទោះបីជាកិច្ចការទាំងនោះស្ថិតនៅក្នុងរូបភាពមានចំណូល ឬមិនមានចំណូលក៏ដោយ។ ស្ត្រីប្រៀបបានដូចជាកាតាលីករ ជាសរសៃឈាម និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ តួយ៉ាងបើយោងទៅតាមរបាយការណ៍វាយតម្លៃរបស់វេទិកាសេដ្ឋកិច្ចពិភពលោកបានឱ្យដឹងថា ស្ត្រីកម្ពុជាជាប់លេខ២៥នៅក្នុងចំណោម១៥៣ប្រទេស ដែលជាតួលេខបង្ហាញពីការចូលរួមរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ចកម្ពុជា។[១៧] ស្ត្រីប្រៀបបានទៅនឹងសរសៃឈាមសង្គម ឆ្អឹងខ្នងសេដ្ឋកិច្ចដែលមិនអាចខ្វះបាន ជាម្តាយ ជាវិចិត្រករមនុស្ស ជាមាតាដៃ១០០ សម្រាប់ពិភពលោក។ ដូច្នេះប្រយោគ «**ស្ត្រីបង្វិលចង្ក្រានមិនជុំ**» ជាពាក្យដែលមិនប្រាសចាកនឹងស្ត្រីនាបច្ចុប្បន្នភាពនោះទេ ហើយប្រយោគនេះ វាបានដាក់ជាប់នៅក្នុងក្រអៅបេះដូងស្ត្រីខ្មែរស្ទើរតែលុបមិនជ្រះ សម្រាប់អ្នកយល់អវិជ្ជមានក៏ដោយ វាក៏ជាឥទ្ធិពលមួយនៅក្នុងការបង្អាក់ដំណើរការអភិវឌ្ឍសមត្ថភាពរបស់ស្ត្រីផងដែរ ដូចជាការកំណត់គោលដៅជីវិតស្ត្រីថា ស្ត្រីគួរតែជាមេផ្ទះ ហើយពុំចាំបាច់រៀនច្រើនពេកជាដើម ដែលនេះគឺជាមូលហេតុដែលនាំឱ្យមានវិសមភាពយេនឌ័រ និងការកើតមាននូវអំពើហិង្សាជាអាទិ៍ ដោយសារតែស្ត្រីមានចំណេះដឹងទាប។ ប៉ុន្តែសម្រាប់អ្នកយល់វិជ្ជមាន ផ្នត់គំនិតអវិជ្ជមានត្រូវបានលុបបំបាត់ជាបណ្តើរៗហើយ ព្រោះតែស្ត្រីខ្មែរបច្ចុប្បន្នខិតខំស្វែងរកចំណេះ

---

[១៧] https://wmc.org.kh/

ដឹង អភិវឌ្ឍន៍ខ្លួនជាបន្តបន្ទាប់ ហ៊ានសម្រេចក្តីបំណងផ្ទាល់ខ្លួន ក្លាហានក្នុងការចាប់យកក្តីស្រមៃ។ ស្ត្រីនាយុគសម័យនេះ ជាទូទៅតែងតែជាស្ត្រីដែលមានជំនឿទុកចិត្តលើខ្លួនឯងកើតឡើងពីការមានចំណេះវិជ្ជាដោយឈរលើគោលការណ៍ពង្រីកចំណេះដឹង ពង្រឹងសមត្ថភាព និងឥរិយាបថ សីលធម៌សមរម្យ។ ប៉ុន្តែទន្ទឹមនឹងនេះ ក៏មានស្ត្រីមួយចំនួនដែលទន់ខ្សោយ ក៏តែងតែគិតថា រូបសម្បត្តិជាកត្តាសំខាន់ដើម្បីចូលចំណោមគេចុះ។ យើងមិនបដិសេធទេ តែវាក៏មិនត្រឹមត្រូវទាំងស្រុងដែរ ដ្បិតថារូបសម្បត្តិក៏វាសំខាន់ដែរដើម្បីទាក់ទាញអារម្មណ៍អ្នកដទៃពេលជួបគ្នាដំបូង។ ប៉ុន្តែចំណេះវិជ្ជា បញ្ញា និងឥរិយាបថរបស់ស្ត្រីបូករួមនឹងសីលធម៌សមរម្យទេ ដែលធ្វើឱ្យគេដក់អារម្មណ៍ និងចងចាំយើង ចង់ធ្វើការងារជាមួយយើងជាស្ត្រី។

តើយើងអាចនិយាយពំនោល ស្ត្រីបង្វិលចង្ក្រានមិនជុំ ជាទស្សនៈអវិជ្ជមានបានទេ បើក្នុងពេលនេះមានស្ត្រីខ្មែរជាច្រើនបានចូលរួមបម្រើការងារនៅក្នុងស្ថាប័នកំពូលៗទាំងបីរបស់ជាតិ ក្នុងនីតិកាលទី៥ នៃព្រឹទ្ធសភា ចំនួន ៦២រូប(២០២៤-២០២៩) មានស្ត្រីចំនួន១១រូប ( **អ៊ុក ម៉ាលី, កង សៅវ៉ធន, ចាន់ សុទ្ធាវី, មុំ សណ្តាប់, មាន សំអាន, ឃួង យុនឌី, នរោត្តម អរុណ រស្មី, ឯម ផលាមុនី, សួស សារ៉ាម, ម៉ាណ ណាវី, ថាក់ ឡានី** )[១៨] និងក្នុងនីតិកាលទី៧នៃ **រដ្ឋសភាដែលចំនួន១២៥រូប(២០២៣-២០២៨)** មានតំណាងរាស្ត្រស្ត្រីចំនួន ១៤រូប គឺ **នួម សោភ័ណ**(បន្ទាយមានជ័យ) **កែវ ចន្ទមុនី**(កំពង់ឆ្នាំង) **ខេង សំវ៉ាដា**(កំពង់ធំ) **អ៊ុន សុគន្ធា** និង **ចមនិម្មល**(កំពត) **ឃួន សុដារី**(កណ្តាល)

[១៨] https://senate.gov.kh

អ៊ុំង កន្ថាផារី, ឡោក ខេង និង គ្រួច សំអាន (ភ្នំពេញ) គង់ សាឡន (ពោធិ៍សាត់) តឹក វ៉េតកំរង(សៀមរាប) ដួង វណ្ណា និង ឯក សុវណ្ណ ភារៈ (ស្វាយរៀង) និន សាមុីន និង នូ សុវណ្ណនី (តាកែវ)[១៩] និងក្នុងស្ថាប័ន**រាជរដ្ឋាភិបាល**ជាច្រើនទៀតមានដូចជា ថ្នាក់រដ្ឋមន្ត្រីមានចំនួន៣រូប (លោកជំទាវ កៀង សកុណា, អ៊ុំង កន្ថាផារី, និង ចម និម្មល) និង ថ្នាក់រដ្ឋលេខាធិការ អនុ-រដ្ឋលេខាធិការមួយចំនួនទៀត។ [២០]

ចំណែកនៅឯថ្នាក់មូលដ្ឋានវិញ វត្តមានរបស់ស្ត្រី ក៏កំពុងកើនឡើងគួរឱ្យកត់សម្គាល់ដែរ គឺមានស្ត្រីដែលមានតួនាទីជាអភិបាលខេត្ត អភិបាលរងខេត្ត-រាជធានី អភិបាលរងខណ្ឌ-ស្រុក សមាជិកក្រុមប្រឹក្សាខេត្ត-រាជធានី សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងមានស្ត្រីជាមេភូមិមួយចំនួននៅទូទាំងប្រទេស។ ទាំងនេះជាសក្ខីភាពបង្ហាញឱ្យឃើញថា ស្ត្រីខ្មែរបាននិងកំពុងចូលរួមយ៉ាងសកម្ម ក្នុងភាពជាអ្នកដឹកនាំនៅក្នុងស្ថាប័នជាតិតាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោម។

នេះនៅមិនទាន់រាប់ស្ត្រីខ្មែរជាច្រើនទៀតដែលកំពុងបម្រើការនិងដឹកនាំក្នុងសង្គមស៊ីវិល និងវិស័យឯកជន ក៏ដូចជាស្ត្រីដែលកំពុងដើរតួនាទីដ៏សំខាន់ក្នុងការកសាងជីវភាពគ្រួសារនោះផងទេ។ ម៉្យាងទៀតការងារមួយចំនួនដែលពីមុននេះ សង្គមខ្មែរចាត់ទុកថាជាការងាររបស់បុរស ឥឡូវនេះក៏មានវត្តមានរបស់ស្ត្រីក្នុងនោះដែរ។ ជាក់ស្តែងការងារជាអ្នកកាសែត ជាភ្នាក់ងារ

---

[១៩] https://www.nec.gov.kh/khmer/content/7265

[២០] សូមមើលឧបសម្ព័ន្ធទី១

សន្តិសុខឯកជន ឬក៏ប៉ូលីស។ល។និង។ល។ ទាំងនេះគឺជាលទ្ធផលនៃការលើកស្ទួយស្ត្រីពីសំណាក់សង្គមខ្មែរទាំងមូល រាប់ចាប់តាំងពីឆន្ទៈនយោបាយរបស់អ្នកដឹកនាំប្រទេស អង្គការសង្គមស៊ីវិល រហូតដល់ប្រជាពលរដ្ឋជាទូទៅ។ «*ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ*» «*ស្ត្រីគឺជាដៃគូមិនអាចខ្វះបានសម្រាប់កសាងជាតិ*» «*ស្ត្រីគឺជាមាតានៃពិភពលោក*» ដែលពាក្យស្លោកទាំងនេះសុទ្ធសឹងជាពាក្យស្លោកដែលគេតែងឮជាញឹកញាប់ ចេញពីមាត់របស់មេដឹកនាំប្រទេស ក៏ដូចជាពីមាត់របស់សកម្មជនការពារសិទ្ធិស្ត្រីជាច្រើនទៀតដែរ។

ចំនួនមន្ត្រីរាជការស៊ីវិលជាបុរសនិងស្ត្រី តាមប្រភេទក្របខណ្ឌ គិតត្រឹមខែមករា ឆ្នាំ២០២៣

| ក្របខណ្ឌ | ថ្នាក់ជាតិ | | | ថ្នាក់ក្រោមជាតិ | | | សរុបរួម |
|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | |
| ក | 21,911 | 8,663 | 30,574 | 25,450 | 11,768 | 37,218 | 67,792 |
| ខ | 4,600 | 3,342 | 7,942 | 37,362 | 28,743 | 66,105 | 74,047 |
| គ | 2,393 | 1,509 | 3,902 | 34,057 | 38,248 | 72,305 | 76,207 |
| សរុប | 28,904 | 13,514 | 42,418 | 96,869 | 78,759 | 175,628 | 218,046 |

ប្រភព៖ ក្រសួងមុខងារសាធារណៈ: Ministry of Civil Service

ប្រទេសកម្ពុជាបានចូលរួមជាមួយបណ្ដាប្រទេសជាច្រើននៅលើសកលលោកដើម្បីអបអរសាទរខួបលើកទី១០០នៃទិវាសិទ្ធិនារីអន្តរជាតិក្រោមប្រធានបទ «*យុវវ័យជួយស្ត្រី គឺជួយខ្លួនឯង និងជួយសង្គមជាតិ*»។ ប្រធានបទនេះមានន័យចង់ជំរុញឱ្យយុវវ័យខ្មែរដែលជាទំពាំងស្នងឬស្សីចូលរួមចំណែកឱ្យបានសកម្មថែមទៀតក្នុងការលើកស្ទួយសិទ្ធិស្ត្រី ដែលកំពុងរងការរំលោភបំពានជាច្រើននៅឡើយពីសំណាក់បុរស។

ជាការពិតណាស់ មិនថាតែរដ្ឋាភិបាលទេ សូម្បីតែគណបក្សនយោបាយនីមួយៗ ក៏បានបង្ហាញឆន្ទៈយ៉ាងមោះមុតរបស់ខ្លួនក្នុងការលើកស្ទួយស្ត្រីដែរ គឺសុទ្ធតែបានដាក់ចេញនូវគោលនយោបាយលើកស្ទួយស្ត្រីដូចៗគ្នា ហើយនិន្នាការនេះ ហាក់កំពុងក្លាយជាចលនាប្រឡងប្រណាំងគ្នាផងដែរ។ យ៉ាងណាក៏ដោយ ស្ត្រីខ្មែរនៅតែមានចំនួនតិចតួចណាស់បើធៀបទៅនឹងតួនាទីបុរស។ មានកត្តាពីរយ៉ាងដែលធ្វើឱ្យចលនាលើកស្ទួយស្ត្រីខ្មែរមិនទាន់ទទួលបានលទ្ធផលជាទីគាប់ចិត្តនៅឡើយ។ កត្តាទី១ គឺកត្តាបុរស មានន័យថា បុរសខ្មែរជាច្រើននៅមិនទាន់លះបង់ចោលទស្សនៈចាស់គំរឹលដែលថា ស្ត្រីបង្វិលចង្ក្រានមិនជុំ នៅឡើយ និងកត្តាទី២ គឺកត្តាស្ត្រីខ្លួនឯងមានន័យថា ស្ត្រីខ្មែរមួយចំនួននៅមិនទាន់យល់ដឹងពីតួនាទីរបស់ខ្លួននៅឡើយ ហើយកំពុងទទួលយកដោយខ្លួនឯងនូវឥទ្ធិពលរបស់បុរសដដែល។ កត្តាទាំងពីរយ៉ាងនេះប្រហែលជាត្រូវការពេលវេលាច្រើនទៀត ដើម្បីសម្រេចគោលដៅលើកស្ទួយស្ត្រីខ្មែរឱ្យមានសិទ្ធិស្មើបុរស។

## ៨- ប្រវត្តិទិវានារីអន្តរជាតិ និងសង្គមខ្មែរ

នៅចុងស.វ.ទី១៩ បច្ចេកវិទ្យាបានរីកចម្រើនយ៉ាងខ្លាំងក្លានៅលើសកលលោក ជាពិសេសនៅសហរដ្ឋអាមេរិក និងបណ្ដាប្រទេសដែលមានខឿនឧស្សាហកម្មរីកចម្រើន។ នារី និងកុមារក្រីក្ររាប់លាននាក់ ត្រូវបានទាក់ទាញឱ្យចូលធ្វើការនៅក្នុងរោងចក្រសហគ្រាសឯកជននានា។ ពួកម្ចាស់រោងចក្រសហគ្រាសមួយចំនួន ដែលមានគំនិតលោភលន់ កេងប្រវ័ញ្ចមិនចេះស្កប់ស្កល់លើកម្លាំងស្ត្រី កុមារ និងកម្មករ បានបង្ខំឱ្យពួកគេធ្វើការជាទម្ងន់ក្នុងមួយថ្ងៃពី១២ម៉ោង ទៅ១៦ម៉ោង ហើយផ្ដល់ប្រាក់បៀវត្សយ៉ាងតិចតួចបំផុត ដោយ

មិនគិតពីសុខភាពរបស់កម្មករឡើយ ជាហេតុធ្វើឱ្យនារី និងកុមារទាំងនោះត្រូវរស់នៅក្នុងជីវភាពជុនជាបលំបាកវេទនា។

ដោយការឈឺចាប់យ៉ាងពុះពោរជាប់ជានិច្ចចំពោះអំពើកៀបសង្កត់កេងប្រវ័ញ្ចហួសប្រមាណនោះ នៅថ្ងៃទី**៨ មីនា ១៨៩៩** កម្មការិនីផ្នែកតម្បាញ និងកាត់ដេរនៅទីក្រុង**ស៊ីកាហ្គូ** និង**ញូវយ៉ក**(សហរដ្ឋអាមេរិក) បានសាមគ្គីឯកភាពគ្នា ក្រោកឈរឡើងតស៊ូយ៉ាងប្តូរផ្តាច់ទាមទារឱ្យបន្ថយម៉ោងធ្វើការ និងតម្លើងប្រាក់បៀវត្ស។ ប៉ុន្តែជាលទ្ធផល កម្មការិនីទាំងនោះត្រូវបានទទួលការកៀបសង្កត់យ៉ាងពេញទំហឹង ត្រូវបានគេចាប់ចងធ្វើទារុណកម្ម និងត្រូវបណ្តេញចេញពីរោងចក្រ។ ទោះបីត្រូវទទួលការឈឺចាប់ និងគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរក៏ដោយ កម្មការិនីនៅតែសាមគ្គីគ្នាយ៉ាងជិតស្និទ្ធ តស៊ូយ៉ាងស្វិតស្វាញ និងងើបឈរឡើងតវ៉ាប្រឆាំងជាសារធាណៈម្តងហើយម្តងទៀត បង្ខំឱ្យពួកម្ចាស់រោងចក្រសហគ្រាសត្រូវតែទទួលយល់ស្របតាម។ ដំណើរតស៊ូនៃកម្មការិនី ទាំងនោះបានលើកទឹកចិត្តយ៉ាងខ្លាំងក្លាចំពោះចលនានារីពលករសកលលោក។

ចលនាដ៏ស្វិតស្វាញនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើនារីពលករនៅប្រទេសអាល្លឺម៉ង់ ដែលជាប្រទេសឧស្សាហកម្មធំមួយនាសម័យនោះ។ នៅប្រទេសអាល្លឺម៉ង់ ក្នុងពេលនោះបានលេចឡើងនូវយុវនារីពររូបដ៏ល្បីល្បាញគឺអ្នកស្រី ***ក្លារ៉ាស្សេតគិន*** ជាជនជាតិ**ប៉ូឡូញ** ដែលបានចូលរួមគ្នាយ៉ាងជិតស្និទ្ធជាមួយ អ្នកស្រី ***គ្រុប ស្កយ៉ា (ភរិយាលោកឡេនីន)*** បំផុសចលនាបង្កើតបានជាគណៈលេខាអន្តរជាតិ ដើម្បីដឹកនាំចលនានារី។

ឆ្នាំ១៩១០ សន្និបាតអន្តរជាតិនារី ដែលមានប្រទេសចំនួន១៧ ចូលរួមដោយធ្វើឡើងនៅទីក្រុង**កូប៉ែនហាក** ដែលជារដ្ឋធានីនៃប្រទេស**ដាណឺម៉ាក**បាន

សម្រេចយកថ្ងៃ **៨ មីនា «ទិវានារីអន្តរជាតិ»** ថ្ងៃមហាសាមគ្គីតស៊ូរបស់នារីពលករទូទាំងសាកលលោក ដើម្បីសិទ្ធិសេរីភាព ប្រជាធិបតេយ្យ ដោយភ្ជាប់ជាមួយនឹងពាក្យស្លោកថា៖

*- មួយថ្ងៃធ្វើការ៨ម៉ោង*

*- ធ្វើការស្មើគ្នា បៀវត្សស្មើគ្នា*

*- ការពារសុខភាពមាតា និង ទារក*

ចាប់តាំងពីពេលនោះមក ថ្ងៃ៨មីនា បានក្លាយទៅជាថ្ងៃ***បុណ្យអន្តរជាតិនារី*** ដែលរំឭកអំពីការតស៊ូរបស់នារីពលករទូទាំងសកលលោក ដែលប្រឹងប្រែងដើម្បីរំដោះនារី ទាមទារឱ្យអនុវត្តសិទ្ធិស្មើភាពរវាងបុរសនិងនារី។ ដោយសារតែមានកិច្ចប្រឹងប្រែងដោយចិត្តអំណត់និងពុះពារនឹងការលំបាកគ្រប់បែបយ៉ាងពី ១០០ឆ្នាំមុននេះហើយ ទើបបច្ចុប្បន្ននេះនារីក្នុងពិភពលោកមានឱកាសទទួលបាននូវសិទ្ធិស្មើភាពគ្នាក្នុងគ្រប់វិស័យទាំងអស់។ លទ្ធផលដ៏ត្រចះត្រចង់នេះបានកាត់បន្ថយអស់ជាច្រើននូវអំពើហិង្សា និងការរើសអើងចំពោះនារីភេទដែលគេចាត់ទុកថាជាភេទទន់ខ្សោយនោះ។

ជាបន្តបន្ទាប់ ចលនានារីអន្តរជាតិបានខិតខំដោះស្រាយបញ្ហានារីដែលនៅសេសសល់តាមរយៈការស្នើឡើងទៅអង្គការសហប្រជាជាតិ ដោយមានសន្និសិទនារីជាច្រើនលើកច្រើនសារ។ នៅឆ្នាំ១៩៧៥ សន្និសីទពិភពលោករបស់នារីលើកទី១ បានប្រារព្ធធ្វើឡើងនៅទីក្រុង**ម៉ិចស៊ិចកូ** ប្រទេស**ម៉ិចស៊ិច** ក្រោមប្រធានបទ «***សមភាព វឌ្ឍនភាព និង សន្តិភាព***»។ ផែនការសកម្មភាពដែលបានសម្រេចនៅពេលនោះ គេបានអំពាវនាវឱ្យមានការលុបបំបាត់រាល់ទម្រង់នៃ

ការរើសអើងប្រឆាំងនឹងនារីភេទ និងរៀបចំទម្រង់ការដ៏មានប្រសិទ្ធភាពសម្រាប់អនុម័តនូវអនុសញ្ញានេះ។

នៅឆ្នាំ១៩៨០ សន្និសិទពិភពលោកលើកទី២ របស់នារីបានធ្វើឡើងនៅទីក្រុង**កូប៉ែនហាក** ប្រទេស**ដាណឺម៉ាក** ដើម្បីពិនិត្យមើលការរីកចម្រើន និងការអនុវត្តន៍ផែនការសកម្មភាពដែលកំណត់ក្នុងសន្និសិទលើកទី១ និងគ្រោងទុកនូវខ្សែបន្ទាត់សម្រាប់ការអនុវត្ត ដើម្បីបំពេញចន្លោះខ្វះខាតក្នុងពាក់កណ្តាលទសវត្សរបស់នារី។ ប្រធានបទបន្ថែមទៀតដែលត្រូវលើកមកពិភាក្សាគឺ *« ការអប់រំការងារ និងសុខភាព»* ។

នៅឆ្នាំ១៩៨៥ ចុងបញ្ចាប់នៃទសវត្សនារី គេបានរៀបចំសន្និសិទលើកទី៣ម្តងទៀតនៅទីក្រុង**ណៃរ៉ូប៊ី** ប្រទេស**កេនយ៉ា** ដើម្បីពិនិត្យ និងវាយតម្លៃលើលទ្ធផលសម្រេចរបស់ទសវត្សនារី ព្រមទាំងធ្វើការអនុម័តលើយុទ្ធវិធីឱ្យរីកចម្រើនទៅមុខសម្រាប់ភាពលូតលាស់របស់នារីក្នុងឆ្នាំ២០០០។ ចុងក្រោយនៅឆ្នាំ១៩៩៥ ពីថ្ងៃទី៤ ដល់ថ្ងៃទី១៥ កញ្ញា អង្គការសហប្រជាជាតិបានរៀបចំសន្និសិទនារីពិភពលោកលើកទី៤ នៅទីក្រុងប៉េកាំងនៃសាធារណៈរដ្ឋប្រជាមានិតចិន។ ប្រធានបទគោលគឺ ***សមភាព វឌ្ឍនភាព និង សន្តិភាព*** ដដែល តែនៅបានលើកបន្ថែមក្នុងកិច្ចពិភាក្សារយៈពេល១២ម៉ោងបន្ថែមទៀតស្តីពីក្តីកង្វល់របស់នារីគឺ **ភាពក្រីក្រ ការអប់រំអំពើហិង្សា ផលវិបាកនៃជម្លោះអាវុធ នារីក្នុងរចនាសម្ព័ន្ធនយោបាយ និងសេដ្ឋកិច្ច តួនាទីនារីក្នុងការធ្វើសេចក្តីសម្រេចចិត្តយន្តការលើកកម្ពស់ការរីកចម្រើនរបស់នារី សិទ្ធិនារីលើប្រព័ន្ធផ្សព្វផ្សាយបរិស្ថាន និងបញ្ហាកុមារ**។ ទាំងនេះគឺ ជាយុទ្ធសាស្ត្រ និងរបៀបដោះស្រាយរបស់នារីដែលតែងតែអនុវត្តតាមបែបសន្តិវិធីតាមរយៈការបញ្ចេញមតិតែ

ប៉ុណ្ណោះ។ ឯលទ្ធផលដែលនារីទទួលបាន គឺការផ្ដល់នូវសិទ្ធិស្មើភាពគ្នាឱ្យបាន គ្រប់គ្រាន់ និងតម្លៃជាមនុស្ស ពោលគឺពុំមានទាមទារអ្វីឱ្យលើសពីនេះឡើយ។

បើយើងធ្វើការប្រៀបធៀបប្រវត្តិទិវានារីអន្តរជាតិ **៨ មីនា** ទៅនឹងកំណើត នៃអង្គការសហប្រជាជាតិ ឃើញថា ប្រវត្តិទិវានារីអន្តរជាតិ **៨មីនា** មានកំណើត មុនអង្គការសហប្រជាជាតិទៅទៀត ហើយក៏មានកំណើតមុនសិទ្ធិមនុស្សដែរ។ ទោះបីជាយ៉ាងនេះក៏ដោយ ក៏សព្វថ្ងៃនៅប្រទេសកម្ពុជាពិតមែនតែមានច្បាប់ ជាតិ ច្បាប់អន្តរជាតិ ដូចជា សេចក្ដីប្រកាសជាសកលរបស់អង្គការសហប្រជា ជាតិស្ដីពីសិទ្ធិមនុស្ស អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់ជំពូក៣ ស្ដីពីសិទ្ធិមនុស្សហើយក៏ដោយ ក៏វិសមភាពរវាងបុរសនិងស្ត្រី ការរើសអើង ប្រឆាំងនឹងនារីភេទ ការរំលោភសិទ្ធិស្ត្រី អំពើហិង្សាក្នុងគ្រួសារ នៅតែកើតមាន ជាបញ្ហា។ ហេតុដូច្នេះហើយបានជារាជរដ្ឋាភិបាលយើងនិងអង្គការក្រៅរដ្ឋា-ភិបាលមួយចំនួនធំ ខំប្រឹងខ្នះខ្នែងយកបញ្ហាទាំងអស់នេះមកផ្សព្វផ្សាយដល់ មនុស្ស គ្រប់រូប ទាំងបុរស ទាំងស្ត្រី ដើម្បីជួយឱ្យទទួលបាននូវ ***សិទ្ធិ និងការប្រើ សិទ្ធិ*** ប្រកបដោយភាពយុត្តិធម៌ និងដើម្បីទប់ស្កាត់ កាត់បន្ថយ និងឈានទៅ ដល់ការលុបបំបាត់នូវរាល់បញ្ហាទាំងឡាយដែលស្ត្រីកំពុងប្រឈមមុខ។

## ៨.១- ការបញ្ជ្រាបយេនឌ័រក្នុងសង្គមខ្មែរ

ដោយមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លារបស់ក្រសួងកិច្ចការនារី រួម ជាមួយនឹងក្រុមប្រឹក្សាជាតិកម្ពុជាសម្រាប់ស្ត្រី ក្រុមការងារបញ្ជ្រាបយេនឌ័រនៅ តាមក្រសួងពាក់ព័ន្ធនិងសង្គមស៊ីវិល បានធ្វើការដាក់បញ្ចូលបញ្ហាយេនឌ័រទៅ ក្នុងរបៀបវារៈនៃការអភិវឌ្ឍនានា ដោយទទួលបានភាពរីកចម្រើនគួរឱ្យកត់

សម្គាល់។ បញ្ហាយេនឌ័រត្រូវបានបញ្ចូលទៅក្នុងឯកសារគោលនយោបាយជាតិសំខាន់ៗជាច្រើនដូចជា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០០៦-២០១០ និងសូចនាករត្រួតពិនិត្យរួមរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ សមិទ្ធផលដែលគួរឱ្យកត់សម្គាល់ផងដែរ គឺការពង្រឹងយន្តការស្ថាប័ន ដើម្បីគាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅកម្ពុជា ដែលក្នុងនោះរួមមានការបង្កើតក្រុមការងារបច្ចេកទេសយេនឌ័រ ដែលជាផ្នែកមួយនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងការបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រ ស្ទើរគ្រប់ក្រសួងពាក់ព័ន្ធទាំងអស់របស់រាជ-រដ្ឋាភិបាល ហើយក្នុងចំណោមនោះ ក្រសួងមួយចំនួនបានរៀបចំបង្កើតផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់វិស័យខ្លួនរួចហើយ ក្រសួងមួយចំនួនទៀត កំពុងដំណើរការរៀបចំផែនការនេះ។ ក្រុមការងារបញ្ជ្រាបយេនឌ័រដែលបានកែសម្រួលពីប្រព័ន្ធមន្ត្រីបង្គោលពីររូបនៅតាមក្រសួងពាក់ព័ន្ធចំនួនដប់ គឺជាភ្នាក់ងារសំខាន់ដែលជំរុញឱ្យមានការគិតគូរពីបញ្ហាយេនឌ័រក្នុងការគ្រប់គ្រង និងកម្មវិធីនានា នៅក្នុងស្ថាប័នរបស់ខ្លួន។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ សមត្ថភាពជាតិក្នុងការវិភាគយេនឌ័រ និងស្វែងរកការគាំទ្រមតិនៅមានកម្រិតនៅឡើយ។ ទន្ទឹមនឹងនោះការធ្វើឱ្យមានសុខដុមនីយកម្មរវាងផែនការបញ្ជ្រាបយេនឌ័រ ផែនការយុទ្ធសាស្ត្រតាមវិស័យ និងយន្តការតាមដានត្រួតពិនិត្យ ព្រមទាំងការគៀងគរធនធានសមស្រប

ដើម្បីធានាការអនុវត្តប្រកបដោយ ប្រសិទ្ធភាព នៅតែជាបញ្ហាប្រឈមមុខដ៏ចម្បងសម្រាប់ប្រទេសកម្ពុជា។[២១]

ចំណែកផែនការយុទ្ធសាស្ត្ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តោតជាសំខាន់លើយុទ្ធសាស្ត្រចំនួន៤គឺ៖ (១)ការបង្កើតការងារ (២)ការធានាលក្ខខណ្ឌការងារល្អប្រសើរ (៣)ការជំរុញអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និង(៤)ការអភិវឌ្ឍសមត្ថភាពជំនាញបច្ចេកទេសនិងវិជ្ជាជីវៈជូនប្រជាពលរដ្ឋ។

ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានគោលនយោបាយដូចខាងក្រោម៖

- បញ្ជ្រាបយេនឌ័រក្នុងរាល់ក្របខ័ណ្ឌច្បាប់គោលនយោបាយ សកម្មភាព គម្រោង និងកម្មវិធីនានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- បង្កើនចំនួនស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេចក្នុងក្រសួង និងក្នុងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- បង្កើនការយល់ដឹងពីទស្សនៈយេនឌ័រ និងការវិភាគយេនឌ័រដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់។
- ជំរុញការអនុវត្តច្បាប់ស្តីពីការងារ ដើម្បីធានាលក្ខខណ្ឌការងារល្អប្រសើរដល់ស្ត្រីនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន និងក្រុមហ៊ុនឯកជន។

---

[២១] ក្រសួងកិច្ចការនារី ***ការបញ្ជ្រាបយេនឌ័រ*** ឆ្នាំ២០១០។

- បញ្ជ្រាបយេនឌ័រទៅក្នុងការអនុវត្តច្បាប់ស្តីពី របបសន្តិសុខសង្គម និងធានាថា ស្ត្រីទទួលបានផលប្រយោជន៍ប្រកបដោយសមភាពពីសេវាបេឡាជាតិរបបសន្តិសុខសង្គម។

- បង្កើនការទទួលបានឱកាស និងសេវាការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយសមធម៌ក្នុងចំណោមស្ត្រីនៅក្នុងកម្លាំងពលកម្ម។

- ជំរុញការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មដោយមានការបែងចែកតាមភេទ។

- សហការជាមួយវិស័យឯកជន ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ឯកជន និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនានា។

- ជំរុញឱ្យមានការរៀបចំគោលនយោបាយគ្រប់គ្រងធនធានមនុស្សដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនៅក្នុងវិស័យឯកជន។

- សហការជាមួយក្រសួងដែលពាក់ព័ន្ធទៅនឹងដៃគូអភិវឌ្ឍន៍និងអង្គការជាតិ និងអន្តរជាតិនានា ក្នុងការស្វែងរកជំនួយថវិកា និងបច្ចេកទេសសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យ និងបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យបានជោគជ័យ។

សូមទាញអារម្មណ៍ទៅកាន់សម័យដើមបន្តិច តើយេនឌ័រមាននៅក្នុងសង្គមខ្មែរចាប់តាំងពីពេលណាមក? ឬទើបតែចាប់ផ្តើមនាសង្គមឥឡូវនេះទេ? ជាការពិតណាស់ បើយើងមើលទៅកាន់សម័យពីបុរាណវិញ ជាពិសេសនាសម័យចេនឡារហូតដល់សម័យអង្គរ យើងឃើញស្រាប់ហើយថា ស្តេចដែលសោយរាជ្យនៅសម័យនគរភ្នំនោះ គឺជាស្ត្រីខ្មែរដំបូង ដែលបានចាប់បើក

ទំព័រប្រវត្តិសាស្ត្ររបស់អាណាចក្រមួយនេះ។ ចំណែកឯសង្គមខ្មែរសម័យបេនទ្បាវិញ ថ្វីត្បិតតែមានលក្ខណៈទន់ខ្សោយ[២២] ក៏ពិតមែន តែក៏អាចបញ្ជាក់បានថា ស្ត្រីក៏មានតួនាទីសំខាន់ផងដែរ នៅក្នុងសង្គមខ្មែរនាសម័យនោះ។ ឯសម័យអង្គរក៏ដូច្នោះដែរ គឺថាសង្គមបានផ្តល់តម្លៃដល់ស្ត្រី ជាពិសេសបានផ្តល់នូវតួនាទី សិទ្ធិសេរីភាព និងមុខងារសំខាន់ៗនៅក្នុងសង្គមទៅឱ្យស្ត្រីភេទ។ ជាក់ស្តែងស្ត្រីក៏អាចធ្វើជាកងទ័ព ជាហោរា ជាគ្រូពេទ្យ(ធ្មប) ជាសាស្ត្រាចារ្យ ឬធ្វើជាសកលវិទ្យាធិការ(ព្រះនាងឥន្ទ្រទេវី) និងធ្វើចៅក្រម ដូចដែលគេឃើញតួនាទីខ្លះត្រូវបានឆ្លុះបញ្ចាំងតាម*របបម្លាក់ប្រាសាទបាយ័ន* ស្រាប់។ គំនិតនយោបាយនេះមានលក្ខណៈស្របទៅនឹងសង្គមខ្មែរអតីតកាល ដែលជាសង្គម *មាតាធិបតេយ្យ* ហើយក៏ស្របទៅនឹងសង្គមជាតិបច្ចុប្បន្ន ដែលកំពុងយកចិត្តទុកដាក់លើ **សមភាពភេទ** រវាងបុរសនិងស្ត្រីនៅក្នុងគ្រប់កិច្ចការសង្គម។ មានន័យថាទស្សនវិជ្ជាខ្មែរមានតាំងពីសម័យនគរភ្នំរហូតដល់សម័យមហានគរ និងបច្ចុប្បន្ន។[២៣]

## ៨.២- ស្ត្រីនិងការដឹកនាំ

ខ្មែរយើងច្រើនតែនិយមហៅស្ត្រីដែលជាម្តាយថា «*មេ*» ហើយក្នុងសង្គមខ្មែរស្ត្រី គឺជាអ្នកដឹកនាំ។ ដើម្បីកុំឱ្យប្រជាជនខ្មែរទាំងអស់ភ្លេចពាក្យស្ត្រី ឬម្តាយជាអ្នកដឹកនាំនេះ គេក៏កំណត់នាមនៃស្ត្រី ឬម្តាយថា *មេ* តែម្តង។ សព្វថ្ងៃ

---

[២២] សូមមើល អ្នកស្រី ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ។

[២៣] រាជបណ្ឌិត្យសភាកម្ពុជា *ទស្សនវិជ្ជាខ្មែរសម័យអង្គរ* គ.ស២០០៨, ទំព័រ៩៩។

នេះពាក្យថា *មេ* មានន័យពីរយ៉ាង៖ មួយគឺមេជាម្ដាយ រីឯមួយទៀតមេជាអ្នកដឹកនាំ ឬអ្នកត្រួតត្រា។ ន័យទី១ គេឃើញមាននៅក្នុងពាក្យ «មេ» មេគង្គ(គង្គា = ទឹក) មេមាន់។ ន័យទីពីរគេឃើញមាននៅក្នុងពាក្យ មេទ័ព មេស្រុក មេភូមិ មេឃ្លាំង ។ល។ ម្យ៉ាងទៀតដើម្បីកុំឱ្យខ្មែរភ្លេចស្ត្រី(មេ) ជាអ្នកដឹកនាំ គេឱ្យខ្មែរហៅខ្លួន ឯងថា *ខ្មែរ* (ខ+មេ+រ) ប្រែមកថាអ្នកដែលនៅក្រោមអំណាចមេ។[២៤]

ថ្វីដ្បិតតែប្រវត្តិសាស្ត្រ និងរឿងព្រេងភាគច្រើនបានលើកឡើងពីស្ត្រីភេទក្នុងបរិបទសង្គមគ្រួសារក៏ដោយ ប៉ុន្តែក៏នៅមានរឿងព្រេងនិទាន ប្រលោមលោកប្រវត្តិសាស្ត្រមួយចំនួនទៀត បាននិយាយអំពីសកម្មភាព និងទង្វើដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់ស្ត្រីក្នុងកិច្ចការកសាងជាតិផងដែរ។ ជាក់ស្តែងតាមការរៀបរាប់នៅខាងលើ យើងអាចដឹងបានថា ពុំមែនមានតែបុរសនោះឡើយ ដែលបានចូលរួមជួយកសាងសង្គមជាតិ តែក៏មាននារីខ្មែរមានសមត្ថភាពជាច្រើនរូបដែលមានបញ្ញាញាណវាងវៃក្នុងការជួយអភិវឌ្ឍប្រទេសជាតិ។ នារីទាំងនោះមិនត្រឹមតែបានចូលរួមបម្រើសកម្មភាពសង្គមនោះទេ ប៉ុន្តែនារីទាំងនោះក៏មានលក្ខណៈជាមេដឹកនាំគេទៀតផង។ ចំណុចត្រង់នេះ បានបញ្ជាក់យ៉ាងច្បាស់អំពីលក្ខណៈពិសេសរបស់ស្ត្រីខ្មែរ ដែលមិនត្រឹមតែមានសមត្ថភាពក្នុងការជួយយឹតយោងគ្រួសារប៉ុណ្ណោះទេ ថែមទាំងបានជួយកសាង និងការពារប្រទេសជាតិផងដែរ។ ជាក់ស្តែង គេឃើញមានរឿងព្រេងមួយចំនួន បានលើកឡើងពីលក្ខណៈស្ត្រីជាមេដឹកនាំ ហើយរឿងទាំងនោះមានដូចជា៖ *រឿងដើមកំណើត*

---

[២៤] ថាច់ ត្វាន់ *ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ* គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ គ.ស. ២០១០ ទំព័រ៧២។

*សត្វមួស រឿងភ្នំប្រុសភ្នំស្រី រឿងភ្នំដូនពេញ រឿងភ្នំបុរីឬភ្នំដា និងរឿងព្រះថោង នាងនាគ ជាដើម។*

## ៨.៣- ស្ត្រីនិងការអប់រំ

អត្រាកុមារដែលបានចុះឈ្មោះចូលរៀនមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ដោយសារនៅកម្រិតបឋមសិក្សាចំនួនកុមារានិងកុមារីបានចូលរៀនមានចំនួនប្រហាក់ប្រហែលគ្នា។ អត្រាកុមារដែលបានចូលរៀននិងសមភាពយេនឌ័រ ក៏មានភាពប្រសើរឡើងដែរនៅកម្រិតសិក្សាខ្ពស់ៗ។ ទន្ទឹមនឹងនោះ អត្រាអក្ខរជន និងការអប់រំរបស់មនុស្សវ័យក្មេងដែលមានអាយុក្រោម២០ឆ្នាំបានទទួលជោគជ័យទៅតាមគោលដៅដែលបានកំណត់។ ទាំងនេះបានឆ្លុះបញ្ចាំងពីភាពរីកចម្រើនក្នុងការទទួលបានការអប់រំនៅកម្រិតបឋមសិក្សា ហើយស្ថាប័នដែលទទួលបន្ទុកក្នុងការផ្តល់ការអប់រំនឹងបន្តពិចារណា និងបញ្ចូលបញ្ហាយេនឌ័រក្នុងគោលនយោបាយវិស័យអប់រំ។

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក្មេងស្រីនៅមានចំនួនតិចជាងក្មេងប្រុសនៅគ្រប់កម្រិតសិក្សា ហើយភាពរីកចម្រើនលើការចុះឈ្មោះចូលរៀន និងសមភាពយេនឌ័រនៅកម្រិតសិក្សាខ្ពស់ៗ ភាគច្រើនមានសម្រាប់តែគ្រួសារដែលមានចំណូលច្រើនតែប៉ុណ្ណោះ។ បញ្ហាសេដ្ឋកិច្ច គឺជាកត្តាមួយផងដែរដែលមានឥទ្ធិពលលើការសិក្សា ប៉ុន្តែក្មេងប្រុសនៅតែមានអាទិភាពក្នុងការទទួលបានការសិក្សាច្រើនជាងក្មេងស្រី។ ការយកចិត្តទុកដាក់ទៅលើការបង្កើនអត្រានៃការសិក្សានិងកាត់បន្ថយគម្លាតយេនឌ័រនៅមធ្យមសិក្សាបឋមភូមិ គឺជាកត្តាសំខាន់ដែលចូលរួមចំណែកបង្កើនគុណភាពនៃកម្លាំងពលកម្ម និងកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌។

ជាទូទៅការទទួលបានការអប់រំក្នុងចំណោមស្ត្រីនៅមានកម្រិតទាប។ ៤០%នៃស្ត្រីដែលមានអាយុពី២៥ដល់៤៤ឆ្នាំគឺជាអនក្ខរជន (ធៀបនឹង២២% សម្រាប់បុរស)។ ទោះបីកម្រិតអប់រំមានភាពប្រសើរឡើងក្នុងចំណោមក្រុមប្រជាជនវ័យក្មេង ប៉ុន្តែមានប្រមាណជា២៣% នៃស្ត្រីដែលមានអាយុពី១៥-២៤ឆ្នាំ គឺជាអនក្ខរជន(ធៀបនឹង១៦% នៃបុរសវ័យក្មេង)។ លើសពីនេះទៀត ស្ត្រីដែលមានអាយុពី២៥-៤៤ឆ្នាំមានចំនួន៣៥% និងស្ត្រីដែលមានអាយុពី ១៥-២៤ឆ្នាំមានចំនួន៣៣% ទទួលបានការសិក្សាអប់រំទាបជាងកម្រិតបឋមសិក្សា។ ស្ត្រីដែលស្ថិតក្នុងកម្លាំងពលកម្ម និងស្ត្រីដែលស្ថិតក្នុងអាយុបន្តពូជមានអត្រាអក្ខរភាព និងការអប់រំទាបដែលនេះជាបញ្ហាមួយដ៏គួរឱ្យព្រួយបារម្ភផងដែរ។[២៥]

នៅក្នុងភាពខុសគ្នាលើយេនឌ័រដែលគេបានកត់សម្គាល់ឃើញ ភាគច្រើនស្ត្រីទទួលបានការអប់រំតិចជាងបុរស។ នេះមិនមែនសំដៅតែលើចំនួនឆ្នាំសិក្សាទេ ក៏ប៉ុន្តែសំដៅទាំងអត្រាអក្ខរភាពទៀតផង ដែលមានភាពខុសគ្នាជាមធ្យម៦៩,៦% រវាងបុរស៨០,៣% ធៀបនឹងស្ត្រី៦០,៣% លើអត្រាអក្ខរភាព។[២៦]

---

[២៥] ក្រសួងកិច្ចការនារី *យេនឌ័រ និង ការអប់រំ* ២០១០ (http://www.mwa.gov.kh/gender-and-education)។

[២៦] ធនាគារពិភពលោកសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ *កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាលបានទេនាឆ្នាំ២០១៥?* ភ្នំពេញ ខែកុម្ភៈ ២០០៦ ទំព័រ១៤៧។

## ៨.៤- ស្ត្រីនិងសេដ្ឋកិច្ច

ដោយឡែកការពង្រឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ជាផ្នែកមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលបានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បី *កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព*។ ដើម្បីធ្វើឱ្យវិស័យនេះកាន់តែប្រសើរឡើង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននឹងកំពុងផ្តល់ជំនាញបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព និងប្រសិទ្ធភាពដល់ប្រជាពលរដ្ឋ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស។ ដើម្បីសម្រេចគោលដៅនេះ ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍសមត្ថភាពជំនាញ និងវិជ្ជាជីវៈដោយស្មើភាពគ្នាដល់ប្រជាជនកម្ពុជាទាំងប្រុសទាំងស្រី សំដៅលើកកម្ពស់ជីវភាពរស់នៅក៏ដូចជាការអភិវឌ្ឍប្រទេសជាតិទាំងមូល។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ស្ត្រីនៅមានចំនួនទាបនៅឡើយ បើធៀបនឹងបុរស ទាំងក្នុងការទទួលបានការបណ្តុះបណ្តាលចំណេះដឹងជំនាញ ជាពិសេសក្នុងកម្រិតមធ្យម និងឧត្តមសិក្សាបច្ចេកទេស និងក្នុងតួនាទីធ្វើសេចក្តីសម្រេច។[២៧]

ម្យ៉ាងទៀត វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈក៏បានបង្កើននូវជំនាញនិងការងារជូនប្រជាពលរដ្ឋ ជាពិសេសការពង្រាយការបណ្តុះបណ្តាលដល់តំបន់ជនបទដាច់ស្រយាល ដើម្បីឱ្យប្រជាពលរដ្ឋមានប្រាក់ចំណូល និងទប់ស្កាត់ការធ្វើចំណាកស្រុក ក៏ដូចជាកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងកាត់បន្ថយការរីករាលដាលនៃជំងឺអេដស៍។ បើទោះបីជាសេវា

---

[២៧] ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដ.ឯ.ម ទំព័រ១៨។

អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅមិនទាន់ឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយ ជាពិសេសនៅតំបន់ជនបទដាច់ស្រយាល ដែលទាមទារឱ្យក្រសួងការងារ និងបណ្តុះបណ្តាលជីវៈ និងក្រសួងពាក់ព័ន្ធនានាខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីពង្រីកសេវារបស់ខ្លួនឱ្យបានដល់ប្រជាពលរដ្ឋនៅគ្រប់ទិសទីក្នុងផ្ទៃប្រទេស និងឆ្លើយតបតាមតម្រូវការ ជាក់ស្តែងនៃទីផ្សារការងារ។ [២៨]

## ៨.៥- ស្ត្រីនិងសុខភាព

អាយុដែលសង្ឃឹមរស់របស់ប្រជាជនកម្ពុជាមានការកើនឡើងចាប់តាំងពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤ ប៉ុន្តែស្ត្រីមានអាយុជាមធ្យមវែងជាងបុរស។ អត្រាមរណភាពទារកនិងកុមារអាយុក្រោម៥ឆ្នាំ មានការថយចុះគួរឱ្យកត់សម្គាល់ក្នុងរវាងឆ្នាំ២០០០ និងឆ្នាំ២០០៥ ប៉ុន្តែអត្រាមរណភាពក្មេងប្រុស នៅតែខ្ពស់ជាងក្មេងស្រីដដែល។ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ ក៏បានបង្ហាញពីការរីកចម្រើនជាមធ្យមផងដែររវាងឆ្នាំ២០០០ និងឆ្នាំ២០០៥ ដែលក្នុងនោះមានភាពប្រសើរឡើងច្រើនសម្រាប់ក្មេងស្រី។

អត្រាមរណភាពមាតានៅតែស្ថិតក្នុងកម្រិតមួយដ៏ខ្ពស់ គឺប្រមាណ៤៧២នាក់ ក្នុងចំណោម១០០.០០០នាក់ ដែលមានកំណើតរស់ ដោយពុំមានភាពប្រសើរឡើងទាល់តែសោះចាប់តាំងពីឆ្នាំ២០០០មក។ ការសម្រាលកូននៅតាមមណ្ឌលសុខភាពមានភាពប្រសើរឡើងខ្លះៗ ប៉ុន្តែនៅតែមានកម្រិត

[២៨] -ដ- ទំព័រ ១៩។

ទាបនៅឡើយ(២២% ប៉ុណ្ណោះ) ហើយសមាមាត្រនៃស្ត្រីដែលបានរំលូតកូនលើសពីម្តងបានកើនឡើងពី ៥% ដល់ ៨%។

ចំនួនស្ត្រីដែលបន្តរាយការណ៍ពីបញ្ហាក្នុងការប្រើប្រាស់សេវាសុខភាពបានថយចុះ ប៉ុន្តែនៅតែស្ថិតក្នុងកម្រិតខ្ពស់ដដែល។ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យល្អក៏មានភាពប្រសើរឡើងដែរ ប៉ុន្តែសេវានេះនៅមានកម្រិត ហើយមានភាពខុសគ្នាយ៉ាងខ្លាំងទៅតាមតំបន់ និងជីវភាពគ្រួសារ។

ប្រហែលជា ៧០% នៃបុរសវ័យក្មេងដែលមានអាយុពី១៥ ដល់១៩ ឆ្នាំ បានរាយការណ៍ថាធ្លាប់បានរួមភេទដោយប្រថុយប្រថាន(ធៀបទៅនឹងស្ត្រីវ័យក្មេងដែលមាន១,២%) ហើយពួកគេមានការយល់ដឹងតិចតួចពីគ្រោះថ្នាក់នៃការចម្លងមេរោគអេដស៍។ ការរងរបួសនិងការស្លាប់ដោយសារគ្រោះថ្នាក់ចរាចរមានការកើនឡើងច្រើនជាងពីរដងរវាងឆ្នាំ២០០០ និង ២០០៥ ហើយជនរងគ្រោះភាគច្រើនគឺជាបុរស។[២៩] តាមសេចក្តីរាយការណ៍ថា ចំនួនអ្នកកើតជំងឺមហារីកមាត់ស្បូននៅប្រទេសកម្ពុជាស្ថិតក្នុងតួលេខមួយគួរឱ្យព្រួយបារម្ភ ដែលភាគច្រើននៃជំងឺនេះ តែងកើតមានចំពោះស្ត្រីចាប់ពីវ័យកណ្តាលឡើង។ យ៉ាងហោចណាស់ជារៀងរាល់ឆ្នាំ ស្ត្រីនៅកម្ពុជាប្រមាណជា១៩០ ទៅ ២៣៥ នាក់ បានកើតជំងឺមហារីកមាត់ស្បូន។ ជំងឺនេះកំពុងឈរនៅលំដាប់ខ្ពស់បំផុតក្នុងចំណោមជំងឺមហារីកដទៃទៀតដែលបានកើតលើស្ត្រីនៅទូទាំងប្រទេស។ តាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត **គួយ សំណាង** ដែលជាប្រធានផ្នែកជំងឺមហារីកនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងថា ជំងឺមហារីមាត់ស្បូន

[២៩] ក្រសួងកិច្ចការនារី ***យេនឌ័រ និង សុខភាព*** (http://www.mwa.gov.kh/gender-and-health)។

ជាជំងឺមហារីកមួយប្រភេទដែលកើតនៅលើមាត់ស្បូនស្ត្រី តាមវិទ្យាសាស្ត្រ គេបានរកឃើញថា ប្រភេទជំងឺនេះបានបង្កមកពីវីរុសម្យ៉ាងមានឈ្មោះថា HPV (ហាសប៉េវេ)។

លោកក៏បានបន្តទៀតថា មូលហេតុដែលស្ត្រីនៅកម្ពុជាមួយចំនួនកើតជំងឺមហារីកប្រភេទនេះ ដោយសារតែនៅកម្ពុជានាពេលបច្ចុប្បន្ន មានស្ត្រីមួយភាគធំនៅមានទម្លាប់តពីប្រពៃណី មានភាពអៀនខ្មាស់ច្រើនមិនហ៊ានទៅជួបឬពិគ្រោះយោបល់ជាមួយគ្រូពេទ្យខាងរោគស្ត្រីពីបញ្ហាដែលកើតមានមកលើសុខភាពសរីរាង្គ រហូតឈានដល់ដំណាក់កាលដែលពិបាកក្នុងការព្យាបាលឱ្យបានជាសះស្បើយ។ លើសពីនេះទៅទៀតនោះជំងឺមហារីកមាត់ស្បូននេះកើតមកពីវីរុស HPV ដែលវីរុសនេះឆ្លងមកពីការរួមដំណេកនឹងគ្នា។ ពីអ្នកជំនាញដដែលបានឱ្យដឹងទៀតថា រោគសញ្ញាដែលបង្ហាញថា ស្ត្រីអាចនឹងកើតជំងឺមហារីកមាត់ស្បូននេះ គឺមានលក្ខណៈដូចគ្នាទៅនឹងរោគសញ្ញាជំងឺរលាកមាត់ស្បូនដែរ ដែលមានលក្ខណៈដូចជា ធ្លាក់ស ពេលខ្លះមានក្លិន និងពេលខ្លះមិនមានក្លិន ឬមានធ្លាក់ឈាមតិចតួចក្រោយពីរួមដំណេកជាមួយគ្នា និងឈឺចង្កេះរហូតអាចមានមេរោគទុំជ្រុះទៅលើថ្លើមបង្កទៅជាមេរោគថ្លើមបន្តទៀត។

ចំពោះវិធីទប់ស្កាត់និងការព្យាបាលជំងឺមហារីកមាត់ស្បូននេះ លោកវេជ្ជបណ្ឌិត **គួយ សំណាង** ក៏បានបញ្ជាក់ដែរថា មានវ៉ាក់សាំងដើម្បីចាក់ឱ្យស្ត្រីការពារពីជំងឺនេះបាន។ ចំណែកការព្យាបាលចំពោះជំងឺនេះ លោកវេជ្ជបណ្ឌិតបញ្ជាក់ថា ប្រសិនបើស្ត្រីកើតនោះ វាស្ថិតក្នុងដំណាក់កាលទីមួយ វិធីព្យាបាលគឺគ្រូពេទ្យត្រូវចៀរសាច់នៅបរិវេណមាត់ស្បូននោះទៅពិនិត្យទើបព្យាបាលទៅតាមស្ថានភាពនៃជំងឺ ដោយធ្វើការវះកាត់ និងបាញ់កាំរស្មី។ លោក **គួយ**

**សំណាង** បានបន្តថា លទ្ធភាពនៃការព្យាបាលជំងឺនេះឱ្យជាសះស្បើយនោះមានតែក្នុងដំណាក់កាលទីមួយនិងទីពីរប៉ុណ្ណោះ ក្រៅពីនេះការព្យាបាលឱ្យជាសះស្បើយមានភាគរយតិចបំផុត។ ជាចុងក្រោយលោកបានផ្តាំផ្ញើដល់ស្ត្រីកម្ពុជាទាំងអស់ថា ស្ត្រីដែលមិនទាន់មានដៃគូរស្នេហា គួរប្រញាប់ទៅចាក់វ៉ាក់សាំងការពារជាបន្ទាន់ ប៉ុន្តែបើស្ត្រីដែលមានគ្រួសារហើយ ចាប់ពីអាយុ៣០ឆ្នាំឡើងទៅគួរទៅរកសេវាពិគ្រោះផ្នែករោគស្ត្រី នៅពេលនោះហើយដែលស្ត្រីអាចចៀសផុតពីជំងឺមហារីកមាត់ស្បូននេះបាន។[៣០] យោងតាមសូចនាករសុខភាពរួម ដែលបានជ្រើសរើសឆ្នាំ២០០៣ បានបង្ហាញថា ក្នុងចំណោមប្រទេសចំនួន០៦ រួមទាំងកម្ពុជាផង ចំនួនអត្រាស្លាប់របស់មាតាកម្ពុជាមានចំនួន៤៥០នាក់ធៀបនឹងឥណ្ឌូណេស៊ី ២៣០នាក់ ឡាវ ៦៥០នាក់ មីយ៉ាន់ម៉ា ៣៦០នាក់ ថៃ ៤៤នាក់ វៀតណាម ១៤០នាក់ តែបើអាយុកាលមធ្យមពីកំណើតវិញ ស្ត្រីកម្ពុជាមាន ៥៧នាក់(៦៥នាក់) ធៀបនឹងឥណ្ឌូណេស៊ី ៦៨នាក់ ឡាវ ៦០នាក់ មីយ៉ាន់ម៉ា ៦៣នាក់ ថៃ ៧៣នាក់ វៀតណាម ៧៤នាក់។ ការស្ទាបស្ទង់ការធ្វើជំរឿនប្រជាជនកម្ពុជាឆ្នាំ២០០៤ បានបង្ហាញថា មានការរីកចម្រើនច្រើនលើសូចនាករស្ថានភាពសុខភាពមួយចំនួន។[៣១]

---

[៣០] សូមមើលគេហៈទំព័រ www.wmc.org.kh.

[៣១] *កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្តាល់បានទេនាឆ្នាំ២០១៥?* ភ្នំពេញ ខែកុម្ភៈ ២០០៦ ទំព័រ១៦៥។

### *ក. ស្ត្រីនិងសុខភាពកុមារ*

សម័យមុនកុមារត្រូវបានប្រសូត្រជាមួយនឹងឆ្មបបុរាណនៅក្នុងផ្ទះ។ បច្ចុប្បន្នគ្រួសារដែលមានធនធាន ឬទ្រព្យសម្បត្តិច្រើនត្រូវបានទៅប្រសូត (សម្រាលកូន)នៅមន្ទីរសម្ភព។ ក្នុងសម័យទំនើប ស្ត្រីក្នុងកំឡុងពេលមានគភ៌ បានធ្វើដំណើរទៅមន្ទីរពេទ្យ ដើម្បីពិគ្រោះជាមួយគ្រូពេទ្យជាប្រចាំ និងឱ្យបាន ទៀងទាត់តាម ការកំណត់របស់គ្រូពេទ្យ(វេជ្ជបញ្ជា) ហើយត្រូវទៅសម្រាកនៅ មន្ទីរពេទ្យនៅពេលប្រសូត។ ប្រព័ន្ធនេះមានសារៈសំខាន់ណាស់ ដោយសារ មាតា និងទារកត្រូវបានពិនិត្យជាប្រចាំដោយគ្រូពេទ្យជំនាញ និងអាចទទួលថ្នាំ សង្កូវនៅពេលដែលមានតម្រូវការចាំបាច់ក្នុងអំឡុងពេលពរពោះ។ ប្រសិនបើ មានគ្រោះថ្នាក់នៅពេលសម្រាល(ប្រសូត) គេអាចប្រើវិធីវះកាត់ដោយគ្មាន ពន្យាពេលឡើយ។ ការខ្វះខាតសម្ភារៈនៅក្នុងផ្ទះ និងកង្វះនូវវិធីព្យាបាលទាន់ សម័យរបស់ឆ្មបបុរាណធ្វើឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតរបស់ម្តាយ និងទារក នៅពេលប្រសូត។ បុព្វហេតុមួយទៀតនៃការប្រើប្រាស់មន្ទីរសម្ភពសម្រាប់ សម្រាលកូន គឺជាការបំបាត់នូវប្រព័ន្ធគ្រួសាររួម ដែលមានលំនៅឋានក្នុងទីក្រុង មានសភាពតូចចង្អៀត ធ្វើឱ្យសាច់ញាតិមានការលំបាកក្នុងការកំដរនៅពេល ស្ត្រីមានជំងឺ ឬប្រសូត្រ។ ដូច្នេះស្ត្រីដែលមានជំងឺ ឬការសម្រាលកូនត្រូវបញ្ជូន ទៅមន្ទីរសម្ភពដែលចៀសវាងនូវក្តីបារម្ភពីគ្រោះថ្នាក់ផ្សេងៗ។ បច្ចុប្បន្ននេះមាន គ្រូពេទ្យ ឬវេជ្ជបណ្ឌិតលើជំនាញឯកទេសតាមផ្នែកផ្សេងៗ ដែលតម្រូវទៅតាម ប្រភេទនៃជំងឺ។ អ្នកជំនាញខាងជំងឺស្ត្រីមាននៅគ្រប់ទីកន្លែងទាំងក្នុងទីក្រុង

និងទីជនបទទូទាំងផ្ទៃប្រទេសសម្រាប់ព្យាបាលជំងឺដល់ស្ត្រីរងគ្រោះ។ ពីអតីតកាលការងារនេះត្រូវបានបំពេញយ៉ាងពិបាក និងគ្រោះថ្នាក់នៅតាមគ្រួសារ។[៣២]

អត្រានៃការពន្យាកំណើតមានភាពប្រសើរជាងមុនបន្តិចបន្តួច រីឯអត្រាកំណើតបានថយចុះយ៉ាងខ្លាំងចាប់ពីឆ្នាំ២០០០ ដល់២០០៥ ចំណែកឯការសម្រាលកូននៅតាមមណ្ឌលសុខភាពការកើនឡើងច្រើនជាងមុនពីរដង។

### *ខ. ស្ត្រីនិងតំហែទាំកុមារ*

យោងតាមសៀវភៅ ***ទស្សនវិទ្យាសម័យចតុមុខ លង្វែក ឧដុង្គ និងសម័យបារាំង*** របស់រាជបណ្ឌិត្យសភា ដែលមានចុះកាលបរិច្ឆេទថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ បានបង្ហាញថា សភាវគតិរបស់ម្តាយ គឺជាទំនោរមួយ ដែលបានចាក់ឫសយ៉ាងជ្រៅទៅក្នុងជីវិតសរីរាង្គរបស់កូនៗ។ វាក៏បានបង្ហាញផងដែរថា នៅក្នុងការស្រឡាញ់របស់ម្តាយតែងមានមនោសញ្ចេតនាមួយដែលជាភាពស៊ីគ្នារវាងញាណមួយ និងញាណមួយទៀត ពោលគឺញាណរបស់ម្តាយត្រូវគ្នាជាមួយនឹងញាណរបស់កូន ហេតុនេះហើយបានជាគេឃើញម្តាយស្រលាញ់កូនដូចសាច់ចេញពីសាច់។ សូម្បីតែសត្វក៏មានសភាវគតិជាម្តាយនេះដែរ។ ចំពោះមនុស្សសភាវគតិនេះតែងប្រកបដោយចិត្តគំនិត និងសីលសញ្ចេតនា ហើយការប្រទាក់ប្រទាញគ្នានៃញាណមានទ្រង់ទ្រាយជាសាមគ្គី រួមបញ្ចូលគ្នា។

សភាវគតិឪពុកវិញប្លែកពីសភាវគតិម្តាយ ពីព្រោះថាឪពុកពុំសូវជិតដិតស្និទ្ធស្នាលនឹងកូនដូចម្តាយឡើយ។ ម្យ៉ាងទៀតការស្រឡាញ់របស់ឪពុកហាក់ដូចជាឃ្លាតឆ្ងាយពីកូន ហើយច្រើនមានសភាពជាសញ្ចេតនាការពារថែទាំទៅ

---

[៣២] បណ្ឌិត វង្ស អែមសំអាន ***សង្គមវិជ្ជាគ្រួសារ*** ឆ្នាំសិក្សា២០០៩ ទំព័រ១២០-១២២។

វិញ។ តាមសៀវភៅ **វប្បធម៌អរិយធម៌** របស់ **ត្រឹង ងា** ក៏បានបង្ហាញដែរថា ស្ត្រីនៅពេលពរពោះ តែងមានការថ្នាក់ថ្នមមើលថែទាំយ៉ាងខ្លាំងចំពោះកូនដែលនៅក្នុងផ្ទៃ សូម្បីតែអាហារដែលគាត់ធ្លាប់តែចូលចិត្ត និងផ្លែឈើដែលគាត់ធ្លាប់ឈោងបេះ ក៏គាត់ហ៊ានលះបង់ ដើម្បីកូនរបស់គាត់ដែលទើបតែចាប់ផ្ទៃដែរ។

ចំណែកឯការដេកដើរឈរអង្គុយវិញក៏មានលក្ខណៈខុសពីមុនដែរ ពោលគឺតាមទំនៀមពីបុរាណ មិនឱ្យនាងអង្គុយនៅមាត់ជណ្ដើរទេ ព្រោះខ្លាចក្រែងកូនកើតមកមិនរួច។ លើសពីនេះទៅទៀត ចាស់ៗលោកហាមមិនឱ្យដេកទម្រន់ទេ គឺត្រូវដេកឱ្យឆាប់ភ្ញាក់មុនប្ដី ហើយមិនត្រូវស្ដាប់រឿងរន្ធត់ៗទេ ត្រូវយកតុំកំបោរដាក់សង្កត់លើពោះ ដើម្បីកុំឱ្យទារកក្នុងផ្ទៃមានការភ័យខ្លាចនឹងឥទ្ធិពលរាហូ។ ចំណែកពេលល្ងាចវិញ ចាស់ៗហាមដាច់ខាតមិនឱ្យស្ត្រីមានផ្ទៃពោះងូតទឹកឡើយ ពីព្រោះខ្លាចកូនថ្លោសពេកកើតមកពុំរួច។ លុះដល់កូនកើតមក បើទោះបីជានាងមានការនឿយហត់ឈឺចុកចាប់នៅពេលសម្រាលយ៉ាងណាក៏ដោយ ក៏ក្ដីឈឺចាប់ទាំងនោះ ត្រូវរលាយបាត់ទៅវិញនៅពេលដែលនាងបានឃើញនូវវង់ភ័ក្ត្ររបស់កូន។ នាងអង្អែលថ្នាក់ថ្នមបីបមបំពេរ និងបំបៅដោះកូនដោយក្ដីរីករាយ រកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ទាំងអស់នេះបញ្ជាក់ឱ្យឃើញថា នាងជានារីមានការលះបង់ខ្ពស់ណាស់ចំពោះកូន និងគ្រួសារ។[៣៣]

ដោយឡែកឪពុកម្ដាយដែលធ្វើការងារ ឬប្រកបមុខរបរចិញ្ចឹមជីវិត ត្រូវការចាំបាច់នូវអ្នកថែរក្សាកូនរបស់គេ។ ហេតុនេះហើយទើបមានស្ត្រីមួយចំនួនបានចេញមុខទទួលរ៉ាប់រងនូវការងារជាអ្នកថែទាំកូនឱ្យគេ ដោយទទួលមើល

---

[៣៣] ត្រឹង ងា *វប្បធម៌អរិយធម៌* ។

ថែទាំ និងផ្តល់ការអប់រំតែនៅពេលដែលឪពុកម្តាយរបស់ក្មេងៗចេញទៅធ្វើការងារ ឬបំពេញភារកិច្ចរបស់ខ្លួននៅពេលថ្ងៃ និងត្រូវត្រលប់មកទទួលកូនវិញនៅពេលល្ងាច។ ថ្នូរដែលស្ត្រីអ្នកមើលថែទាំងនោះទទួលបានមកវិញ គឺជាប្រាក់កម្រៃដែលឪពុកម្តាយរបស់ក្មេងៗទាំងអស់នោះបង់ថ្លៃឈ្នួល។[៣៤] ដូច្នេះហើយទើបបច្ចុប្បន្ននេះ គេឃើញឪពុកម្តាយដែលមានការងារ ឬមុខរបរនៅក្រៅផ្ទះតែងតែបញ្ជូនកូនតូចៗឱ្យទៅសាលាដែលជាកន្លែងអប់រំដោយមានអ្នកមើលថែរក្សា និងចិញ្ចឹមក្មេង។ កុមារត្រូវបានគេមើលថែនៅក្នុងមត្តេយ្យសាលា និងលេងកម្សាន្តរហូតដល់ឪពុកម្តាយរបស់គេមកទទួលក្រោយសម្រាកពីការងារ។ នៅក្នុងទីក្រុងធំៗ គេឃើញមានការបង្កើតនូវសួនកុមារសម្រាប់ឱ្យកុមារលេងកម្សាន្ត ដែលពីមុនមកការងារនេះ គឺជាការគិតគូររបស់គ្រួសារ។ នៅក្នុងសាលាមត្តេយ្យឯកជនភាគច្រើនទទួលអប់រំកុមារចាប់ពីអាយុ៣-៦ឆ្នាំ និងមានសាលាមួយចំនួនទៀត បានទទួលការអប់រំបណ្តុះបណ្តាលកុមារតាំងពីកម្រិតមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ។ ការងារទាំងអស់នេះ ជាការជួយសម្រួលដល់ការលំបាករបស់ឪពុកម្តាយ ជាពិសេសស្ត្រីដែលមានការងារ ឬប្រកបមុខរបរនៅខាងក្រៅផ្ទះ។[៣៥]

---

[៣៤] វង្ស អែមសំអាន *សង្គមវិជ្ជាគ្រួសារ* ដ.ឯ.ម ទំព័រ១២២,១២៣។

[៣៥] វង្ស អែមសំអាន *សង្គមវិជ្ជាគ្រួសារ* ដ.ឯ.ម ទំព័រ១២០។

# ៩- តួនាទីស្ត្រីខ្មែរតាមសម័យកាលនីមួយៗ

## ៩.១- ស្ត្រីខ្មែរសម័យមុនអង្គរ

សម័យមុនអង្គរនេះសំដៅយកតែត្រឹមសម័យ**នគរភ្នំឬហ្វូណន**ប៉ុណ្ណោះ គឺចាប់ពីដើមស.វ.ទី១ រហូតដល់ឆ្នាំ៨០២ នៃគ.ស.(ដើមស.វ.ទី៩)។ តើស្ត្រីនៅសម័យមុនអង្គរនោះមានសកម្មភាពអ្វីខ្លះនៅក្នុងសង្គមខ្មែរ? ខាងក្រោមនេះជាការរៀបរាប់ត្រួសៗ ដោយបែងចែកជាសម័យកាលទៅតាមដំណាក់កាលនីមួយៗ៖

### ៩.១.១- សម័យនគរភ្នំ

ជាការពិតណាស់ បើយើងពិនិត្យតាមរយៈរឿងព្រេងកថាបានបង្ហាញឱ្យឃើញថា មុនការមកដល់នៃព្រះបាទ **ហ៊ុន ទៀន** (កៅណ្ឌិន្យ) ប្រទេសខ្មែរបានមានស្ត្រីជាបឋមក្សត្រគ្រប់គ្រងរួចមកហើយ គឺព្រះនាង **លីវយី** (សោមា) ដោយព្រះនាងបានរៀបចំវិស័យរដ្ឋបាលដឹកនាំប្រទេសតាមបែបមាតាធិបតេយ្យនៅលើកោះគោកធ្លក ដែលនិយមប្រើពាក្យ *វេ* នៅខាងដើម។ ទើបតែក្រោយមក គឺនៅពេលដែលព្រះបាទ **ហ៊ុន ទៀន** ចូលមក គេក៏បានកែប្រែការងាររដ្ឋបាលជំនួសដោយបុរសជាអ្នកដឹកនាំវិញ។

ដោយសារមានស្ត្រីជាធំលើគេនៅក្នុងប្រទេស ហេតុនេះហើយបានជាយើងសង្កេតឃើញថា វប្បធម៌ខ្មែរយើងមានលក្ខណៈពិសេសផ្ទាល់ខ្លួនខុសពីវប្បធម៌ឥណ្ឌានិងចិន ដែលចូលមកស្រុកខ្មែរតាមក្រោយ។ វប្បធម៌ខ្មែរយើង ជាវប្បធម៌មាតាធិបតេយ្យ គឺយកមាតាឬស្ត្រីជាធំ រីឯវប្បធម៌មួយចំនួននិងចិន ជាវប្បធម៌បិតាធិបតេយ្យ គឺយកបិតាឬបុរសជាធំ។

ភស្តុតាងនៃឥទ្ធិពលមាតាធិបតេយ្យ ដែលយើងឃើញច្បាស់នាពេលបច្ចុប្បន្ននេះគឺពាក្យថា «*មេ*»។ ក្នុងភាសាខ្មែរ *មេ* សំដៅដល់ភេទ**ញី** ឬភេទ**ស្រី** ដូចជា មាន់មេ គោមេ ជាដើម។ ការឱ្យតម្លៃទៅលើស្ត្រីជាធំ បានធ្វើឱ្យពាក្យថា *មេ* នេះ ត្រូវបានខ្មែរយើងយកទៅដាក់នាំមុខពាក្យដទៃទៀត កាលណាគេចង់បញ្ជាក់ថា របស់នោះជាធំ ជាដើមចម ជាប្រធាន ឬជាអ្នកដឹកនាំ។ល។ ជាក់ស្តែងយើងតែងតែឮគេហៅថា *មេដឹកនាំ មេចោរ មេទ័ព មេស្រុក មេឃុំ មេភូមិ មេសោរ មេដៃ មេដំបូល មេភ្លើង រើសយកអាណាមេៗ.....ជាដើម។* ទោះបីជារបស់នោះគ្មានភេទ ឬមានភេទឈ្មោល ឬភេទប្រុសក៏ដោយ ក៏គេនិយមយកពាក្យ*មេ* ដាក់ពីមុខ ឬដាក់នាំមុខដែរ។

នៅក្នុងទស្សនៈព្រះពុទ្ធសាសនាខ្មែរយើង ក៏គេសង្កេតឃើញថា ភិក្ខុដែលទទួលនាទីជាអ្នកគ្រប់គ្រងវត្តក៏ត្រូវបានខ្មែរយើងហៅថា*មេ* ដែរគឺ លោកគ្រូមេកុដិ លោកគ្រូមេវត្ត ដែលអាចមានន័យថា អ្នកដឹកនាំវត្ត ប្រធានវត្ត នាយកវត្ត ជាដើម។ ដូច្នេះបញ្ជាក់ឱ្យឃើញថា ពាក្យថា «*មេ*» នេះពិតជាមានឥទ្ធិពលយ៉ាងខ្លាំងមកលើសង្គមខ្មែរ តាំងពីបុរាណកាលរហូតមកដល់បច្ចុប្បន្ន។

ឯកសារចិនរបស់លោក **កាំង ថៃ** ដែលបានមកទស្សនានគរភ្នំនៅពាក់កណ្តាលសតវត្សទី៣នៃគ្រិស្តសករាជ បានរៀបរាប់ថា *ប្រហែលជាក្នុងឆ្នាំ៥០ នៃគ្រិស្តសករាជ មានជនជាតិឥណ្ឌា ជាព្រាហ្មណ៍ម្នាក់ឈ្មោះ **ហ៊ុន ទៀន** បានធ្វើដំណើរពីប្រទេសឥណ្ឌា តាមកោះខាងត្បូងមកអាណាចក្រភ្នំ។ ហេតុដែលបណ្តាលឱ្យព្រាហ្មណ៍ **ហ៊ុន ទៀន** ធ្វើដំណើរមកកាន់នគរភ្នំនេះ ព្រោះយប់មួយព្រះបាទ **ហ៊ុន ទៀន** បានយល់សប្តិឃើញថា ទេវតាដែលបីបាច់ថែរក្សាព្រះអង្គបានធ្វើអំណោយធ្នូទិព្វមួយដល់ព្រះអង្គ ហើយបញ្ជាឱ្យព្រះអង្គឡើងជិះសំពៅ*

*ដ៏ធំមួយ។* លោក **កាំង ថៃ** បន្តថា *លុះព្រឹកឡើង ព្រះអង្គក៏ធ្វើដំណើរទៅកាន់ទេវស្ថានដើម្បីធ្វើសក្ការបូជា ស្រាប់តែបានឃើញធ្នូទិព្វនោះដូចសុបិន្តមែន។ ដោយសុបិនចុតដូច្នេះ ព្រះអង្គក៏ធ្វើដំណើរតាមសមុទ្រទៅកាន់អាណាចក្រភ្នំតាមការណែនាំរបស់ទេវតាក្នុងការយល់សុបិននោះ។*

មកដល់នគរភ្នំ ព្រះបាទ **ហ៊ុន ទៀន** បានពើបប្រយុទ្ធជាមួយរាជធានីនៃវង្ធនេះ ដែលលោក **កាំង ថៃ** អះអាងថា មានក្សត្រីដឹកនាំដែលមានព្រះនាមថា ព្រះនាង **លីវយី** គឺព្រះនាងបាននាំកម្លាំងទ័ពមកវាយលុកលើសំពៅព្រះបាទ **ហ៊ុន ទៀន** មុន។ ដោយឫទ្ធានុភាពធ្នូទិព្វ ព្រះអង្គក៏ទទួលបានជ័យជម្នះលើព្រះនាង **លីវ យី** ដែលជាម្ចាស់ស្រុក ដោយព្រះអង្គបានបាញ់សំពៅរបស់ព្រះនាងឱ្យធ្លាយពីម្ខាងទៅម្ខាង។ ដោយឃើញព្រះបាទ **ហ៊ុន ទៀន** មានឫទ្ធិខ្លាំងពូកែដូច្នោះ ព្រះនាង **លីវ យី** ក៏ព្រមចាញ់ព្រះអង្គ ហើយព្រះអង្គក៏បានរៀបអភិសេកព្រះនាងជាអគ្គមហេសី តាំងពីពេលនោះមក។

ត្រង់ចំណុច ព្រះនាង **លីវ យី** បាននាំកម្លាំងទ័ពមកវាយលុកលើសំពៅព្រះបាទ **ហ៊ុន ទៀន** មុននេះហើយ ដែលបានឆ្លុះបញ្ចាំងពីវីរភាពរបស់ស្ត្រីក្នុងការការពារនគររបស់ខ្លួនពីការឈ្លានពានរបស់សត្រូវ ហើយអ្វីដែលយើងគួរកោតសរសើរ ព្រះនាង **លីវ យី** ថែមទៀតនោះ គឺការព្រមរៀបអភិសេកជាមួយអ្នកដែលឈ្លានពានខ្លួនដើម្បីរក្សាវង្សត្រកូលនិងជាតិសាសន៍ខ្លួនបន្តមរតកជាបន្តទៀតរហូតមកដល់សព្វថ្ងៃ។

ប្រភពមួយទៀតដែលរៀបរាប់ពីព្រឹត្តិការណ៍នេះដែរ គឺសិលាចារិកចាមនៅ**មីសឺន**(គ្រិស្តសករាជ ៦៥៨) បានឱ្យយើងដឹងថា ព្រះបាទ **ហ៊ុន ទៀន** ដែលចិនហៅនោះឈ្មោះ **កៅណ្ឌិន្យ** ឯព្រះនាង **លីវ យី** វិញ គឺព្រះនាង **សោមា**

កូនព្រះច័ន្ទ។ ឯខាងព្រះរាជពង្សាវតារនៃព្រះរាជាណាចក្រកម្ពុជាវិញ បានហៅព្រះនាមស្តេចនោះថា **ព្រះថោង**និង**នាងនាគ** ដែលបានបន្សល់ទុកនូវកេរ្តិ៍ដំណែលទំនៀមទម្លាប់ប្រពៃណីជាច្រើន ក្នុងជីវភាពសង្គមខ្មែររហូតមកដល់សព្វថ្ងៃនេះ។

ដូច្នេះ រួមសេចក្តីមក គឺព្រះបាទ **ហ៊ុន ទៀន** ឬ **កៅណ្ឌិន្យ** ឬ **ព្រះថោង** និងព្រះនាង **លីវ យី** ឬ ព្រះនាង **សោមា** កូនព្រះច័ន្ទ ឬ **នាងនាគ** នេះហើយដែលជាអ្នកបានកសាងឡើងនូវសន្តតិវង្ស ឬរាជវង្សខ្មែរជាដំបូងគេបង្អស់នោះ។ ម៉្យាងទៀត គឺពេលនោះហើយដែល**ព្រះថោង** ឬ **កៅណ្ឌិន្យ** ឬ **ហ៊ុន ទៀន** ដែលជាជាតិឥណ្ឌា បាននាំយកនូវទំនៀមទម្លាប់ប្រពៃណីផ្សេងៗពីប្រទេសឥណ្ឌា មានសាសនា ភាសា អ្នកប្រាជ្ញអក្សរសាស្ត្រ ច្បាប់ទម្លាប់ផ្សេងៗពិសេស គឺរបៀបរៀបចំ ឬគំនិតដឹកនាំប្រទេសតាមបែបរាជាធិបតេយ្យមកបន្ថែមឱ្យឬបញ្ចូលគ្នានឹងអ្វីៗដែលសង្គមខ្មែរមានរួចទៅហើយ ដូចជាជំនឿលើព្រលឹងដូនតា គោរពមេបា អារក្ខអ្នកតា និងលទ្ធិមាតាធិបតេយ្យយកមេជាធំដែលជាហេតុធ្វើឱ្យសង្គមខ្មែរក្នុងសម័យនោះមានការរីកចម្រើនយ៉ាងឆាប់រហ័ស។[៣៦]

## ៩.១.២- សម័យចេនឡា

ចំពោះសម័យនេះ ជាទូទៅយើងពុំឃើញមានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់ថា នៅសម័យនេះ ស្ត្រីដើរតួនាទីសំខាន់អ្វីខ្លះក្នុងការកសាងសង្គមជាតិនោះទេ? ប៉ុន្តែយើងអាចសន្និដ្ឋានថា ស្ត្រីសម័យនោះប្រហែលជាធ្វើ

---

៣៦ https://www.rfa.org/

មេផ្ទះ គ្រប់គ្រងកូនចៅ និងជួយស្វាមីក្នុងការប្រកបរបរកសិកម្មប៉ុណ្ណោះ ពុំមានតួនាទីអ្វីធំដុំក្នុងជួររាជការឡើយ។ ប៉ុន្តែនៅសម័យនេះ គេក៏ឃើញមានក្សត្រី (ស្តេចស្រី)ឡើងគ្រងរាជ្យដែរ ហើយក៏ប្រហែលជាដោយសារក្សត្រីឡើងគ្រងរាជ្យនេះហើយដែលបណ្តាលឱ្យមានទំនាស់ផ្ទៃក្នុង ធ្វើឱ្យនគរចេនឡាបានបែកបាក់ជាពីរ គឺចេនឡាដីគោក និងចេនឡាទឹកលិច។ ចំណែកចេនឡាទឹកលិចត្រូវបានបែងចែករាជធានីជាពីរទៀតគឺ រាជធានីមួយគ្រប់គ្រងដោយរាជវង្សមួយក្រុមដែលអះអាងថា ជាប់ខ្សែស្រឡាយជាមួយព្រះបាទ*កៅណ្ឌិន្យ* និង ព្រះនាង*សោមា* ហើយរាជធានីមួយទៀតគ្រប់គ្រងដោយរាជវង្សដែលជាប់ខ្សែស្រឡាយជាមួយព្រះនាង **ជ័យរាជទេវី** ដែលជាអគ្គមហេសីរបស់ព្រះបាទ **ជ័យវរ្ម័នទី១**។ ការបែកបាក់ចេនឡាជាពីរនេះក៏បណ្តាលមកពីទំនាស់ខាងសាសនា ដែលព្រះបាទ **ជ័យវរ្ម័នទី១** បានប្រព្រឹត្តអំពើហិង្សាចំពោះអ្នកកាន់សាសនាផ្សេងពីព្រះអង្គ និងការមិនពេញចិត្តរបស់នាម៉ឺនសព្វមុខមន្ត្រីចំពោះព្រះនាង**ជ័យទេវី** ដែលបានឡើងសោយរាជ្យបន្តពីព្រះបាទ**ជ័យវរ្ម័នទី១** ក្រោយពេលដែលទ្រង់សោយទិវង្គតផងដែរ។ ការបែកបាក់នេះបានធ្វើឱ្យ**ជ្វា**នៅ**កោះជ្វា**ធ្វើការលុកលុយរាតត្បាតរហូតដល់រាជធានី ហើយក៏បានវាយយកនគរ**ចេនឡា**ទាំងមូលដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន បន្ទាប់ពីពួកគេច្បាំងបានជ័យជំនះលើនគរ**ចម្ប៉ា**។ នគរ**ចេនឡា**បានបាត់បង់ឯករាជ្យរបស់ខ្លួន ព្រមទាំងស្ថិតនៅក្រោមការត្រួតត្រារបស់**ជ្វា**អស់រយៈពេល១០ឆ្នាំ។[៣៧]

[៣៧] រាជបណ្ឌិត្យសភាកម្ពុជា *ទស្សនៈវិជ្ជាខ្មែរសម័យអង្គរ* គ.ស ២០០៨។

សូមបញ្ជាក់ផងដែរថា បុព្វហេតុនៃការបែកបាក់អាណាចក្រដ៏ធំធេង និងខ្លាំងពូកែ ត្រូវបែកបាក់ដោយសារមូលហេតុច្រើនយ៉ាងដូចជា៖

**ក. វិសាលភាពទឹកដី៖** អាណាចក្រ**ចេនឡា**មានទឹកដីធំធេងណាស់ ខាងជើងទល់នឹងប្រទេសចិន ខាងកើតជាប់និងប្រទេសចម្ប៉ា និងឈូងសមុទ្រចិន ខាងត្បូងជាប់នឹងសមុទ្រខ្មែរនិងឧបទ្វីបម៉ាឡាយូ ខាងលិចទល់នឹងប្រទេសភូមា។

**ខ. វិបត្តិផ្ទៃក្នុង៖** ក្រោយពីព្រះបាទ**ជ័យវរ្ម័នទី១** ចូលទិវង្គតទៅ ពុំមានរជ្ជទាយាទបន្ត នាំឱ្យសាមន្តរជ្ជជាច្រើនបានបះបោរចង់ផ្ដាច់ខ្លួនផង ចង់គ្រប់គ្រងអំណាចមជ្ឈិមផងនោះ ចម្បាំងក៏បានកើតមានឡើងឥតឈប់ឈរ និងធ្វើឱ្យបែកបាក់ចេនឡាតែម្ដង។

**គ. សមត្ថភាពគ្រប់គ្រង៖** ព្រះបាទ**ជ័យវរ្ម័នទី១** សោយទិវង្គតគ្មានរជ្ជទាយាទ រាជសម្បត្តិត្រូវធ្លាក់មកលើព្រះនាង**ជ័យទេវី** ជាបុត្រី។ ព្រះនាងបានត្អូញត្អែរពីការលំបាកក្នុងការគ្រប់គ្រងប្រទេស ដោយព្រះនាងជាស្ត្រី រជ្ជចំណុះនិងមន្ត្រីក្រោមឱវាទមិនស្តាប់បង្គាប់ ក៏កើតជម្លោះគ្នាមិនចេះឈប់ឈរ ដែលទីបញ្ចប់អាណាចក្រ**ចេនឡា**ត្រូវបែកបាក់ជាពីរគឺ **ចេនឡាដីគោក** និង**ចេនឡាទឹកលិច**។

ការបែកបាក់នោះ ចេនឡាដីគោកជារដ្ឋឯករាជ្យ ដោយចេនឡាដីគោករក្សាបានឯករាជ្យជាតិ មានរាជធានី ភវបុរៈ ក្បែរវត្តភូ(លាវ)។ តំបន់នេះសម្បូរជួរភ្នំ ជ្រលងភ្នំ និងខ្ពង់រាប ដែលមានវិសាលភាពលាតសន្ធឹងលើប្រទេសលាវ និងភាគខាងត្បូងនិងតំបន់ខ្ពង់រាបកូរ៉ាត ប្រទេសថៃ។ តាមប្រវត្តិសាស្ត្រចិនបានឱ្យដឹងថា ចេនឡាដីគោក ចិនហៅថា **វេន្ទរិនតាន** (Wentan) ព្រោះធ្លាប់មាន

ចំណងការទូតជាមួយគ្នា។ នៅឆ្នាំ៦២១ នៃ គ.ស. ស្តេចចិនឈ្មោះ **កៅតុង** នៃរាជវង្ស**ថាំង** បានបញ្ជាឱ្យមេទ័ពឈ្មោះ **ខូវ៉ា** លើកទ័ពមកវាយយកស្រុក**យ៉ាវចូវ** (ស្រុកយួន)។ ក្រោយមកនៅឆ្នាំ៦៧៩ នៃគ.ស. ស្តេច**កៅតុង** ដូរឈ្មោះស្រុក**យ៉ាវចូវ** ជា **អាណ្ណាម ដូហូតូ** (ជាអាណាព្យាបាល) វិញ។ ពេលនោះមេទ័ពយួន **ម៉ៃហាក់ដេ** (Maihac-de) បានបះបោរប្រឆាំងនឹងចិន ដោយចងសម្ព័ន្ធមិត្តជាមួយចេនឡាដីគោកនិងចម្ប៉ា។ នៅឆ្នាំ៧១៧ នៃគ.ស. ចេនឡាដីគោក បានបញ្ជូនទូតទៅស្រុកចិន។ នៅឆ្នាំ៧២២ នៃគ.ស. ចេនឡាដីគោកបានលើកទ័ពទៅជួយមេទ័ពយួន **ម៉ៃហាក់ដេ** ដែលបះបោរប្រឆាំងនឹងការត្រួតត្រារបស់ប្រទេសចិនក្នុងរាជវង្សថាំង(៦១៨-៩០៧ នៃ គ.ស.)។ នៅឆ្នាំ៧៥៣ នៃគ.ស. ចេនឡាដីគោកបានបញ្ជូនទូតទៅស្រុកចិនម្តងទៀត។ ចិនបានស្នើឱ្យចេនឡាដីគោកទៅបង្ក្រាបចលនាបះបោរនៅតំបន់**ណានឆាវ**។ នៅឆ្នាំ៧៧១ និងឆ្នាំ៧៧៩ នៃគ.ស. ចេនឡាដីគោក បានបញ្ជូនទូតទៅស្រុកចិនទៀត។ ព្រះរាជានៃរដ្ឋចេនឡាដីគោក ដែលមានមហិទ្ធិឫទ្ធិជាងគេគឺ «**ព្រះបាទជ័យសិង្ហវរ្ម័ន**» (សិលាចារឹកនៅនគររាជសីមា)។

ចំណែកចេនឡាទឹកលិចស្ថិតក្រោមអំណាចផ្វានោះ គឺមិនអាចរក្សាឯកភាពជាតិបានយូរអង្វែង ក៏បែកខ្ញែកជារដ្ឋបុរីតូចៗយ៉ាងតិចចំនួន៥ទៀត ដូចជា **សម្ភុបុរៈ អនិន្ទិត្យបុរៈ ពលាទិត្យបុរៈ សក្រានកាបុរៈ អាមូហបុរៈ** ... ហើយរាជធានីរបស់ចេនឡាទឹកលិចគឺស្ថិតនៅ **សម្ភុបុរៈ**(ក្រចេះ)។ ព្រះរាជាដែលគ្រងរាជ្យនៅចេនឡាទឹកលិច គឺ ព្រះបាទ**បុស្ករាក្ស** ដែលជាប់ញាតិវង្សនឹងព្រះបាទ**ហ៊ុនទៀន** ព្រះនាង**លីវយី**។ នៅសតវត្សទី៨ ចេនឡាទឹកលិចមានវិបត្តិផ្ទៃក្នុងរដ្ឋបុរីតូចៗដណ្តើមកាន់កាប់អំណាចកណ្តាលរៀងៗខ្លួន។ នៅសតវត្សទី៨ ពួក

ចោរសមុទ្រជ្វាបានចូលរាតត្បាតឆក់ប្លន់ទ្រព្យសម្បត្តិតាមឆ្នេរសមុទ្រនិងតាមដងទន្លេនៅតំបន់អាស៊ីអាគ្នេយ៍។ នេះបណ្តាលមកពីនៅកោះជ្វា មានរាជវង្ស **សៃលេន្រ្ទ** (Sailen) ខ្លាំងពូកែកសាងប្រាសាទ **បូរ៉ូប៊ូឌួរ** (Borobudur) ដ៏ល្បីល្បាញ និង**ពុទ្ធរូបតារា** (Tara) ដោយស្តេចជ្វា **ប៉ាណាម ការ៉ាណា** (Panamkarana)។[៣៨]

## ៩.២- ស្រ្តីខ្មែរសម័យអង្គរ

សម័យអង្គរត្រូវបានគេកំណត់យកចាប់ពីឆ្នាំ៨០២មក។ មូលហេតុដែលគេកំណត់យកឆ្នាំ៨០២នេះ ដោយសារតែព្រះបាទ**ជ័យវរ្ម័នទី២** បានវាយរំដោះប្រទេសពីជ្វានៅឆ្នាំ៨០២នេះ ហើយក៏ជាឆ្នាំដែលប្រទេសមួយនេះ ធ្វើពិធីទេវរាជលើកទីមួយក្នុងប្រវត្តិសាស្រ្តខ្មែរ ដើម្បីជាតំណាងឱ្យការរួចផុតពីការត្រួតត្រា និងជាការបង្រួបបង្រួមជាតិឡើងវិញ។

នៅឆ្នាំ៨៧៩ ព្រះបាទ **ឥន្រ្ទវរ្ម័ន** ទ្រង់បានកសាងប្រាសាទ**ព្រះគោ** ឬ **បាគោ** ដើម្បីឧទ្ទិសថ្វាយចំពោះបុព្វបុរសរបស់ព្រះអង្គ មានព្រះមាតា ព្រះបិតា ជីដូនជីតាខាងព្រះមាតា ព្រះបាទ**ជ័យវរ្ម័នទី២** និងអគ្គមហេសី។ ប្រាសាទនេះមានរាងជាប្រាង្គឥដ្ឋប្រាំមួយ តម្រៀបជាពីរជួរមុខក្រោយ ហើយស្ថិតនៅលើខឿនតែមួយ។ បុព្វបុរសទាំងនោះមានព្រះរាមជាទេវនាម ហើយមានរូបតំណាងជាសិវលិង្គចំពោះបុព្វបុរសប្រុស និងរូបទេវី ចំពោះបុព្វបុរសស្រី។[៣៩]

---

[៣៨] ក្រសួងអប់រំ *សិក្សាសង្គមថ្នាក់ទី១០* ទំព័រទី១៤១-១៤៣, បោះពុម្ពផ្សាយ ឆ្នាំ២០១៦។

[៣៩] ត្រឹង ងា *ប្រវត្តិសាស្រ្តខ្មែរ ភាគ១-២* គ.ស ១៩៧៣ ទំព័រ៨១-៨២។

ក្នុងរជ្ជកាលព្រះបាទ**ជ័យវរ្ម័នទី២** គេឃើញមានការកសាងប្រាសាទ**បាតជុំ** ដើម្បីឧទ្ទិសព្រះពុទ្ធ **ព្រះវជ្របាណិ**( ពោធិសត្វមួយអង្គ ក្នុងពុទ្ធសាសនាមហាយាន ) និងព្រះនាងប្រាជ្ញាបារមីតា ដែលកសាងដោយស្ថាបត្យករ **កវិន្ទ្រារីមថន** នៅគ.ស.៩៤៦។[៤០] ជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សខ្មែរក្នុងសង្គម តែងតែផ្សារភ្ជាប់ទៅនឹងរបាំប្រជាប្រិយ។ បើទោះបីជាមានការផ្លាស់ប្តូរជំនឿសាសនាក្នុងសង្គមខ្មែរពីព្រហ្មញ្ញសាសនាមកពុទ្ធសាសនាក៏ពិតមែន ក៏របាំក្បាច់ដែលជាប្រពៃណីដូនតានាសម័យមុនអង្គរ ត្រូវបានរក្សាទុកយ៉ាងខ្ជាប់ខ្ជួនបំផុតក្នុងព្រះបរមរាជវាំងអង្គរធំ និងតាមប្រាង្គប្រាសាទធំៗ។

វត្តមានរបស់ស្រីៗរាំ ឬស្រីទេពអប្សរ ដែលមានរូបឆោមល្អដូចស្រីសួគ៌ា ដែលបុព្វបុរសខ្មែរឆ្លាក់តាមប្រាសាទថ្ម ឬឥដ្ឋនានា ក្នុងចក្រភពអង្គរ ធ្វើឱ្យយើងយល់បានអំពីអ្វីដែលស្ត្រីបានធ្វើក្នុងសង្គមខ្មែរបុរាណ ដូចជាការដោះដូរតួនាទីរបស់ស្រីរបាំខ្មែរពីស្ថានភាពជាទេវទាសី ឬអ្នកបម្រើទេវតា ទៅជាពុទ្ធទាសី ឬអ្នកបម្រើព្រះពុទ្ធអង្គក្នុងព្រះវិហារទៅវិញ ហើយដែលយើងអាចកត់សម្គាល់តាមរយៈក្បាច់ចម្លាក់នៃប្រាសាទមួយចំនួនក្នុងសម័យនោះ ដែលស្ថាបនាឡើងដោយព្រះមហាក្សត្រខ្មែរកំពូលៗដូចជា ព្រះបាទ**សុរិយាវរ្ម័នទី២** និងព្រះបាទជាដើម។

តាមប្រភពនៃសិលាចារិកនៃប្រាសាទតាព្រហ្ម ដែលជាវិហារស្តេច (រាជវិហារ) សាងសង់ឡើងនៅឆ្នាំ១១៨៦ នៃគ.ស. ដើម្បីឧទ្ទិសចំពោះព្រះមាតា និងព្រះរាជគ្រូរបស់ព្រះអង្គឈ្មោះ**មង្គលាចំ**។ ចំនួនអ្នករបាំទាំងអស់មានដល់ទៅ

[៤០] -ដ- *ប្រវត្តិសាស្ត្រខ្មែរ ភាគ១-២* ទំព័រ៨៧។

៦១៥នាក់។ រីឯក្នុងប្រាសាទ**ព្រះខ័ន** ឬ **ជ័យស្រី** វិញ ដែលសាងសង់នៅឆ្នាំ ១១៩១ នៃគ.ស. ដើម្បីឧទ្ទិសចំពោះព្រះមាតាព្រះអង្គ អ្នករបាំសម្រាប់រាំថ្វាយក្នុងពិធីបុណ្យផ្សេងៗ ក្នុងប្រាសាទនេះមានចំនួន១០០នាក់។[៩១]

នៅលើផ្ទាំងចម្លាក់ គេឃើញមានការពិពណ៌នាអំពីការប្រកួតរវាងក្រុមយក្ខ និងក្រុមទេវតា ដើម្បីយកទឹកអម្រឹតផ្តល់ជីវិតអមតៈរបស់ទេវតា និងមនុស្សលោក។ នៅក្នុងសម័យបុព្វកាលនោះ ពោលគឺនៅពេលដែលលោកយើងនេះ ទើបតែត្រូវគេបង្កបង្កើតឡើងជាលើកដំបូងបង្អស់ គេឃើញវត្តមានព្រះវិស្ណុទ្រង់ឈរនៅចំកណ្តាលនៃពពួកទេវតានិងយក្ខ ដោយដៃឆ្វេងរបស់ព្រះអង្គកាន់សសរតំណាងភ្នំព្រះសុមេរុ ឬតំណាងសសរនៃលោកយើងនេះ។ ក្នុងចម្លាក់រឿងកូរសមុទ្រទឹកដោះ ក៏បានបង្ហាញផងដែរនូវវត្តមានស្រីទេពអប្សរនៅលើអាកាសកំពុងថ្វាយពរជ័យដល់ព្រះវិស្ណុ។ ចំណែកនៅក្នុងរឿងរាមកេរ្តិ៍ គឺក៏បានបង្ហាញពីការយាងចូលព្រៃរបស់ព្រះរាម និងនាងសីតា ដែលបានជួបប្រទះនូវរឿងរ៉ាវហេតុការណ៍ជាច្រើនចំពោះអ្នកទាំងពីរ។ ព្រះរាមនៅពេលដែលបានដឹងថា ព្រះនាងសីតាត្រូវយក្ខក្រុងរាពណ៍ចាប់យកទៅហើយ ព្រះអង្គក៏បានកៀងគរទ័ពរេពល ដើម្បីដណ្តើមយកនាងសីតាមកវិញ ទោះបីជាមានការប៉ះពាល់ដល់ប្រយោជន៍ទូទៅខ្លាំងក៏ដោយ។

**- ស្ត្រីផ្ទើមនិងតួនាទីដែលមានក្នុងសម័យអង្គរ**

. ព្រះនាង **ជ័យរាជទេវី** ជាអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ បានខិតខំតាំងសមាធិនៅពេលដែលព្រះអង្គចូលសមរភូមិធ្វើចម្បាំងជាមួយសត្រូវ។

[៩១] មីសែលត្រាណេ ***សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទ ជ័យវរ្ម័នទី៧*** គ.ស ២០០៣ ទំព័រ១០១-១០៣។

. ក្រោយពីព្រះនាង**ជ័យទេវី** ចូលទិវង្គតទៅ ព្រះនាង**ឥន្ទ្រទេវី** ដែលជាព្រះរាមរបស់ព្រះនាង ក៏បានរៀបអភិសេកធ្វើជាមហេសីរបស់ព្រះបាទ**ជ័យវរ្ម័ន ទី៧**ជាបន្ត។ ក្នុងរាជរបស់ព្រះអង្គ ព្រះនាងបានជំរុញឱ្យមហាក្សត្រងាកមករកព្រះពុទ្ធសាសនាមហាយាន តែមិនបោះបង់ចោលសាសនាព្រាហ្មណ៍ចោលទេ។ លើសពីនេះទៅទៀត ព្រះនាងបានបង្កើតឱ្យមានបណ្ណាល័យ និងមន្ទីរពេទ្យ មណ្ឌលបណ្តុះបណ្តាលស្ត្រី ព្រមទាំងមានស្នាព្រះហស្តនិពន្ធសិលាចារឹកដែលសរសើរពីស្នាដៃរបស់ព្រះបាទ**ជ័យវរ្ម័នទី៧** នៅប្រាសាទ**ភិមានអាកាស**។

អ្នកប្រវត្តិសាស្ត្រជាតិនិងអន្តរជាតិតែងលើកសរសើថា នៅក្នុងរាជរបស់ព្រះបាទ**ជ័យវរ្ម័នទី៧** ប្រទេសកម្ពុជាបានក្លាយជាប្រទេសដ៏រុងរឿងទាំងវិស័យសេដ្ឋកិច្ច យោធា នយោបាយ និងសង្គម។ លទ្ធផលដ៏ត្រចះត្រចង់ និងល្បីរន្ទឺឮពាសពេញសកលលោកនេះ ពិតជាមានចំណែកដ៏ធំធេងក្រៃលែងរបស់ព្រះអគ្គមហេសីទាំងពីរព្រះអង្គ ដែលល្បីល្បាញខាងមានចំណេះប្រាជ្ញាវាងវៃ មានចំណេះវិជ្ជាខ្ពង់ខ្ពស់ ជាសកលវិទ្យាធិការិនី ជាកវីនិពន្ធលើផ្ទាំងសិលាចារិកដែលមានមកដល់សព្វថ្ងៃ។ លើសពីនេះទៅទៀតនោះគឺថា ព្រះនាង**ឥន្ទ្រទេវី** បានទទួលនូវការគោរពកោតស្ញប់ស្ញែងពីសំណាក់ព្រះរាជាព្រះបាទ**ជ័យវរ្ម័នទី៧** អំពីសតិបញ្ញាដ៏វាងវៃរបស់ព្រះនាង ទើបព្រះអង្គប្រទានងារឱ្យព្រះនាងថាជា «***សាស្ត្រាចារ្យកំពូល*** »។ តាមសិលាចារឹកពេលនោះ គេនិយាយថា មហាក្សត្រីជា «***ទេពធីតាចំណេះវិជ្ជា***» ដោយសារព្រះនាងបានបង្រៀនដល់ស្ត្រីកំព្រាខ្មែរបីបួនរយនាក់ ដែលជា «***រាជាប្រិយ*** » គឺអ្នកសម្លាញ់របស់ព្រះមហាក្សត្រ។ ដូច្នេះគេអាចសន្និដ្ឋានថា ព្រះបាទ**ជ័យវរ្ម័នទី៧** ជាអ្នកកាន់ចង្កូត ចំណែកព្រះនាងទាំងពីរ គឺជាផែនទីបង្ហាញផ្លូវទៅរកភាពជោគជ័យរុងរឿង។ ម្យ៉ាងវិញទៀត ការ

កសាងប្រាសាទមិនត្រឹមតែសម្រាប់ឧទ្ទិសដល់សាសនា ការផ្លាស់ប្តូររាជធានី ការរីកចម្រើនសេដ្ឋកិច្ច និងបម្លាស់ប្តូររាជធានីនោះទេ តែក៏ដើម្បីឧទ្ទិសដល់បុព្វបុរសមានមាតាបិតាជាដើម ដូចជា ប្រាសាទបន្ទាយក្តី ប្រាសាទបាគង...។ល។

## ៩.៣- ស្ត្រីខ្មែរសម័យក្រោយអង្គរ

### ៩.៣.១- សម័យចតុមុខ (គ.ស.១៥២៥ - ១៥៩៣)

នៅឆ្នាំ១៤៣១ ព្រះបាទ**ពញាយ៉ាត** ទ្រង់បានលើករាជធានីពីអង្គរទៅតាំងនៅ**ទួលបាសាន** ក្នុងខេត្ត**ស្រីសឈរ**(កំពង់ចាម)វិញ។ តែដោយតំបន់នោះរងគ្រោះដោយទឹកជំនន់ ព្រះអង្គក៏បញ្ជាឱ្យលើករាជធានីពី**ទួលបាសាន្ត** ទៅតាំងនៅ**ចតុមុខ**វិញ។ ក្រោយពីការកសាងរាជធានីរួចរាល់ ព្រះរាជាទ្រង់តាំងប្រទាននាមឱ្យព្រះនគរថា៖ **ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរ បវរឥន្ទបត្តបុរីរដ្ឋរាជសីមា មហានគរ**។

នៅ គ.ស. ១៤៣១ ព្រះបាទបរមរាជា**ចៅពញាយ៉ាត** ទ្រង់បានលើករាជធានីទៅតាំងនៅទួលបាសាន្តក្នុងខែត្រស្រីសឈរវិញ តែគង់នៅទីនោះបានតែ១ឆ្នាំ(ក្បួនខ្លះថាដល់៩ឆ្នាំ) ដោយមានទឹកជំនន់ធំខុសធម្មតា ព្រះអង្គក៏បញ្ជាឱ្យលើករាជធានីពី**ទួលបាសាន្ត**ទៅតាំងនៅក្រុងភ្នំពេញវិញ នៅលើត្រើយខាងលិចនៃទន្លេប្រាបឈាម។ ព្រះអង្គទ្រង់ត្រាស់បង្គាប់ឱ្យសម្តេចចៅ**ពញាកែ** និង **ឧកញ៉ាហោរាធិបតីខៀវ** ព្រមដោយមន្ត្រីឯទៀតខ្លះផង ឱ្យទៅពិនិត្យមើលទីដីដែលស្ថិតនៅជិតៗភ្នំដូនពេញ។ លុះទៅធ្វើការពិនិត្យក្បួនតម្រាសព្វគ្រប់ហើយ មន្ត្រីទាំងនោះក៏ថ្វាយដំណឹងទៅព្រះរាជាវិញថាតំបន់ដែលស្ថិតនៅទិសអាគ្នេយ៍នៃភ្នំដូនពេញ មានជ័យភូមិល្អល្មមស្ថាបនារាជធានីបាន។ ព្រះអង្គក៏ទ្រង់ត្រាស់ឱ្យអស់ចៅហ្វាយស្រុកកែនរាស្ត្រ មកជួយកសាងព្រះរាជនិវេសន៍

ដោយលើកដីធ្វើកំពែង សង់ប្រាសាទ និងដំណាក់តូចធំក្នុងរយៈពេលដ៏ខ្លីបំផុត។ លុះកិច្ចការបានបំពេញចប់សព្វគ្រប់ហើយ ព្រះអង្គក៏បានយាងមកគង់នៅរាជវាំងភ្នំដូនពេញតាមផ្លូវទឹកដោយមាននាម៉ឺនសព្វមុខមន្ត្រីដង្ហែមកផង។ លុះយាងមកដល់ហើយ ព្រះអង្គក៏ទ្រង់ត្រាស់បង្គាប់ចៅ**ពញាតេជោ** ចៅហ្វាយស្រុកខែត្រសំរោងទង ឱ្យកែនរាស្ត្រលើកដីចាក់បំពេញតំបន់នៅជុំវិញវត្តភ្នំ និងក្នុងរាជវាំង។ ដូច្នេះតំបន់នោះក៏បានរាបស្មើល្អ រហូតដល់មាត់ទន្លេដែលអ្នកផងនិយមហៅកំពង់រាប ចាប់តាំងពីពេលនោះមក។ ឯទីដែលចៅ**ពញាតេជោ**ឱ្យរាស្ត្រជីកយកអាចម៍ដីនោះ ក៏ក្លាយទៅជាបឹងមួយធំជ្រៅទូលាយទើបបានគេឱ្យឈ្មោះហៅ **បឹងតេជោ** តរៀងមក គឺទីដីត្រង់ផ្សារថ្មីសព្វថ្ងៃ។ តមកទៀតព្រះរាជាទ្រង់ត្រាស់បង្គាប់ **ឧកញ៉ាវង្សាអនុជិតផ្លុង** ចៅហ្វាយស្រុកខែត្របាទីឱ្យជីកព្រែកបង្ហូរទឹកទន្លេចូលទៅក្នុងបារាយណ៍មួយ នៅក្នុងរាជធានីសម្រាប់យកទឹកប្រើប្រាស់ដល់ប្រជារាស្ត្រទាំងអស់គ្នា ព្រែកនោះគេហៅថា **ព្រែកឧកញ៉ាផ្លុង**។ បើតាមស្រាវជ្រាវទៅឃើញថា ពីដើមព្រែកនេះស្ថិតនៅតាមបណ្ដោយសួនច្បារនៅមុខស្ថានីយកណ្ដាលនៃអយស្ម័យយាន គឺស្របនឹង**វិថីឧកញ៉ាផ្លុង**សព្វថ្ងៃនេះឯង។ ដើម្បីជាកិច្ចការពារ ព្រះរាជាទ្រង់បញ្ជាឱ្យជីកគូ និងលើកដីកំពែង តាំងជាសើន ជាបន្ទាយព័ទ្ធជុំវិញរាជធានី។ ដូច្នេះនៅទិសខាងត្បូងគឺព្រែកតាកែវ ខាងលិចគឺព្រែកអូគរ ខាងជើងគឺព្រែកពោងពាយ ឬព្រែកចិនដំដែក ព្រោះនៅកន្លែងនោះមានជនជាតិចិនរកស៊ីរបរដំដែក។ ក្រៅពីមុខងារការពារក្រុង ព្រែកទាំងនោះនៅមានមុខងារសំខាន់ម្យ៉ាងទៀត គឺយកទឹកសម្រាប់ឱ្យរាស្ត្រធ្វើស្រែនៅទិសខាងលិច។ ពួកនាម៉ឺនសព្វមុខមន្ត្រី និងពួកប្រជារាស្ត្របានសង់គេហដ្ឋានរៀងៗខ្លួនក្នុងបរិវេណនៃរាជធានី។ លុះសម្រេច

ការកសាងហើយ ព្រះរាជាទ្រង់តាំងប្រទាននាមព្រះនគរថា **ក្រុងចតុមុខមង្គល សកលកម្ពុជាធិបតី សិរីធរ បវរ ឥន្ទបត្តបុរី រដ្ឋរាជ សីមា មហានគរ**។ ចំណែកឯ **ទន្លេប្រាបឈាម** ក៏ត្រូវបានប្រសិទ្ធិនាមថ្មីថា **ទន្លេចតុមុខ** វិញដែរ។ ក្រោយបន្តិចមក ព្រះរាជបុត្រច្បងព្រះនាម **នារាយណ៍រាជា** ទ្រង់បានតែងតាំងជាឧបរាជ ហើយយាងទៅគង់ក្នុងព្រះដំណាក់ នៅជ្រោយរលួស។ ឯព្រះរាជបុត្រទីពីរព្រះនាម**ស្រីរាជា** យាងទៅគង់នៅខាងលិច ត្រង់ដីទួលមួយកន្លែងដែលតមកគេហៅថា **ទួលព្រះស្រី** (មុំវត្តព្រះពុទ្ធមានបុណ្យសព្វថ្ងៃ)។ នៅគ្រានោះព្រះវិហារកសាងឡើងដោយដូនពេញក៏បានទ្រុឌទ្រោមខ្លះទៅតាមកាលវេលា។ ព្រះបរមរាជាចៅ**ពញាយ៉ាត**ទ្រង់បានកសាងវិហារនោះជាថ្មីឡើងវិញ ដោយពង្រីកនិងពូនភ្នំដីឱ្យកាន់តែខ្ពស់ជាងដើម ហើយទ្រង់ចាត់ឱ្យក្រាលថ្មនៅកំពូលខាងលើ និងកសាងចេតិយមួយយ៉ាងធំពីខាងក្រោយព្រះវិហារ។ រួចព្រះអង្គទ្រង់បញ្ជាឱ្យទៅយកព្រះពុទ្ធបដិមាលង្ហិនដែលសេសសល់នៅនគរវត្ត ព្រមទាំងរូបសិង្ហតោ មកតម្កល់និងតាំងនៅលើភ្នំនោះ។ ពិធីនេះត្រូវធ្វើអស់រយៈពេលបីថ្ងៃ គេយកព្រះពុទ្ធបដិមាដែលដូនពេញបានរកឃើញពីក្នុងដើមគគីរពីមុននោះទៅតម្កល់ក្នុងជាន់ខាងលើនៃចេតិយធំ ឯព្រះពុទ្ធបដិមាដែលយកពីនគរវត្ត ត្រូវបានតម្កល់នៅក្នុងជាន់ក្រោម។ វត្តភ្នំដូនពេញត្រូវប្រសិទ្ធិនាមថ្មីថា **វត្តព្រះចេតិយបព៌ត** វិញ។ ក្រៅពីនេះ ព្រះរាជាទ្រង់បានចាត់ឱ្យកសាងវត្តអារាមនៅច្រើនកន្លែងក្នុងរាជធានីថែមទៀត ដូចជា វត្តពីរនៅខាងកើតវត្តភ្នំគឺ **វត្តធម្មលង្កា** និង **វត្តកោះ** វត្តមួយនៅខាងត្បូងអូរចិនដំដែកគឺ **វត្តព្រះពុទ្ធឃោសា** (សព្វថ្ងៃហៅ **វត្តព្រះពុទ្ធឃោសារាម ឬ វត្តចិនដំដែក** និងនៅជាប់នឹងវត្ត**ពិភទ្ធរង្សី** មានវិថី**ឧកញ៉ាអ៊ុំ** ខណ្ឌកណ្ដាល។ នៅខាងមុខព្រះវិហារវត្តនេះ សព្វថ្ងៃគេ

ឃើញមានរូបទ្វារបាលពីរនាក់ជារូបចិនដែលគេអាចមើលស្គាល់យ៉ាងងាយ ដោយសារលក្ខណៈមុខមាត់ និងសម្លៀកបំពាក់ ក៏ដូចជាគ្រឿងអាវុធ។ វត្តមួយនៅត្រង់មាត់ទន្លេក្បែរពាមព្រែកឧកញ៉ា ផ្លុងគឺ **វត្តពាមផ្លុង** វត្តមួយនៅត្រង់ចេតិយធំ គឺ**វត្តឧណ្ណាលោម** និងវត្តមួយទៀតហៅ **វត្តខ្លបតាយ៉ង**។ គួរគប្បីកត់សម្គាល់ថា វត្តចុងក្រោយនេះ សព្វថ្ងៃស្ថិតនៅត្រង់**វត្តបទុមវតី**។ បើតាមអក្សរចារឹកតម្កល់នៅទីនោះ ព្រះបាទបរមរាជាចៅ**ពញាយ៉ាត**បានសាងវត្តនេះនៅ គ.ស.១៤៤២ លើទីមួយមានទំហំ ២០២ម X ២៦០ម។ វត្តនេះគេហៅថា **វត្តខ្លបតាយ៉ង** ព្រោះនៅខាងត្បូងមានខ្លបរបស់**តាយ៉ង**។ ព្រះវិហារវត្តនេះ ត្រូវបានកសាងថ្មីពីរលើកទៀត៖ លើកទី១ នៅគ.ស.១៨៦៥ ក្នុងរជ្ជកាលព្រះបាទសម្តេច**នរោត្តម** លើកទី២ នៅគ.ស.១៩៣៧ ក្នុងរជ្ជកាលរបស់**ព្រះស៊ីសុវត្ថិមុនីវង្ស**។ គួរគប្បីជ្រាបម្យ៉ាងទៀតថា **វត្តឧណ្ណាលោម**នៅរក្សាឈ្មោះដដែលតាំងពីពេលកសាងរហូតមកដល់សព្វថ្ងៃ ហើយឈ្មោះនេះត្រូវបានប្រសិទ្ធឡើងដោយយកតាមឈ្មោះចេតិយដែលគេបញ្ចុះ**ព្រះឧណ្ណាលោម**។ នៅខាងមុខវត្តនេះ គឺនៅជិតមាត់ទន្លេ ព្រះរាជាទ្រង់ឱ្យសាង**ឃ្លាំងមឿង**មួយ(អ្នកតាចាំស្រុក) ឈ្មោះ**អ្នកតាប្រាជ្ញ**។[៤២]

តាមរាជពង្សាវតារខ្លះបាននិទានពីប្រវត្តិនៃក្រុងភ្នំពេញដោយមានសេចក្តីសម្រួលដូចតទៅ៖ ក្នុងកាលដែលកន្លងយូរទៅហើយ មានស្ត្រីមេម៉ាយម្នាក់ជាអ្នកមានទ្រព្យស្តុកស្តម្ភ ដែលអ្នកផងហៅថា **ដូនពេញ**។ ផ្ទះគាត់តាំងនៅលើទួលខ្ពស់មួយនៅលើត្រើយខាងលិចនៃ**ទន្លេប្រាបឈាម** (**ទន្លេចតុមុខ**

[៤២] ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ទំ.១៣០-១៣២។

សព្វថ្ងៃ)។ នាសម័យថ្ងៃមួយ ក្នុងរដូវវស្សាមានទឹកជំនន់នៅប្រទេសលាវយ៉ាងធំ បណ្តាលឱ្យបោកច្រាំងរលំដើមគគីរជាច្រើន ហើយអណ្តែតបណ្តោយទឹកតាម**ទន្លេមេគង្គ**រហូតមកដល់**ទន្លេប្រាបឈាម**។ ក្នុងចំណោមនោះ មានដើមគគីរធំមួយ បានអណ្តែតមកទើរនៅត្រង់មាត់កំពង់របស់ដូនពេញ។ គាត់ក៏បានបបួលញាតិមិត្តជិតខាងជិះទូកទៅចងដើមគគីរនោះ ហើយនាំយកមកលើគោក។ កាលបើអ្នកទាំងនោះរើសំរាមនៅគល់គគីរ ស្រាប់តែឃើញព្រះពុទ្ធរូបបួនព្រះអង្គ និងរូបបដិមាថ្ម មានលក្ខណៈជាព្រាហ្មណ៍ នៅក្នុងប្រហោងឈើនោះ។ ពួកអ្នកស្រុកបានដង្ហែរូបបដិមាទាំងនោះយកទៅតម្កល់ទុកនៅផ្ទះដូនពេញ ហើយគាត់បានឱ្យគេជញ្ជូនដីពូនដំបូកធំខាងលៀសានផ្ទះ និងឱ្យគេយកឈើគគីរនោះសង់ព្រះវិហារតូចមួយនៅលើកំពូលភ្នំនោះ ហើយបានយកព្រះពុទ្ធរូបទៅតម្កល់នៅក្នុងព្រះវិហារនោះនៅក្នុងឆ្នាំជូត ឆស័ក ព.ស.១៩១៦ គ.ស. ១៣៧២។ តមកទៀតដូនពេញបានឱ្យគេសង់ខ្ទមមួយខាងទិសលៀសានព្រះវិហារ រួចយកបដិមាថ្មទៅតម្កល់ទុកនៅទីនោះ ហើយបានសន្មតថា**អ្នកតាព្រះចៅ** តរៀងមក (សព្វថ្ងៃហៅថា **លោកតាព្រះចៅ**)។ ពិធីបុណ្យសម្ពោធក៏ត្រូវបានប្រារព្ធធ្វើឡើង ដើម្បីសម្ពោធពុទ្ធសេនាសនៈយ៉ាងអធិកអធម។ ដោយអាស្រ័យហេតុនេះ ភ្នំនោះក៏មានឈ្មោះហៅថា **ភ្នំដូនពេញ** ហើយដែលយូរៗទៅក្លាយនៅត្រឹមតែ **ភ្នំពេញ** ដូចយើងហៅសព្វថ្ងៃនេះ។ គួរគប្បីបញ្ជាក់ថា ចំពោះរូបបដិមាដែល**ដូនពេញ**បានរកឃើញក្នុងរន្ធដើមគគីរនោះ រាជពង្សាវតារ និងអត្ថបទចម្លងតៗមកទៀត និយាយមិនស្របគ្នា ខ្លះថាមានព្រះពុទ្ធបដិមា៤អង្គធ្វើពីលង្ហិន និងបដិមាថ្មកាន់ស័ង្ខនិងគទា(ព្រះនារាយណ៍?) ខ្លះថាមានព្រះពុទ្ធរូបពីរព្រះអង្គមានព្រះភ័ក្ត្រឈមជា៤ទិស ខ្លះទៀតថាមានព្រះពុទ្ធរូប

សំរិទ្ធមួយព្រះអង្គមានព្រះភ័ក្ត្រ៤ តាំងសមាធិនិងរូបសិលា១ដៃកាន់ស័ង្ខមានផ្នូងសក់ ដូចជាព្រាហ្មណ៍។ តែបើតាមរូបតំណាងដែលមានតម្កល់ក្នុងព្រះវិហារវត្តភ្នំ(ភ្នំដូនពេញ) សព្វថ្ងៃគឺជាព្រះពុទ្ធរូបប្រក់នាគ៤អង្គគង់លើបុស្បុកទល់ព្រះប្រឹស្ឋ(ខ្នង) នឹងគ្នា។[៤៣]

ដូច្នេះតាមរយៈរឿងព្រេងដែលទាក់ទងនឹងដូនពេញ ដែលជាប្រវត្តិឈ្មោះទីក្រុងភ្នំពេញនេះ គឺបានបង្ហាញពីតួនាទីស្ត្រី ក្នុងការចូលរួមចំណែកក្នុងការកសាងសង្គមជាតិ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ប្រាជ្ញាស្មារតីប្រកបដោយភាពឈ្លាសវៃ និងមានបន្សល់កេរ្តិ៍ឈ្មោះរហូតមកដល់សព្វថ្ងៃសក្តិសមជាគំរូសម្រាប់ស្ត្រីគ្រប់ៗជំនាន់ផងដែរ។

### ៩.៣.២- សម័យលង្វែក(គ.ស. ១៤៣១-១៦១៨)

សម័យលង្វែកគឺជាសម័យក្រោយពីរជ្ជកាលព្រះបាទ**ពញាយ៉ាត** ហើយប្រទេសកម្ពុជាកើតមានចម្បាំងជាច្រើនលើកច្រើនសា។ រាជធានីត្រូវបានផ្លាស់ប្តូរជាច្រើនកន្លែង វិលចុះវិលឡើងពី**ក្រុងអង្គរ ទួលបាសាន្ត**(កំពង់ចាម) **ភ្នំពេញ**(ចតុមុខ) **លង្វែក**(កំពង់ឆ្នាំង)។ ក្នុងរាជ្យ**ព្រះអង្គចន្ទទី១** រាជធានីតាំងនៅ**ក្រុងមានជ័យ** ខេត្ត**ពោធិ៍សាត់** រួចប្តូរមក**ក្រុងលង្វែក**វិញ។ ព្រះបាទ**ចន្ទរាជា** ឬព្រះ**អង្គចន្ទទី១** ជាអនុជពៅរបស់ព្រះបាទ**ស្រីសុគន្ធបទ** ពេលដែល**ស្តេចកន**ធ្វើគត**ស្រីសុគន្ធបទ**នៅបន្ទាយ**ស្ទឹងសែន** នៅឆ្នាំ១៥១២ **ពញាចន្ទ**នៅក្រុង**អយុធ្យា**នៅឡើយ។ ក្នុងពេលធ្វើសង្គ្រាមជាមួយ**ស្តេចកន** មន្ត្រី និងរាស្ត្របាន

---

[៤៣] ត្រឹង ងា *ប្រវត្តិសាស្ត្រខ្មែរ* ទំ.១២៩-១៣០។

សុំឱ្យព្រះអង្គចន្ទឡើងសោយរាជ្យ ទ្រង់ក៏យល់ព្រម។ ទ្រង់ជាស្តេចមួយអង្គដ៏ល្បីល្បាញដែលបានរំដោះដីខ្មែរភាគខាងលិចពីសៀម។ ទ្រង់ជាស្ថាបនិកដែលកសាងរាជធានីលង្វែក ដោយត្រូវបានកសាងឡើងរយៈពេល៣ឆ្នាំ គឺពីឆ្នាំ១៥២៧ ដល់១៥២៩ ក្នុងរាជព្រះបាទចន្ទរាជា។ បន្ទាយនេះមានបរិមាត្រ (៣ គ.ម × ២ គ.ម) ដែលមានរបងបីជាន់គឺ៖ របងដី(ការពារទឹកចូលរាជធានី) របងទឹក(សម្រាប់យកទឹកប្រើប្រាស់ក្នុងរាជធានី) និងរបងឫស្សី(មានកម្រាស់២សិន ស្មើនឹង៨០ម៉ែត្រ ដែលក្រាស់ខ្មឹកសម្រាប់ការពារខ្មាំងសត្រូវ) និងមានកំពែង៥ជាន់ គឺក្នុងកំពែងជាន់ទី១ ដាក់សុទ្ធតែទាហានកាំភ្លើងធំ ហើយនៅមុខកំពែងនេះ មានរោងដំរី និងរោងសេះ។ កំពែងទី២ ដាក់ទាហានកាំភ្លើងវែង សាលាជំនុំ សាលាដំបូង និងសាលាឧទ្ធរណ៍។ កំពែងទី៣ដាក់ទាហានអាវុធខ្លីមានដាក់ផ្គាក់ កាំបិត។ កំពែងទី៤ ដាក់ទាហានរក្សាព្រះអង្គ រោងល្ខោន និងព្រះពន្លាទតល្ខោន។ ចំណែកកំពែងទី៥ មានរោងបញ្ញក្សេត្រ និងដំណាក់សំរឹទ្ធ វិមានកម្សាន្ត រោងភិរម្យ ក្រុមបាគូ បុរោហិត និងក្រុមមហាតលិកនៅ។ ក្នុងកំពែងនេះដែរ មានរាជវាំងកំពូលប្រាំបិទមាស និងលាបម្រ័ក្សណ៍សម្រាប់ព្រះមហាក្សត្រាធិរាជផ្ទុំ ហើយមានតម្កល់វត្ថុស័ក្តិសិទ្ធិគឺ **ព្រះកែវ** ឬ**ព្រះត្រឡែងកែង** និង**ព្រះគោ**ចំនួន១២ ដែលនៅក្នុងពោះព្រះគោទាំងនោះមានរក្សានូវគម្ពីរក្បួនសាស្ត្រាដ៏មានតម្លៃលើសលប់។ តាមជំនឿរបស់ខ្មែរ **ព្រះគោ** និង**ព្រះកែវ** ជាបងប្អូនបង្កើតនឹងគ្នាដែលអ្នកស្រុកតែងតែគោរពបូជាទុកជាវត្ថុស័ក្តិសិទ្ធិ។ ដោយសារនៅក្នុងបន្ទាយលង្វែកមានរូប **ព្រះគោ ព្រះកែវ** ប្រជាជនសម័យនោះមានជំនឿថា នេះជាបន្ទាយមួយយ៉ាងមាំសម្រាប់ការពារសត្រូវផង និងឃ្លាំងវប្បធម៌ជាតិផងបន្ទាប់ពីសម័យអង្គរ។

ទីតាំងភូមិសាស្ត្ររាជធានីលង្វែក ជាទីតាំងប្រវត្តសាស្ត្រខ្មែរមួយដែលសព្វថ្ងៃស្ថិតនៅក្នុងស្រុក**កំពង់ត្រឡាច** ខេត្ត**កំពង់ឆ្នាំង** ជាកន្លែងយុទ្ធសាស្ត្រមួយដោយមានទន្លេ បឹង ជាពិសេសព្រៃក។ បន្ទាយលង្វែកត្រូវបានកសាងឡើងនៅក្នុងរាជធានី ដោយជីកបុកគ្រឹះរៀបថ្ម៦ហត្ថជុំវិញបន្ទាយជាបីជ្រុង ហើយលើកដីច្រុះក្ដារធ្វើបន្ទាយកម្ពស់១៤ហត្ថ កម្រាស់ខ្នងលើ១០ហត្ថ ជើងទេរខាងក្រោម២២ហត្ថ(១ហត្ថ=កន្លះម៉ែត្រ)។ **ព្រះចន្ទរាជា**បញ្ជាឱ្យមន្ត្រីឧកញ៉ាសេនាបតីកេណ្ឌរាស្ត្រកាប់ឈើ ជញ្ជូនថ្ម រែកដី ដើម្បីសង់បន្ទាយ និងរាជវាំង។ នៅកណ្ដាលរាជធានីលង្វែក **ព្រះបាទចន្ទរាជា**បានសាងវត្តមួយឈ្មោះ**វត្តត្រឡែងកែង** ដែលនៅសល់រហូតមកដល់សព្វថ្ងៃ។ ក្រៅពីបន្ទាយលង្វែកទ្រង់បានកសាងវត្តអារាមជាច្រើននៅខែត្រពោធិ៍សាត់ បរិបូណ៌ ជួសជុលវត្តនៅឧដុង្គមានវត្តលើភ្នំរាជទ្រព្យជាដើម(ព្រះពុទ្ធរូបចូលព្រះនិព្វាន) វត្តត្រឡែងកែងនៅក្នុងបន្ទាយលង្វែក ដែលស្ថិតនៅលើទួលមួយកន្លែង មានរាងជាជើងក្អែក ក្នុងវិហារនេះតម្កល់ព្រះពុទ្ធរូបត្រឡែងកែង គឺព្រះពុទ្ធរូបបួនអង្គគង់ឈរទល់ព្រះខ្នងនឹងគ្នា ហើយបែរព្រះភក្ត្រទៅទិសទាំងបួន និងបានកសាងបដិមាត្រឡែងកែងរូបព្រះគោ។ ទ្រង់បានប្រមូលអ្នកប្រាជ្ញ បណ្ឌិត កវីឱ្យចងក្រង និងសរសេរគម្ពីរក្បួនច្បាប់គ្រប់ប្រភេទសម្រាប់កូនខ្មែរជំនាន់ក្រោយ។ តែគួរឱ្យស្ដាយ នៅឆ្នាំ១៥៦៦ ទ្រង់ក៏សោយទិវង្គត ហើយអដ្ឋិធាតុរបស់ទ្រង់ត្រូវបានតម្កល់ទុកលើភ្នំព្រះរាជទ្រព្យ។

បន្ទាយលង្វែកត្រូវបានបែកបាក់នៅឆ្នាំ១៥៩៣ ដោយហេតុ**ព្រះបាទសត្ថាទី១** ដែលជាចៅរបស់**ព្រះចន្ទរាជា**(អង្គចន្ទ) បានផ្ទេររាជសម្បត្តិឱ្យបុត្រាច្បង គឺព្រះបាទ**ជ័យជេដ្ឋាទី១** ដែលទើបមានព្រះជន្ម១១វស្សា និងដកតួនាទី

ឧបរាជពីអនុជរបស់ទ្រង់គឺ**ព្រះស្រីសុរិយោទ័យ** ឱ្យបុត្រាទី២ ដែលទើបមានព្រះជន្ម៦វស្សា។ បញ្ហានេះធ្វើឱ្យប្រជារាស្ត្រលែងគាំទ្រ និងបះបោរគ្រប់ទីកន្លែង។ ឮដំណឹងនេះ សៀមបានលើកទ័ពមកវាយខ្មែរ តែមិនបានសម្រេច។ ក្រោយមកសៀមបានប្រើល្បិចបាចប្រាក់ឌួងចូលក្នុងព្រៃឫស្សី ឱ្យប្រជារាស្ត្រខ្មែរកាប់ឆ្ការ ទីបំផុតសៀមក៏វាយកម្ទេចបន្ទាយលង្វែកបាននៅឆ្នាំ១៥៩៣។

បើនិយាយពីតួនាទីរបស់ស្ត្រីខ្មែរសម័យលង្វែកវិញ យើងមិនមានឯកសារណាយកមកសិក្សាបានក្រៅពីអត្ថបទអក្សរសិល្ប៍រឿងទុំទាវនោះទេ ដ្បិតរឿងនេះបានបកស្រាយពីតថភាពសង្គមនាសម័យលង្វែក ហើយអក្សរសិល្ប៍ជាកញ្ចក់ឆ្លុះបញ្ចាំងពីសង្គម។

តាមរយៈរឿង**ទុំទាវ** ដែលបានតាក់តែងឡើងដោយ***ព្រះភិក្ខុបទុមត្ថេរសោម*** ជាអត្ថបទពាក្យកាព្យ បានបង្ហាញពីសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករ ដែលស្តែងឡើងតាមរយៈសកម្មភាពរបស់តួអង្គទុំនិងទាវ ដែលចង់បង្ហាញដល់អ្នកសិក្សាទាំងឡាយ ជាពិសេសបណ្តាសាធារណៈជនទូទៅឱ្យឃើញពីការគោរពប្រពៃណី( ពិធីចូលម្លប់និងអាពាហ៍ពិពាហ៍ ) បើទោះបីជាក្រោយមកនាងទាវបានប្រព្រឹត្តខុសឆ្គងគន្លងប្រពៃណី( ទុំមុនស្រគាល ) ក៏ពិតមែន តែនាងក៏បានបញ្ជាក់ពីទឹកចិត្តភក្តីស្នេហ៍ដ៏ប្តូរផ្តាច់ចំពោះទុំជាស្វាមី។ មានន័យថា នាងទាវហ៊ានជំទាស់នឹងម្តាយរបស់ខ្លួនដែលបង្ខំខ្លួនឱ្យរៀបការជាមួយមនុស្សដែលខ្លួនមិនស្រឡាញ់។ ម្យ៉ាងវិញទៀតតាមរយៈតួអង្គនាងទាវនេះផងដែរ ក៏ចង់បង្ហាញឱ្យឃើញថា នាងជាមនុស្សដែលមិនឈ្លក់វង្វេងនឹងទ្រព្យសម្បត្តិ មាស ប្រាក់ ប្រាស់ចាកនឹងពាក្យសត្យ( សច្ចធម៌ ) និងឱ្យតម្លៃលើសុភមង្គលនៃជីវិត។ ជាក់ស្តែងនៅពេលម្តាយនាងទាវនាំនាងទៅថ្វាយព្រះរាជា

(ព្រះបាទរាមាជើងព្រៃ) ហើយនៅពេលដែលព្រះរាជាបានជ្រាបអំពីរឿងនេះ ទ្រង់ក៏ត្រាស់សួរនាងទាវ ដើម្បីឱ្យនាងបញ្ជាក់ពីការពិតនៃរឿងនេះ។ នាងបានឆ្លើយប្រាប់ការពិតអំពីទំនាក់ទំនងរបស់នាងនិងទុំ ដោយពុំខ្លាចអំណាចចេស្តារបស់ព្រះមហាក្សត្រ ឬក៏មានចិត្តលោភលន់ចង់បានអំណាច បុណ្យសក្តិ មាសប្រាក់ ទ្រព្យសម្បត្តិ ដោយមិនបំភ្លៃឱ្យខុសពីការពិតឡើយ ហើយនៅពេលដែលទុំបង្គាប់ឱ្យនាងចាក់ស្រាដាក់លើបាតដៃដើម្បីក្រេបផឹករួមគ្នា នាងក៏ធ្វើតាមដោយពុំប្រកែកឡើយ និងពុំកោតខ្លាចឬក្រែងរអារនឹងម្តាយរបស់ខ្លួន ក៏ដូចជាអំណាចរបស់អរជូនដែលជាស្តេចត្រាញ់នៅខេត្តត្បូងឃ្មុំអ្វីឡើយ។

បើយើងធ្វើការសិក្សាវិភាគឱ្យបានដិតដល់ទៅឃើញថា ស្ត្រីវ័យក្មេងដូចជានាងទាវគឺសឹងតែបាត់បង់នូវសិទ្ធិជាមូលដ្ឋានរបស់គេ ប៉ុន្តែគេក៏សង្កេតឃើញផងដែរថា នាងទាវនៅតែខិតខំរក្សាសិទ្ធិរបស់នាងយ៉ាងម៉ឺងម៉ាត់ នាងសុខចិត្តបោះបង់ព្រះរាជាចោលហើយរត់មករកទុំវិញ។ នៅពេលដែលទាវត្រូវម្តាយនាងផ្តាច់នាងចេញពីទុំឱ្យទៅរៀបការជាមួយម៉ឺនងួនវិញ នាងទាវក៏បានសម្រេចចិត្តខ្លួនឯងមិនធ្វើតាមបង្គាប់របស់ម្តាយនាង គឺហាក់បីដូចជាទុំគ្មានបានជួយគិតគូរអ្វីបន្តិចមកលើរូបនាងនោះទេ។ ជាការពិតហើយដែលថា ទាវស្ថិតនៅក្នុងការគាបសង្កត់របស់ម្តាយនាង ប៉ុន្តែការសម្រេចផ្សេងៗគឺស្ថិតនៅលើនាង។ ពេលដែលនាងកំពុងរៀបការជាមួយម៉ឺនងួន នៅពេលដែលទុំមកដល់ ទុំគ្មានសិទ្ធិសម្រេចអ្វីទាំងអស់ បើទោះបីគេមានព្រះរាជសង្ហាររបស់ព្រះរាជាក្តី គឺទុំទាល់ប្រាជ្ញ ទុំគ្មានជម្រើសអ្វីទៀតក្រៅពីផឹកស្រាស្រវឹងដើម្បីសាសងទុក្ខព្រួយរបស់គេនោះទេ។ ដូច្នេះឃើញថានាងទាវពិតជាអ្នកសម្រេចជោគវាសនារបស់នាងពោលគឺនាងបានប្រកាន់ឥរិយាបថជាអ្នកសម្រេចនេះតាំងពីពេលនាងបានជួប

នឹងទុំនៅពេលលើកដំបូងមកម៉្លេះ ដូចជានាងបានសម្រេចចិត្តឱ្យម្ដាយទៅនិមន្ត ទុំនិងពេជ្រមកទេសនានិងស្វូតនៅផ្ទះរបស់នាងតែម្ដង ហើយដូចគ្នានេះដែរ ម្ដាយរបស់នាងទាវក៏មិនរវល់ខ្វល់នឹងបទបញ្ជារបស់ព្រះរាជាដែរ ជាពិសេសគឺមិនខ្វល់ពីព្រះរាជាដែលបានសព្វព្រះរាជហទ័យរៀបការទាវជាមួយទុំនោះទេ។ ឥរិយាបទនេះបញ្ជាក់ថា ម្ដាយរបស់នាងទាវបានប្រើសិទ្ធិយ៉ាងធំធេងរបស់ខ្លួនជាម្ដាយ ទោះបីព្រះរាជាក៏មិនញញើតដែរ ប៉ុន្តែព្រះរាជាក៏បានប្រយុទ្ធតស៊ូរក្សាអំណាចរបស់ព្រះអង្គជាព្រះរាជាដែរ គឺការដាក់ទណ្ឌកម្មយ៉ាងស្ដែងអស្ចារ្យដល់ជនណាដែលហ៊ានប្រមាថដល់ចេស្ដាររបស់ព្រះអង្គ។

ដោយឆ្លងតាមរយៈការធ្វើការសិក្សាទៅលើស្នាដៃអត្ថបទអក្សរសិល្ប៍ យើងសង្កេតឃើញថា តម្លៃស្ត្រីខ្មែរតាមរយៈតួអង្គនាងទាវនេះ គឺនាងជាមនុស្សម្នាក់ដែលមានរូបឆោមស្អាតជាច់គេអស់ទាំងស្រីក្នុងនគរ រហូតដល់ស្ដេចពេញចិត្តជ្រើសយកទៅធ្វើជាស្នំទៀតផង។ នាងទាវគឺជាមនុស្សដែលមានសុជីវធម៌ល្អ នាងជាមនុស្សដែលមានភាពរាក់ទាក់ មិនចេះឆ្មើងឆ្មៃ ទៅណាមកណា គឺគេតែងតែមានគេស្រលាញ់រាប់អានច្រើន ជាពិសេស ចេះគោរពចាស់ទុំ ចាស់ព្រឹទ្ធាចារ្យ ចេះស្ដាប់បង្គាប់ឪពុកម្ដាយនិងចេះគោរពឪពុកម្ដាយខ្លួនឯងណាស់។ នាងគឺជាមនុស្សដែលបានសិក្សារៀនសូត្រផ្នែកស្ត្រីធ្វើជាមេផ្ទះ រៀនចេះនូវច្បាប់ប្រុស ច្បាប់ស្រី និងបានរៀននៅមុខវិជ្ជាដទៃៗច្រើនទៀតដែរ។ នាងទាវពិតជាបានបំពេញនូវកតញ្ញូតាធម៌ចំពោះមាតាយ៉ាងពិតប្រាកដមែន។ បើទោះបីជាការបំពេញនោះវាមិនបានល្អនិងត្រូវទាំងស្រុងក៏ដោយ តែនាងគឺបានប្រឹងប្រែងអស់ពីលទ្ធភាពដែលខ្លួនឯងមានហើយ។ ជាក់ស្ដែងនាងទាវ បើទោះជាពេលខ្លះនាងបានប្រឆាំងតតបនឹងម្ដាយខ្លួនក៏ពិតមែន តែពេលខ្លះនាង

ក៏បានបំពេញតាមតម្រូវការរបស់ម្ដាយនាងផងដែរ ដូចជានាងបានបង្ខំចិត្តយល់ព្រមទៅធ្វើជាស្នំនៅឯរាជវាំងទៀត និងយល់ព្រមរៀបការជាមួយម៉ឺនងួនទាំងដែលខ្លួនមិនបានស្រឡាញ់ពេញចិត្តសូម្បីតែបន្តិច ជាការបំពេញនូវកាតព្វកិច្ចជាកូនកតញ្ញូចំពោះម្ដាយខ្លួន ឱ្យសមតាមបំណងគាត់ដែរ។ នាងទាវជានារីដែលមនុស្សស្រីរាល់គ្នាគួរតែយកគំរូតាម ក្រៅពីការទុំមុនស្រគៀលព្រោះនាងមានភក្ដីភាពណាស់ចំពោះរឿងស្នេហា ពោលគឺនាងមានស្នេហ៍សច្ចៈស្នេហ៍មួយនិងមួយ ទោះស្លាប់ក៏មិនប្រែចិត្តពោល គឺនាងទាវមានស្នេហ៍ស្មោះនឹងទុំ បើទោះបីទុំជាមនុស្សមិនមានទ្រព្យសម្បត្តិច្រើន មិនមានយសសក្ដិឬអំណាចក៏ដោយ ក៏នាងនៅតែស្រឡាញ់ប្តូរផ្តាច់នឹងស្នេហាដែរ។ ជាក់ស្តែងនៅពេលដែលម៉ឺនងួនសុំនាងរៀបការ ក៏នាងមិនបានបោះបង់ទុំឡើយ រហូតដល់ទុំត្រូវគេយកទៅសម្លាប់ ទាវស្រីក៏បានចាក់សម្លាប់ខ្លួនទៅតាមទុំដែរ ដើម្បីបញ្ជាក់ពីភក្ដីភាពស្នេហ៍ចំពោះទុំ។

ដូច្នេះជាសរុបសេចក្តី ស្ត្រីសម័យលង្វែកដែលឆ្លុះបញ្ចាំងតាមរយៈរឿងទុំទាវ គឺបានប្រើប្រាស់សិទ្ធិសេរីភាពរបស់ខ្លួនតាមតួនាទីរៀងៗខ្លួន គឺទាវបានប្រើប្រាស់សិទ្ធិផ្ទាល់ខ្លួនក្នុងតួនាទីជាកូនដែលឪពុកម្ដាយមិនអាចបង្ខំនាងបានក្នុងការរើសគូស្រករ សិទ្ធិជាពលរដ្ឋហ៊ានបង្ហាញការពិតដល់មហាក្សត្រដោយមិនខ្លាចព្រះចេស្ដា សិទ្ធិជាភរិយាក្នុងការរក្សាភាពស្មោះត្រង់ភក្តីភាពចំពោះទុំជាដើម។ ចំណែកម្ដាយទាវក៏បានប្រើប្រាស់សិទ្ធិរបស់ខ្លួនជាម្ដាយក្នុងការបង្ខំទាវឱ្យបំពេញតាមបំណងរបស់ខ្លួន និងសិទ្ធិក្នុងការប្រឆាំងនឹងបំណងរបស់ស្ដេចផងដែរ។

## **៩.៣.៣- សម័យឧដុង្គ(គ.ស.១៦២០-១៨៦៣)**

សម័យឧដុង្គជាសម័យដែលពោរពេញដោយព្រឹត្តិការណ៍ដ៏ជូរចត់បំផុតនៃប្រវត្តិសាស្ត្រខ្មែរ។ ក្នុងរយៈពេលជាង២៤០ឆ្នាំនេះ សត្រូវរបស់ខ្មែរគឺសៀម និងយួនដែលពួកគេពុំបានអនុញ្ញាតឱ្យប្រជារាស្ត្រខ្មែររស់នៅដោយសេចក្ដីសុខចម្រើនក្នុងវិស័យកសាងជាតិ និងកសាងសមិទ្ធផលសំខាន់ៗសម្រាប់វឌ្ឍនភាពរបស់ខ្លួននោះឡើយ។

ចំពោះវិស័យអក្សរសាស្ត្រវិញ ក៏យើងពុំសូវឃើញមានសកម្មភាពឡើយ ទើបតែនៅចុងសម័យឧដុង្គ គឺក្នុងរជ្ជកាលរបស់ព្រះបាទអង្គឌួង(គ.ស.១៨៤១-១៨៦០) វិស័យអក្សរសាស្ត្រចាប់ផ្ដើមរីកចម្រើនឡើងគួរឱ្យកត់សម្គាល់ រហូតត្រូវបានគេចាត់ទុកសម័យនោះថាជាសម័យយុគមាសនៃអក្សរសាស្ត្រខ្មែរ។ ដោយសារព្រះបញ្ញាញាណ និងការយកចិត្តទុកដាក់ដល់វិស័យអក្សរសាស្ត្ររបស់**ព្រះអង្គឌួង** ទើបពេលនោះក្បួនខ្នាត រឿងរ៉ាវផ្សេងៗព្រមទាំងអ្នកនិពន្ធ បណ្ឌិត កវីកើតឡើងយ៉ាងច្រើនជាបន្តបន្ទាប់គ្នាដូចផ្សិតត្រូវទឹកសន្សើម យ៉ាងសស្រាកសស្រាំ ដែកាន់ដែកចាររៀបចំតុបតែងឡើងនូវក្បួនខ្នាតបង្កើតបានជាយុគថ្មីនៃអក្សរសាស្ត្រ ហើយគង់វង្សមកដល់សព្វថ្ងៃនេះសម្រាប់ជាការសិក្សាត្រិះរិះ និងអានរបស់អនុជន។[៤៤]

រឿងរ៉ាវផ្សេងៗនៅក្នុងសម័យឧដុង្គសឹងតែជាទូទៅមានលក្ខណៈជារឿងប្រឌិតដែលចងក្រងឡើងតាមបែបមនោសញ្ចេតនា ដោយជ្រើសរើសរឿងក្នុង

[៤៤] គង់ សុខហេង *អក្សរសាស្ត្រខ្មែរសម្រាប់ថ្នាក់មធ្យមសិក្សាចំណេះទូទៅ* ភ្នំពេញ, គ.ស ២០១១, ទំព័រ ១៤៩-១៥០។

ទសជាតក បញ្ញាជាតក ជាដើម។ រឿងទាំងនោះបានបង្ហាញអំពីការសាងបុណ្យបារមីរបស់ព្រះពោធិសត្វ និងបានឆ្លុះបញ្ចាំងពីទស្សនៈកម្មផលដោយយកបញ្ហាបុណ្យ បាប ល្អ អាក្រក់ សុខ ទុក្ខ មកធ្វើជាគោលបង្កើតបញ្ហា ដូចជា នរណាធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ កម្មសឱ្យផលស កម្មខ្មៅឱ្យផលខ្មៅ ជាដើម។

បើនិយាយទាក់ទងទៅនឹងបញ្ហារបស់ស្ត្រីនៅសម័យឧដុង្គវិញ យើងសូមលើកយកនូវស្នាដៃចំនួនពីរ ជាប្រលោមលោកប្រវត្តិសាស្ត្រមកបង្ហាញ ដែលស្នាដៃទាំងពីរនេះមានសាច់រឿងតែមួយ ក៏ប៉ុន្តែមួយជាស្នាដៃរបស់លោក **គង្គ ប៊ុនឈឿន** និងមួយទៀតជាស្នាដៃរបស់លោក **ទី ជីហួត**[៤៥] ដែលបានរៀបរាប់ពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅចុងរាជ្យព្រះបាទ**ស្រីសុរិយោពណ៌** និងដើមរាជ្យព្រះបាទ**ជ័យជេដ្ឋាទី២**។ តាមរយៈរឿងនេះផងដែរ អ្នកនិពន្ធបានបង្ហាញយ៉ាងច្បាស់ពីស្ត្រីក្នុងការចូលរួមចំណែកកិច្ចការប្រទេសជាតិ តាមរយៈតួអង្គ***ជំទាវស្រែន*** ជាមនុស្សដែលមានមនសិការស្នេហាជាតិមាតុភូមិ ដោយហេតុថា នាងបានឃើញទាំង **តេជោមាស** និង **តេជោយ៉ត** ពុំមានសមត្ថភាពអាចកំចាត់**ស្ដេចសម្រែ**បាន ដូច្នេះហើយនាងក៏សុខចិត្តលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីសង្គមជាតិ ហ៊ានប្រថុយខ្លួនចូលទៅលួងលោម**ស្ដេចសម្រែ** ដែលជាជនបះបោរនៅដែនដីកំពង់លែង រហូតអាចចាប់បានជននោះមកប្រហារជីវិត។ មូលហេតុដែលធ្វើឱ្យនាងបានចូលទៅជិត**ស្ដេចសម្រែ** គឺដោយសារតែនាងបានរៀបចំគម្រោងការ ដោយធ្វើពុតជាលែងលះប្ដី ហើយរឿងនេះក៏បានលេច

---

[៤៥] ក្រសួងអប់រំ ***ភាសាខ្មែរថ្នាក់ទី១២*** (ក្ដៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ) បោះពុម្ពឆ្នាំ២០០២។

ឮដល់**ស្តេចសម្រែ** ដែលប្រាថ្នាចង់បានរូបនាងជាយូរមកហើយ។ ពេលនេះហើយ ដែលបានបង្ហាញថា ស្ត្រីជាអាវុធដ៏មុតស្រួចក្នុងការដោះស្រាយបញ្ហា។

### ៩.៣.៤- សម័យអាណាព្យាបាលបារាំង និងសម័យសង្គមរាស្ត្រនិយម(គ.ស.១៨៦៣-១៩៧០)

តាមរយៈស្នាដៃរបស់លោក ***ឌឹក គាម*** និង ***ឡឿក អំ*** ដែលមានចំណងជើងថា ***ភូមិតិរច្ឆាន*** និងស្នាដៃរបស់លោក ***អ៊ឹម ថុក*** មានចំណងជើងថា ***គូលីកំណែន*** បានបង្ហាញឱ្យឃើញពីតួនាទីស្ត្រីតាមរយៈតួអង្គ នាងនី និង នាងបី[៤៦] (តួអង្គប្រឌិត) ដែលមានសេចក្តីក្លាហានហ៊ានតស៊ូប្រឆាំងនឹងការជិះជាន់របស់បារាំងនៅមុខសាលាឃុំក្រាំងលាវ ដោយហ៊ានតវ៉ាមិនខ្លាចការគំរាមកំហែងរកសម្លាប់ពីសំណាក់ពួកបារាំងសេស(លោក **បាដេស បូង៉ាំង**) ដែលគាត់មកទារពន្ធម្តងណា គេតែងតែឃើញមានមនុស្សជាប់ខ្នោះដៃជើង ដោយសារឥតមានលុយបង់ពន្ធ។ ចំណែកឯនៅក្នុងស្នាដៃរបស់លោក **អ៊ឹម ថុក** តាមរយៈតួអង្គ**នាងហេង** ដែលជាគូដណ្តឹងរបស់**អន្ទិតលឹម** នាងមិនត្រឹមតែជាមនុស្សមានទេពកោសល្យក្នុងការងារត្បាញរវៃមុងភួយដល់ពួកបារាំងប៉ុណ្ណោះទេ តែថែមទាំងជាមនុស្សមានភក្តីភាពចំពោះស្នេហា បើទោះបីជាលោក**មេឃុំផាន់**ខំបញ្ចុះបញ្ចូលនាងឱ្យយកលោកចៅហ្វាយស្រុកចោលអន្ទិតលឹមក៏ដោយ ក៏នាងពុំព្រមធ្វើតាមពាក្យល្បួងលួងលោមនោះដែរ។

[៤៦] ឌឹក គាម និង ឡឿក អំ ***ភូមិតិរច្ឆាន*** ភ្នំពេញ ឆ្នាំ១៩៧១។

ចំណែកអ្នកស្រី ***ស៊ូ សិទ្ធិ***[៤៧] ដែលជាអ្នកនិពន្ធស្ត្រីមួយរូបក្នុងសម័យអាណានិគមបារាំង អ្នកស្រីកើតនៅថ្ងៃពុធ ខែមិគសិរ ឆ្នាំមមី ព.ស.២៤១៤ ត្រូវនឹងឆ្នាំ១៨៨១ នៅសង្កាត់លេខ៤ ក្រុងភ្នំពេញ និងបានទទួលមរណភាពនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៦៣។ លោកស្រីបានបន្សល់ទុកស្នាដៃមួយចំនួនដូចជា៖

១. រឿង ពិម្ពាពិលាប (បោះពុម្ពឆ្នាំ១៩៤២)

២. រឿង គួរសាងមិត្តមិនទ្រុស្តមិត្ត (បោះពុម្ពឆ្នាំ១៩៥២)

៣. រឿង ចិត្តសត្យា (បោះពុម្ពឆ្នាំ១៩៥៣)

៤. បែបបទសកវាទី (ភាគខ្លះបោះពុម្ពឆ្នាំ១៩៣២)

លើសពីនេះទៅទៀតអ្នកស្រី **ស៊ូ សិទ្ធិ** មានបទពិសោធន៍ក្នុងកិច្ចការមួយចំនួនដូចជា៖

- អ្នកស្រីចេះបើកក្រាំង បើកបទ ក្នុងរបាំព្រះរាជទ្រព្យយ៉ាងប៉ិនប្រសប់
- អ្នកស្រីក៏ប៉ិនប្រសប់ក្នុងការតែងកាព្យភ្លាមៗផងដែរ
- អ្នកស្រីបានធ្វើជានាយិកា នៃក្រុមបើកក្រាំងមហោរី។

ចំណែកនៅក្នុងសម័យសង្គមរាស្ត្រនិយម គេឃើញមានសម្ទុះស្ត្រីបានកើនឡើងក្នុងសង្គមខ្មែរនាសម័យនោះ ជាពិសេសបើគេមើលក្នុងវិស័យសិល្បៈវិញ គេឃើញមានតារាចម្រៀង និងតួកុនជាច្រើន(**រស់សេរីសុទ្ធា**, **ប៉ែនរ៉ន**, ....) ចំណែកឯនៅតាមសកលវិទ្យាល័យ និងនៅតាមរោងចក្រផ្សេងៗនៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជាតាមបណ្តាខេត្តដទៃៗទៀត ក៏មានចំនួនបុគ្គលិកកម្មករស្ត្រីជា

---

[៤៧] http://km.wikipedia.org.

ច្រើនដែលពួកគេទាំងនោះសុទ្ធតែបានផ្តល់នូវអន្តេវាសិកដ្ឋានសម្រាប់ស្នាក់នៅផងដែរ។ ចំណែកឯនៅក្នុងជួរកងទ័ពវិញក៏មិនចាញ់គ្នាប៉ុន្មានដែរ គេឃើញមានកងជីវពលនារីក្លាហានជាច្រើនបានចូលរួមរំដោះជាតិចេញពីរបបអាណានិគមនិយមបារាំង។

នាសម័យសង្គមរាស្ត្រនិយម ស្ត្រីខ្មែរក៏បានចូលរួមចំណែកយ៉ាងខ្លាំងក្លាក្នុងការជួយស្តារសេដ្ឋកិច្ចគ្រួសារដែលជាកោសិកានៃសេដ្ឋកិច្ចជាតិផងដែរ។ ស្ត្រីជាមេផ្ទះ ស្ត្រីជាអ្នកព្យួររាស់ដកស្ទូង ស្ត្រីជាអ្នកត្បាញរវៃ ស្ត្រីជាអ្នកដាំដុះ ស្ត្រីជាកសិករ ស្ត្រីជាកម្មករ ស្ត្រីជាសិល្បៈករ ស្ត្រីជាជាងគំនូរ ស្ត្រីជាគ្រូពេទ្យ ស្ត្រីជាគ្រូបង្រៀន ស្ត្រីជាមន្ត្រីរាជការ ស្ត្រីជាថ្នាក់ដឹកនាំជាដើម ដែលពួកគាត់បានខិតខំលះបង់កម្លាំងកាយចិត្តដើម្បីជួយជ្រោមជ្រែងគ្រួសារក៏ដូចជាសង្គមជាតិមួយដែលទើបតែតស៊ូរើបម្រាស់ពីការត្រួតត្រារបស់អាណានិគមបារាំង។

### ៩.៣.៥- សម័យសាធារណរដ្ឋ និងសម័យកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)

សាធារណរដ្ឋខ្មែរ ជារដ្ឋាភិបាលនៃសាធារណរដ្ឋកម្ពុជាដែលត្រូវបានប្រកាសឡើងជាផ្លូវការនៅថ្ងៃ៩តុលា ឆ្នាំ១៩៧០។ សាធារណរដ្ឋខ្មែរត្រូវផ្តួលរំលំនៅឆ្នាំ១៩៧៥ និងត្រូវបានបន្តដោយរដ្ឋកុម្មុយនិស្តផ្តាច់ការ ដែលគេស្គាល់ថាជា**កម្ពុជាប្រជាធិបតេយ្យ**។ សាធារណរដ្ឋខ្មែរ គឺជារដ្ឋាភិបាលដឹកនាំដោយយោធានិយមសហរដ្ឋខាងស្តាំ ដែលដឹកនាំដោយលោកឧត្តមសេនីយ៍ **លន់ នល់** និងព្រះអង្គម្ចាស់**ស៊ីសុវត្ថិសិរិមតៈ** ដែលដណ្តើមអំណាចបាននៅក្នុង

រដ្ឋប្រហារ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រឆាំងនឹងសម្ដេច**នរោត្ដម សីហនុ** គឺក្រោយមកក្លាយជាប្រមុខរដ្ឋរបស់ប្រទេសនេះ។

សម័យកម្ពុជាប្រជាធិបតេយ្យ ឬសម័យខ្មែរក្រហម ជាសម័យមួយដែលមានរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ ខ្មែរក្រហម គឺជាពាក្យសាមញ្ញមួយដែលត្រូវបានគេប្រើប្រាស់សំដៅលើបក្សកុម្មុយនីស្ដកម្ពុជា។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ១៩៦០មក ប្រទេសកម្ពុជាបានឆ្លងកាត់សម័យកាលអស្ថិរភាព និងជម្លោះបន្ទាប់ពីសង្រ្គាមរវាងប្រទេសវៀតណាម និងសហរដ្ឋអាមេរិក។ បន្ទាប់ពីរដ្ឋប្រហារក្នុងឆ្នាំ១៩៧០ ដែលធ្វើឡើងដោយកងកម្លាំងរបស់ **លន់ នល់** គាំទ្រដោយសហរដ្ឋអាមេរិកទល់នឹងអតីតប្រមុខរាជរដ្ឋាភិបាល គឺអតីតព្រះមហាក្សត្រព្រះបាទ**នរោត្ដមសីហនុ** មក សង្រ្គាមស៊ីវិលបានកើតឡើងរវាងកងកម្លាំងរបស់ **លន់ នល់** និងកងកម្លាំងដែលគាំទ្រអតីតព្រះមហាក្សត្រព្រះបាទ**នរោត្ដម សីហនុ** ដែលរួមមានខ្មែរក្រហម។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ដោយប្រកាសថា សង្រ្គាមស៊ីវិលបានបញ្ចប់ និងបានដាក់ឈ្មោះប្រទេសកម្ពុជាថា **កម្ពុជាប្រជាធិបតេយ្យ**។ ប្រជាជនបានប្រមូលផ្ដុំគ្នាតាមផ្លូវថ្នល់អបអរសាទរ និងស្វាគមន៍ក្រុមទាហានខ្មែរក្រហម។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពបានប្រែក្លាយភ្លាមៗទៅជាហិង្សា នៅពេលដែលអ្នករស់នៅទីក្រុងភ្នំពេញត្រូវបានបង្ខំឱ្យចាកចេញពីទីក្រុងទៅកាន់ជនបទ។

ប៉ុលពត ″**បងធំទីមួយ**″ របស់ខ្មែរក្រហមដែលបានព្យាយាមកសាងសង្គមកសិកម្មគ្មានវណ្ណៈ ដោយផ្អែកលើមនោគមវិជ្ជាកុម្មុយនីស្ដ គាត់បានប្រកាសថា កម្ពុជាប្រជាធិបតេយ្យនឹងចាប់ផ្ដើមជាថ្មីនៅឆ្នាំសូន្យ។ រដ្ឋាភិបាល១

ត្រូវបានគ្រប់គ្រងនៅថ្នាក់មជ្ឈិមដោយក្រុមបក្ខជនជិតស្និទ្ធនឹងគ្នា រដ្ឋាភិបាលនេះ មានអំណាចធ្វើសេចក្តីសម្រេចទាំងអស់។ គ្រប់ស្ថាប័នទាំងអស់ដែលរួមមានស្ថាប័នហិរញ្ញវត្ថុ អប់រំនិងសាសនា ព្រមទាំងគ្រួសារ ត្រូវបានលុបបំបាត់ចោល ហើយកម្មសិទ្ធិឯកជន ជីវភាពការរស់នៅឯករាជ្យ និងទំនាក់ទំនងផ្លូវភេទ មិនត្រូវបានអនុញ្ញាត គឺត្រូវបានចាត់ទុកជាការខុសច្បាប់។ ប្រជាជនត្រូវបានបង្ខំឱ្យធ្វើការងារកសិកម្ម និងកសាងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រគោលដៅរបស់ខ្មែរក្រហម។ ក្នុងរបបនេះមានការខ្វះខាតនិងការដកហូត ដូចជាកង្វះខាតម្ហូបអាហារនិងសម្ភារៈចាំបាច់ជាមូលដ្ឋាន ការដកហូតសិទ្ធិសេរីភាព សូម្បីតែសិទ្ធិមនុស្សជាមូលដ្ឋានក៏ត្រូវបានដកហូតដែរ ការសម្រាកមិនគ្រប់គ្រាន់និងមិនទទួលបានការព្យាបាលជំងឺ ព្រមទាំងការដកហូតនូវទំនាក់ទំនងជាមួយក្រុមគ្រួសារ និងទំនាក់ទំនងរវាងមនុស្សនិងមនុស្ស។

ចាប់តាំងពីការមកដល់របស់ខ្មែរក្រហមក្នុងទីក្រុងភ្នំពេញ ក្នុងរបបនេះ អ្នកដែលត្រូវបានរកឃើញថា ជាអ្នកមានទ្រព្យសម្បត្តិច្រើន មានការសិក្សាអប់រំខ្ពស់ ឬជាប់ពាក់ព័ន្ធនឹងមូលធននិយម ឬរបបពីមុនៗមក អ្នកទាំងអស់នេះគឺត្រូវបានសម្លាប់ជាប្រព័ន្ធ។ លើសពីនេះទៅទៀត សមាជិកក្រុម ជាតិពន្ធុ និងក្រុមភាគតិចផ្នែកសាសនា គឺជាកម្មវត្ថុនៃការធ្វើទុក្ខបុកម្នេញ។ ប្រជាជនទាំងនេះត្រូវទទួលរងនូវការជម្លៀសដោយបង្ខំ ការបង្ខំឱ្យធ្វើការ ការឃុំឃាំងតាមទំនើងចិត្ត ការបង្ខំឱ្យរៀបការ និងអំពើហិង្សាជាប្រព័ន្ធដែលរួមមាន ការវាយដំ សាហាវយង់ឃ្នង ការធ្វើទារុណកម្ម ការកាត់អវយវៈភេទ អំពើហិង្សាផ្លូវភេទ និងការកាប់សម្លាប់។ ជីវិតគឺពោរពេញដោយការភ័យខ្លាចសេចក្តីស្លាប់ និងស្ថិតនៅក្រោមស្ថានភាពនៃការឈឺចាប់ជាប្រចាំ។ ស្របពេលគ្នានេះដែរ សង្គ្រាម

បានកើតឡើងជាមួយវៀតណាម ដែលជាប្រទេសជិតខាង។ គេប៉ាន់ប្រមាណថា ប្រជាជនប្រហែលជា១,៧លាននាក់បានស្លាប់ដោយសារការអត់អាហារ ការធ្វើទារុណកម្ម ការកាប់សម្លាប់ និងការបង្ខំឱ្យធ្វើការ មុនពេលដែលទាហានវៀតណាម ចូលមកក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។

សម័យខ្មែរក្រហម ឬរបបកម្ពុជាប្រជាធិបតេយ្យនេះបានគ្រប់គ្រងស្រុកខ្មែរពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។ ក្នុងរបបនេះ គេបានបង្ហាញពីការលះបង់អាយុជីវិតរបស់គេទាំងប្រុសទាំងស្រី។ បើយោងតាមអត្ថន័យក្នុងបទចម្រៀងខ្មែរក្រហម១៧មេសា ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃបដិវត្តន៍រំដោះពីភាពខ្ញុំគេ ដូចមានក្នុងការដកស្រង់ឃ្លាមួយចំនួនថា៖ *ឈាមក្រហមប្រាលស្រោចស្រពក្រុងវាល កម្ពុជាមាតុភូមិឈាមកម្មករ កសិករដ៏ឧត្តម ឈាមយុទ្ធជនយុទ្ធនារីបដិវត្តន៍។ ឈាមប្រែក្លាយជាកំហឹងខ្លាំងក្លា តស៊ូមោះមុត ដប់ប្រាំពីរមេសា ក្រោមទង់បដិវត្តឈាមរំដោះអំពីភាពខ្ញុំគេ។*[៤៨] ក្នុងសម័យនេះប្រជាជនកម្ពុជា ទាំងស្ត្រីនិងបុរសត្រូវបានគេបង្ខំឱ្យទៅធ្វើការនៅឯវាលស្រែ ដើម្បីបង្កបង្កើនផល ក៏ដូចជាការលើកទំបន់ ជីកប្រឡាយ និងប្រជនជនមួយចំនួនតូចបានក្លាយជាកម្មាភិបាលខ្មែរក្រហម ហើយពួកគេទាំងអស់នោះអាចជាឈ្លបយកការណ៍ផងដែរ។ ចំពោះថ្នាក់ដឹកនាំកំពូលៗវិញ គេឃើញមានលោកស្រី **អៀង ធារិទ្ធ** ជាដើម ដែលត្រូវបានគេចោទប្រកាន់ថា បានជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ នៅលើទឹកដីនៃ

---

[៤៨] http://km.wikipedia.org

ព្រះរាជាណាចក្រកម្ពុជាក្នុង អំឡុងពេល ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[៤៩] ក្នុងចំណោមមេដឹកនាំកំពូលទាំង៤ នាក់ ដែលបានបង្ហាញពីការចូលរួមរបស់ស្ត្រីនាសម័យកម្ពុជាប្រជាធិបតេយ្យ។

បើយោងលើដំណើររឿងពលិកម្មម៉ែៗយើង ក៏បានបង្ហាញពីការលះបង់តស៊ូរបស់ស្ត្រីក្នុងបុព្វហេតុគ្រួសារក៏ដូចជាជាតិមាតុភូមិផងដែរ។

## ៩.៣.៦- ស្ត្រីសម័យបច្ចុប្បន្ន (គ.ស.១៩៧៩ - បច្ចុប្បន្ន)

### ៩.៣.៦.១- តួនាទីស្ត្រីថ្នាក់ជាតិ

បច្ចុប្បន្ននេះ សិទ្ធិស្ត្រីត្រូវបានគេលើកតម្កើងបានយ៉ាងសមស្របតាមច្បាប់ជាតិ និងអន្តរជាតិ។ តួយ៉ាងគេឃើញមានស្ត្រីខ្មែរជាច្រើនបាននឹងកំពុងតែបម្រើការនៅក្នុងតួនាទីសំខាន់ៗមួយចំនួន ទាំងក្នុងស្ថាប័នរដ្ឋ ទាំងក្នុងស្ថាប័នអង្គការក្រៅរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល និងស្ថាប័នផ្សេងៗទៀតមានដូចជា សម្តេចព្រះមហាក្សត្រីមុ**នីនាថសីហនុ** លោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** លោកជំទាវ **ពេជ្រចន្ទមុនី ហ៊ុនម៉ាណែត** លោកជំទាវ **ឃួន សុដារី** លោកជំទាវ **ម៉ែន សំអន** លោកជំទាវ **និន សាផុន** លោកជំទាវ **គី លំអង** លោកជំទាវ **អ៊ឹងកន្ថា ផាវី** លោកស្រី **ពុង ឈីវ កេក** លោកស្រី **កែវ ចន្ទបូរណ៍** លោកស្រី **ពាន់ ភួងបុប្ផា** លោកស្រី អ្នកនាងកញ្ញាដែលជាថ្នាក់ដឹកនាំនិងសហការីនៅតាមស្ថាប័ននីមួយៗ ព្រមទាំងតារាចម្រៀង និងតារាសម្តែងស្ត្រីនៅតាមផលិតកម្មមួយចំនួនដែលមានឈ្មោះបោះសំឡេង និងមិនមានឈ្មោះបោះសំឡេងផងដែរ។ គួរកត់សម្គាល់ដែរថា ទោះបីជាស្ត្រីមួយចំនួនមានចំណុច

---

[៤៩] http://www.akp.gov.kh/kh/?p=12295

វិជ្ជមាន និងអវិជ្ជមានក៏ដោយ ក៏ពួកគាត់នៅមានចំណុចមួយចំនួនគួរឱ្យយកជាគំរូល្អៗនៅក្នុងសង្គមដែរ។ ម្យ៉ាងវិញទៀត តាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(WMC)បានឱ្យដឹងថា នៅតាម ភូមិ ឃុំ សង្កាត់ ស្រុក ខេត្ត មួយចំនួន និងនៅរាជធានីភ្នំពេញក៏មានស្ត្រីជាអ្នកដឹកនាំ និងបានឈរឈ្មោះបោះឆ្នោតនៅតាមឃុំសង្កាត់នានាទូទាំងខេត្តក្រុង។[៥០] ទន្ទឹមនឹងនោះដែរ ក៏មានស្ត្រីនៃប្រទេសកម្ពុជាប្រមាណជាជិត១៣ភាគរយផងដែរ ដែលទទួលរងអំពើហិង្សាពីស្វាមី។[៥១]

## ៩.៣.៦.២- តួនាទីស្ត្រីថ្នាក់សកល

ជាទូទៅគេយល់ថា មនុស្សប្រុសជាអ្នកខ្លាំងពូកែខាងនយោបាយ ដឹកនាំប្រទេស ខាងសឹកសង្គ្រាមមានជំហរស្មារតីរឹងប៉ឹងជាងនារី។ តើបុរសពិតជារឹងប៉ឹងដោយគ្មានវត្តមានស្ត្រីបានទេ? តើបុរសគួរមើលរំលងនារីភេទបានដែរឬទេ? បើសិនជាយើងក្រឡេកទៅមើលពិភពលោកនាពេលបច្ចុប្បន្ននេះ យើងឃើញថា ស្ត្រីកាន់តែមានមុខមាត់បន្តិចម្តងៗជាមួយនឹងបុរស ឬជួនកាលអាចខ្ពស់ជាងបុរសទៅទៀត។ ការងារយេនឌ័រ ត្រូវបានគេលើកតម្កើង ហើយការងារខ្លះបុរសមិនអាចធ្វើបានដូចស្ត្រីនោះទេ ហើយពេលខ្លះក៏ស្ត្រីមិនអាចធ្វើបានដូចបុរសវិញដែរ។ តើសង្គមអាចមានមួយអត់មួយបានដែរឬទេ? តាមគំនិតជា

---

[៥០] ក្រសួងធម្មការនិងសាសនា *សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី៣* អក្សរសាស្ត្រខ្មែរ ទំព័រ២១-២២ ការពារថ្ងៃ១២ ខែមីនា ព.ស.២៥៥៥ គ.ស.២០១២។

[៥១] យោងតាមសាពត៌មានគ្មានទីបញ្ចប់ abcnonstop.net

ទូទៅជឿថា ពិតជាមិនអាចខ្វះមួយណាបានទេ។ ឧបមាថា គ្រួសារមួយមានប្ដីជាអ្នករកស៊ី រីឯប្រពន្ធជាមេផ្ទះ ប្រសិនបើទ្រព្យសម្បត្តិទាំងឡាយដែលប្ដីរកបានមក យកមកឱ្យប្រពន្ធទុកដាក់ដើម្បីចាត់ចែងលៃលកតាមការគួរនោះ សួរថា ប្រសិនបើប្រពន្ធនោះ មិនមែនជាអ្នកចេះរក្សាទ្រព្យឱ្យគង់ តើគ្រួសារនោះអាចរុងរឿងថ្កុំថ្កើងទៅរួចដែរឬទេ? នៅក្នុងរឿងអាកម្ទិលអាំងផេះ ដែលនាយកម្ទិលបានប្រពន្ធគ្រប់លក្ខណ៍ ទោះបីជាប្ដីល្ងង់នោះយ៉ាងណាក៏ដោយ ក៏នាងនៅតែអាចអូសទាញប្ដីឱ្យចេះរកស៊ីរហូតបានជាអ្នកមានបាន។[៥២] យ៉ាងណាមិញបើយើងនិយាយពីក្របខណ្ឌស្ត្រីថ្នាក់អន្តរជាតិវិញ នៅក្នុងប្រទេសជាច្រើននៅលើពិភពលោក ស្ត្រីកំពុងតែបានដើរតួនាទីយ៉ាងសំខាន់ទាំងក្នុងវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រពិត។ តួយ៉ាងដូចជា អ្នកស្រីឥណ្ឌា **វ៉ា គន្ធី** ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីនៅទសវត្សរ៍ទី៦០ មហាក្សត្រីយានី**អេលីហ្សាបែតទី២** (សោយរាជ្យនៅអង់គ្លេសបច្ចុប្បន្ន) អ្នកស្រី Margaret Thatcher (គឺជាស្ត្រីនាយករដ្ឋមន្ត្រីអង់គ្លេសដំបូងក្នុងប្រវត្តិនៃប្រទេសនេះ) អ្នកស្រីអធិការបតី **ជូលីកាលេត** (ប្រធានាធិបតីអូស្ត្រាលី) អ្នកស្រីប្រធានាធិបតីកូរ៉េ **ប៉ាក់ គួនហេ** (Park Geun-hye)[៥៣] អ្នកស្រីអធិការបតី **អង់កូឡាម៉ាកេល** (ប្រធានាធិបតីអាល្លឺម៉ង់) អ្នកស្រី **កុងដូលីហ្សារ៉ៃ** អ្នកស្រី **ហ៊ីលឡារី គ្លីនតុន**[៥៤] ជាដើម។

---

[៥២] ពុទ្ធសាសនបណ្ឌិត្យ *ប្រជុំរឿងព្រេងខ្មែរ* ភាគ១។

[៥៣] http://en.wikipedia.org/wiki/List_of_Presidents_of_South_Korea

[៥៤] http://en.wikipedia.org/wiki/Hillary_Rodham_Clinton

សរុបមកវិញ ប្រសិនបើយើងឆ្លុះបញ្ចាំងត្រឡប់បកទៅក្រោយដោយពិនិត្យមើលទីតាំងនិងស្ថានភាពស្ត្រីនៅគ្រប់កាលៈទេសៈ រឿងព្រេង ប្រវត្តិសាស្ត្រ អត្ថបទអក្សរសាស្ត្រជាតិខ្មែរ និងទីតាំងឋានៈតួនាទីស្ត្រី ក្នុងក្របខណ្ឌសកលលោកក៏ល្មមឃើញនិងយល់បាន ថាតើស្ត្រីពិតមានសារៈសំខាន់ និងចាំបាច់យ៉ាងណា? ហេតុអ្វីបានជាស្ត្រីមួយចំនួនមានឥទ្ធិពលទាំងក្នុងវិស័យសេដ្ឋកិច្ច ព័ត៌មានវិទ្យា នយោបាយ សាសនា និងវិស័យផ្សេងៗទៀត?

បន្ទាប់ពីការបោះឆ្នោតជាតិលើកដំបូងនៅឆ្នាំ១៩៩៣ រដ្ឋាភិបាលបានរៀបចំ និងអនុវត្តគោលនយោបាយកំណែទម្រង់មីក្រូ និងម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ច កម្ពុជាទៅក្នុងតំបន់និងពិភពលោក ក៏ដូចជាជំរុញកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ តាមរយៈការធ្វើជំរឿនចុងក្រោយនៅឆ្នាំ២០១៩ ប្រជាពលរដ្ឋខ្មែរត្រូវបានគេកំណត់ថាមានចំនួនសរុបជាង១៥,៥លាននាក់ ក្នុងនោះស្ត្រីមានជិត៨លាននាក់ ក៏ប៉ុន្តែបើយើងក្រឡេកទៅមើលក្នុងវិស័យវិទ្យាសាស្ត្រ ស្ត្រីហាក់នៅមានតិចតួចនៅឡើយប្រៀបធៀបទៅនឹងបុរស ជាពិសេសនៅក្នុងបរិបទនៃបដិវត្តឧស្សាហកម្ម៤.០ និងឈរលើសមភាពយេនឌ័រផងនោះ ប្រទេសកម្ពុជាពិតជាមិនអាចមើលរំលងលើនារីនៅក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបានឡើយ។ សម្រាប់ប្រទេសកម្ពុជា ស្ត្រីត្រូវបានគេមើលឃើញថាមានប្រមាណជា៥%ប៉ុណ្ណោះដែលបានចាប់អារម្មណ៍សិក្សានិងចាប់យកការងារតាមបែបវិទ្យាសាស្ត្រ ដូចជាជំនាញបច្ចេកវិទ្យា វិស្វករ និងគណិតវិទ្យាជាដើម។ ចំនួននេះ នៅតិចតួចណាស់ បើប្រៀបធៀបទៅនឹងប្រទេសនៅក្នុងតំបន់និងពិភពលោក ដែលប្រទេសខ្លះ ចំនួនស្ត្រីនៅក្នុងវិស័យវិទ្យាសាស្ត្រមានប្រហាក់ប្រហែលនិងបុរស។

ការដែលប្រទេសកម្ពុជាមានចំនួនស្ត្រីតិចតួច នៅក្នុងវិស័យវិទ្យាសាស្ត្រ គឺរឿងនេះទាក់ទងទៅនឹងកត្តាមួយចំនួន ក្នុងនោះក៏មានកត្តាសង្គម វប្បធម៌ ទំនៀមទម្លាប់ប្រពៃណីដែរ។ នៅពេលដែលប្រទេសក្នុងតំបន់កំពុងតែអភិវឌ្ឍន៍ ជាពិសេសលើផ្នែកសមភាពយេនឌ័រ ស្ត្រីកម្ពុជាបែរជាកំពុងស្ថិតនៅក្នុងភ្នក់ភ្លើងសង្គ្រាមស៊ីវិល ដែលបានកើតឡើងពីរបបមួយទៅរបបមួយឥតឈប់ឈរទៅវិញ។ យើងសង្កេតឃើញថា ការសិក្សារបស់ស្ត្រីកាលពីជំនាន់មុនៗ បានធ្វើឡើង គ្រាន់តែឱ្យស្គាល់អក្សរ និងចេះដឹងបន្តិចបន្តួចនៅក្នុងកម្រិតមួយដែលមិនអាចយកទៅប្រើការនៅក្នុងការងារជំនាញ ឬបច្ចេកទេសវិទ្យាសាស្ត្របាននោះទេ។ ម្យ៉ាងទៀតក្មេងស្រីនៅក្នុងគ្រួសារ តាមប្រពៃណីខ្មែរតំណតមក តែងផ្សារភ្ជាប់តែចង្ក្រានជើងផ្ទាំង ដែលអគ្រាបោះបង់ចោលការសិក្សារបស់សិស្សស្រីមានកម្រិតខ្ពស់ ខណៈដែលប្រទេសកម្ពុជាបានស្ថិតនៅក្រោមបន្ទាត់ក្រីក្រនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស្ត្រីភាគច្រើន មិនទាន់យល់បានទូលំទូលាយពីសារៈសំខាន់នៃវិទ្យាសាស្ត្រ និងមិនទាន់ទុកចិត្តខ្លួនឯងថា មានសមត្ថភាពដូចបុរស។ ក៏ប៉ុន្តែបដិវត្តឧស្សាហកម្ម៤.០នាបច្ចុប្បន្ននេះ បើទោះបីជាកម្ពុជានៅយឺតជាងគេក៏ដោយ ក៏វាជាការជួយពញ្ញាក់អារម្មណ៍ឱ្យប្រទេសនេះ បង្ខំចិត្តត្រូវតែរត់ឱ្យទាន់វិស័យបច្ចេកវិទ្យា វិទ្យាសាស្ត្រ ដោយមានការចូលរួមទាំងបុរសទាំងស្ត្រី ជាពិសេសស្ត្រីខ្លួនឯងត្រូវមានឆន្ទៈចូលរួមស្វែងរកយន្តការដ៏មានប្រសិទ្ធភាព ដែលអាចឱ្យមានវត្តមានស្ត្រីកាន់តែច្រើននៅក្នុងវិស័យនេះ។ បើយោងតាមសមភាពយេនឌ័រ គេត្រូវតែជំរុញស្ត្រីឱ្យបានកាន់តែច្រើនដែលអាចធ្វើទៅបាន បានចូលសិក្សាចាប់ពីកម្រិតបឋម រហូតដល់ថ្នាក់ជំនាញវិជ្ជាជីវៈ ថ្នាក់ឧត្តមសិក្សា បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដោយគ្រវាត់ចោលនូវ

ទស្សនៈប្រពៃណីអន់ថយ ដែលថា «**ស្រ្តីបង្វិលចង្ក្រានមិនជុំ**» ហើយជំនួសមកវិញនូវទ្រឹស្តី និងការអនុវត្តជាក់ស្តែងលើវិស័យវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ ដ្បិតវិស័យបច្ចេកវិទ្យា និងនវានុវត្តន៍ មិនត្រឹមតែជួយលើកមុខមាត់ស្រ្តីនៅក្នុងវិស័យវិទ្យាសាស្រ្តប៉ុណ្ណោះទេ តែថែមទាំងជួយលើកស្ទួយតម្លៃស្រ្តីនៅក្នុងសង្គមផងដែរ ដោយមានការផ្លាស់ប្តូរផ្នត់គំនិតគិតមិនដល់ មុជមិនជ្រៅ ទៅមិនឆ្ងាយ ទៅជាអ្នកដែលមានផែនការបង្កើតថ្មីដែលចំណុចនេះ ជាធាតុផ្សំចាំបាច់ក្នុងការអភិវឌ្ឍសង្គមគ្រួសារ និងប្រទេសជាតិ។

ដូច្នេះប្រទេសដែលមានការរីកចម្រើនទៅបាន លុះត្រាតែមានការចូលរួមដោយស្មើភាពគ្នារវាងស្រ្តីនិងបុរស។ ដើម្បីឱ្យស្រ្តីអាចបង្ហាញសមត្ថភាពចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ សូមឱ្យបុរសរួមគ្នាផ្តល់ឱកាសលើកទឹកចិត្ត ឱ្យតម្លៃគោរពស្រឡាញ់ មិនប្រើអំពើហិង្សាលើស្រ្តី ចំណែកស្រ្តីខ្លួនឯងវិញ ត្រូវបន្តភាពក្លាហានរបស់ខ្លួន បង្កើនចំណេះដឹង ខំប្រឹងតស៊ូដើម្បីទទួលសិទ្ធិអំណាច លទ្ធផលការងារ ការយល់ដឹង ដើម្បីធ្វើឱ្យបុរសយល់កាន់តែច្បាស់អំពីភាពមិនអាចខ្វះបាន នូវការរួមចំណែករបស់ស្រ្តី ដើម្បីឱ្យសង្គមមានភាពរីកចម្រើនរុងរឿង។

បច្ចុប្បន្ននេះ ស្រ្តីបានចូលរួមយ៉ាងសកម្មគ្រប់វិស័យក្នុងការអភិវឌ្ឍសង្គមជាតិដូចជាវិស័យនយោបាយ វិស័យឯកជន វិស័យសេដ្ឋកិច្ច សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល។ ដើម្បីបង្ហាញពីសក្តានុពលរបស់ខ្លួនក្នុងការចូលរួមចំណែកកិច្ចអភិវឌ្ឍន៍សង្គមប្រកបដោយសមធម៌។

ក្នុងចំណោមក្រសួងនិងស្ថាប័នដែលដឹកនាំដោយស្រ្តីជារដ្ឋមន្រ្តី មានក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ក្រសួងកិច្ចការនារី

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អភិបាលខេត្តជាស្ត្រី មានខេត្តកោះកុង និងខេត្តប៉ៃលិន។

ក្នុងបរិការណ៍បច្ចុប្បន្ន ការសិក្សាស្រាវជ្រាវបានបង្ហាញថា ជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់អវិជ្ជមានលើស្ត្រីច្រើនជាងបុរសទាំងក្នុងវិស័យសេដ្ឋកិច្ច និងសង្គម ជាពិសេសស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលកំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារស្ត្រីភាគច្រើនមានការងារនៅក្នុងវិស័យសេវាកម្ម និងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយអាចមិនបានទទួលនូវការឧបត្ថម្ភពីកម្មវិធីគាំពារសង្គមដែលជាធម្មតាគ្របដណ្តប់តែទៅលើកម្មករ និយោជិត សម្រាប់សេដ្ឋកិច្ចក្នុងប្រព័ន្ធ។

ទោះយ៉ាងណាក៏ដោយ ការលើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ត្រូវបានចាត់ទុកថាជាកាលានុវត្តភាព និងកាតាលីករថ្មីមួយ សម្រាប់ពន្លឿនការសម្រេចបាននូវសមភាពយេនឌ័រ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយបរិយាប័ន្ន។ ជាក់ស្តែងការចូលរួមចំណែករបស់ស្ត្រីក្នុងការជំរុញកំណើន សេដ្ឋកិច្ច គឺនៅមានសក្តានុពលច្រើន។ ហេតុនេះ រដ្ឋាភិបាលប្រទេសសមាជិកអាស៊ាន និងភាគីពាក់ព័ន្ធ ជាពិសេស វិស័យឯកជន ត្រូវរួមគ្នាបង្កើតបរិយាកាសមួយអំណោយផលដែលអាចឱ្យស្ត្រីមានភាពងាយស្រួលក្នុងការចាប់យកកាលានុវត្តភាព និងសក្តានុពលថ្មីទាំងនេះ។ ក្នុងន័យនេះ យើងគួរបន្តផ្តល់អាទិភាពខ្ពស់ចំពោះការលើកកម្ពស់តួនាទីស្ត្រីក្នុងយុគសម័យឌីជីថលដោយផ្តោតលើការងារដូចតទៅ៖

**ទី១**. បង្កើនការផ្តល់សេវា និងលើកកម្ពស់ការទទួលបានសេវារបស់ស្ត្រី និងកុមារី ក្នុងការប្រើប្រាស់សេវា ICT តាមរយៈការផ្តល់សេវា និងទីកន្លែងដែល

ស្ត្រីអាចប្រើប្រាស់សេវា ICT ដោយងាយស្រួល និងមានសុវត្ថិភាព និងផ្តល់ការវិនិយោគតាមរយៈការរៀបចំគោលនយោបាយ ប្រកបដោយបរិយាប័ន្ន សំដៅផ្តល់សេវា ICT ក្នុងតម្លៃសមរម្យ( affordable ICT service )។

**ទី២**. ផ្តោតការយកចិត្តទុកដាក់លើការអប់រំផ្នែក STEAM ដែលអាចឱ្យស្ត្រី និងកុមារីទទួលបានចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងICT។

**ទី៣**. បន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុតាមរយៈការបង្កើនការយល់ដឹងអំពីការអភិវឌ្ឍអាជីវកម្មសំខាន់ៗ ជាពិសេសសហគ្រាសខ្នាតតូច មធ្យម និងវិស័យ ICT។ ពង្រីកវិសាលភាពគ្របដណ្តប់លើប្រព័ន្ធគាំពារសង្គម និងរៀបចំដាក់វិធានការលើកកម្ពស់តួនាទីរបស់ស្ត្រី ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិទៅក្នុងក្របខណ្ឌ នៃផែនការស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩។

**ទី៤**. រៀបចំប្រព័ន្ធបរិស្ថាន( Eco system )មួយឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាស កម្រិតមីក្រូខ្នាតតូច មធ្យម និងសហគ្រិនជាស្ត្រីដោយយកចិត្តទុកដាក់ដល់ការបញ្ជ្រាបបច្ចេកវិទ្យាឌីជីថល ការទទួលបានធនធានហិរញ្ញវត្ថុ ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព។ល។ ដើម្បីជំរុញការអភិវឌ្ឍធុរៈកិច្ចថ្មីៗក្នុងវិស័យឌីជីថល។

**ទី៥**. ពង្រឹងជំនាញដូចជា អក្ខរកម្មឌីជីថល( Digital literacy ) និងការពារអត្តសញ្ញាណ ដើម្បីឱ្យស្ត្រីអាចទទួលបានផលប្រយោជន៍ពេញលេញ និងប្រកបដោយសុវត្ថិភាពពីសេដ្ឋកិច្ចឌីជីថល។

**និងទី៦**. លើកកម្ពស់គំនិតផ្តួចផ្តើមថ្មីៗ និងឧត្តមានុវត្តន៍នានា ( Best practice ) ពាក់ព័ន្ធនឹងការលើកស្ទួយតួនាទីស្ត្រីលើផ្នែកបច្ចេកវិទ្យាឌីជីថល ព្រមទាំងចែករំលែកនិងផ្លាស់ប្តូរបទពិសោធន៍រវាងប្រទេសសមាជិកអាស៊ាន។

ធ្វើឌីជីថលូបនីយកម្មតាមរយៈការរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពដល់មន្ត្រីក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការងារប្រចាំថ្ងៃ និងការដាក់ឱ្យដំណើរការទំព័រហ្វេសប៊ុក ប្រព័ន្ធបណ្តាញសង្គម និងគេហទំព័រក្រសួង ក្នុងការផ្តល់ព័ត៌មាន បង្កើនការយល់ដឹង និងការប្រមូលព័ត៌មានត្រឡប់ពីមហាជន តាមរយៈសកម្មភាពមួយចំនួនដូចជា៖ យុទ្ធនាការ១៦ថ្ងៃ ដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី ទិវាអន្តរជាតិនារី ៨មីនា ការប្រឹក្សាផ្នែកច្បាប់តាម Hotline កិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ កម្មវិធីពិភាក្សា និងផ្សព្វផ្សាយតាម Webinar កម្មវិធីអប់រំផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម លិខិតរដ្ឋបាល និងឯកសារពាក់ព័ន្ធជាដើម ដែលមានអ្នកទទួលនិងចូលរួមសរុបប្រមាណ ២លាននាក់ ក្នុងអំឡុងឆ្នាំ២០១៩-២០២១។

តាម**ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា** *ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិតាមច្បាប់រដ្ឋធម្មនុញ្ញ ក្នុងការចូលរួមក្នុងដំណើរការផ្នែកនយោបាយរបស់ប្រទេសកម្ពុជា។* មាត្រា៣៤នៃរដ្ឋធម្មនុញ្ញចែងថា *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។* មាត្រា៣៤ និង៧៦ ចែងថា *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច២៥ឆ្នាំ អាចឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសជាតំណាងរាស្ត្រ និងធ្វើការងារក្នុងផ្នែកសាធារណៈដទៃទៀតបាន។*

សេចក្តីបន្ថែមលើសិទ្ធិផ្នែកនយោបាយដ៏ជាក់លាក់ ក្នុងការបោះឆ្នោត និងការឈរឈ្មោះឱ្យគេបោះឆ្នោត ដើម្បីចូលធ្វើការងារក្នុងផ្នែកសាធារណៈ ច្បាប់រដ្ឋធម្មនុញ្ញទទួលស្គាល់សិទ្ធិផ្នែកនយោបាយជាទូទៅមួយទៀត។ មាត្រា ៣៥នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួម យ៉ាងសកម្មក្នុង "**ជីវភាពផ្នែកនយោបាយ សេដ្ឋកិច្ចសង្គម និងវប្បធម៌**" របស់ ប្រទេសជាតិ។

រដ្ឋត្រូវការពារនិងលើកស្ទួយរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជា ជំហាន។ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប រដ្ឋត្រូវយកចិត្ត ទុកដាក់ដល់វិស័យអប់រំកាយនិងកីឡា ដែលជាសុខុមាលភាពពលរដ្ឋគ្រប់រូប។

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍ សេរីភាពខាងសិក្សាធិការ និងគោលការណ៍ សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត។

រដ្ឋអនុវត្តកម្មវិធីសិក្សានិងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូល ទាំងបច្ចេកវិទ្យា និងភាសាបរទេស។

ស្ត្រីបានចូលរួមគ្រប់ផ្នែកដូចជា៖ ក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាដើម។

រដ្ឋធម្មនុញ្ញដែលជាច្បាប់គោលនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ គោលការណ៍ស្មើភាពគ្នាជាសារវន្តរវាងបុរសនិងស្ត្រី មានជាអាទិ៍៖

- មាត្រា៣១៖ សមភាពចំពោះមុខច្បាប់

- មាត្រា៣៤៖ សមភាពក្នុងការបោះឆ្នោតនិងឈរឈ្មោះឱ្យគេបោះឆ្នោត
- មាត្រា៣៦៖ សមភាពក្នុងការជ្រើសរើសមុខរបរ
  សមភាពក្នុងការទទួលប្រាក់បំណាច់
  សមភាពក្នុងការទទួលបានការធានារ៉ាប់រងសង្គម
  សមភាពក្នុងបង្កើតសហជីព និងចូលរួមជាសមាជិក
  សហជីពសមភាពក្នុងការងារក្នុងផ្ទះ និងការងារក្រៅផ្ទះ
- មាត្រា៣៨៖ សមភាពខាងកិច្ចការពារខ្លួនតាមផ្លូវតុលាការ
- មាត្រា៤៣៖ សមភាពខាងជំរឿន
- មាត្រា៤៤៖ សមភាពខាងសិទ្ធិលើកម្មសិទ្ធិ
- មាត្រា៤៥៖ សមភាពក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ។

### ៩.៣.៦.៣- ស្ត្រីក្នុងវិស័យសាធារណៈ និងនយោបាយ

បន្ទាប់ពីរួចផុតពីរបបអាណានិគមបារាំងឆ្នាំ១៩៥៣ ដល់បច្ចុប្បន្ននេះប្រទេសកម្ពុជាបានឆ្លងកាត់របបគ្រប់គ្រងប្រទេសជាច្រើនដំណាក់កាលទៅតាមរបបនយោបាយនីមួយៗ។

ចាប់ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០ ប្រទេសកម្ពុជាស្ថិតនៅក្នុងរបបនយោបាយរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រសោយរាជ្យ និងជាប្រមុខដឹកនាំប្រទេស។ របបនេះត្រូវផ្តួលរំលំក្រោមរដ្ឋប្រហារនៅឆ្នាំ១៩៧០ដែលដឹកនាំដោយឧត្តមសេនីយ៍ **លន់ នល់** ហើយដាក់ប្រទេសកម្ពុជានៅក្នុងរបបសាធារណរដ្ឋវិញ។

ឆ្នាំ១៩៧៥ របបសាធារណរដ្ឋត្រូវបានបរាជ័យដោយកងកម្លាំងយោធាខ្មែរក្រហមដែលដឹកនាំ ដោយ **ប៉ុល ពត** ហើយប្រទេសកម្ពុជាបានប្តូរទៅកាន់

របបប្រល័យពូជសាសន៍ក្រោមឈ្មោះ **កម្ពុជាប្រជាធិបតេយ្យ** ដែលត្រូវបានផ្តួលរំលំដោយកងកម្លាំងខ្មែរអ្នកតស៊ូ ក្រោមការជួយគាំទ្រពីកងកម្លាំងយោធាវៀតណាម នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់មកប្រទេសកម្ពុជាបានប្រកាន់យករបបនយោបាយថ្មីទៀតដែលមានឈ្មោះថា **សាធារណរដ្ឋប្រជាមានិតកម្ពុជា** និងបានប្តូរមកជា **រដ្ឋកម្ពុជា** នៅឆ្នាំ១៩៨៨។

ទសវត្សទី៩០ បញ្ហាកម្ពុជាត្រូវបានមជ្ឈដ្ឋានអន្តរជាតិយកចិត្តទុកដាក់ជួយជ្រោមជ្រែងនិងផ្តល់លទ្ធភាពឱ្យភាគីជំលោះខ្មែរទាំង៤(ភាគីរដ្ឋកម្ពុជា រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រណសិរ្សរួបរួមជាតិកម្ពុជា កម្ពុជាប្រជាធិប-តេយ្យ) បានចូលរួមដោះស្រាយដោយសន្តិវិធីលើតុចរចា ដើម្បីពន្លត់ភ្លើងសង្គ្រាមដែលអូសបន្លាយជាយូរឆ្នាំមកហើយ)។

ថ្ងៃទី២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងអន្តរជាតិមួយនៅទីក្រុងប៉ារីសស្តីពីបញ្ហាសន្តិភាពនៅកម្ពុជា ត្រូវបានភាគីខ្មែរទាំងបួនបានចុះហត្ថលេខា ហើយស្ថិតក្នុងស្មារតីនេះបានបង្កើតឡើងនូវឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC)ដែលតំណាងអធិបតីភាពជាតិ និងមាននាទីដឹកនាំបង្រួបបង្រួមផ្សះផ្សាជាតិ។

អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ បានមានវត្តមាននៅកម្ពុជាចូលរួមត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង និងជួយរៀបចំការបោះឆ្នោតជាសកលនៅថ្ងៃទី២៣-២៨ ឧសភា ១៩៩៣។

ក្រោយបោះឆ្នោត សភាធម្មនុញ្ញបានបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍សភាមួយនាសម័យប្រជុំពេញអង្គលើកទី១ ថ្ងៃទី៣០ មិថុនា ១៩៩៣ ដើម្បីរៀបរៀងរដ្ឋធម្មនុញ្ញដែលតំណាងឱ្យឆន្ទៈប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ហើយ

ដែលត្រូវបានអនុម័តនៅថ្ងៃទី២១ កញ្ញា ១៩៩៣។ រដ្ឋសភាត្រូវបានបង្កើតឡើង ដែលបដិសន្ធិដល់រាជរដ្ឋាភិបាលដឹកនាំដោយ នាយករដ្ឋមន្ត្រី២រូប ក្នុងអណត្តិ១៩៩៣ ដល់ ១៩៩៨។

ប្រព័ន្ធអភិបាលកិច្ចបច្ចុប្បន្ន បានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលបានចែងថា *សិទ្ធិរបស់ពលរដ្ឋកម្ពុជាបានការពារតាមរយៈស្ថាប័ន៣ផ្សេងៗគ្នាគឺ អង្គនីតិប្រតិបត្តិ និងអង្គតុលាការ។* អង្គនីតិបញ្ញតិ មានរដ្ឋសភា និងព្រឹទ្ធសភា។ រដ្ឋសភាគឺបានបង្កើតឡើងតាមរយៈការបោះឆ្នោតជាលក្ខណៈសកលរៀងរាល់ប្រាំឆ្នាំម្តង ហើយចំណែកឯព្រឹទ្ធសភាវិញបានបង្កើតឡើងតាមរយៈការបោះឆ្នោតជាលក្ខណៈអសកលរៀងរាល់ប្រាំឆ្នាំម្តងដែរ។ អង្គនីតិប្រតិបត្តិរួបរួមរដ្ឋបាលស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលមានស្ថាប័នកំពូលមួយពីគណៈរដ្ឋមន្ត្រីដែលដឹកនាំដោយនាយករដ្ឋមន្ត្រី។ គណៈរដ្ឋមន្ត្រីនេះ រួមមានក្រសួងពាក់ព័ន្ធចំនួន២៥ និងរដ្ឋលេខាធិការដ្ឋានចំនួន២។ អង្គតុលាការគឺជាស្ថាប័នឯករាជ្យ១ដាច់ដោយឡែកពីអង្គនីតិបញ្ញតិ និងអង្គនីតិប្រតិបត្តិដែលមានតួនាទីក្នុងការវិនិច្ឆ័យទោសដោយប្រើប្រាស់ច្បាប់ និងគោលនយោបាយដែលអនុលោមទៅតាមច្បាប់រដ្ឋធម្មនុញ្ញ ដោយដែលដាក់ប្រយោជន៍ប្រជាពលរដ្ឋជាចម្បង។ ចៅក្រមត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ដោយមានសំណើរពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានព្រះមហាក្សត្រគង់ជាព្រះប្រធានអធិបតី។

រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់ការងារវិមជ្ឈការ និងវិសហមជ្ឈការមួយ ដែលមានភាពទូលំទូលាយ ដោយបង្កើតឡើងឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់លើទីមួយនៅឆ្នាំ២០០២ និង

លើកទីពីរ ឆ្នាំ២០០៧។ អភិបាលកិច្ចថ្នាក់ក្រោមជាតិនៅតែបន្តធ្វើការវិវត្តរបស់ខ្លួនទៅមុខជាបណ្តើរៗ តាមរយៈច្បាប់ថ្មីស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ ដែលនឹងការប្រគល់ការទទួលខុសត្រូវ កាន់តែច្រើនឡើងៗដល់ថ្នាក់រាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងឃុំ-សង្កាត់។

ជំពូកនេះនឹងបរិយាយពីគម្លាតយេនឌ័រនៅក្នុងស្ថាប័នកំពូលៗទាំងបីរបស់រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការវិភាគទៅលើសកម្មភាពនានាដែលបានអនុវត្តឱកាស និងឧបសគ្គផ្សេងៗដែលរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចក្នុងរដ្ឋបាលសាធារណៈ។

ការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យសាធារណៈនិងថ្នាក់ធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ត្រូវបានចាត់ទុកជាចំណុចអាទិភាពក្នុងកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណ គោលនយោបាយតាមវិស័យការងារកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីមជ្ឈការនិងវិសហមជ្ឈការ រួមទាំងក្នុងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅតាមវិស័យ នៅតាមក្រសួង-ស្ថាប័ន។

ក្រសួង-ស្ថាប័នភាគច្រើន បានអនុវត្តគោលការណ៍ជ្រើសរើសមន្ត្រីរាជការថ្មី ដែលយកចិត្តទុកដាក់បង្កើនចំនួនមន្ត្រីរាជការជាស្ត្រី ជាពិសេសលើការកំណត់ជ្រើសរើសមន្ត្រីរាជការជាស្ត្រី ពី២០% ទៅ៥០% ក្នុងក្របខណ្ឌថ្មី ការអនុវត្តព្រះរាជក្រឹត្យស្តីពីការពន្យារអាយុនៃការចូលនិវត្តន៍របស់មន្ត្រីរាជការជាស្ត្រី ដល់អាយុ៦០ឆ្នាំ និងវិធានការតែងតាំងស្ត្រីនៅក្នុងរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងយ៉ាងតិច១រូប នៅក្នុងក្រសួង-ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត។ ជាក់ស្តែងកាលពីឆ្នាំ២០១៨ នៅកម្ពុជាមានមន្ត្រីរាជការជាស្ត្រីមាន៤១% ក្នុងចំណោមមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងស្ត្រី

ជាថ្នាក់ដឹកនាំដែលមានតួនាទីចាប់ពីអនុប្រធានការិយាល័យដល់អគ្គនាយកមាន២៤%។ នៅក្នុងគណៈអភិបាលរាជធានីខេត្តមាន ស្ត្រី២រូបជាអភិបាលខេត្ត(ស្មើ៤%) អភិបាលរង២៦រូប(ស្មើ១៧,៤៤%)។ នៅក្នុងគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានអភិបាលក្រុង ស្រុក ខណ្ឌ ចំនួន៦រូបជាស្ត្រី(ស្មើ៣,០៦%) និងអភិបាលរងក្រុង ស្រុក ខណ្ឌជាស្ត្រីមានចំនួន១៩៤រូប(ស្មើ២៥,៥២%)។

ក្រសួងកិច្ចការនារី ក្នុងភាពជាដៃគូជាមួយសាលាភូមិន្ទរដ្ឋបាល ក្រសួង-ស្ថាប័នដែលពាក់ពន្ធ និងសាលាជាតិរដ្ឋបាលមូលដ្ឋាន បានរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំរបស់ស្ត្រី ជាអាទិ៍ក្នុងឆ្នាំ២០១៦ សាលាភូមិន្ទ-រដ្ឋបាល បណ្តុះបណ្តាលថ្នាក់ដឹកនាំជាស្ត្រី មកពីគ្រប់ក្រសួង-ស្ថាប័នសុរប៨៣រូប មានឋានៈជារដ្ឋលេខាធិការ ៣៣រូប និងអនុរដ្ឋលេខាធិការ ៥០រូបប្រកបដោយជោគជ័យ។ ក្រសួងកិច្ចការនារី បានពង្រឹងបណ្តាញ និងអភិវឌ្ឍសមត្ថភាពស្ត្រីជាសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អភិបាល និងអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ដឹកនាំមន្ទីរកិច្ចការនារីដែលមានចំនួនសរុប៩៣៣រូប។

កម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការជំរុញការគាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយនិងភាពជាអ្នកដឹកនាំ បានរៀបចំនិងផ្សព្វផ្សាយនៅក្នុងបណ្តាញសង្គមនិងតាមសហគមន៍ដោយមានការចូលរួមភាពជាដៃគូជាមួយសង្គមស៊ីវិល និងដៃគូពាក់ព័ន្ធនៅគ្រប់កម្រិត។

ក្រសួងបានបង្កើតក្រុមការងារបច្ចេកទេសស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ច(TWGG-WLG) នៅឆ្នាំ២០១៥ ដែលជាផ្នែកមួយនៃក្រុម

ការងារបច្ចេកទេសយេនឌ័រ(TWG-G) ក្នុងគោលបំណងសម្របសម្រួលការលើកកម្ពស់ស្ត្រីក្នុងថ្នាក់ធ្វើសេចក្ដីសម្រេច និងពង្រឹងសមភាពយេនឌ័រនៅក្នុងដំណើរការអភិបាលកិច្ច ដែលមានសមាសភាពមកពីក្រសួង-ស្ថាប័ន(ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួងអប់រំ យុវជននិងកីឡា លេខាធិការ-ដ្ឋាន គ.ជ.អ.ប អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ ក.ជ.ក.ស និងសាលាភូមិន្ទរដ្ឋ-បាល) តំណាងដៃគូអភិវឌ្ឍន៍(UNDP, UN Women, Oxfam) និងតំណាងសង្គមស៊ីវិល។ ក្រុមការងារបានរៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាស ដើម្បីពិនិត្យលើវឌ្ឍនភាពក្នុងការអនុវត្តការងារ និងចែករំលែកបទពិសោធន៍ទាក់ទងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់នានា។

ក្នុងភាពជាដៃគូរវាងក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាវិធានការជំរុញនិងធានាថារាល់ការយកចិត្តទុកដាក់ពាក់ព័ន្ធការលើកកម្ពស់សមភាពយេនឌ័រ ដែលកំណត់ក្នុងក្របខណ្ឌកម្មវិធីជាតិត្រូវបានអនុវត្ត និងធ្វើស្ថាប័ននីយកម្មឱ្យកាន់តែពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

### *ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយនិងកម្មវិធីកំណែទម្រង់រាជរដ្ឋាភិបាល*

គោលនយោបាយជាតិជាច្រើនបានដាក់ចេញនូវការការពារសិទ្ធិរបស់ស្ត្រី និងការឆ្លើយតបសមភាពយេនឌ័រ មានដូចជា គោលនយោបាយអភិវឌ្ឍយុវជនកម្ពុជា គោលនយោបាយជាតិស្ដីពីការសិក្សាពេញមួយជីវិត គោលនយោបាយជាតិប្រជាជន ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម គោល

នយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មុខរបរ និងការងារ ការអភិវឌ្ឍបៃតង រួមទាំងកម្មវិធីនិងលិខិតបទដ្ឋានគតិយុត្តលើការងារកំណែទម្រង់រដ្ឋបាលសាធារណៈនិងកម្មវិធីវិមជ្ឈការនិងវិសហមជ្ឈការ។

យេនឌ័របានបញ្ជ្រាបនិងជំរុញការអនុវត្តនៅក្នុងកម្មវិធីកំណែទម្រង់ជាតិសំខាន់ៗ ដូចជាកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិ១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តជាបន្តបន្ទាប់។

ការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងការពង្រឹងយន្តការបញ្ជ្រាបយេនឌ័ររួមបញ្ចូលទាំងក្រុមការងារបច្ចេកទេសយេនឌ័រ ដែលជាផ្នែកមួយនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ និងដំណើរការរបស់ក្រុមការងារយេនឌ័រតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ។ គិតត្រឹមឆ្នាំ២០១៨ ក្រសួង-ស្ថាប័នចំនួន២៨ក្នុងចំណោម៣០ បានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារនៅថ្នាក់មូលដ្ឋាន។

**បញ្ហាប្រឈម និងភាពលំនុវត្តភាព**

- និន្នាការនៃការកើនឡើងតំណាងស្ត្រីក្នុងវិស័យនយោបាយនៅមានកម្រិតនៅឡើយបើធៀបនឹងការចូលរួមនៅក្នុងវិស័យសេដ្ឋកិច្ចនិងសាធារណៈ។
- ផ្នត់គំនិតរបស់សង្គមដែលបន្តចាត់ទុកការងារផ្ទះសម្បែងនិងការមើលថែទាំគ្រួសារជាកាតព្វកិច្ចរបស់ស្ត្រី បានរារាំងជាចម្បងដល់ស្ត្រី មិនអាចអនុវត្តសិទ្ធិ និងប្រើប្រាស់សក្តានុពលពេញលេញលើកិច្ចការក្នុងវិស័យសាធារណៈ និងភាពជាអ្នកដឹកនាំ។

- ការគាំទ្រនៅកន្លែងធ្វើការងារដែលមានលក្ខណៈទន់ភ្លន់ និងបត់បែន ដែលលើកកម្ពស់តុល្យភាពជីវិតនិងការងារ ជាកត្តាលើកទឹកចិត្តស្ត្រីចូលបំពេញការងារប្រកបដោយផលិតភាព និងប្រសិទ្ធផល។

- បន្តលើកកម្ពស់ការចូលរួមរបស់ស្ត្រីជាតំណាង ក្នុងការអនុវត្តមុខងារតាមវិស័យរបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងអភិវឌ្ឍសមត្ថភាពពួកគេជាប្រចាំទៅតាមតម្រូវការ។

- គណនេយ្យភាពរបស់ក្រសួង-ស្ថាប័នក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើទំនើបកម្ម ស្ថាប័ននីយកម្ម ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រមិនទាន់បានពេញលេញនិងទូទាំងវិស័យ។

- ភាពចាំបាច់ក្នុងការអភិវឌ្ឍសមត្ថភាព និងការអនុវត្តមុខងាររបស់យន្តការបញ្ជ្រាបយេនឌ័រគ្រប់កម្រិតនិងពង្រឹងក្របខណ្ឌត្រួតពិនិត្យតាមដាន និងវាយតម្លៃតាមវិស័យ។

- តម្រូវការពង្រឹង និងពង្រីកប្រព័ន្ធចងក្រង ចែករំលែកបទពិសោធ និងលើកទឹកចិត្តដល់កិច្ចការដែលបានអនុវត្ត។

- តម្រូវការរៀបចំឯកសារគោលការណ៍ណែនាំជាតិ ស្តីពី ការបញ្ជ្រាបយេនឌ័រក្នុងវិស័យ ដែលជាជំនួយបច្ចេកទេសដល់ក្រសួង-ស្ថាប័នលើការងារបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យនិងអង្គភាពរបស់ខ្លួន។

- ការថយចុះជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍ(ODA)លើគ្រប់វិស័យរួមទាំងការងារយេនឌ័រដែលចាំបាច់ត្រូវការស្វែងរកកាលានុវត្តភាពថ្មីៗបន្ថែមទៀត រួមទាំងលើកកម្ពស់ការចូលរួមពីវិស័យឯកជននិងថវិកាជាតិ។

រាជរដ្ឋាភិបាលកម្ពុជាបានបន្តយកចិត្តទុកដាក់បង្កើនសមាមាត្រស្ត្រីក្នុងការដឹកនាំនិងថ្នាក់ធ្វើសេចក្តីសម្រេចនៅថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីចូលរួមលើកកម្ពស់ពង្រឹងអភិបាលកិច្ចប្រកបដោយបរិយាប័ន្ន។

## ១០- ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច

យើងសង្កេតឃើញថា ស្ត្រីក្នុងតួនាទីធ្វើការសម្រេចចិត្តនៅមានកម្រិតពោលគឺមានចំនួនតិចនៅឡើយ បើយើងធ្វើការប្រៀបធៀបទៅនឹងចំនួនស្ត្រីសរុបដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន ប៉ុន្តែនេះក៏ជាសញ្ញាមួយដែលបានបញ្ជាក់អំពីសមត្ថភាពស្ត្រីបានដើរតួនាទីជាអ្នកធ្វើសេចក្តីសម្រេចផងដែរ ដែលក្នុងនោះកាលពីឆ្នាំ២០២០ យើងឃើញមាន៖

. ក្រុមប្រឹក្សាធម្មនុញ្ញស្រី ចំនួន២នាក់
. ស្ត្រីជាសមាជិកព្រឹទ្ធសភា ចំនួន១០នាក់ (១៦.១៣%)
. ស្ត្រីជាសមាជិករដ្ឋសភា ចំនួន២៦នាក់ (២០.៨០%)
. ស្ត្រីជារដ្ឋមន្ត្រី ចំនួន៣នាក់ (១០.៣៤%)
. ស្ត្រីជារដ្ឋលេខាធិការ ចំនួន៥៩នាក់
. ស្ត្រីជាអនុរដ្ឋលេខាធិការ ចំនួន៧៥នាក់
. ស្ត្រីជាអភិបាលខេត្ត ចំនួន២នាក់
. ស្ត្រីជាអភិបាលខេត្តរងខេត្ត រាជធានី ចំនួន២៥នាក់
. ស្ត្រីជាអភិបាលស្រុក ក្រុង ចំនួន៧នាក់
. ស្ត្រីជាអភិបាលរងស្រុក ក្រុង ចំនួន១៩៤នាក់
. ស្ត្រីជាប្រធានក្រុមព្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន៥នាក់
. ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន៦១៧នាក់

. ស្ត្រីជាមេឃុំ ចៅសង្កាត់ ចំនួន១៣០នាក់ (៧.៨៩%)
. ស្ត្រីជាជំទប់ទី១ ចំនួន២៧២នាក់ (១៦.៣១%)
. ស្ត្រីជាជំទប់ទី២ ចំនួន២៨៥នាក់ (១៧.៣១%)
. ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ ចំនួន១,៦១១នាក់ (១៤%)
. ស្ត្រីជាចៅក្រម ចំនួន៤៦នាក់ (១៥.២៨%(២០១៩)
. ស្ត្រីជាព្រះរាជអាជ្ញា ចំនួន២៥នាក់ (១៣.៥១%)
. ស្ត្រីជាក្រឡាបញ្ជី ចំនួន១៨៩នាក់ (២២.៧%)
. ស្ត្រីជាមន្ត្រីរាជការ ចំនួន៤១% (២០២០)
. និងស្ត្រីជាមន្ត្រីរាជាការដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យតាមស្រុក ដល់ថ្នាក់អគ្គនាយក ចំនួន២៦% (២០២០)។

ក្នុងអង្គនីតិបញ្ញត្តិ នៅក្នុងអាណត្តិទី៦ នៃរដ្ឋសភាមានស្ត្រីចំនួន១រូប ជាអនុប្រធានរដ្ឋសភាស្ត្រីចំនួន២រូប ជាប្រធានគណកម្មការ និងស្ត្រីចំនួន៤រូប ជាអនុប្រធានគណៈកម្មការ។ នៅក្នុងអាណត្តិទី៤នៃព្រឹទ្ធសភា មានស្ត្រីជាប្រធានគណៈកម្មការចំនួន២រូប ក្នុងចំណោម១០រូប។ នៅក្នុងអាណត្តិទី៥នៃឆ្នាំ១៩៨៨ សមាគមនារីបដិវត្តន៍កម្ពុជាបានរៀបចំមហាសន្និបាតលើកទី២ ដើម្បីលើកទិសដៅសម្រាប់អនុវត្តបន្ត និងបានប្តូរឈ្មោះមកជា "សមាគមនារីកម្ពុជា"។

សមាគមត្រូវបានទទួលស្គាល់ជាអង្គការមិនមែនរដ្ឋាភិបាលជាផ្លូវការពីទីស្តីការគណៈរដ្ឋមន្ត្រីតាមលិខិតលេខ១៣២សជណ.ផក ចុះថ្ងៃទី២៤ មករា ឆ្នាំ១៩៩៤ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០០។

## ១១- តួនាទីស្ត្រី និងច្បាប់

ចំពោះតួនាទីស្ត្រីនិងច្បាប់គឺស្ត្រីមានសិទ្ធិក្នុងការប្ដឹងតវ៉ាដើម្បីរកយុត្តិធម៌ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ហើយក្ដីរបស់គេនឹងត្រូវបានដោះស្រាយដោយនីតិវិធីដូចគ្នា។ មាត្រា៣៩នៃរដ្ឋធម្មនុញ្ញចែងថា *ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្ដឹងតវ៉ា មានសិទ្ធិប្ដឹងបរិហា ឬប្ដឹងទារសំណងជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការសង្គម ឬរបស់បុគ្គលិកនៃអង្គការទាំងនោះ។* មាត្រា៣៨នៃរដ្ឋធម្មនុញ្ញចែងថា *ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយរបស់ជនណាមួយឡើយ។* ប៉ុន្តែការជាក់ស្ដែងក្នុងគ្រួសារដែលមានអំពើហិង្សាកើតឡើង ស្ត្រីជាភរិយាពុំមានលទ្ធភាពអនុវត្តសិទ្ធិនេះទេ ដោយសារការប្រើប្រាស់សិទ្ធិនេះ គឺជាការពិបាកសម្រាប់ស្ត្រីភេទ។

តុលាការជាស្ថាប័នមានសមត្ថកិច្ចក្នុងការស្វែងរកយុត្តិធម៌ តែការអនុវត្តជាក់ស្ដែង មានចៅក្រមនិងព្រះរាជអាជ្ញាមួយចំនួនមិនសូវបានយកចិត្តទុកដាក់ចំពោះនារីទេ គឺមានការរើសអើងចំពោះ "នារី" ។

ច្បាប់បានការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ការកាត់ទោស ការចាប់ខ្លួន ការឃាត់ខ្លួនបុគ្គលណាមួយ ត្រូវបានហាមឃាត់ លើកលែងតែបានធ្វើឡើងដោយអនុលោមទៅតាមច្បាប់។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រតិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មទៅលើជនជាប់ការឃុំឃាំង ឬជាប់ពន្ធនាគារត្រូវបានហាមឃាត់។ បុគ្គលដែលជាអ្នកដៃដល់ អ្នកចូលរួមប្រព្រឹត្ត ឬផ្សំគំនិតនៅក្នុងសកម្មភាពបែបនេះ ត្រូវបានទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយចិត្តក្ដីមិនត្រូវទទួលយកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ ជនជាប់ចោទ

មិនត្រូវបានចាត់ទុកថាជាមនុស្សមានទោសទេ ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ដើម្បីធានានូវនិតិវិធីត្រឹមត្រូវនិងយុត្តិធម៌ រាជរដ្ឋាភិបាលបានអនុម័តច្បាប់ស្ដីពី **និតិវិធីព្រហ្មទណ្ឌ នីតិវិធីរដ្ឋប្បវេណី** និង**នីតិវិធីអនុវត្តសាលក្រម** នៅឆ្នាំ ១៩៩៣ ដែលនឹងត្រូវជំនួសដោយច្បាប់ថ្មីៗដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការពិនិត្យរបស់ក្រសួងយុត្តិធម៌ ហើយតុលាការនៅគ្រប់ជាន់ថ្នាក់ទាំងអស់ត្រូវអនុវត្តនីតិវិធីនោះនៅលើមូលដ្ឋាននៃសមភាព និងភាពគ្មានការរើសអើង។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជំរុញការអប់រំផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងអំពីរដ្ឋធម្មនុញ្ញច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណី ព្រមទាំងការយល់ដឹងអំពីសិទ្ធិនិងការប្រើប្រាស់សិទ្ធិរបស់ខ្លួននៅក្នុងប្រព័ន្ធតុលាការ។ មានការទទួលស្គាល់ថា លទ្ធភាពទទួលពត៌មានគឺនៅមានកម្រិតនៅឡើយសម្រាប់ស្ត្រីភេទ។ ដូច្នេះស្ត្រីត្រូវបានលើកទឹកចិត្តជាពិសេសឱ្យអនុវត្តសិទ្ធិ និងលើកឡើងនូវការតវ៉ារបស់ខ្លួនចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់។ នៅតាមជនបទចំនួនស្ត្រីកាន់តែមានច្រើនឡើងៗដែលបានរាយការណ៍ទៅកាន់ប៉ូលីសអំពីករណីអំពើហិង្សាក្នុងគ្រួសារ និងអំពីអំពើរំលោភសេពសន្ថវៈ។

## ១២- តម្លៃអប់រំស្ត្រីតាមទស្សនៈព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនាបានចាប់កំណើតឡើងនៅលើទឹកដីកម្ពុជា តាំងពីសតវត្សទី៥មកម៉្លេះ ដោយមានប្រភពខ្លះបានបង្ហាញថានៅសតវត្សទី៣នៃគ្រិស្តសករាជ និងឯកសារខ្លះទៀតបង្ហាញថា ព្រះពុទ្ធសាសនាថេរវាទត្រូវបាននាំចូលមកលើទឹកដីកម្ពុជាក្នុងរាជព្រះបាទអសោក ដែលបានបញ្ជូនសមណទូត២អង្គព្រះនាម **សោណត្ថេរ** និង**ឧត្តរត្ថេរ** មកកាន់ទឹកដីសុវណ្ណភូមិតាំងពី

សតវត្សទី៣មុនគ្រិស្តសករាជ។ សាសនានេះបានបន្តរីកចម្រើនបន្តិចម្តងៗ ជាមួយនឹងព្រហ្មញ្ញសាសនា ដូចមានសិលាចារឹកមួយនៅលើទឹកដីវៀតណាម សព្វថ្ងៃ គឺសិលាចារឹកវ៉ូកាញ់ ខេត្តញ៉ាត្រាង ចុះកាលបរិច្ឆេទនាសតវត្សទី៣ ដែលបាននិយាយពីព្រះមហាក្សត្រ គឺព្រះបាទ**ស្រីមារៈ** ទាក់ទងទៅនឹងពុទ្ធសាសនានេះ។ ក្រៅពីការចូលមកកាន់ទឹកដីខ្មែរតាមរយៈអ្នកផ្សព្វផ្សាយទាំងនោះ ពុទ្ធសាសនាក៏ត្រូវបានមកតាមរយៈពួកអ្នកជំនួញឥណ្ឌាផងដែរ ហើយចាប់ពីសតវត្សទី១៣រៀងមក លើកលែងតែសម័យដែលខ្មែរក្រហមគ្រប់គ្រងអំណាច។ បច្ចុប្បន្នព្រះពុទ្ធសាសនាបានក្លាយទៅជាសាសនារបស់រដ្ឋ ដែលមានពុទ្ធសាសនិកជាខ្មែរប្រមាណជា៩០% នៃប្រជាជនសរុបដែលបានគោរពជឿ និងមានលក្ខណៈអប់រំទូន្មានជន្មានុជនប្រកបដោយធម្មចរិយាគ្រប់ប្រភេទនៃបុគ្គលក្នុងសង្គម។

## ១២.១- សង្គហធម៌របស់ស្វាមីចំពោះភរិយា៥យ៉ាង

បើនិយាយអំពីសង្គហធម៌របស់ស្វាមីចំពោះភរិយា ព្រះពុទ្ធបានចែងអំពីតួនាទីស្វាមីចំពោះភរិយាដោយធម៌ប្រាំយ៉ាង ដើម្បីបានជាប្រយោជន៍ដែលគួរឱ្យយើងយល់ ដែលក្នុងនោះមាន៖

១- **សម្មាននាយ** បុរសគួរគប្បីស្រឡាញ់រាប់អានថាជាភរិយារបស់ខ្លួន។ យើងជាស្វាមីរបស់ស្ត្រីណា យើងគួរគប្បីសង្គ្រោះស្ត្រីនោះ ដោយចិត្តស្មោះត្រង់ គឺលើកតម្កើងជាភរិយាពេញសិទ្ធិដែលមិនអាចមានស្ត្រីផ្សេងមានសិទ្ធិស្មើភរិយានោះឡើយ។

២- **អវិមាននាយ** បុរសជាស្វាមីមិនគួរប្រមាថមើលងាយភរិយាដូចជាខ្ញុំកំដរបាវព្រាវនោះទេ។ ខណៈពោលទៅកាន់ភរិយា បុរសជាស្វាមីគួរគប្បី

ពោលពាក្យសំដីផ្អែមល្ហែម ពីរោះពិសា មិនពោលពាក្យរោយរាយ ឥត ប្រយោជន៍ បើភរិយាមានកំហុងឆ្គងបន្តិចបន្តួច ក៏គួរអន់ឱនឱ្យ ហើយទូន្មាន ប្រៀនប្រដៅស្ងាត់ៗដោយសេចក្ដីល្អ។

៣- **អនតិចរិយាយ** ស្វាមីមិនប្រព្រឹត្តកន្លងចិត្តភរិយា គឺមិនប្រព្រឹត្តក្បត់ ព្រំដែនជាប្ដី ដោយយកបេះដូងរបស់ខ្លួនដែលមានម្ចាស់ហើយទៅបូជាដល់ស្ត្រី ដទៃ ដូចពាក្យចាស់បុរាណាចារ្យលោកបានពោលថា "**ត្រីងៀតឆ្កៀតពង**"។

៤- **ឥស្សរិយវោស្សគ្គេន** ស្វាមីត្រូវប្រគល់អំណាចជាធំចំពោះភរិយា ជា ស្ត្រីមេផ្ទះ រៀបចំទុកដាក់លុយកាក់ទ្រព្យសម្បត្តិ រក្សាថែទាំ លំអគេហដ្ឋានឱ្យ មានសិរីសួស្ដី។

៥- **អលង្ការានុប្បទានេន** ក្នុងនាមជាស្វាមី គប្បីរៀបចំឱ្យមានគ្រឿង អលង្ការដល់ភរិយាគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់តាមកាលៈទេសៈ តាមសម័យ និយម និងតាមសមត្ថភាព។[៥៥]

ត្រង់ចំណុចទី១ ទី២ និងទី៣ ជាការថ្នមចិត្តស្ត្រីជាភរិយា ដោយលើក តម្កើងថា ជាភរិយាពេញមុខ មិនប្រទុស្តរ៉ាយទឹកចិត្តរបស់នាងឡើយ។ ការមិន មើលងាយ វាអាចទាក់ទងនឹងរូបរាងកាយ មុខមាត់ ឬក៏ការខ្វះខាតដោយប្រការ ខ្លះរបស់នាងដោយយកមេត្តាករុណា គុណធម៌ដទៃទៀត មកជំនួសសេចក្ដី ស្រលាញ់ ស្នេហាដែលចុះខ្សោយទៅនោះ ព្រោះថាការមិនមើលងាយ គឺជា ទេវតារក្សាជីវិតនាង។ ភាពស្មោះស្ម័គ្ររបស់ស្វាមី ជាសេចក្ដីសុខរបស់ភរិយា ជាការប្រោះព្រំនូវទឹកអម្រឹតដល់បេះដូង និងដើមទ្រូងនាងមិនឱ្យក្ដៅងំដូចជា រងើកភ្លើងនេះឯង។ ចំណុចទី៤ ជាការបែងចែកតួនាទីឱ្យភរិយា ប្រគល់ភាពជា

[55] https://5000-years.org/kh/read/2320

ធំក្នុងផ្ទះឱ្យទទួលខុសត្រូវក្នុងការងារ ភាពល្អិតល្អន់ចាប់ផ្ដើមតាំងពីការថែរក្សាទុកដាក់ទ្រព្យសម្បត្តិគ្រប់គ្រងកូនប្រុសស្រីជាដើមទៅ (ពោលចំពោះតែភរិយានៅផ្ទះ ឯស្វាមីប្ដីចេញទៅរកទ្រព្យប៉ុណ្ណោះ)។ ចំណុចទី៥ ជាការឱ្យកម្លាំងចិត្តដល់ភរិយា គឺការឱ្យភរិយានូវគ្រឿងប្រដាប់កាយ តែងខ្លួនបានសមគួរតាមឋានៈ។ នេះជាការថែរក្សាទំនុកបម្រុងទឹកចិត្តរបស់នាង និងដើម្បីសេចក្ដីសុខក្នុងការគ្រប់គ្រងផ្ទះទាំងអស់គ្នា។ ស្វាមីថ្នមចិត្តភរិយា ប្រគល់ភាពជាធំក្នុងផ្ទះ និងទំនុកបម្រុងទឹកចិត្តដូចដែលពោលហើយនេះឱ្យដល់ភរិយាទៅបាននោះ ក៏ព្រោះតែភរិយាបានបដិបត្តិតួនាទីរបស់ខ្លួនឆ្លើយតបទៅស្វាមីក្នុងភាពជាស្រីល្អ គឺល្អដោយបញ្ញាឆ្លាតវៃ ទឹកចិត្តទូលាយចេះសង្គ្រោះញាតិ ស្មោះត្រង់ មានអំណត់អត់ធ្មត់គ្រប់ភារកិច្ច និងលម្អទៅដោយសេចក្ដីឧស្សាហ៍ខ្មីឃ្មាតនៅក្នុងតួនាទីរបស់ខ្លួន។ ដូចមានសេចក្ដីបញ្ជាក់ថា៖

នាមជាស្វាមី ត្រូវមានករុណា
ចំពោះភរិយា ត្រូវចេះថ្នាក់ថ្នម
បីបមការពារ ខុសត្រូវអធ្យា
ដោយធម៌ប្រាំយ៉ាង។
ទីមួយករុណា ស្រឡាញ់ភរិយា
ដោយចិត្តភក្ដី ទោះមានកំហុស
ឆ្គងខុសម្ដេចក្ដី ត្រូវចេះខន្តី
ប្រណីទោសា។
ទីពីរពោលស្ដី ដោយពាក្យសម្ដី
ទន់ភ្លន់វាចា មិនត្រូវមើលងាយ

ពោលវាយប្រហារ បន្ទោកចរិយា
ភរិយាខ្លួនឯង។
ទីបីស្មោះត្រង់ មិនត្រូវបោះបង់
ក្បត់ចិត្តភរិយា ត្រូវតែរួមស្នេហ៍
រួមរក្សគ្រប់គ្រា លុះក្សយជន្មា
នៅតែស្រឡាញ់។
ទីបួនប្រគល់ តំណែងវិបុល
ងារស្រីមេផ្ទះ ឱ្យដល់ភរិយា
បញ្ជាប្រើប្រាស់ ពេញគ្រប់លក្ខណៈ
បម្រើគ្រួសារ។
ទីប្រាំជួយផ្តល់ វត្ថុមង្គល
គ្រឿងអលង្ការ សម្រាប់ចាត់ចែង
តុបតែងកាយា ជូនដល់ភរិយា
ក្នុងគ្រប់ពិធី។

## ១២.២- សង្គហធម៌របស់ភរិយាចំពោះស្វាមី៥យ៉ាង

ក្នុងសង្គហធម៌ក៏បានចែងថាតួនាទីភរិយាចំពោះស្វាមីផងដែរ គឺភរិយាឬប្រពន្ធត្រូវមានមុខងារបម្រើស្វាមីដោយចិត្តស្មោះស្នេហ៍តាមធម៌៥យ៉ាង៖

- ត្រូវចេះទុកដាក់របស់ទ្រព្យ និងចេះសន្សំសំចៃ
- ត្រូវចេះរាប់អានញាតិខាងប្តីដូចជាញាតិខាងខ្លួនដែរ
- ត្រូវចេះរក្សាទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីរកបានឱ្យបានគង់វង្ស

- ត្រូវចេះស្រលាញ់ប្តី
- ត្រូវចេះចាត់ចែងការងារនៅក្នុងគ្រួសារឱ្យបានសមរម្យ

ដូចមានសេចក្តីពិស្តាដាកំណាព្យដូចតទៅ៖

ខ្លួនជាភរិយា ត្រូវមានមុខងារ
បម្រើស្វាមី ដោយចិត្តស្មោះស្ម័គ្រ
រួមរក្សមេត្រី បំពេញករណី
ដូចបានបរិយាយ។
ទីមួយចាត់ការ នៅក្នុងគេហា
រាល់គ្រប់ករណី ដោយការសំចៃ
ចំណាយរូបីយ៍ បម្រើស្វាមី
នឹងក្រុមគ្រួសារ។
ទីពីររាប់អាន ញាតិផៅសណ្តាន
ប៉ែកខាងស្វាមី ដោយចិត្តស្មោះស
បវរមេត្រី ស្មើស្មោះភក្តី
មិនឱ្យមានហ្មង។
ទីបីរក្សា ទ្រព្យទាំងឡាយណា
ដែលប្តីរកបាន ទុកដាក់សម្ងាត់
សម្បត្តិដ៏ថ្កាន ចាយគិតប្រមាណ
កុំបីខ្ជះខ្ជាយ។
ទីបួនភក្តី ចំពោះស្វាមី
ដោយចិត្តស្ម័គ្រស្មោះ ទោះស្លាប់មិនក្បត់

ទោះព្រាត់មិនបោះ ចិត្តនៅតែស្មោះ

ចិត្តមួយថ្លើមមួយ។

ទីប្រាំសិក្សា រាល់គ្រប់កិច្ចការ

ឱ្យប៉ិនប្រសប់ កិច្ចការទាំងឡាយ

ប្រឹងច្នៃជាទ្រព្យ បរិបូរណ៍គ្រប់សព្វ

សាងក្ដីសុខសាន្ត។

## ១២.៣- ជីវភាពស្ត្រីនិងព្រះពុទ្ធសាសនា [៥៦]

តើព្រះពុទ្ធសាសនាមានទស្សនៈយ៉ាងណា ចំពោះស្ត្រីធ្វើការក្រៅផ្ទះ ស្ត្រីមិនមានស្វាមី និងស្ត្រីពេស្យា?

*- ស្ត្រីធ្វើការក្រៅផ្ទះ*

ព្រះពុទ្ធសាសនាក្នុងឋានៈជាស្ថាប័នមួយក្នុងសង្គម បានជ្រែកខ្លួនចូលមកក្នុងសង្គមមនុស្សនាសម័យនោះ មិនមែនជាស្ថាប័នផ្នែកគ្រប់គ្រង ដែលនឹងត្រូវមកមើលថែក្នុងការហូបចុករបស់ប្រជាជននោះឡើយ។ ព្រះពុទ្ធសាសនាជាស្ថាប័នផ្នែកសាសនា ដែលមានមុខងារខាងការអប់រំពន្យល់នូវព្រហ្មចរិយធម៌ ដើម្បីឱ្យដំណើរជីវិតបានប្រសើរឡើង។ ដូច្នេះព្រះពុទ្ធសាសនា មិនមានតួនាទីអ្វីកំណត់បែបបទតួនាទីឱ្យប្រជាជន ថាត្រូវធ្វើការងារអាជីពអ្វី ត្រូវធ្វើការងាកន្លែងណា ឬអ្នកណាត្រូវទៅធ្វើការក្រៅផ្ទះ ហើយអ្នកណាត្រូវធ្វើការនៅក្នុងផ្ទះយ៉ាងនេះជាដើមឡើយ។ ប៉ុន្តែព្រះពុទ្ធសាសនាបានអប់រំនូវគោលធម៌កណ្ដាលៗ ដែលអាចនាំយកទៅបដិបត្តិគ្រប់ការងារអាជីព គ្រប់ស្ថានទី និងគ្រប់

[៥៦] ប៊ុតសាវង្ស *ស្ត្រីក្នុងព្រះពុទ្ធសាសនា* ទំព័រ ៣២,៤៦ ព.ស ២៥៥១។

កាលសម័យ ដើម្បីឱ្យការងារនោះបានសម្រេចផលល្អបានត្រឹមត្រូវ។ គួរជ្រាប ផងដែរថា ការងារមនុស្សវាទៅតាមកាលសម័យនីមួយៗ មិនមែនសុទ្ធតែដូចគ្នា នោះទេ។ វាស្ថិតនៅត្រង់ថា មានហេតុ មានបច្ច័យយ៉ាងណា សង្គមបរិយាកាស យ៉ាងម៉េច វប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ការនិយមជំនឿប្រពៃណី ព្រម ដោយស្ថានការណ៍ក្នុងសង្គម សេដ្ឋកិច្ចគ្រួសារ។ល។ បុរសចេញទៅធ្វើការក្រៅ ផ្ទះតែម្នាក់ឯង រមែងមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារ ដូច្នេះរឿងចាំបាច់ក្នុង បញ្ហាសេដ្ឋកិច្ចតម្រូវឱ្យស្ត្រីចេញទៅធ្វើការក្រៅផ្ទះផងដែរ ទាំងដែលស្ត្រីឥឡូវ នេះបានឱកាសសិក្សាចេះដឹងច្រើន និងមានការកសាងខ្លួនឱ្យចម្រើនទៅគ្រប់ ផ្នែក ដូច្នេះបានធ្វើឱ្យស្ត្រីប្រើប្រាស់ចំណេះដឹងរបស់ខ្លួនក្នុងកិច្ចការសង្គមជាតិ ឱ្យកាន់ទូលំទូលាយបន្ថែមទៀត។

ចំពោះព្រះពុទ្ធសាសនាមិនបានប្រឆាំងអ្វីទៅនឹងការរកការងារខាង ក្រៅផ្ទះនោះឡើយ ហើយក៏មិនបានឱ្យតម្លៃតែលើបុរសនោះដែរ។ ព្រះពុទ្ធ សាសនាបានសម្ដែងគោលធម៌សម្រាប់ទាំងអស់គ្នា និងគ្រប់ការងារទាំងអស់ ដែលនាំឱ្យបានសម្រេចប្រយោជន៍ ទោះជាធ្វើនៅកន្លែងណាក៏ដោយ ពេល ណាក៏ដោយ គឺត្រូវមានគោលធម៌នៃឥទ្ធិបាទទាំង៤នេះ៖

(១)- ឆន្ទៈ = ពេញចិត្តក្នុងការងារ។

(២)- វិរិយៈ = ព្យាយាមធ្វើ។

(៣)- ចិត្តៈ = យកចិត្តទុកដាក់។

(៤)- វិមង្សាៈ = ចេះពិចារណាហេតុផល។

*. ស្ត្រីមិនមានស្វាមី*

ក្នុងសម័យពុទ្ធកាល មានស្ត្រីយ៉ាងច្រើនចូលបដិបត្តិកាន់ព្រះពុទ្ធសាសនា ក្នុងនោះមានស្ត្រីដែលអត់ស្វាមីមិនតិចនាក់ឡើយ។ ស្ត្រីខ្លះមិនយកស្វាមី ហើយចូលកាន់ផ្នួស ស្ត្រីខ្លះទៀតក៏មិនយកស្វាមីដែរ តែប្រព្រឹត្តព្រហ្មចរិយាក្នុងផ្ទះ និងស្ត្រីមេម៉ាយដោយប្រការផ្សេងៗ បានចូលមកកាន់ព្រះពុទ្ធសាសនា ហើយអាចទូន្មានខ្លួនឯងបានដោយល្អ រហូតដល់ថ្នាក់លោកុត្តរ ផុតកង្វល់ពីរឿងលើលោកិយទៀតផង។

ក្នុងបិដកលេខ៧៦ នាង**ខេមាថេរ** បាននិទានប្រាប់ពីរាជធីតាទាំង៧អង្គរបស់**ព្រះបាទកិកិ** ដែលគ្រប់គ្រងនគរពារាណសី ក្នុងសម័យព្រះសម្មាសម្ពុទ្ធកស្សបៈ មានសេចក្តីថា *ក្នុងកាលនោះខ្ញុំម្ចាស់ជាធីតាច្បងរបស់ព្រះរាជា ខ្ញុំម្ចាស់មាននាមប្រាកដថា* ***សមណី*** *បានស្តាប់ព្រះធម៌របស់ព្រះ**វិជិតមារ** ហើយក៏ពេញចិត្តចូលបព្វជ្ជា។ ដោយព្រះបិតាទ្រង់មិនអនុញ្ញាតឱ្យខ្ញុំម្ចាស់ទាំងឡាយបានចូលកាន់ផ្នួស កាលដែលនៅក្នុងផ្ទះ គ្រានោះ ពួកយើងខ្ញុំម្ចាស់ជារាជកញ្ញាមិនខ្ជិលច្រអូស ប្រព្រឹត្តព្រហ្មចរិយធម៌ តាំងពីកុមារី ឋិតក្នុងសុខសម្បត្តិពីរម៉ឺនឆ្នាំ។*

ព្រះរាជធីតាទាំង៧អង្គសុទ្ធតែពេញចិត្តក្នុងការទំនុកបម្រុងព្រះពុទ្ធសាសនា ព្រះនាងទាំងនោះមាន **នាងសមណី១ នាងសមណគុត្តា១ នាងភិក្ខុនី១ នាងភិក្ខុតាសិកា១ នាងធម្មា១ នាងសុធម្មា១ និងនាងសង្ឃាទាសិកា** ជាគម្រប់៧។

នៅក្នុងក្រុងកោសម្ពី នាង**ខុជ្ជុត្តរាឧបាសិកា**មិនមានស្វាមី ជាស្រីគមលួចទ្រព្យសម្បត្តិគេញយៗ ក្រោយពីបានស្តាប់ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់

រួចមក ក៏បានសម្រេចនូវគុណធម៌ជាន់ខ្ពស់ បានរួចផុតពីការបម្រើគេ ដោយសារតែនាងបានសម្តែងព្រះធម៌ទាំងនោះ ឱ្យអ្នករាំងស្តាប់ ញ៉ាំងអ្នកស្តាប់បានសម្រេចមគ្គផល។

នៅក្នុងបិដកលេខ៤៧[៥៧] មាតាសូត្រ បានសម្តែងអំពី**នន្ទមាតា**ឧបាសិកា ជាព្រះអរិយបុគ្គល**អនាគាមី** បានសូត្រធម៌នៅពេលជិតភ្លឺប្រមាណ ២៥០គាថា ក្នុង**បរាយនវគ្គ** ដោយសំឡេងដ៏ពីរោះ។ ក្នុងកាលនោះ ទេវរាជព្រះនាម**វេស្សវ័ណ** បានអនុមោទនាចំពោះការស្វាធ្យាយធម៌នន្ទមាតាឧបាសិកា។ ព្រះអដ្ឋកថា បានបញ្ជាក់សេចក្តីនៃការអនុមោទនាថា *សាធុ! សាធុ! បងស្រី ព្រះធម៌ទេសនារបស់បងស្រី បានទទួលមក ល្អណាស់ ទាំងដែលបានស្វាធ្យាយដោយល្អទៀតផង ខ្ញុំមិនឃើញបានថាមានការប្លែកគ្នាអ្វី អំពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅ**បាសានកចេតិយ** ត្រាស់សម្តែងដល់**បារាយនិកព្រាហ្មណ៍**ទាំង១៦នាក់នោះឡើយ។ បងស្រីសូត្រថ្ងៃនេះ ដូចជាព្រះតម្រាស់របស់ព្រះសាស្តា ដែលព្រះអង្គទ្រង់ត្រាស់ហើយនោះឯង។*

**ស្តេចវេស្សវ័ណ** ជាព្រះ**សោតាបន្នបុគ្គល** មានព្រះជន្ម៩លានឆ្នាំមនុស្ស ប៉ុន្តែហៅនន្ទមាតាថា បងស្រី ព្រោះ**នន្ទមាតា** បងដោយគុណធម៌នេះឯង។

**នន្ទមាតា**ជាស្រីមេម៉ាយ កូនឈ្មោះ**នន្ទ**ក៏ត្រូវគេសម្លាប់។ នាងត្រូវបានគេតែងតាំងជាស្រីគំរូដោយព្រះសាស្តា ជាមួយនាង**ខុជ្ជុត្តរា**។

---

[៥៧] ***បិដកលេខ៤៧*** ទំព័រ១១៦។

*. ស្ត្រីពេស្យាចារ*

នាង**អម្ពបាលី** ជាស្រីសោភិនីប្រចាំនគរ***វេសាលី***បានភ្ញាក់ខ្លួនទាន់ពេលវេលា ក៏បានសង់ព្រះវិហារនៅក្នុងចម្ការស្វាយរបស់ខ្លួនថ្វាយជាសង្ឃារាម ចំណែកខ្លួនឯងក៏បានចូលកាន់ផ្នួស ហើយសម្រេចនូវព្រះអរហត្ត ចាកផុតកិលេសដែលជាគ្រឿងសៅហ្មងគ្រប់យ៉ាង។ នាង***សិរិមា*** ជាសោភិនីប្រចាំក្រុងរាជគ្រឹះ ព្រមដោយបរិវារាប់រយនាក់ បានជួបនឹងព្រះសម្ពុទ្ធស្តាប់ព្រះធម៌ សម្រេចជាឧបាសិកាដល់នូវព្រះរតនត្រ័យ ជាទីពឹងទីរឭក ព្រមដោយធម្មចក្ខុមានភ្នែកឃើញនូវអរិយសច្ចធម៌។

ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់អំពីបញ្ហានេះ យើងសូមលើកយកស្ត្រីមួយចំនួនមកបង្ហាញដូចខាងក្រោមនេះ៖

- ***ព្រះនាងគោតមី*** ៖ ជាព្រះមាតុឆារបស់ព្រះពុទ្ធជាម្ចាស់ ទ្រង់មាននាទីដ៏ឧត្តុង្គឧត្តមក្នុងការដឹកនាំគ្រប់គ្រងភិក្ខុនី និងសាមណេរ រាប់ពាន់អង្គក្នុងជំនាន់ពុទ្ធកាល។

- ***ព្រះនាងយសោធរាពិម្ពា***៖ ជាកន្សែសារពេជ្ជនៃព្រះបរមគ្រូ ដោយព្រះនាងបានបំពេញរាជភារកិច្ចជាអគ្គមហេសីដ៏ចម្បង បង្កលក្ខណៈឱ្យ**ព្រះសិទ្ធត្ថ**ជា**ព្រះភស្តា** បានត្រាស់ដឹងប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ជាកំពូលមនុស្សក្នុងលោក។

- ***នាងវិសាខា***៖ បុត្រីរបស់សេដ្ឋី បានសម្រេចសោតាបត្តិផលតាំងពីអាយុ៧ឆ្នាំ ហើយក្រោយមកអាស្រ័យដោយគុណធម៌ដ៏ឆ្នើមក្នុងការឧបត្ថម្ភទ្រទ្រង់ព្រះពុទ្ធសាសនា ក៏ត្រូវព្រះពុទ្ធអង្គតែងតាំងឧឡារិកជា **នាមឧបដ្ឋាយិកា**

ជាមហាឧបាសិកាដ៏មានកិត្តិយស ក្នុងចំណោមពុទ្ធសាសនិកជននាជំនាន់នោះ។

- ***ព្រះនាងមទ្រី*** ក្នុងរឿងព្រះវេស្សន្តរជាតក ព្រះនាងជាតួអង្គស្រីដែលបង្ហាញស្វាមីភក្តិដាច់ខាតចំពោះតួអង្គព្រះវេស្សន្តរជាស្វាមី។ ដូចព្រះនាងសីតាដែរ ព្រះនាងសុខចិត្តបោះបង់នូវសេចក្តីសុខគ្រប់បែបយ៉ាងក្នុងនាមជាព្រះអគ្គមហេសីនៃមហាក្សត្រចេញចាកពីវាំងចរលើលាជាមួយបុត្រាបុត្រី រួមសុខទុក្ខជាមួយ**ព្រះវេស្សន្តរ** ក្នុងដំណើរចេញសាងផ្នួសជាឫសីតាបសក្នុងបព៌តគិរីវង្គតវេងទុក្ខលំបាកគ្រប់បែបយ៉ាង រស់ដោយផលាផលក្នុងព្រៃហេមពាន្ត។ ដោយព្រះរាជភារកិច្ចដ៏វិសេសវិសាលនេះហើយដែលក្នុងជាតិជាបន្ទាប់មក ព្រះវេស្សន្តរបានត្រាស់ដឹងប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ឋានៈជាព្រះសម្មាសម្ពុទ្ធ សង្គ្រោះសត្វលោក។[៥៨]

## ១៣- តម្លៃអប់រំស្ត្រីខ្មែរតាមរយៈច្បាប់ស្រី

### ១៣.១- ច្បាប់ព្រះរាជសម្ភារ

តាមរយៈកំណាព្យដែលបានចារលើស្លឹកត្នោតរបស់**ព្រះរាជសម្ភារ** ក្រៅពីអប់រំទូន្មានដល់សាមណេរទាំងឡាយឱ្យខិតខំប្រតិបត្តិតាមក្រឹត្យក្រមវិន័យរបស់ព្រះសង្ឃនោះ ក៏មានគោលបំណងបង្ហាញពីការផ្តល់នូវគុណតម្លៃយ៉ាងពិសេសដល់ស្ត្រីជាម្តាយក្នុងការទំនាក់ទំនងជាមួយសាមណេរផងដែរ។ មានន័យថា ព្រះសង្ឃគ្រប់អង្គ ត្រូវតែគោរពសងគុណដល់ម្តាយឪពុក និងគ្រូបាធ្យាយដែលជាអ្នកមាននូវគុណូបការៈដ៏ធំធេង។ ម្យ៉ាងវិញទៀត រាជកវីអង្គ

---

[៥៨] មៀច ប៉ុណ្ណ *កម្រងឯកសារស្តីអំពីប្រពៃណីទំនៀមទម្លាប់ខ្មែរ ភាគ៤* គ.ស២០១២ ទំព័រ៦៤,៦៥។

នេះបានប្រៀបធៀបគ្រូបាធ្យាយទៅនឹងម្ដាយ ហើយជាបុគ្គលដែលសាមណេរត្រូវគោរពកោតក្រែង មិនត្រូវរិះគន់ ឬប្រឆាំងតបតនោះទេ។ ដូចមានសេចក្ដីបញ្ជាក់ថា៖

- ហៃអស់សាមណេរ កុំធ្វើដែលដែរ ត្រង់ក្ដីពាយងាយ
  លំអុតបម្រើ អ្នកជាបាធ្យាយ ជូនបុណ្យទៅម្ដាយ
  អាពុកទីទៃ។ (ល្បះទី១០)
- ក្ដីនេះជាច្បាប់ ឱ្យសាមណេរគ្រាប់ សព្វសរិលទាំងឡាយ
  កុំសើចតិះដៀល អ្នកជាបាធ្យាយ អ្នកហោងស្មើម្ដាយ
  បង្កើតក្ដីច្បាប់។ (ល្បះទី ១៦)

លើសពីនេះទៅទៀត បើគេពិនិត្យលើកាព្យឱវាទសមួយទៀតរបស់ព្រះអង្គ គឺច្បាប់**រាជនីតិ** ឬច្បាប់**ព្រះរាជសម្ភារ**នោះ យើងប្រាកដជាឃើញកាន់តែច្បាស់អំពីវិសេសភាពរបស់ស្ត្រីខ្មែរនៅក្នុងគ្រួសារ។ ស្ត្រីជាកម្លាំងចលករមួយមិនអាចខ្វះបាន ពីព្រោះថា ស្ត្រីមិនត្រឹមតែជាមេផ្ទះ ជាអ្នកថែរក្សានូវរាល់ទ្រព្យសម្បត្តិ កូនចៅ ស្វាមី និងឪពុកម្ដាយប៉ុណ្ណោះទេ ថែមទាំងជាទីប្រឹក្សាដ៏ឆ្លាតវៃរបស់ប្ដី ឬអាចជាអ្នកកំណត់នូវវាសនារបស់គ្រួសារទៀតផង។ គ្រួសារណាក៏ដូចជាគ្រួសារណាដែរ ប្រសិនបើគ្រួសារនោះមាននូវភរិយាជា(ភរិយាដ៏ល្អ) គ្រួសារនោះរមែងជួបតែសេចក្ដីសុខក្សេមក្សាន្តរកស៊ីមានបានត្រជាក់ត្រជុំជាក់ពុំខាន។ ក៏ប៉ុន្តែបើបុរសណាជួបប្រសព្វនឹងភរិយាដែលជាស្រីខាតលក្ខណ៍ក្របាក់អន្សាវិញនោះ គ្រួសារនោះពិតជាមិនអាចស្គាល់នូវពន្លឺនៃសេចក្ដីសុខសុភមង្គលសោះឡើយ។ ដូច្នេះហើយបានជារាជកវីយើងបានគាស់កកាយ

អធិប្បាយរៀបរាប់អំពីតួនាទីដ៏សំខាន់របស់ស្ត្រីមកចងក្រងឡើងជាច្បាប់រាជនីតិនេះឡើង ដូចបានលើកយកមកបញ្ជាក់ខាងក្រោមនេះ៖

- ខ្លែងហើរត្បិតខ្យល់ នាយថ្កើងត្បិតពល រក្សាឱ្យសុខ
  ទ្រព្យគង់ត្បិតស្រី បេះសំចៃទុក ផ្ទះធំស្រណុក
  ត្បិតភរិយាជា។ (ល្បះទី ១១)
- ដូចចិត្តប្ដីជា ដូចមានភរិយា នៅផ្ទះស្រណុក
  ដូចកូនទទួល យកពាក្យអាពុក ដូចខ្ញុំឱ្យមុខ
  អម្ចាស់ប្រើហៅ។ (ល្បះទី ៣០)

អាស្រ័យដោយហេតុថា កំណាព្យរបស់**ព្រះរាជសម្ភារ**មានអត្ថន័យដ៏ជ្រាលជ្រៅសម្រាប់អប់រំរាល់មហាជនទូទៅនៅក្នុងសង្គម។ ដូច្នេះហើយទើបស្នាដៃរបស់ព្រះអង្គបានទទួលនូវការពេញនិយម មានអ្នកយកមកសិក្សាប្រតិបត្តិ និងយកមកអប់រំកូនចៅតាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន។ ជាពិសេសនៅត្រង់ឃ្លាឃ្លោងមួយចំនួន ត្រូវបានប្រជាជនខ្មែរចងចាំរត់មាត់រហូតក្លាយទៅជាពាក្យសុភាសិតទៀតផង។

សរុបសេចក្តីមកតាមរយៈច្បាប់របស់ព្រះរាជសម្ភារនេះបានបញ្ជាក់ឱ្យឃើញថា ព្រះអង្គយកព្រះទ័យទុកដាក់នៅក្នុងការអប់រំ និងលើកតម្កើងនូវតម្លៃនៃស្ត្រីខ្មែរនាសម័យនោះទៀតផង។ កំណាព្យនេះក៏បានធ្វើឱ្យប្រជាជនខ្មែរយើងយល់កាន់តែច្បាស់ពីវិសេសភាព ឬតម្លៃរបស់ស្ត្រីនៅក្នុងសង្គមគ្រួសារ និងសាសនា នៅសម័យកាលនោះ។

## ១៣.២- ច្បាប់ស្រីរបស់ព្រះបាទអង្គឌួង

នៅក្នុងច្បាប់នេះ ព្រះបាទ**អង្គឌួង**បានលើកឡើងពីលក្ខណៈជាមង្គល និងអពមង្គលរបស់ស្ត្រីសរុបទៅមានចំនួន១០៨ជំពូក។ ក្នុងនោះលក្ខណៈមង្គលរបស់ស្ត្រីមានតែ៨ជំពូកប៉ុណ្ណោះ រីឯអពមង្គលរបស់ស្ត្រីមានដល់ទៅ ១០០ជំពូក ដោយបែងចែកស្ត្រីជា៥ប្រភេទគឺ *ស្រីមាយាមាន៤០ជំពូក ស្រីបង្ខិនប្តីមាន១០ជំពូក ស្រីចើកមាន១៨ជំពូក ស្រីអាសមាន២០ជំពូក និងស្រីមាក់ងាយប្តីមាន១២ជំពូក។*[៥៩] តាមរយៈការបង្ហាញទាំងលក្ខណៈវិជ្ជមាន និងអវិជ្ជមាននេះ គឺចង់ឱ្យស្ត្រីខ្មែរចេះប្រៀបធៀបថ្លឹងថ្លែងទាញយកនូវគុណប្រយោជន៍ ឬលក្ខណៈដែលល្អប្រពៃមកប្រតិបត្តិនិងជម្រុះនូវគុណវិបត្តិ ឬលក្ខណៈមិនគាប់ប្រសើរទាំងនោះចោល ដើម្បីប្រព្រឹត្តឱ្យត្រូវតាមគន្លងនៃប្រពៃណីទំនៀមទម្លាប់ខ្មែរ។ ថ្វីត្បិតតែច្បាប់នេះមានភាពតឹងតែងចំពោះស្ត្រីក៏ពិតមែន ប៉ុន្តែពុំមែនជាការបន្ទុះបង្អាប់ស្ត្រីនោះទេ។ ផ្ទុយទៅវិញវាជាការបង្ហាញឱ្យស្ត្រីមើលឃើញពីអ្វីដែលខ្លួនគួរធ្វើ និងអ្វីដែលខ្លួនពុំគួរធ្វើ ដើម្បីប្រតិបត្តិឱ្យត្រូវនឹងសីលធម៌ ដែលសង្គមនាសម័យនោះឱ្យតម្លៃ។

រាជករីអង្គនេះបានលើកសរសើរចំពោះតែស្ត្រីណាដែលប្រតិបត្តិតាមសុចរិតទាំង៨ប្រការប៉ុណ្ណោះ ដោយចង់ឱ្យនារីខ្មែរនាពេលនោះត្រូវបានសង្គមទទួលស្គាល់។ ព្រះអង្គក៏បានលើកឡើងអំពីប្រការ ឬក្រឹត្យក្រមដែលស្ត្រីពុំគួរធ្វើពីព្រោះនាំឱ្យអាប់ឱនកិត្តិយសខ្លួន ហើយសង្គមក៏មិនឱ្យតម្លៃផងដែរ ដូចមានបញ្ជាក់នៅក្នុងពាក្យកាព្យស្រាប់៖

---

[៥៩] ព្រះអង្គឌួង *ច្បាប់ស្រី* ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦២ ទំព័រ០២។

- សុចរិតប្រាំបី ជាមង្គលស្រី ប្រសើរក្រមាន
អ្វីមកផ្ទឹមផ្ទាល់ ឱ្យដល់នេះបាន ស្រីណាអាចធ្យាន
ចិត្តចាំរៀនយក៍។
- ទាំងប្រាំបីច្បាប់ ហៅស្រីមហាគាប់ លោកិយកម្រ
ស្រីកាន់សុចរិត ប្រព្រឹត្តល្អិតល្អ ស្រីណាថាក្រ
ធ្វើតាមពុំបាន។
- លោកថាស្រីនោះ ចិត្តអាក្រក់ស្មោះ ស្អប់ដំបូន្មាន
ផ្សារដោយសារចិត្ត ទុច្ចរិតសន្តាន បង្ខិនធនធាន
ចើក អាស មាយា។[៦០]

មង្គលស្រីប្រាំបីប្រការនោះរួមមាន៖ **ស្រីជា**(មានឫកពារនិងសម្តីល្អ) **ស្រីត្រង់**(ចេះរក្សាទ្រព្យដោយការមិនប្រមាថ) **ស្រីគាប់**(ឧស្សាហ៍ព្យាយាមនិងសន្សំសំចៃ) **ស្រីប្រាជ្ញ**(មានអធ្យាស្រ័យល្អនិងរួសរាយរាក់ទាក់) **ស្រីស្អាត**(ចេះរៀបចំទុកដាក់និងផ្គាប់ចិត្តប្តី) **ស្រីស្មោះ**(មានស្វាមីភក្តិ) **ស្រីស្លូត**(ស្តាប់បង្គាប់ប្តី) និង**ស្រីស្មើ**(មានអំណត់អត់ធន)។

ក្រៅអំពីការលើកឡើងពីកិច្ចជាមង្គល និងអពមង្គលរបស់ស្រ្តី ព្រះអង្គឌួងក៏បានលើកឡើងពីកិច្ចរបស់ភរិយាក្នុងការសង្រ្គោះប្តី និងកិច្ចសង្រ្គោះរបស់ប្តីចំពោះភរិយាខ្លួន។ ទន្ទឹមនឹងនេះ ទ្រង់ក៏បានបែងចែកប្រភេទភរិយាជាប្រាំពីរប្រការទៅតាមទ្រឹស្តីព្រះពុទ្ធសាសនាដែរ។ ភរិយាទាំងប្រាំពីរប្រការមាន៖ **មាតុភរិយា**(ប្រពន្ធដូចជាម្តាយ) **ភគិនីភរិយា**(ប្រពន្ធដូចជាប្អូន) **សខាភរិយា**

[៦០] ព្រះអង្គឌួង *ច្បាប់ស្រី* ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦២ ទំព័រ ៨-៩។

(ប្រពន្ធដូចជាមិត្ត) **ទាសីភរិយា**(ប្រពន្ធដូចជាអ្នកបម្រើ) **វធការភរិយា**(ប្រពន្ធដូចសត្រូវ) **ចោរីភរិយា**(ប្រពន្ធដូចចោរ) និង**អយ្យាភរិយា**(ប្រពន្ធតម្កើងខ្លួនធំជាងប្តី)។ ត្រង់សេចក្តីបន្ថែមនៃភរិយាទាំងប្រាំពីរប្រការនេះ យើងខ្ញុំនឹងអធិប្បាយនៅផ្នែកបន្ទាប់។

ឆ្លងតាមការបកស្រាយខាងលើនេះយើងសង្កេតឃើញថា ថ្វីត្បិតតែច្បាប់នេះមានលក្ខណៈតឹងតែង ចំពោះស្ត្រីខ្មែរបន្តិចមែន ប៉ុន្តែវាក៏ជាទស្សនាទាន ឬក៏ជាឧបករណ៍សម្រាប់វាស់ស្ទង់ពីតម្លៃទឹកចិត្តរបស់ស្ត្រីខ្មែរ មួយផ្នែកធំដែរ ពីព្រោះថាជាទូទៅគេតែងតែចាត់ទុកស្ត្រីជាអ្នកថែរក្សា និងតំណាងឱ្យវប្បធម៌ទំនៀមទម្លាប់ប្រពៃណីរបស់ជាតិសាសន៍នីមួយៗ។ ដូច្នេះហើយទើបបានជាកវីអង្គនេះ ចង់បង្ហាញឱ្យស្ត្រីខ្មែរយល់ដឹងកាន់តែច្បាស់ពីតម្លៃរបស់ខ្លួន និងចេះរក្សានូវតម្លៃនេះឱ្យបានល្អខ្ជាប់ខ្ជួនសាកសមជាស្ត្រីខ្មែរពិតៗ។

## ១៣.៣. ច្បាប់ស្រីរបស់បណ្ឌិត ម៉ឺនម៉ៃ

តាមរយៈច្បាប់ស្រីរបស់កវី**ម៉ឺនម៉ៃ** បានផ្តល់នូវទស្សនៈអប់រំទូន្មានដល់ស្ត្រីទាំងឡាយ ដើម្បីបណ្តុះនារីខ្មែរឱ្យបានក្លាយទៅជាស្ត្រីល្អ និងមាតាដ៏ល្អនៅក្នុងក្រុមគ្រួសារ ក៏ដូចជានៅក្នុងសង្គមជាតិផងដែរ។ កំណាព្យឧបទេសច្បាប់ស្រីនេះ បានពណ៌នាពីកិច្ចប្រតិបត្តិប្រចាំថ្ងៃរបស់ស្ត្រីដូចជាការអប់រំឱ្យមាននូវកិរិយាមារយាទ និងសម្តីសំដៅល្អគាប់ប្រសើរឱ្យស្ត្រីជាភរិយាចេះប្រណិបតិន៍ចំពោះប្តី មាតាបិតា និងទូន្មានឱ្យចេះធ្វើកិច្ចការទាំងក្នុង និងទាំងក្រៅគ្រួសារ ប្រកបដោយការត្រិះរិះពិចារណាដ៏ល្អត្រឹមត្រូវ តាមក្រឹត្យក្រមសង្គមមនុស្ស។ ជាក់ស្តែងនៅត្រង់ល្បះទី៥-៦ លោកបានណែនាំឱ្យស្ត្រីជាប្រពន្ធត្រូវចេះគោរពប្រណិបតិន៍ប្តីឱ្យបានល្អប្រសើរ៖

- ទៅឋានមនុស្សលោកនាយអេះ ចូរនាងចាំចេះ បម្រើស្វាមី។
- ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឱ្យស្វាមី អាក់អន់ចិន្តា។

ម្យ៉ាងវិញទៀតច្បាប់នេះក៏បានបង្ហាញពីលក្ខណៈជាមង្គល និង អពមង្គលរបស់ស្ត្រីផងដែរ។ លោកក៏បានចារឹកទុកនូវកិច្ចជាមង្គលទាំងឡាយ របស់ស្ត្រីជាប្រពន្ធ អំពីអ្វីដែលគួរធ្វើនិងអ្វីដែលពុំគួរធ្វើចំពោះស្វាមីរបស់ខ្លួន ចំពោះញាតិមិត្តជិតខាង ចំពោះក្រុមគ្រួសារ និងកិច្ចការទាំងឡាយដែលជា ប្រការគួរចៀសវាង ដូចជាការប្រព្រឹត្តខុសជាមួយប្រុសដទៃក្រៅអំពីស្វាមីរបស់ ខ្លួនជាដើម។ មិនតែប៉ុណ្ណោះ យើងក៏កត់សម្គាល់ឃើញផងដែរថា លោកជាកវី មួយរូបដែលឱ្យតម្លៃស្ត្រីទៅលើចរិយាសម្បត្តិជាជាងរូបសម្បត្តិ ពីព្រោះការមាន នូវចរិយាសម្បត្តិល្អ គឺជាស្នេហ៍មុខរបស់ស្ត្រីគ្រប់រូប ដូចមានបញ្ជាក់ក្នុងស្នាដៃ របស់លោកត្រង់ល្បះទី៩-១១ថា៖

- មួយល្អរូបសសន្លាង ឥតគេផ្ទឹមខាង ច្បាប់ផងមិនចេះ។
- ល្អពិតគំនិតមិនផេះ ទោះខ្មៅក្រងេះ ការសោតសមគួរ។
- គឺមោះនាងនោះមិនជួ ចេះដឹងសមគួរ ស្គាល់អស់ឥរិយា។

ជាមួយគ្នានេះដែរ កវីនិពន្ធយើងក៏បានលើកឡើងពីអពមង្គលស្ត្រី១០ ប្រការ ដែលស្ត្រីខ្មែរគ្រប់រូបត្រូវវៀរចាក។ ចំណុចដែលពុំគាប់ប្រសើរទាំង១០ ប្រការនោះរួមមាន៖ ***មិនចេះគោរពប្តី១ ដើរកន្លងជើងប្តី១ សើចខ្លាំងៗរំលងផ្ទះ ពីរបី១ ដេកបែរខ្នងដាក់ប្តី១ ទុកសក់វែង ហើយអង្គុយមាត់ទ្វា១ ដើរព្រជាយ សំពត់១ ដើរទម្លាក់ជើងខ្លាំងៗ១ មិនចេះរៀបចំទុកដាក់ទ្រព្យ១ មិនបិទទ្វារ ពេលចេញចូល១ និងហូបចុកគ្មានសណ្តាប់ធ្នាប់១។*** ក្រៅពីនេះលោកក៏បាន បែងចែកប្រពន្ធជា៧ប្រភេទ ដោយយកតាមការទេសនាទុករបស់ព្រះពុទ្ធអង្គ។

ភរិយាទាំង៧ជំពូកនោះមាន៖ ***មាតុភរិយា ភាតុភរិយា មិត្តភរិយា ទាសភរិយា ពេជ្ឈឃាតភរិយា សត្រូវភរិយា និងចោរភរិយា។*** ស្ត្រីបួនជំពូកខាងដើមជាស្ត្រីដែលគួរជាទីគោរពប្រតិបត្តិតាម ចំណែកស្ត្រីបីជំពូកខាងចុងគួរចៀសវាងឱ្យឆ្ងាយកុំយកខ្លួនបៀត។ លើសពីនេះទៅទៀតប្រការប្រតិបត្តិរបស់ស្ត្រីមានចំណុចជាច្រើនទៀតដែលតម្រូវឱ្យនារី ឬស្ត្រីហាត់ពត់លត់ដំចិត្ត គោរពប្រណិប័តន៍ឱ្យខ្ជាប់ខ្ជួនទៅតាមក្រឹត្យក្រមច្បាប់វិន័យ។ ច្បាប់នេះផងដែរក៏បានធ្វើឱ្យស្ត្រីខ្មែរដែលប្រតិបត្តិតាមនាពេលនោះត្រូវបានគេគោរពកោតសរសើរថាជានារីដ៏ល្អប្រសើរ នារីគ្រប់លក្ខណ៍នៅក្នុងគ្រួសារ។ ទន្ទឹមនឹងនេះដែរ ដើម្បីឱ្យមានសមភាពនឹងគ្នារវាងបុរសនិងស្ត្រីនោះ លោកបណ្ឌិត **ម៉ឺន ម៉ៃ** ក៏បានតាក់តែងជាច្បាប់ប្រុសមួយទៀតសម្រាប់អប់រំទូន្មានដល់បុរស។ លោកបានអប់រំទូន្មានបុរសនាពេលនោះឱ្យប្រតិបត្តិកិច្ចការអ្វីៗឱ្យសមជាប្រុស ឬជាស្វាមីដ៏ល្អ ស្គាល់ពីតួនាទីរបស់ខ្លួនឱ្យបានច្បាស់លាស់។ នៅក្នុងច្បាប់ប្រុសនោះទៀតសោត លោកក៏បានលើកកម្ពស់នូវតម្លៃរបស់ស្ត្រីដែរ គឺបុរសជាស្វាមីគួរគប្បីចេះសាកសួរឬពិភាក្សាផ្លាស់ប្តូរមតិយោបល់ជាមួយនឹងភរិយាមុននឹងសម្រេចចិត្តធ្វើអ្វីមួយដូចជា ការចាយវាយប្រាក់កាសឬទ្រព្យសម្បត្តិ ការប្រកបកិច្ចការងារចិញ្ចឹមជីវិតជាដើម។ ទាំងនេះ គឺជាតឹកតាងបញ្ជាក់យ៉ាងច្បាស់ថាស្ត្រីមានសិទ្ធិធំណាស់នៅក្នុងការសម្រេចកិច្ចការក្នុងក្រុមគ្រួសារ។

- ប្រយ័ត្នប្រយោជន៍យូរ ទោះលក់ដូរមើលថៃធួន
ទោះទ្រព្យរបស់ខ្លួន ឱ្យសួរកូនសួរប្រពន្ធ។
- កុំអាងឯងជាប្រុស ចាយរបស់មិនគិតគន់

មិនដឹងដល់ប្រពន្ធ ព្រមព្រៀងគ្នាឥតបើថា។[៦១]

លើសពីនេះទៅទៀត ច្បាប់ស្រីរបស់បណ្ឌិត **ម៉ឺន ម៉ៃ** ជាកម្រងអត្ថបទមួយដែលត្រូវបានគេលើកយកមកសិក្សាវិភាគអំពីអត្ថន័យខ្លឹមសារដែលឆ្លុះបញ្ចាំងពីតថភាពនៃផ្នត់គំនិតរបស់ខ្មែរចំពោះស្ត្រី។ អត្ថបទនេះអ្នកនិពន្ធបានតាក់តែងឡើងជាបទកុជង្គលីលា ហើយបរិយាកាសនៃការប្រើប្រាស់កំណាព្យនេះគឺសម្រាប់អប់រំស្ត្រី ដោយបែងចែកជាប្រាំពីរផ្នែក៖

❖ **ផ្នែកទី១៖ អំពីកិរិយាមារយាទ និងកិច្ចជាស្ត្រី**

- នៅឋានមនុស្សលោកនាយអះ ចូរនាងចាំចេះ បម្រើស្វាមី។
- ធ្វើវត្តប្រតិបត្តិប្រក្រតី កុំឱ្យស្វាមី អាក់អន់ចិន្តា។
- នាងអើយគម្លែងក្រឡា ជាម្ចាស់សិរសា កូនកុំមាក់ងាយ។[....]
- ទោះកាន់ការធ្វើឱ្យស្ទាត់ ហូលគោមគាតកាត់ អន្ទងត្បាញទៅ។
- កុំទុកក្នុងស្នុកស្នាញនៅ ក្រែងដល់យូរទៅ ខាតខូចអាសារ។
- ហែកូនស្រីស្ងួនមាតា ចូរចាំរក្សា កុំភ្លេចស្មារតី»។[៦២]

ត្រង់ចំណុចនេះអ្នកនិពន្ធចង់លើកបង្ហាញពីកិរិយាមារយាទ ឬកិច្ចរបស់ស្ត្រីចំពោះ៖

▪ **ស្វាមី៖** ភរិយាត្រូវប្រកាន់នូវអត្តចរិកឱ្យល្អ ទាំងពាក្យសម្តី កាយវិការ ព្រមទាំងគោរពបម្រើស្វាមី ចាត់ទុកស្វាមីដូចជាម្ចាស់របស់ខ្លួន។

---

[៦១] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ប្រុស* ល្បះទី៤៣-៤៤។

[៦២] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ប្រុស* -ដ- ល្បះទី៥-៣៤។

- **ញាតិ៖** នាមជាស្រីត្រូវមានទម្លាប់ល្អក្នុងការប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ ចាស់ព្រឹទ្ធាចារ្យ និងអ្នកជិតខាងប្រកបដោយកិរិយាសមសួន ចេះគួរសម និងរួសរាយរាក់ទាក់ជានិច្ច។
- **កិច្ចការផ្ទះ៖** ស្ត្រីត្រូវចេះរៀបចំកិច្ចការផ្ទះសម្បែង ដោយយកចិត្តទុកដាក់ប្រុងប្រយ័ត្ន ធ្វើអ្វីត្រូវធ្វើឱ្យរួចរាល់ចៀសវាងទុកការងារចោលខ្ជះខ្ជាយពេលវេលាឥតប្រយោជន៍។ សមដូចពាក្យសុភាសិតមួយឃ្លា ពោលថា "***ធ្វើអ្វីធ្វើឱ្យហើយ កុំទុកឡើយបង្កើតកេរ្តិ៍***"។

**❖ ផ្នែកទី២៖ ការរក្សាភ្នក់ភ្លើងទាំងបី ពោលគឺការរក្សាទំនាក់ទំនងរវាងមនុស្សបីក្រុមក្នុងគ្រួសារ**

. ចូររៀនយកច្បាប់ស្រី ឱ្យកោតខ្លាចប្តី គម្លែងក្រឡា។
. ធ្វើវត្តប្រតិបត្តិសោតណា ឱ្យនាងរក្សា ភ្នក់ភ្លើងទាំងបី។
. ឱ្យកាន់ឱ្យគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្លុំឱ្យឆេះ។ [....]
. នេះហៅភ្នក់ភ្លើងទាំងបី ម្តាយផ្តាំកូនស្រី ឱ្យខំរក្សា។
. នាងអើយគម្លែងក្រលា ខុសឆ្គងម្តេចម្តា ម្តាយផ្តាំកូនស្រី។
. ឱ្យអត់សង្កត់ហឫទ័យ កូនកុំស្រដី ដើមប្តីកំបាំង។
. កុំដេរកុំចេញជាខ្លាំង ខ្សត់ខ្សោយខ្លៅខ្លាំង នាងកុំមើលងាយ។
. ល្ងង់ខ្សោយប្រើឱ្យនិយាយ ណែនាំលេងលាយ ឱ្យស្រួលវាចា។[៦៣]

[៦៣] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ស្រី* ល្បះទី៣៥-៦៤។

- **ឪពុកម្ដាយបង្កើត៖** គោរពប្រណិប័តន៍ ថែរក្សាអ្នកមានគុណឱ្យបានខ្ជាប់ខ្ជួន និងចេះរក្សាភាព ស្មៀមស្ងាត់លាក់កំបាំងរឿងរ៉ាវដែលអាចបង្កឱ្យមានជម្លោះក្នុងគ្រួសារ ក្នុងការទំនាក់ទំនងប្ដីប្រពន្ធ និងឪពុកម្ដាយ។

- **ឪពុកម្ដាយក្មេក៖** គោរពស្រឡាញ់ បម្រើទឹកក្ដៅទឹកត្រជាក់ចាត់ទុកដូចជាឪពុកម្ដាយបង្កើតរបស់ខ្លួន ព្រមទាំងចេះរក្សាទំនាក់ទំនងល្អ ចៀសវាងរាល់ជម្លោះទាំងឡាយក្នុងការទំនាក់ទំនងគ្រួសារ។

- **ប្ដី៖** ថែរក្សាទំនាក់ទំនងប្ដីប្រពន្ធឱ្យបានល្អជានិច្ច ចៀសវាងរាល់ជម្លោះប្រកបដោយចិត្តអំណត់អត់ធ្មត់ មិនប្រកាន់កិរិយាគំរោះគំរើយទ្រគោះបោះបោក ឆេវឆាវដែលទាំងអស់នេះស្ដែងឡើងតាមរយៈពាក្យសម្ដី ក៏ដូចជាកាយវិការជាដើម។

❖ **ផ្នែកទី៣៖ កិរិយាមារយាទស្ត្រីចំពោះទំនាក់ទំនងជាមួយស្វាមីក្នុងគ្រួសារ**

« ទោះប្ដីស្រដីម្ដេចម្ដា ខេខឹងជេរថា បោះពាក្យទំងន់។
ក្រោធក្រេវធុលឆេវមិនអន់ មិនអាក់ស្រាកស្រន់ ដោយចិត្តគ្នាន់ក្នាញ់។
អ៊ើរទាំទន្ទេញ ជេរថាជន្លេញ ត្បិតទាស់នឹងចិត្ត។
ឱ្យកូនស្រីស្ងួនខំអត់ ឱ្យបានរលត់ រលាយកំហឹង។ [....]
នេះមិនរាប់ជាស្រីទេ ជាអ្នកប៉ោឡៃ ចិត្តចោរដកទង។
ឱ្យមាត់បង្រ្គបប្ដីផង ឱ្យគេស្ដាប់ហោង ថាឯងគ្រាន់បើ។
គឺមោះនាងនោះមិនប្រើ មិនបើកឱ្យដើរ បញ្ចើឱ្យទេ។
ទោះបីប្ដីប្រើមាសមេ កុំកូនចំអែរ ចំអៀកមិនទៅ។

ឆ្ងាយជិតកុំគិតរង់នៅ ក្រោកក្រេសដើរទៅ កុំឱ្យប្ដីជេរ។[៦៤]

**ស្ត្រីដែលជាប្រពន្ធគួរប្រកាន់កិរិយាមួយចំនួនដូចជា៖**

✍ ពាក្យសម្ដីទន់ភ្លន់មានចិត្តអំណត់ មិនឆេវឆាវពេលមានជម្លោះជាមួយស្វាមី

✍ មិនគួរប្រកាន់ការនិយាយទ្រគោះបោះបោក ឬតិះដៀលស្វាមីខ្លួនដែលនាំឱ្យអាប់ឱនដល់កិត្តិយស

✍ មិនគួរបំផ្លាញ ឬបោះបោករបស់របរប្រើប្រាស់ តាមតែកំហឹងខ្លួន

✍ គួរស្តាប់តាមឱវាទទូន្មានរបស់ប្ដី ដើម្បីចៀសវាងជម្លោះទាំងឡាយ

✍ ចៀសវាងការនិយាយឡូឡារករឿងឈ្លោះដែលនាំឱ្យមានឈ្មោះថាជាស្រីប៉ោទ្បៃ។

នៅក្នុងន័យនេះ ស្ត្រីគួរតែមានចិត្តអំណត់អត់ធ្មត់ ដើម្បីបង្ការនូវរាល់អំពើហិង្សា និងជម្លោះផ្សេងៗនៅក្នុងគ្រួសារ។

❖ **ផ្នែកទី៤ ៖ ស្ត្រី និងការបញ្ចៀសនូវឧបទ្រពទាំងដប់**

« កុំទៅនៅយូរផ្ទះគេ វល់ទំនេរ វៀសមកណា។
ហៃកូនខ្លឹមខ្លួនមាតា ជាស្រីនេះណា កម្រណាស់នាង។ [....]

ទោះធីចំណីនូវបាយ លបលូកកកាយ ពមពុំសណ្ដាប់»។[៦៥]

---

[៦៤] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ស្រី* ល្បះទី៦៥-៨៩។

[៦៥] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ស្រី* ល្បះទី ៩០-១២២។

**ស្ត្រី ឬ ភរិយាគួរតែចៀសវាងនូវឧបទ្រពទាំងដប់ប្រការនេះឱ្យបាន៖**

១. ការមិនចេះពីក្រមច្បាប់ឥរិយាជាស្ត្រី ត្រូវបានចាត់ទុកជាឧបទ្រព មួយ បើទោះបីជាស្ត្រី ឬភរិយានោះមានរូបសម្បត្តិល្អយ៉ាងណាក៏ដោយ។

២. ការកាន់ក្បាលប្តី ដោយមិនបានលើកដៃសុំខមាទោសជាមុន ទង្វើ នេះប្រៀបបាននឹងភាពចង្រៃ ដូចសត្វកុកទុំលើដំបូលផ្ទះ។

៣. ការកន្លងជើងប្តី ក៏ចាត់ទុកជាការចង្រៃប្រៀបបាននឹងសត្វលលក ខ្មោចដែលនាំរោគា។

៤. ពេលចេញចូលក្នុងផ្ទះ ពុំបានបិទបាំងទ្វារក៏ចាត់ទុកជាចង្រៃ ប្រៀប ដូចជាការដុតចន្លុះ ឬបំភ្លឺភ្លើងឱ្យចោរចូលផ្ទះ។

៥. ការសើចឮខ្លាំងៗរំលងផ្ទះពីរបី ចាត់ទុកដូចជាសត្វចចាត ដែលនាំ ចង្រៃដល់ភូមិស្រុក

៦. ការដេកឱ្យខ្នងទៅប្តី ចាត់ទុកដូចជាសត្វពស់អប្រិយ

៧. ការដែលទុកសក់វែងអន្លាយ ចាត់ទុកដូចជាមជ្ឈរាធ្មាលាក់ក្រចក

៨. ការដើរឮលាន់ខ្លាំងៗ

៩. ការដើរលាន់ឮជាយសំពត់ខ្លាំងៗ

១០. ការមិនចេះទុកដាក់ទ្រព្យសម្បត្តិ ចាត់ទុកជាការវិនាសអន្តរាយ។

❖ **ផ្នែកទី៥៖ លក្ខណៈចរិតប្រាំពីរប្រការរបស់ស្ត្រី**

« ឱ្យចៀសអស់ទាំងនេះណា ឱ្យរៀនលក្ខណា ទាំងប្រាំពីរផង។
គឺព្រះមានបុណ្យកន្លង ទេសនាចែងចង ជាបទគាថា។[.....]
ហេតុអកុសលនេះហើយ ត្បិតខ្លួនឥតត្រើយ ធ្វើខុសគន្លង។

ខុសវត្តប្រតិបត្តិផ្ដាំផ្ដង មិនរៀនមិនរង ខុសនឹងច្បាប់ស្រី។[៦៦]

## ក. លក្ខិណារបស់ភរិយាទាំងបួនពួក

. **មាតុភរិយា៖** ប្រពន្ធជាម្ដាយ មានលក្ខណៈបីប្រការគឺ៖

. ការយកចិត្តទុកដាក់ប្រយោជន៍ និងកិត្តិយសរបស់ស្វាមី

. ការទំនុកបម្រុងស្វាមី

. ការថែរក្សាយកចិត្តទុកដាក់ចំពោះស្វាមីពេលមានជំងឺឈឺថ្កាត់។

. **ភាតុភរិយា៖** ប្រពន្ធជាបងប្អូន មានលក្ខណៈពីរប្រការគឺ៖

. មានចិត្តស្រឡាញ់ គោរពស្វាមី

. ចេះថែរក្សា ការពារគ្នាទៅវិញទៅមក។

. **មិត្តភរិយា៖** ប្រពន្ធជាមិត្ត មានលក្ខណៈបីប្រការគឺ៖

. ចេះស្រឡាញ់គ្នា

. ចេះរក្សាទំនាក់ទំនងល្អជាមួយស្វាមី មិនឱ្យមានក្ដីសៅហ្មងឡើយ

. មានចិត្តស្មោះត្រង់ ភក្ដីភាពចំពោះស្វាមី

. **ទាសភរិយា៖** ប្រពន្ធជាខ្ញុំបម្រើរបស់ស្វាមី មានចរិតលក្ខណៈប្រាំបីប្រការគឺ៖

. ការគោរពកោតក្រែងស្វាមី

. ចេះរៀបចំតាក់តែងកាយកុំឱ្យខ្មាសគេ

. ការចេះរៀបចំខ្លួនកុំឱ្យទាស់ចិត្តស្វាមី នាំមានរឿងឈ្លោះប្រកែកគ្នា

. ការចេះរៀបចំខ្លួនមិនឱ្យប្ដីស្ដីបន្ទោស

---

[៦៦] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ស្រី* ល្បះទី១២៤-១៨៨។

. ការមិនតបតឈ្លោះទាស់ទែងជាមួយស្វាមី
. ចេះអត់ធ្មត់ មានអំណត់ (ខន្តី)
. ការចេះរៀបចំទំនុកបម្រុងម្ហូបអាហារ ពេលប្តីចេញទៅណាមកណា
. រង់ចាំបរិភោគអាហារជុំគ្នាជាមួយស្វាមី

**ខ. ចរិតភរិយាអាក្រក់ទាំងបីប្រការ**

ភរិយាអាក្រក់បីប្រការដែលគួរចៀសវាងរួមមាន៖

. **ពធ្យឃាតភរិយា**៖ ប្រពន្ធជាស្ត្រីដែលមានចរិតបួនប្រការគឺ៖
- ការបំពារបំពានប្តីដោយគំនិតចង់ឈ្នះ
- ការបង្អាប់ដោយឱ្យប្តីស្តាប់ខ្លួន
- ការមានគំនិតផិតក្បត់នឹងស្វាមីរបស់ខ្លួន
- ការមានគំនិតសម្លាប់ប្តី ហើយទៅយកប្តីថ្មី

. **សត្រូវភរិយា**៖ ប្រពន្ធជាស្ត្រីដែលមានចរិតប្រាំពីរប្រការគឺ៖
- ការមិនកោតខ្លាចស្វាមីរបស់ខ្លួន
- ការមិនស្រដីតបនឹងប្តី
- ការមិនស្តាប់ប្តីស្តីប្រដៅ
- ការមិនចេះទំនុកបម្រុងប្តី
- ចចេសរឹងរូសជាមួយនឹងប្តី
- ប្រចណ្ឌនឹងប្តីខុសទំនង
- ការនិយាយបើកកកាយកេរ្តិ៍អាស្រូវរបស់ប្តី។

. **ចោរភរិយា**៖ ប្រពន្ធក្នុងផ្នែកនេះមានចរិតបីប្រការគឺ៖
- ចាយវាយទ្រព្យប្តីខ្ជះខ្ជាយឥតប្រយោជន៍

- មិនចេះទុកដាក់ទ្រព្យសម្បត្តិដែលប្តីរកបានមក
- ខ្ជិលច្រអូសក្នុងកិច្ចការងារ ដោយយកលេស ឬប្រើល្បិចកលដោយប្រការផ្សេងៗ

❖ **ផ្នែកទី៦៖ អំពើមាក់ងាយប្តីប្រាំបីប្រការដែលស្រ្តីគួរចៀសវាង**

មាក់ងាយនោះមានប្រាំបី មានក្នុងបាលី ព្រះធម៌លោកថា។
មាក់ងាយមួយនោះឯងណា ត្បិតប្តីពិការ មិនបានមាំមួន។ [....]
ធ្វើខ្នាញ់បែរចេញព្រងើយ គេនឹងកន្តើយ ក្និចក្នក់មាយា។

ពុំបានក្សេមក្សាន្តនឹងគ្នា មាក់ងាយនេះជា គម្រប់ប្រាំបី។[៦៧]

អំពើមាក់ងាយដែលស្រ្តីជាភរិយា គប្បីចៀសវាងការប្រព្រឹត្តនូវទង្វើទាំងនោះចំពោះស្វាមីរបស់ខ្លួន រួមមានប្រាំបីប្រការគឺ៖

. ការមាក់ងាយស្វាមីរបស់ខ្លួនដែលពិការ
. ការមាក់ងាយស្វាមីរបស់ខ្លួនដែលខ្សត់ខ្សោយទ្រព្យធន
. ការមាក់ងាយស្វាមីដែលអប្បយស
. ការមាក់ងាយស្វាមីរបស់ខ្លួនដែលល្ងិតល្ងង់ ឬខ្វះនូវសតិបញ្ញា
. ការមាក់ងាយស្វាមីដែលមានរូបសម្បត្តិអាក្រក់
. ការមាក់ងាយស្វាមីរបស់ខ្លួនដែលមិនខិតខំខ្នះខ្នែងក្នុងកិច្ចការងារ
. ការមាក់ងាយស្វាមីដែលចេះផឹកស្រា ឬប្តីប្រមឹក
. ការមាក់ងាយស្វាមី នៅពេលដែលដឹងថាស្វាមីស្រឡាញ់ខ្លួនខ្លាំង។

[៦៧] បណ្ឌិត ម៉ឺន ម៉ៃ *ច្បាប់ស្រី* ល្បះទី១៨៩-២១១។

## ❖ ផ្នែកទី៧ ៖ ផលនៃការប្រតិបត្តិតាមច្បាប់ស្រី

« កូនអើយនេះហើយច្បាប់ស្រី ឱ្យកូនពិសី រករៀនរក្សា។
យកទុកក្នុងអង្គអាត្មា ប្រសើរក្តាត់ណា កើតសុខសួស្តី។[.....]
សម្រាប់ជាច្បាប់មាត្រា សូរេចបការា បរិបូណ៌ចែងចប់។

នៅក្នុងផ្នែកនេះកវីយើងចង់បង្ហាញពីគុណប្រយោជន៍ ឬកុសលដែលបានមកពីការបដិបត្តិយ៉ាងខ្ជាប់ខ្ជួននូវកិច្ចទាំងឡាយដែលស្រ្តី ឬភរិយាត្រូវធ្វើ។ មានន័យថា ប្រសិនបើស្រ្តីឯណានីមួយ មានការយល់ដឹង និងប្រតិបត្តិនូវព្រហ្មចរិយា ដឹកនាំក្រុមគ្រួសារឱ្យកើតមាននូវសេចក្តីសុខចម្រុងចម្រើន កើតលាភកើតយស កិត្តិយសកេរ្តិ៍ឈ្មោះ និងទ្រព្យធនជាដើម ស្រ្តីនោះរមែងតែងមានគេគោរពកោតក្រែង និងមានឈ្មោះក្រអូបសាយទៅ ជាស្រ្តីដែលប្រកបទៅដោយលក្ខិណា ដែលនឹងជាគំរូដ៏ល្អដល់កូនចៅ និងជនដទៃៗទៀត។ លើសពីនេះទៅទៀតនោះ គឺមិនត្រឹមតែនៅក្នុងបច្ចុប្បន្នជាតិនេះទេ សូម្បីតែទៅអនាគតជាតិ ក៏ស្រ្តីនោះរមែងមានសតិបញ្ញាបរិបូណ៌ដោយភាពឈ្លាសវៃ ក្នុងកិច្ចការជាកុសលផ្សេងៗ ឬរមែងញ៉ាំងឱ្យមនុស្សដែលរស់នៅជុំវិញខ្លួន ទាំងសមាជិកក្នុងគ្រួសារក្តី និងអ្នកជិតខាងក្តី ឱ្យកើតនូវសទ្ធាជ្រះថ្លា នៅក្នុងអំពើជាសប្បុរសនានា បេះដួយសង្រ្គោះគ្នាទៅវិញទៅមក ឆ្ពោះទៅរកវិថីនៃជីវិតដែលប្រកបដោយសេចក្តីសុខសន្តិភាព។

តាមរយៈការរៀបរាប់ខាងលើនេះ យើងអាចសន្និដ្ឋានបានថា ជាទូទៅនៅក្នុងសង្គមនីមួយៗមនុស្សម្នាក់ៗ តែងតែមានផ្នត់គំនិតដោយឡែកពីគ្នាទាក់ទងទៅនឹងបញ្ហារស់នៅ និងការប្រព្រឹត្តនៅក្នុងសង្គមទៅតាមបរិបទនៃសង្គមនោះ។ ដើម្បីអប់រំមនុស្សទាំងនោះឱ្យដើរលើមាគ៌ាមួយដ៏ត្រឹមត្រូវ មានកវី

បណ្ឌិត អ្នកប្រាជ្ញជាច្រើនបានតាក់តែងជាច្បាប់អប់រំផ្សេងៗ និងធ្វើការផ្សព្វផ្សាយនូវក្បួនច្បាប់ទាំងនោះទៅដល់ស្រទាប់មហាជន។ គួយ៉ាងច្បាប់ស្រីគឺជាស្នាដៃមួយដែលត្រូវបានតាក់តែងចងក្រងឡើង ដោយផ្អែកលើវិធានជាទម្លាប់ប្រពៃណីរបស់ប្រជាជនខ្មែរដែលត្រូវបានគេចាត់ទុកជាច្បាប់ទំនៀម។ រីឯច្បាប់ទំនៀមនេះផងដែរ គឺជាវិធានច្បាប់សម្រាប់អប់រំទាក់ទងទៅនឹងផ្នែកសីលធម៌ ការទំនាក់ទំនង និងការរស់នៅរបស់មនុស្សក្នុងសង្គម ដោយផ្សារភ្ជាប់យ៉ាងស្អិតរមួតទៅនឹងប្រពៃណីទំនៀមទម្លាប់របស់ប្រទេស។ ជាក់ស្តែងច្បាប់ស្រីរបស់បណ្ឌិត **ម៉ឺន ម៉ៃ** ត្រូវបានចងក្រងឡើងជាអត្ថបទពាក្យកាព្យដែលមានគោលបំណងចង់អប់រំទូន្មានប្រៀនប្រដៅដល់ស្ត្រីខ្មែរ តាមបែបទស្សនវិជ្ជា  សីលធម៌ និងសាសនា ដោយកវីបានលើកឡើងនូវវិធីសាស្ត្រអប់រំទាំងការអប់រំបែបអត្ថានុរូប(ន័យត្រង់) និងអត្ថាបដិរូប(ន័យធៀប)។ បច្ចុប្បន្ននេះថ្វីត្បិតតែច្បាប់នេះ ក្លាយជាច្បាប់ទំនៀម កំណត់ត្រឹមតែការអប់រំប៉ុណ្ណោះ ពុំមានលក្ខណៈចាប់បង្ខំក៏ដោយ ក៏ច្បាប់នេះនៅតែមានតម្លៃប្រើប្រាស់ក្នុងសង្គមខ្មែរ ដោយគេអាចទាញយកនូវវិធានល្អៗទាក់ទងនឹងផ្នែកសីលធម៌ ឥរិយាបថ ឬកិរិយាមារយាទ សេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរ ទាំងទំនាក់ទំនងក្នុងគ្រួសារ និងសង្គមទាំងមូលផងដែរ។ លើសពីនេះទៅទៀតនោះ គឺច្បាប់ស្រីបានគូសបញ្ជាក់ឱ្យឃើញក្រោមទម្រង់ជាស្នាដៃអក្សរសិល្ប៍ដែលបង្ហាញពីអត្តសញ្ញាណជាតិខ្មែរ ដោយឆ្លុះបញ្ចាំងពីអត្តចរិតសុភាពរាបសារ ស្លូតបូតរម្យទមថ្លៃថ្នូរ និងចេះថែរក្សាឱ្យបានស្ថិតស្ថេរគង់វង្សនូវប្រពៃណីវប្បធម៌ជាតិរបស់ខ្លួន សមដូចពាក្យស្លោកថា «***វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើនថ្កាន***»។

## ១៣.៣.១- តម្លៃអប់រំស្ត្រីផ្នែកសីលធម៌ក្នុងគ្រួសារ

តាមច្បាប់ធម្មជាតិ ស្ត្រីជាអ្នកពរពោះ ជាអ្នកផ្តល់កំណើតឱ្យមនុស្ស ឬអាចនិយាយបានថា ស្ត្រីជាមាតានៃពិភពលោក។ មិនថាតែក្នុងសង្គមខ្មែរឬសង្គមណាៗទេ សុទ្ធតែបានផ្តល់តម្លៃឱ្យស្ត្រី បើទោះបីជាមានមនុស្សមួយចំនួន(កវី អ្នកប្រាជ្ញ) បានសរសេររិះគន់បណ្តុះបង្អាប់ស្ត្រីក៏ដោយ តែក្នុងគោលបំណងចង់ឱ្យស្ត្រីទាំងនោះចេះគិតពិចារណាអំពីឥរិយាបថរបស់ខ្លួនក្នុងការរស់នៅ ឬបែបបទនៃការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃប៉ុណ្ណោះ។ ជាពិសេសចង់ឱ្យស្ត្រីចេះអប់រំខ្លួនឯង ចេះសម្របខ្លួនឱ្យស្របទៅនឹងមជ្ឈដ្ឋានខ្លួនរស់នៅ តាមរយៈការសង្កេតពិចារណាពីអ្វីដែលខ្លួនគួរធ្វើ និងអ្វីដែលពុំគួរធ្វើ អ្វីដែលគួរនិយាយ និងអ្វីដែលពុំគួរនិយាយ។ មានន័យថា មុននឹងហាស្តី ឬធ្វើអ្វីមួយត្រូវពិនិត្យសង្កេតមើលឱ្យសព្វជ្រុងជ្រោយសិន ពីព្រោះទៅអនាគត ស្ត្រីអាចនឹងអាចក្លាយជាភរិយា ជាមាតា ជាមេគ្រួសារ ជាបុគ្គលិក ឬជាមេដឹកនាំសង្គម ដូច្នេះអ្វីដែលខ្លួនធ្វើ អ្វីដែលខ្លួននិយាយត្រូវតែមានការពិតមានមូលដ្ឋានច្បាស់លាស់ អាចឱ្យអ្នកនៅជុំវិញខ្លួនយកជាគំរូតាមបាន ដូចមានជាកំណាព្យ មួយពោលថា៖

*មុននឹងនិយាយស្រដី ការកេរ្តិ៍ជាស្រី កុំស្តីឡេះឡោះ*
*ញុំាញ្រើដំណើរ រញ៉េះរញ៉ោះ ឃើញប្រុសកម្លោះ*
*សសៀរចូលជិត។*

មានស្ត្រីទើបមានបុរស មានបុរសទើបមានស្ត្រី តួអង្គទាំងពីរនេះ មិនអាចមានមួយអត់មួយបានទេ។ ស្ត្រីមិនមែនមានតួនាទីក្នុងសង្គមប៉ុណ្ណោះទេ ថែមទាំងជាអ្នកមើលថែទាំក្នុងគ្រួសារ និងជាអ្នកផ្តល់ប្រឹក្សាដល់ប្តីថែមទៀត

ផង។ បញ្ហាភាគច្រើន ប្តីច្រើនតែជាអ្នកបង្កឡើង ហើយពេលនោះហើយ ដែលនាងសុខចិត្តទ្រាំនូវការស្តីបន្ទោស ឬពេលខ្លះក៏ត្រូវប្តីធ្វើបាបទៀត។ តួយ៉ាងដូចមានក្នុងរឿង ***អាកម្ជិល អាំងផេះបានប្រពន្ធគ្រប់លក្ខណ៍*** នាងប្រពន្ធដឹងថា ប្តីជាមនុស្សល្ងង់មិនចេះរកស៊ីអ្វី នាងក៏បានណែនាំប្តីឱ្យចេះ រកស៊ីថែមទាំងស្វែងរកសិរីក្នុងគ្រួសារ ដោយនៅពេលទេវតាចាំមាត់ទ្វាររកសម្លាប់ប្តី នាងចេះយកទឹកមកលាងជើង ដើម្បីជម្រះឧបទ្រព្យចង្រៃឱ្យវិនាស។ .

## ១៣.៣.២- គម្លែអប់រំស្ត្រីនិងការចេះថែរក្សា(ពាក្យចាស់លោកថា រក្សាភ្នក់ភ្លើងទាំងបី)

ការថែរក្សាជាតួនាទីចម្បងរបស់មនុស្សគ្រប់ៗរូបមិនថាបុរសឬស្ត្រីទេ ហើយក៏មិនថាជាទ្រព្យសម្បត្តិឬចរិយាសម្បត្តិនោះទេ ដ្បិតថា បើគ្មានការថែរក្សា នោះអ្វីៗគ្រប់យ៉ាងនឹងបាត់បង់។ ចំពោះការថែរក្សានៅទីនេះ គឺនិយាយពីការថែរក្សាចរិយាសម្បត្តិ ជាពិសេសស្ត្រី ដែលចាស់ៗលោកតែងតែទូន្មានថា ការថែរក្សាភ្នក់ភ្លើងទាំងបី ហើយភ្នក់ភ្លើងទាំងបីដែលស្ត្រីគួរគប្បីថែរក្សានោះរួមមាន៖ **ទី១** មិនត្រូវយករឿងរាវក្នុងគ្រួសារទៅប្រាប់អ្នកដទៃ ដែលនឹងនាំឱ្យមានទំនាស់បែកបាក់គ្រួសារខ្លួនឯងនៅពេលក្រោយ។ **ទី២** ត្រូវចេះស្រឡាញ់ឪពុកម្តាយក្មេកឱ្យដូចឪពុកម្តាយខ្លួនឯង ព្រោះគាត់ជាអ្នកមានគុណបំណាច់ចំពោះស្វាមីរបស់ខ្លួន និង**ទី៣** មិនត្រូវមើលងាយស្វាមីរបស់ខ្លួន បើទោះបីជាគាត់មានរូបរាងមិនល្អ ឬសម្ផស្សមិនសូវបាន មានអវយវៈមិនគ្រប់គ្រាន់(ពិការដោយប្រការណាមួយ) ជាដើម។ ជាក់ស្តែងដូចមានឃ្លាសេចក្តីបញ្ជាក់ថា៖

- [...] ធ្វើវត្តប្រតិបត្តិសោតណា ឱ្យនាងរក្សា ភ្នក់ភ្លើងទាំងបី។
- ឱ្យកាត់ឱ្យគង់ប្រក្រតី សព្វថ្ងៃកុំបី ភ្លេចផ្តុំឱ្យចេះ។

- ក្រែងរាលដួចដាលព្រាយប្រេះ កើតក្តៅរលេះ រលាយអស់អង្គ។
- .......................... .......................... ....................។
- ទោះកើតហេតុភេទសារពើ ពាក្យពុំប្រសើរ ជញ្ជឹងចាំស្តាប់។
- ទោះប្តីស្រដីពុំគាប់ ពុំគួរឱ្យប្រាប់ បានដឹងដល់ម្តាយ។[៦៨]

## ១៣.៣.៣- តម្លៃអប់រំស្ត្រីនិងការចេះដាក់ទុករបស់ទ្រព្យឱ្យបានត្រឹមត្រូវ

ក្នុងន័យនេះកវីបានអប់រំឱ្យនារីត្រូវចេះរៀបចំទុកដាក់ផ្ទះសម្បែង និងរបស់ទ្រព្យឱ្យបានត្រឹមត្រូវសមជាប្រពន្ធល្អ។

ស្រីមួយឃើញទ្រព្យនៅផ្លូវ កន្លងហួសទៅ មិនចាប់ចេញទុក។
ពុំចេរចំណោរទៅមុខ ពុំចេះដាក់ទុក រាយរាល់តែល្វែង។
ទ្រព្យនោះរលោះចេញឯង ចង្រៃទាស់ទែង ធ្វើឱ្យអន្តរាយ។

## ១៣.៣.៤- តម្លៃអប់រំស្ត្រីក្នុងជីវភាពសង្គម

នៅក្នុងជីវភាពសង្គម កវីមិនបានលម្អិតឱ្យបានច្បាស់ពីជីវភាពសង្គមទេគ្រាន់តែបង្ហើបបន្តិចត្រង់៖

*ហែកូនស្រីស្ងួនមាសម្តាយ ក្រណាស់នាងអាយ តាមដោយច្បាប់ស្រី។*
*ក្រមួយមិនបានសម្តី ពាក្យទន់តិចនៃ ឱ្យញាតិចូលចិត្ត។*
*ក្រមួយមិនចេះរិះគិត ឃើញញាតិឆ្ងាយជិត ហៅឡើងផ្ទីស្លា។*
*ទោះមានមិនមានក្តីណា ពាក្យផ្អែមបរចា ទើបគេស្រលាញ់។*

---

[៦៨] ការផ្សាយរបស់សមាគមសម្តេច ជួន ណាត ***ច្បាប់ផ្សេងៗ*** ភ្នំពេញ ឆ្នាំ១៩៧៤ ទំព័រ ២២-២៣, ល្បះទី៣៦-៥៤។

*កុំដូចិត្តស្នូរកំណាញ់ មិនមានអស់អញ នឹងញាតិសណ្ដាន។*
*កើតយសរបស់ផងបាន កើតសុខក្សេមក្សាន្ត ចំពោះកូនស្រី។*

ដោយផ្អែកលើអត្ថន័យខាងលើនេះសឱ្យឃើញថា បើទោះបីជាកវីមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់មែន តែក៏បានបង្ហាញថា កូនស្រីត្រូវចេះប្រាស្រ័យទាក់ទងជាមួយញាតិមិត្ត បើទោះជាគ្រួសារមាន ឬក្រក៏ដោយ គឺធ្វើយ៉ាងណាត្រូវមានទំនាក់ទំនងល្អ ពីព្រោះទំនាក់ទំនងល្អអាចធ្វើឱ្យមនុស្សស្គាល់ និងស្រឡាញ់រាប់អានយើងច្រើន ដែលនឹងអាចផ្ដល់នូវលក្ខណៈងាយស្រួលក្នុងការប្រកបមុខរបររកស៊ីប្រចាំថ្ងៃ។

ម្យ៉ាងវិញទៀត នៅក្នុងកំណាព្យនេះក៏បានបញ្ជាក់ផងដែរថា ស្ត្រីត្រូវចេះទុកដាក់របស់ទ្រព្យឱ្យបានល្អ ត្រូវចេះបិទបាំងផ្ទះឱ្យបានជិតល្អ មិនត្រូវចំហរមាត់ទ្វាបង្អួចឱ្យគេឃើញទ្រព្យរបស់ឡើយ ដូចមានជាកំណាព្យបញ្ជាក់ថា៖

*ចង្រៃមួយរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង។*
*ធ្វេសប្រាណខុសខានមិនរាំង មិនរុញរបាំង មើលយល់សាយសុស។*
*ទុកស្មើគេអុចចន្លុះ ឱ្យចោរចូលចុះ យកទ្រព្យទាំងឡាយ។*

ដូច្នេះការងារមួយចំនួនមិនចាំបាច់តែបុរសឬស្ត្រីទេ ពោលគឺអ្វីដែលគិតថាធ្វើបាន គួរបំពេញតែក្នុងលក្ខណៈជាប្រយោជន៍សម្រាប់គ្រួសារនិងសង្គម។

### ១៣.៣.៥- តម្លៃអប់រំស្ត្រីជាឃ្លាំងនៃវប្បធម៌

ដោយសារតែស្ត្រីជាមនុស្សដែលមានភេទផ្ទុយពីបុរស ហើយដែលមានចរិតលក្ខណៈទន់ភ្លន់ជាងបុរស ស្របទៅតាមភេទពីធម្មជាតិ និងជាមនុស្សចេះស្រឡាញ់ខ្លួនឯង ស្រឡាញ់គ្រួសារ ស្រឡាញ់វប្បធម៌នោះ ទើបពេលមានពិធី

បុណ្យឬអាពាហ៍ពិពាហ៍ម្តងៗ គេតែងតែឃើញស្ត្រីនៅតែមានការប្រកាន់ខ្ជាប់នូវប្រពៃណីទំនៀមទម្លាប់ ដូចជាការស្លៀកពាក់ ការប្រាស្រ័យទាក់ទងជាដើម។

នៅក្នុងបរិបទខ្មែរ ឥទ្ធិពលរបស់ស្ត្រីបានមានកំណើតនៅក្នុងវប្បធម៌ខ្មែរបានចំនួន២០០០ឆ្នាំហើយ។ តាមប្រវត្តិសាស្ត្រខ្មែរក្នុងដើមសតវត្សទី១នៃគ្រិស្តសករាជ អាណាចក្រកម្ពុជាគ្រប់គ្រងដោយម្ចាស់ក្សត្រីយ៍មួយព្រះអង្គ ព្រះនាមថា ‹‹**សោមា**›› ឬតាមភាសាចិនហៅថា ‹‹**ព្រះនាងលីវយី**››។ ដោយសារការមានស្រីជាធំលើគេនៅក្នុងប្រទេស ដូច្នេះហើយបានជាយើងឃើញថា វប្បធម៌ខ្មែរយើងមានលក្ខណៈពិសេសផ្ទាល់ខ្លួនខុសពីវប្បធម៌ឥណ្ឌា និងចិនដែលចូលមកតាមក្រោយ។ វប្បធម៌ខ្មែរយើងជាវប្បធម៌មាតាធិបតេយ្យ គឺយកមាតាឬស្រីជាធំ ឯវប្បធម៌ឥណ្ឌានិងចិន ជាវប្បធម៌បិតាធិបតេយ្យ គឺយកប្រុសឬបិតាជាធំ។ តាមកំណត់ហេតុរបស់បេសសកទូតចិន ដែលបានមកដល់រាជធានីអង្គរនៅក្នុងសតវត្សរ៍ទី១៣ ឈ្មោះ **ជីវតាក្វាន់** ក៏បានរៀបរាប់ពីឥទ្ធិពលដែលមានប្រៀបជាងបុរសរបស់ស្ត្រីដែរ។ ភស្តុតាងនៃឥទ្ធិពលមាតាធិបតេយ្យដែលឃើញច្បាស់នាបច្ចុប្បន្ន គឺពាក្យថា ‹‹**មេ**››។ ក្នុងភាសាខ្មែរ **មេ** សំដៅដល់ភេទញីភេទស្រី ដូចជា មាន់មេ គោមេ ជាដើម។ ការឱ្យតម្លៃទៅលើស្រីជាធំ បានធ្វើឱ្យពាក្យ មេ នេះត្រូវខ្មែរយើងយកទៅដាក់នាំមុខពាក្យដទៃទៀត កាលណាគេចង់បញ្ជាក់ថា របស់នោះធំ ជាដើមចមជាប្រធាន ជាអ្នកដឹកនាំ ជាអ្នកនាំនូវសេចក្តីសុខ ឬសេចក្តីទុក្ខជាដើមទាំងខាងផ្នែកគ្រប់គ្រងរដ្ឋ ក៏ដូចជាខាងរាស្ត្រប្រជា។ ជាឧទាហរណ៍ផ្នែកខាងរដ្ឋមានដូចជាពាក្យថា មេកងពន្ធស្រូវ មេកងពន្ធទាស មេការ មន្ត្រីមេការ ក្រុមមេការ ក្រសួងមេការ មេគយ មេព្រៃ មេស្រែ មេឃុំ មេស្រុក មេទ័ព មេកង មេទាហានជាដើម។ សម្រាប់ពាក្យរាស្ត្រប្រជាទូទៅ មាន

ដូចជា មេបន្ទុក មេចោរ មេកោយ មេខ្លោង មេក្រាន មេចង្ក្រាន មេចុងភៅ មេចង្ហាន់ មេផ្ទះ មេបា មេដែកមេដំបូល មេជើង មេដៃ មេទឹក មេភ្លើង មេខ្យល់ ព្រះមេ មេបទ មេពាក្យ មេលេខ មេសូត្រមេកាព្យ មេស៊ី មេដឹកនាំ មេសោរ មេខូច មេរោគ មេក្រមី រើសយកអាណាមេៗ ជាដើម។ ថ្វីដ្បិតរបស់នោះគ្មានភេទ ឬជាភេទឈ្មោល ភេទប្រុសក្តី ក៏គេយកពាក្យ **មេ** ដាក់ពីមុខដែរ ដែលសូម្បីតែនៅក្នុងស្ថាប័នពុទ្ធសាសនា ភិក្ខុដែលទទួលនាទីជាអ្នកគ្រប់គ្រងវត្តក៏ត្រូវខ្មែរយើងហៅដោយពាក្យ **មេ** ពីមុខដែរ ដូចជាពាក្យ **លោកគ្រូមេវត្ត ព្រះគ្រូមេគណ លោកមេកុដិ** ជាដើម ថ្វីត្បិតតែព្រះសង្ឃទាំងអស់អង្គនោះជាបុរសភេទក្តី។

ស្ត្រីនិងតួនាទីនៅក្នុងព្រះពុទ្ធសាសនា ក្នុងបរិបទព្រះពុទ្ធសាសនានៅក្នុងឥស្សរសូត្រទី៧ បានសរសេរថា មានទេវតាមួយរូបបានមកទូលសួរព្រះសម្មាសម្ពុទ្ធថា៖ *«អ្វីជាធំក្នុងលោក អ្វីឧត្តមជាងទ្រព្យទាំងឡាយក្នុងលោក អ្វីជាសេចក្តីអន្តរាយក្នុងលោក»*? សំណួររបស់ទេវតារូបនេះ អាចយល់បាននៅក្នុងសេចក្តីដោយងាយថាតើ ក្នុងសង្គមមនុស្សជាតិនេះ តើបញ្ហាអ្វីដែលធំជាងគេ? តើទ្រព្យសម្បត្តិមួយណាដែលមានតម្លៃជាងគេ? តើអ្វីដែលនាំឱ្យសង្គមនេះវិនាសម្តងបន្តិចៗ ដូចជាដែកដែលត្រូវច្រេះស៊ី? និងតើអន្តរាយមួយណាដែលនាំឱ្យសង្គមនេះជួបនឹងវិបត្តិ? ព្រះពុទ្ធអង្គបានតបថា *អំណាចជាធំនៅក្នុងលោក* ។ ស្ត្រីឧត្តមជាងទ្រព្យទាំងឡាយនៅក្នុងលោក។ ពួកចោរជាសេចក្តីអន្តរាយនៅក្នុងលោក»។ ពាក្យថា **ស្រី** ឧត្តមជាងទ្រព្យទាំងឡាយនៅក្នុងលោក អាចមានន័យថា បណ្តាទ្រព្យទាំងឡាយ ទ្រព្យគឺមនុស្សស្រី មានតម្លៃជាងទ្រព្យណាៗទាំងអស់តែក៏អាចមានន័យថា មនុស្សស្រីមិនអាចកាត់ថ្លៃស្មើនឹងទ្រព្យសម្បត្តិឡើយ ព្រោះមនុស្សស្រីគឺជាមនុស្សស្រី មិនមែនជា ភណ្ឌឬជាទ្រព្យប្រើ

ប្រាស់ទេ។ បើស្រីមានតម្លៃស្មើនឹងទ្រព្យសម្បត្តិណាមួយ មនុស្សប្រុសក៏គង់មានទ្រព្យដែលអាចទិញដូរដោយតម្លៃបានដែរ។ ក្នុងសេចក្ដីពន្យល់មួយទៀតអំពីពាក្យ **ស្រីឧត្តមជាងទ្រព្យទាំងឡាយនៅក្នុងលោក** គឺស្រីមានឧត្តមភាពជាងទ្រព្យទាំងឡាយក្នុងលោក( ឥត្ថី ភណ្ឌានំ ឧត្តមំ) ក៏ព្រោះព្រះពុទ្ធក្តី និងពួកក្សត្រទាំងឡាយក្តី សុទ្ធតែកើតមកអំពីមនុស្សស្រីទាំងអស់។[៦៩]

នៅក្នុងធីតុសូត្រ បាននិយាយអំពីព្រះបាទ**បសេនទិកោសល** ទ្រង់អាក់អន់មិនសប្បាយព្រះទ័យជាខ្លាំង ដោយហេតុថាព្រះមហេសីទើបនឹងប្រសូត្របានបុត្រី១អង្គ។ ព្រះពុទ្ធអង្គបានផ្តល់ឱវាទថា *បើព្រះរាជាចិញ្ចឹមបុត្រីនោះឱ្យមានបញ្ញាឆ្លាត មានសីល មានបិតាក្មេកមាតាក្មេកដែលល្អ ជាភរិយាដែលគោរពប្តី ជាស្រីប្រសើរ នោះកូនប្រុសដែលកើតអំពីស្រីនោះ នឹងទៅជាមនុស្សក្លៀវក្លា ឯកូន(ស្រី)ទាំងឡាយនៃភរិយាណាដែលល្អប្រាកដ ដូច្នោះកូនទាំងឡាយនោះក៏អាចប្រៀនប្រដៅនូវជនទាំងឡាយដែលនៅក្នុងប្រទេសបានដែរ*។ ក្នុងន័យនេះការមានកូនជាស្រីសំខាន់ស្ថិតនៅលើការផ្តល់ការសិក្សាអប់រំសតិបញ្ញា និងគុណធម៌ចំពោះកូនស្រីនោះដែលកូនស្រីនោះនឹងត្រូវក្លាយជាភរិយាល្អ ជាមាតាល្អ ក្នុងការបង្កើតកូនស្រីល្អជាបន្តទៀត។ អ្វីដែលសំខាន់ជាងគេបំផុត នៅក្នុងទស្សនាទានរបស់ព្រះពុទ្ធសាសនា គឺស្ត្រីអាចត្រាស់ដឹងបាននូវព្រះនិព្វានដែលជាគោលបំណងដ៏ខ្ពស់បំផុតរបស់ជីវិតមនុស្សបានដូចបុរសដែរ។ ដូច្នេះហើយបានជាព្រះពុទ្ធអង្គបង្កើតឱ្យមាន**ភិក្ខុនី** គឺព្រះសង្ឃស្រីនៅក្នុងអង្គការចាត់តាំងពុទ្ធសាសនារបស់ព្រះអង្គ និងមានឋានៈជាសាវ័ក

---

[៦៩] ***បិដកភាគ២៩*** ទំព័រទី១១៤។

មហាសាវ័ក អគ្គសាវ័ក និងជំនាញជាឯតទគ្គ ដូចជាភិក្ខុសង្ឃដែរ។ ចំណែកខាងឧបាសិកាវិញ ក៏ព្រះអង្គបានផ្ដល់ឋានៈជា**តុលា** គឺ ជាឧបាសិកាគំរូ ដូចជាខាងឧបាសកដែរ។ ដូច្នេះការសម្រេចគោលដៅក្នុងជីវិត មិនមានបែងចែកទុកសម្រាប់តែបុរសទេ គឺស្ត្រីក៏មានសិទ្ធិស្មើគ្នានឹងបុរសដែរ នៅក្នុងពុទ្ធសាសនា។

នៅពេលដែលព្រះពុទ្ធអង្គសន្ទនាជាមួយនឹងមារស្ដីពីការបរិនិព្វាន ឬការចូលនិវត្តរបស់ព្រះអង្គពីការដឹកនាំពុទ្ធសាសនា ព្រះពុទ្ធអង្គក៏បានប្រាប់មារអំពីតួនាទីពុទ្ធបរិស័ទទាំង៤ គឺ **ភិក្ខុ ភិក្ខុនី ឧបាសក** និង**ឧបាសិកា** គឺជាអ្នកដែលមានតួនាទីដ៏សំខាន់ក្នុងការបន្តវេនព្រះពុទ្ធសាសនាទាំងអស់គ្នា ពុំមែនតែលើ**ភិក្ខុសង្ឃ** និង**ឧបាសក**ឡើយ ហើយមារក៏បានយល់ពីរឿងនេះដូចព្រះពុទ្ធអង្គដែរ។ ការណ៍នេះជាការបង្ហាញនូវគំរូមួយទៀតនៃពុទ្ធសាសនាដល់សង្គមខ្មែរដែលបង្ហាញថា វត្តមានស្រីទៅក្នុងការដឹកនាំស្ថាប័នរដ្ឋ និងឯកជនទាំងឡាយធ្វើឡើងប្រកបដោយសមធម៌។ តួនាទីស្ត្រីនៅក្នុងបរិបទវប្បធម៌ខ្មែរមានសារៈសំខាន់ណាស់ដូចជា ស្ត្រីជាពាក្យមានសិរីសួស្ដីសម្រាប់ស្ត្រីទាំងឡាយ។ ស្ត្រីទាំងឡាយគួររៀបចំខ្លួនឱ្យទៅជាស្រីក្នុងការរក្សាឱ្យគង់នូវទ្រព្យទាំងឡាយរួមទាំងប្រទេសជាតិខ្មែរដែលជាទ្រព្យសម្បត្តិរួមរបស់កូនខ្មែរនាអនាគត ដែលព្រះរាជសម្ភារបានបញ្ជាក់ថា *«ទ្រព្យគង់ត្បិតស្រីចេះសំចៃទុក ផ្ទះធំស្រណុកត្បិតភរិយាជា»* ដែលបានបង្ហាញនូវតួនាទីដ៏សំខាន់របស់ស្រីពោលគឺភរិយាដែលបុរសនិងសង្គមជាតិត្រូវការជំនួយអំពីស្រីដែលមានប្រាជ្ញាស្រីមានសីល ស្រីប្រសើរក្នុងការចិញ្ចឹមកូនឱ្យល្អ ចាត់ចែងកិច្ចការផ្ទះរបស់គ្រួសារខ្លួន និងកសាងប្រជាជាតិខ្មែរ ឱ្យមានភាពស្រណុកសុខសប្បាយ និងអប់រំកូនចៅឱ្យបានល្អនៅក្នុងសង្គម។ នៅក្នុងទស្សនៈនេះ ព្រះពុទ្ធអង្គបានទេសនាបើកផ្លូវ

មុនគេអំពីរឿងសមជីវិតា ឬជីវិតសមភាព ឬដែលបច្ចុប្បន្នហៅថា **យេនឌ័រ** (Gender) តាំងពីជាង២៦០០ឆ្នាំមកហើយ។ ក្នុងព្រះពុទ្ធសាសនា **យេនឌ័រ** រវាងបុរសនិងស្ត្រី គឺស្ថិតនៅលើ៖ **១)សទ្ធា** គឺការជឿជាក់លើខ្លួន និងលើវិថីជីវិតហេតុផលដែលប្រៀនប្រដៅដោយព្រះពុទ្ធអង្គ **២)សីល** គឺព្រឹត្តិកម្មល្អក្នុងជីវិតដែលរួមដោយសកម្មភាពដែលល្អ មុខរបរចិញ្ចឹមជីវិតដែលល្អ និងសម្ដីនិងទំនាក់ទំនងក្នុងសង្គមដែលល្អ **៣)ចាគៈ** គឺការលះបង់ ការហ៊ានសេចក្ដីក្លាហានក្នុងការលះបង់កម្លាំងកាយកម្លាំងចិត្តដើម្បីសម្រេចឱ្យបាននូវសទ្ធានិងសីល និង **៤)បញ្ញា** គឺការមានចំណេះដឹងខ្ពង់ខ្ពស់ ការសិក្សាល្អត្រឹមត្រូវ ការអភិវឌ្ឍប្រាជ្ញាឱ្យមានរឹងមាំនិងរីកចម្រើន។

ការសិក្សាអប់រំ**យេនឌ័រ** គួរផ្ដោតលើគោលធម៌ទាំង៤ ដែលអាចជួយឱ្យស្រីមានសមភាពក្នុងជីវិតដូចបុរសបាន។ ស្ត្រីត្រូវបានគេឱ្យតម្លៃថាជាមេ ពោលគឺជាអ្នកដឹកនាំ មានន័យថា អ្វីៗដែលស្រីខ្មែរគួរធ្វើ គឺកុំខ្លាចការដឹកនាំ កុំផ្អើលនៅពេលដែលប្រុសៗបន្លាចពីរឿងការដឹកនាំនិងខំបំពេញការគិត ការនិយាយនិងការធ្វើរបស់ខ្លួន តាមគោលធម៌របស់ព្រះសម្មាសម្ពុទ្ធ គឺ សទ្ធា សីល ចាគៈ និងបញ្ញា និងធម៌ដទៃទៀតឱ្យបានគ្រប់គ្រាន់ ដើម្បីរៀបចំខ្លួនជាមេដោយស្មើភាពជាមួយបុរស។

## ១៣.៣.៦- តម្លៃអប់រំស្ត្រីនិងការយល់ដឹង

បានបង្ហាញឱ្យឃើញពីភរិយាដែលមានការចេះយល់ដឹងទុក្ខធុរៈ ចេះរក្សាការកេរ្តិ៍ប្ដី ចេះមើលព្យាបាលពេលប្ដីមានជំងឺនិងថែរក្សាទ្រព្យសម្បត្តិដែលស្វាមីរកបានឱ្យបានគង់វង្សផងដែរ ដូចមាននៅក្នុងសេចក្ដីខាងក្រោមនេះ៖

គឺព្រះមានបុណ្យកន្លង ទេសនាចែងចង ជាបទគាថា។
មួយមាតុមួយមិត្តភរិយា ភាតុភរិយាជា ទាសភរិយា។
........................ .................. ..................។
នេះឯងហៅទាសភរិយា សម្តេចភគវា ទេសនាប្រោសប្រាប់។

### ១៣.៣.៧- ការអប់រំសីលធម៌ក្រៅគ្រួសារឬទីសាធារណៈ

កវី **ម៉ឺន ម៉ៃ** ក៏បានបង្ហាញផងដែរពីសណ្តាប់ធ្នាប់ឬភាពរវាសរវៃរបស់ស្ត្រី នៅពេលចេញដើរហើរទៅណាមកណាដូចជា ការទៅប្រាស្រ័យទាក់ទងក្នុងមុខការងារអ្វីមួយនៅផ្ទះរបស់អ្នកដទៃ លោកហាមមិនឱ្យនៅផ្ទះគេយូរពេកទេ ត្រូវតែឆាប់វិលត្រលប់មកផ្ទះរបស់ខ្លួនវិញ។ ដូចមានសេចក្តីបញ្ជាក់ថា៖

កុំទៅនៅយូរផ្ទះគេ រវល់ទំនេរ រវៀសមកណា។
ហៃកូនខ្លឹមខ្លួនមាតា ជាស្រីនេះណា កម្រណាស់នាង។
មិនថាត្បិតល្អរូបរាង មិនរើសត្បិតជាង ចេះការទាំងគ្រប់។
មិនបានស្គាល់ទីគោរព ស្គាល់តែឧបទ្រព ទាំងគ្រប់ប្រការ។

### ១៣.៣.៨- គុណសម្បត្តិ និងគុណវិបត្តិនៃច្បាប់ស្រី

### ក- គុណសម្បត្តិ

យោងទៅតាមការសិក្សាទៅលើច្បាប់ស្រីរបស់បណ្ឌិត **ម៉ឺន ម៉ៃ** រួចមកយើងសង្កេតឃើញថា ច្បាប់នេះបានផ្តល់នូវគុណសម្បត្តិដូចខាងក្រោម៖

**- អប់រំស្ត្រីឱ្យចេះបង្កើតទំនាក់ទំនងល្អជាមួយញាតិមិត្ត៖** កាលណាស្ត្រីចេះបង្កើត និងរក្សានូវទំនាក់ទំនងជាមួយញាតិមិត្តជិតខាងដែលនៅជុំវិញខ្លួនបានល្អហើយនោះ ស្ត្រីអាចនឹងទទួលបាននូវចំណេះដឹង ក៏ដូចជាបទពិសោធន៍ល្អៗនានាទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ កូនចៅ ឬការគ្រប់គ្រងក្រុម

គ្រួសារទាំងមូល។ ម្យ៉ាងវិញទៀត ស្ត្រីក៏អាចចែករំលែកនូវចំណេះដឹង ឬបទពិសោធន៍ទាំងនោះទៅកាន់ស្ត្រីដទៃៗទៀតផងដែរ។ លើសពីនេះទៀតនោះកាលបើស្ត្រីអាចរក្សាបាននូវទំនាក់ទំនងល្អជាមួយអ្នកដទៃ នោះពួកគេអាចនឹងមានឱកាសកាន់តែច្រើន ដើម្បីទទួលបានជោគជ័យនៅក្នុងមុខរបររកស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ព្រមទាំងអាចឈានទៅដល់ការពង្រីកមុខរបរជួញដូរដ៏ល្អរបស់ខ្លួនផងដែរ។

- **អប់រំស្ត្រីឱ្យក្លាយជានារីដ៏ប្រពៃទាំងមុនពេលរៀបការ និងក្រោយពេលរៀបការ៖** ជានារីដែលមានកិរិយាទន់ភ្លន់តែរឹងមាំ មិនឆាប់ជឿក្នុងការអូសទាញពីអ្នកដទៃ(ជាពិសេសគឺបុរស) មិនចិត្តងាយ មិនចេះប្រមាថ ចេះថែរក្សាប្រពៃណី ធ្វើជាគំរូល្អក្នុងគ្រួសារ និងក្នុងសង្គមជាតិ។ ជាមួយគ្នានេះដែរ ស្ត្រីខ្មែរក៏ត្រូវមានក្រមសីលធម៌ល្អក្នុងការប្រាស្រ័យទាក់ទងគ្នា ទាំងការនិយាយស្តី ការប្រព្រឹត្តផ្សេងៗ។

**ខ- គុណវិបត្តិ**

**. ឆាប់ទទួលយកនូវវប្បធម៌បរទេស៖** នៅពេលដែលមនុស្សមានការទាក់ទងគ្នាទាំងខាងពាណិជ្ជកម្មសាសនា ឬនយោបាយ ពេលនោះហើយដែលមនុស្សមានការទទួលឥទ្ធិពលវប្បធម៌គ្នាទៅវិញទៅមក។ ស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការអប់រំនិងផ្សព្វផ្សាយវប្បធម៌ ពោលគឺកាលណាស្ត្រីពុំសូវមានចំណេះដឹង នោះពួកគេងាយនឹងទទួលយកវប្បធម៌បរទេសដោយមិនបានស្វែងយល់ពីគុណតម្លៃនៃសីលធម៌របស់ស្ត្រីខ្មែរ ដូចជាការស្លៀកពាក់មិនសមរម្យជាដើម។ កត្តាទាំងអស់នេះ គឺដោយសារតែកត្តាខ្លួនឯង កត្តាគ្រួសារនិងកត្តា

សង្គមផង។ ឧទាហរណ៍ ដូចជាការឡូយឆាយនឹងឧបករណ៍ប្រើប្រាស់ទំនើបៗ ការគេចវេសសាលាជាដើម។

. **សង្គមពេលខ្លះឱ្យតម្លៃស្ត្រី និងពេលខ្លះទម្លាក់តម្លៃស្ត្រី៖** ជាការពិតណាស់ សង្គមពេលខ្លះក៏ឱ្យតម្លៃស្ត្រី ហើយពេលខ្លះក៏បានបន្ទាបតម្លៃស្ត្រីដែរ។ នេះអាចនិយាយបានថា ដោយសារតែកត្តាជាច្រើនដែលបណ្តាលឱ្យរឿងនេះកើតមានឡើង។ កត្តាទាំងនោះក៏ដោយសារតែសង្គមមានការប្រែប្រួល (មានសង្គ្រាម គ្រោះទុរភិក្ស) ការទទួលវប្បធម៌បរទេស កង្វះការទទួលការអប់រំ និងការដណ្តើមតួនាទីស្ត្រី។ល។ ឧទាហណ៍៖ សង្គមខ្មែរពីដើម ស្ត្រីជាអ្នកដឹកនាំប្រទេស តែក្រោយមកត្រូវបានបុរស ដណ្តើមតួនាទីនោះទៅវិញ(ព្រះថោងនាងនាគ)។ សម័យកាលក្រោមមក របបសង្គមផ្លាស់ប្តូរជាច្រើនតំណ តម្លៃស្ត្រីក៏ត្រូវបានធ្លាក់ចុះជាបន្តបន្ទាប់ នារីខ្មែរត្រូវជាប់ច្រវាក់ប្រពៃណី រងគំនាបសង្គម និងពាក្យដំនៀលជាច្រើន តួយ៉ាង «**ស្ត្រីបង្វិលចង្ក្រានមិនជុំ**» «**មានកូនស្រី ដូចមានបង្គន់នៅមុខផ្ទះ** ឬកូនស្រីពិបាកណាស់ **ញ៉េញញ៉ុញ មុជមិនជ្រៅទៅមិនឆ្ងាយ**» «**កូនស្រីមិនចាំបាច់រៀនខ្ពស់ទេ**»...រហូតដល់មានការចងជាកាព្យទូន្មានទៀតថា «**លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង**» ដែលក្នុងនេះក៏មាន«**ឆ្កួតនឹងស្រី**»ជាធម្ជូតទី១ដែរ។ ការបង្អាប់មើលងាយមនុស្សស្រីយ៉ាងដូច្នេះ ធ្វើឱ្យតម្លៃនារីកាន់តែស្រកស្រុតចុះ ពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយមានការលំបាកខ្លាំងពេក នារីមួយចំនួនបានចាប់ផ្តើមងើបឈរតស៊ូ កែប្រែផ្នត់គំនិតអវិជ្ជមានទាំងនោះ។ ដោយបានការគាំទ្រពីមតិលើឆាកអន្តរជាតិផង ស្ត្រីខ្មែរបានស្គាល់នូវពន្លឺថ្មី។ ពាក្យស្លោក និងពាក្យលើកកម្ពស់តម្លៃនារីជាច្រើន ត្រូវបានគេស្រាវជ្រាវមកផ្សព្វផ្សាយដែលមានជាអាទិ៍ «**ស្ត្រីជា**

**មាតានៃពិភពលោក**» «**សំណាបយោងដី ស្រីយោងប្រុស**» «**សម្លឆ្ងាញ់ដោយសារគ្រឿង គ្រួសាររុងរឿងដោយសារភរិយា**»។ ក្នុងសង្គមខ្មែរបច្ចុប្បន្ន ទស្សនៈអវិជ្ជមានចំពោះស្ត្រី នៅតែបានបន្តអនុវត្តដោយអន្លើដែរ ពោលគឺពុំអាចបំបាត់ចេញទាំងស្រុងនោះឡើយ ហើយនេះជាហេតុធ្វើឱ្យនារីត្រូវរងទុក្ខវេទនាទាំងផ្លូវកាយ ផ្លូវចិត្ត និងរងអំពើហិង្សាក្នុងគ្រួសារ បាត់បង់សិទ្ធិរស់នៅប្រកបដោយភាពថ្លៃថ្នូរនៅក្នុងសង្គម គ្មានឱកាសទទួលបានការអប់រំ។ ការណ៍ដែលកូនស្រីមិនបានទៅរៀន ធ្វើឱ្យនាងខ្វះខាតចំណេះដឹង និងមិនអាចស្វែងរកការងារល្អធ្វើ ហើយស្ត្រីខ្មែរមួយចំនួនសម្រេចចិត្តចេញទៅធ្វើការតាមផ្ទះនៅបរទេស តែត្រូវគេជិះជាន់វាយធ្វើបាប អ្នកខ្លះត្រូវគេប្រើហិង្សា និងបង្ខំចាប់រំលោភផងដែរ។ ពេលត្រឡប់មកស្រុកវិញ ពលការិនីខ្មែរដែលទៅបម្រើការនៅក្រៅប្រទេសមួយចំនួនត្រូវវង្វេងបាត់បង់ស្មារតីផងក៏មាន។ ទាំងនេះបានផ្តល់សំណល់ទឹកភ្នែកសម្រាប់ក្រុមគ្រួសារជនរងគ្រោះ។

. **កង្វះការពិចារណារកចំណុចខ្សោយដោយខ្លួនឯង៖** នៅក្នុងទស្សនៈព្រះពុទ្ធសាសនា កាលបើបុគ្គលមិនយល់ពីលក្ខណៈពិតនៃលោកនេះ គេរមែងជាប់ជំពាក់ជ្រុលជ្រប់ងប់ក្នុងទ្រព្យសម្បត្តិ គេខ្វល់ខ្វាយក្នុងជីវិត ស្អិតជាប់នៅក្នុងសេចក្តីប្រាថ្នា តែគេក៏ក្តៅក្រហាយមិនធម្មតាព្រោះតែការលោភលន់ ហួងហែងខ្វល់ខ្វាយនៅក្នុងរឿងទ្រព្យសម្បត្តិនោះ។ ព្រះសម្ពុទ្ធទ្រង់យល់ពីសេចក្តីប្រាថ្នារបស់សត្វលោកយ៉ាងនេះហើយ ទើបព្រះអង្គត្រាស់ទេសនាអប់រំដល់ពុទ្ធបរិស័ទអំពីសេចក្តីទុក្ខដែលកើតពីចិត្តជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិជ្រុលជ្រប់ពេក រមែងជាបុគ្គលដេកមិនលក់ស៊ប់ ចិត្តរវើរវាយមិនស្ងប់រម្ងាប់ ព្រោះកាលបើបុគ្គលចងចិត្តលោភលន់ ស្រលាញ់ ស្អប់ ចងកំហឹង ច្រណែន ការចងគំនុំ...

ទាំងអស់ហ្នឹងហើយដែលជាទុក្ខ ជាគ្រឿងចងចិត្តសត្វលោកមិនឱ្យមើលឃើញនូវអ្វីជាអបាយភូមិ ថែមទាំងវេចខ្ចប់វិញ្ញាណរបស់សត្វលោកមិនឱ្យមើលឃើញនូវសេចក្តីល្អទៀតផង។ ព្រះអង្គត្រាស់សម្តែងថា អវិជ្ជាគឺសេចក្តីមិនដឹងទុក្ខ មិនដឹងក្នុងតណ្ហា មិនដឹងក្នុងចំណង់ គ្រឿងជាប់ជំពាក់ហ្នឹងហើយដែលជាហេតុនាំឱ្យកើតទុក្ខ លុះណាតែបុគ្គលលះការលោភលន់ លះការជាប់ជំពាក់ក្នុងវត្ថុកាមដទៃៗទៀតទើបបានសុខ ពោលគឺកាលណាស្ត្រីបណ្តោយខ្លួនឱ្យធ្លាក់ទៅក្នុងភាពលោភលន់ទ្រព្យសម្បត្តិ សេចក្តីមិនស្កប់ក្នុងផ្លូវកាមគុណក៏ជាប្រភពដ៏សំខាន់ដែលនាំឱ្យស្ត្រីអស់តម្លៃនៅក្នុងសង្គម ដោយភាពឈ្លក់វង្វេងនឹងទ្រព្យសម្បត្តិ និងការសប្បាយភ្លេចខ្លួនរបស់ស្ត្រី ជាដើម។ ដូចជាករណីអំពើ «ផិត» គឺជាការលួចលាក់មានស្នេហាខុសគន្លងទៅលើប្តីប្រពន្ធកូនអ្នកដទៃ ការលះបង់ដៃគូចាស់ ចាប់យកដៃគូថ្មីដោយហេតុផល ផលប្រយោជន៍ ស្នេហា ឬនិន្នាការនយោបាយ។ ការលបលួចលះបង់ស្នេហាចាស់ ផ្លាស់យកស្នេហាថ្មីដោយលាក់កំបាំងក្តី ដោយចំហរក្តី នេះបើតាមការបកស្រាយក្រៅផ្លូវការរបស់អ្នកនិពន្ធ។

អំពើផិតក្បត់ មិនត្រូវបានគេចាត់ទុកជាអំពើល្អប្រសើរនោះទេ ហើយរូបភាពនៃអំពើផិតក្បត់គេច្រើនសំដៅទៅលើស្ត្រីដែលមានដៃគូស្នេហាហើយ ហើយទៅលបលួចមានដៃគូថ្មី គេហៅថា ស្រីផិតឬស្រីក្បត់ ឬស្រីផិតក្បត់។ ចំណែកបុរសវិញ គេច្រើនប្រើពាក្យ«ទៅមានស្រី» វិញ តែពាក្យពីរនេះមានន័យដូចគ្នា។ ជាទូទៅអំពើផិតក្បត់បានកើតឡើងដោយសារកត្តាមួយចំនួនក្នុងជីវិតគូរបស់មនុស្ស ដូចជាការមិនចុះសម្រុងផ្នែករាងកាយ ការមិនចុះសម្រុងផ្នែកសុវត្ថិភាព ការមិនចុះសម្រុងផ្នែកអារម្មណ៍ និងមនោសញ្ចេតនា និងការមិនចុះ

សម្រុងផ្នែកជីវភាព សេដ្ឋកិច្ច។ ឧទាហរណ៍ ក្នុងរឿង «**សព្វសិទ្ធិ**» ចាបញីយល់ច្រឡំថាចាបឈ្មោលមានអំពើលួចលាក់ផិតក្បត់នឹងខ្លួន ដោយលួចទៅប្រលោមប្រលែងនឹងចាបញីដទៃទៀត ក៏សុខចិត្តលោតចូលភ្លើង តែមុននឹងលោតក៏បានតាំងសច្ចាប្រណិធានថា នឹងមិននិយាយរកមនុស្សប្រុសជាដាច់ខាតនៅជាតិក្រោយ។ នេះគឺជាការវិនាសប្រាស់ព្រាត់គ្នា ដោយសារការយល់ច្រឡំរឿងផិតក្បត់។ បើយើងសង្កេតតាមរយៈអក្សរសិល្ប៍ខ្មែរ រឿងបែបនេះវាកើតមានតាំងពីយូរយារណាស់មកហើយ។ អ្នកនិពន្ធខ្មែរយើង បានបង្ហាញឱ្យឃើញថារឿង«ផិតក្បត់» វាផ្ដើមចេញពីកត្តាជីវសាស្ត្រ ពីសេចក្ដីត្រូវការក្នុងរឿងកាមគុណ ដែលគេនិយមហៅថា«វិបត្តិកាមគុណ»។ ជាទូទៅយើងឃើញថាការផិតក្បត់នេះ ច្រើនតែកើតមានឡើងក្នុងករណីដែលបុរសជាប្ដីមិនបានបំពេញកាមកិច្ចជាមួយភរិយាឱ្យបានគ្រប់គ្រាន់ ដូចជាក្នុងករណីបុរសមានប្រពន្ធច្រើន បុរសមិនរវល់នឹងកាមកិច្ច ឬខ្វះបច្ចេកទេស ឬឃ្លាតឆ្ងាយពីភរិយាជាដើម។ យើងមានរឿងនិទានជាច្រើនដែលឆ្លុះបញ្ចាំងតថភាពបែបនេះ ដូចជារឿង«**ពស់កេងកង**» ប្រពន្ធបានក្បត់ប្ដីទៅរួមរក្សជាមួយសត្វពស់កេងកង ក៏ព្រោះតែប្ដីជាអ្នកជំនួញ ដើរបាត់ពីផ្ទះបួនប្រាំឆ្នាំទើបមកជួបប្រពន្ធម្ដង។ រឿង«**មាយាស្ត្រី**» ប្រពន្ធក្បត់ប្ដី ក៏ដោយសារប្ដីនោះជាមនុស្សដែលមិនរវល់សោះក្នុងរឿងកាមគុណ សូម្បីតែប្រពន្ធមានសាហាយក៏មិនដឹងផង។ រឿង «**កាកី**» កាកីក្បត់នឹងព្រហ្មទត្ត ក៏ស្ថិតលើមូលហេតុមិនខុសពីនេះដែរ។ ជាការពិតណាស់ដែលថា ព្រហ្មទត្តស្រឡាញ់កាកីយ៉ាងខ្លាំង ពេលបាត់កាកី ព្រហ្មទត្តកើតទុក្ខ នៅមិនស្ងៀម តែក្នុងទំនាក់ទំនងរស់នៅជាមួយគ្នារាល់ថ្ងៃយើងឃើញថា ព្រហ្មទត្តពិតជាពុំបានបំពេញកាមកិច្ចឱ្យបានគ្រប់គ្រាន់ដល់កាកីឡើយ។ ទី

១ **ព្រហ្មទត្ត**ជាស្ដេចដែលចូលចិត្តលេងល្បែងបាស្កា ភ្លេចពេលវេលាសម្រាប់ប្រពន្ធ។ ទី២ **ព្រហ្មទត្ត**ជាស្ដេចមានស្រីស្នំរាប់រយ ពោលគឺមិនមានពេលវេលារួមរស់តែជាមួយនាងកាកីនោះទេ។ រឿង«ផិតក្បត់» គឺវាកើតចេញពីសេចក្ដីត្រូវការផ្នែកកាមគុណដែលជាច្បាប់ធម្មជាតិ។ ឯនារីជាទូទៅក៏ដូចគ្នាដែរ តែងតែត្រូវការបុរសម្នាក់ជាស្វាមីដែលចេះថ្នាក់ថ្នមនាង អាចបំពេញកាមតណ្ហាឱ្យនាងបានគ្រប់គ្រាន់ បើពុំនោះទេការផិតក្បត់វានឹងកើតមាន។ បើយើងគិតតាមច្បាប់ធម្មជាតិ គេមិនត្រូវដាក់ទោសចំពោះអំពើរបៀបនេះទេ តែក្នុងសង្គមខ្មែរយើង អ្នកដែលប្រព្រឹត្តិបែបនេះតែងតែទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ។ តួយ៉ាងក្នុងរឿង«**កាកី**» នាងកាកីដែលត្រូវបានគេចោទថាជាស្រីផិតក្បត់នោះ ត្រូវបានគេនិរទេសទៅកាន់មហាសាគរ ជាមួយទូកតូចមួយ ហើយនាងក៏បានបង់សង្ខារក្នុងមហាជលសារនោះទៅ។ ចំណែកក្នុងរឿងពស់«**កេងកង**»ក្រោយពេលដែលដឹងថានាងជាភរិយាសាហាយស្មន់និងសត្វពស់ ក៏បណ្ដេញចេញពីភូមិស្រុកឱ្យទៅរស់នៅក្នុងព្រៃតែម្នាក់ឯង។ ដោយឡែក រឿង«**មាយាស្ត្រី**» អ្នកនិពន្ធខ្មែរហាក់ចង់បង្ហាញពីឥទ្ធិពលនៃមន្តមាយាច្រើនជាងការបង្ហាញពីភាពផិតក្បត់របស់មនុស្សស្រី ប៉ុន្តែក៏បង្ហាញពីភាពល្ងង់ឆោតរបស់ស្វាមីដែលមិនយល់បន្តិចសោះ ក្នុងការស្វែងយល់ពីឥរិយាបថរបស់ភរិយា ដូច្នេះអ្នកនិពន្ធមិនបានផ្ដល់ទោសបញ្ញត្តិសម្រាប់ការផិតក្បត់ក្នុងមន្តមាយានេះដែរ។

ជារួមគ្មានរូបមន្តសម្រាប់បញ្ចប់ភាពផិតក្បត់របស់មនុស្សបានទេ ព្រោះតែតម្រូវការផ្នែកកាមគុណ ផ្នែកសុវត្ថិភាពផ្លូវចិត្ត និងកត្តាទ្រព្យសម្បត្តិ និយាយឱ្យចំគឺកាលណាមនុស្សនៅតែមិនអាចលះបង់កាមរាគៈបាន មនុស្សនៅតែធ្វើរឿងផិតក្បត់។ ប៉ុន្តែអ្វីដែលអាចជួយបាន គឺដៃគូស្នេហាត្រូវហ្វឹកហាត់ក្នុងការ

ផ្តល់នូវតម្រូវការឱ្យគ្នាទៅវិញទៅមក ស្វែងយល់សាកសួរពីអ្វីដែលគ្នានិងគ្នាចង់បាន ពីព្រោះបើអ្នកនិយាយចេញមក ឬអ្នកសំណូមពរវា នោះអ្នកនឹងមានវិធីដោះស្រាយជាជាងការលាក់ទុក ហើយទៅលួចលាក់ក្រោយខ្នង បង្កជាភាពរកាំរកូសអូសដំណើរឈានដល់ការបែកបាក់ ធ្វើឱ្យជីវិតជាតិនេះក្លាយជាល្បីងផ្លូវចត់អត់ន័យខ្លឹមសារទៅវិញ។

**. ឆាប់ចាញ់បោកគេ៖** ចង់ដឹងថាមនុស្សណាម្នាក់ជាអ្នកស្មោះ មិនអាចកំណត់ពាក្យដែលគេនិយាយត្រឹមតែពីបីឃ្លានោះទេ។ គប្បីត្រូវពិចារណាឱ្យបានម៉ត់ចត់ មុននឹងជ្រើសយកបុរសណាម្នាក់ ឬក៏នរណាដែលបបួលបញ្ចុះបញ្ចូលឱ្យធ្វើអ្វីមួយ។ ឧទាហរណ៍ អាជ្ញាធរខ្មែរជារឿយៗតែងតែបានរំដោះស្ត្រីខ្មែរមួយចំនួន ដែលបានចាញ់បោកគេដោយការរៀបការទៅនៅក្រៅប្រទេស។ មន្ត្រីសង្គមស៊ីវិលដែលឃ្លាំមើលសិទ្ធិការងារលើកឡើងថា ដោយសារតែបញ្ហាជីវភាពទើបធ្វើឱ្យស្ត្រីខ្មែរងាយស្រួលបាញ់បោករៀបការជាមួយជនជាតិបរទេសដែលមិនស្គាល់ប្រវត្តិច្បាស់លាស់។

ក្រសួងការបរទេសកម្ពុជាថា ស្ថានកុងស៊ុលកម្ពុជាប្រចាំនៅក្នុងទីក្រុងសៀងហៃ ប្រទេសចិន បានសហការជាមួយអាជ្ញាធរចិនជួយស្ត្រីខ្មែរមួយរូបស្នាក់នៅក្នុងខេត្តជីជាំង ដោយសារតែលោកស្រីរស់នៅមិនចុះសម្រុងគ្នាជាមួយស្វាមី ហើយបានបង្ហោះតាមបណ្តាញសង្គមហ្វេសប៊ុក សុំឱ្យលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជួយអន្តរាគមន៍។ រដ្ឋាភិបាលកម្ពុជាបានជួយស្ត្រីខ្មែរចំនួន៧៥នាក់ហើយ ក្រោយពីចាញ់បោកគេទៅរៀបការនៅក្នុងប្រទេសចិន ក្នុងរយៈពេល៩ខែកន្លងទៅនេះ។ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អ្នកស្រី **ជូ ប៊ុនអេង** និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរ

មនុស្សបានមានប្រសាសន៍ប្រាប់ក្រុមអ្នកការសែតនៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីការជួយជូរមនុស្សថា *ស្ត្រីខ្មែរក្មេងៗងាយនឹងរងគ្រោះដោយសារចាញ់បោកគេទៅរៀបការជាមួយនៅក្រៅប្រទេស* ។ អ្នកស្រីបន្តទៀតថា ការរៀបការនៅក្រៅប្រទេសដោយសង្ឃឹមថា នឹងមានជីវភាពសមរម្យ ធ្វើឱ្យស្ត្រីខ្មែរងាយស្រួលក្នុងការចាញ់បោកគេ។ អ្នកស្រីបានឱ្យដឹងទៀតថា ស្ត្រីខ្មែរគួរតែទប់ស្មារតីដើម្បីកុំឱ្យចាញ់បោកគេ ហើយរៀនរស់នៅក្នុងប្រទេសប្រសើរជាង «*អុីចឹងកុំចេញប្រថុយប្រថាន យើងរៀនរស់នៅក្នុងស្រុក ក្នុងស្ថានភាពមួយល្អប្រសើរដូចគេដូចឯង ពីព្រោះមនុស្សរាប់លាននាក់គេអាចរស់បាន តើហេតុអ្វីយើងមិនអាចរស់បាន ហើយបើចេញទៅក្រៅប្រទេស យើងមិនហាមឃាត់ទេ បើក្នុងករណីមានសុវត្ថិភាព។ ប៉ុន្តែបើយល់ថា ចេញទៅចាញ់បោកគេ ហើយគ្មាន សុវត្ថិភាព គួរតែទប់ស្កាត់ចិត្តខ្លួនឯងដើម្បីកុំឱ្យមានការចាញ់បោកបន្តទៀត*»។ ទាក់ទិននឹងបញ្ហាស្ត្រីខ្មែរចាញ់បោកគេនេះ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស លោក **មឿន តុលា** មានប្រសាសន៍ថា *ស្ត្រីខ្មែរងាយស្រួលរងគ្រោះចាញ់បោកគេ ទៅរៀបការនៅក្រៅប្រទេស គឺបណ្តាលមកពីភាពក្រីក្រ គ្មានការងារធ្វើ ជំពាក់បំណុលគេ ហើយនឹងប្រព័ន្ធសេវាសង្គមរបស់រដ្ឋាភិបាលមិនទាន់បានទូលំទូលាយ។*

លោកថា នៅបណ្តាប្រទេសមួយចំនួននៅពេលណាដែលពលរដ្ឋអត់ការងារធ្វើ រដ្ឋាភិបាលជាអ្នកទទួលបន្ទុកចំណាយមួយចំនួនរបស់ពលរដ្ឋ ប៉ុន្តែនៅកម្ពុជាពុំទាន់មានប្រព័ន្ធសង្គមឱ្យបានគ្រប់គ្រាន់ទេ គឺពលរដ្ឋប្រឹងរស់ ប្រឹងរកការងារ ប្រឹងរកចំណូលអ្វីផ្សេងៗដោយខ្លួនឯង។ លោកបន្ថែមថា មេខ្យល់ក៏ជាចំណុចសំខាន់ក្នុងការទាក់ទាញស្ត្រីខ្មែរទៅរៀបការនៅក្រៅប្រទេសផងដែរ

*«ដោយសារតែមានមេខ្យល់មកបញ្ចុះបញ្ចូលថា គាត់អាចមានឱកាសទទួលបានការងារធ្វើនៅក្រៅប្រទេស។ល។ ទាំងប្រទេសថៃ(Thailand)ក្តី ម៉ាឡេស៊ី (Malaysia) ចិន (China) កូរ៉េ (South Korea) ឬមួយជប៉ុន (Japan) ជាដើម។ មេខ្យល់នេះមែនទែនទៅ ដោយសារការអនុវត្តច្បាប់នៅកម្ពុជានៅមានភាពធូររលុង ហើយអំពើពុករលួយយើងនៅខ្ពស់។ អ៊ីចឹងជាឱកាសមួយរបស់មេខ្យល់ហ្នឹងអាចធ្វើសកម្មភាពរាងទូលំទូលាយដែរ»*។

របាយការណ៍ ក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីពីការជួញដូរមនុស្សឆ្នាំ២០២០ បានបង្ហាញថា អំពើពុករលួយយ៉ាងរាលដាលជួយជំរុញមានបទល្មើសជួញដូរមនុស្ស។ របាយការណ៍បន្ថែមទៀតថា មន្ត្រីពុករលួយសម្រួលការជួញដូរឆ្លងកាត់ព្រំដែន រារាំងការស៊ើបអង្កេត និងការកាត់ទោស ហើយក្នុងករណីខ្លះ ទទួលបានផលចំណេញដោយផ្ទាល់ពីការជួញដូរ។[៧០]

. **មាយាស្ត្រី**៖ ក្នុងជំពូកនេះ ស្ត្រីប្រសិនបើនាងយករូបឆោមលោមពណ៌របស់ខ្លួនមកបង្អួតបុរស ឬទាក់ទាញឱ្យធ្វើអ្វីមួយ លទ្ធផលអាចនឹងទទួលបានក្នុងពេលយូរឬក៏ឆាប់ ហើយក្នុងករណីដែលស្ត្រីនោះមានប្តីហើយ កុំគប្បីទៅឡេះឡោះជាមួយនឹងបុរសដទៃឡើយ។ តួយ៉ាងដូចជានាងកាកីអញ្ចឹង មានស្វាមីហើយ ហេតុអ្វីក៏មកអើតឡឺមបញ្ចេញសុជន់ដាក់**គ្រុឌ**ដែលកំពុងតែលេងបាស្ការជាមួយស្តេច**ព្រហ្មទត្ត**ឱ្យវង្វេង រហូតដល់ទៅធ្វើជាព្យុះព្យមកឆាបយកនាងកាកីចេញទៅ ហើយទុកក្នុងនគរតែម្នាក់ឯង។

---

[៧០] https://www.central-cambodia.org/km/archives/4727

ដូច្នេះតាមការបកស្រាយខាងលើឃើញថា ស្ត្រីមានតួនាទីយ៉ាងសំខាន់នៅក្នុងគ្រួសារនិងសង្គម ទាំងការអប់រំ សីលធម៌ គុណធម៌និងឥរិយាបថ ពោលគឺនៅក្នុងគ្រួសារស្ត្រីបានអប់រំកូនចៅឱ្យមានចំណេះដឹង មានឥរិយាបថល្អ ដើម្បីឱ្យពួកគេចេះរស់នៅក្នុងសង្គមមួយប្រកបដោយសេចក្តីថ្លៃថ្នូរ។ រីឯនៅក្នុងសង្គមស្ត្រីមានតួនាទីជាអ្នកដឹកនាំស្ថាប័នរដ្ឋនិងឯកជន ពោលគឺស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចដ៏សំខាន់ក្នុងការអភិវឌ្ឍសង្គម។

សរុបយើងឃើញថា ការដែលលោកខិតខំតាក់តែងកំណាព្យអប់រំដល់ស្ត្រីនេះឡើង គឺជាសក្ខីកម្មមួយដែលបង្ហាញឱ្យឃើញថា លោកយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើស្ត្រីដូចកវីអ្នកប្រាជ្ញដទៃទៀតដែរ គឺចង់ឱ្យស្ត្រីខ្មែររស់នៅប្រកបដោយលក្ខណាជាលម្អ និងជាកម្លាំងចលករដ៏ប្រសើរសម្រាប់ក្រុមគ្រួសារនិងប្រទេសជាតិទាំងមូល។

## ១៣.៤- ច្បាប់សុភាសិតរបស់ឧកញ៉ាសុត្តន្តប្រីយជាឥន្ទ្រ

នៅក្នុង **ច្បាប់សុភាសិត** របស់ **ឧកញ៉ាសុត្តន្តប្រីយជាឥន្ទ្រ** នេះ លោកបានចងក្រងច្បាប់នេះឡើង គឺដើម្បីទុកជាគតិអប់រំជាច្រើនសម្រាប់ប្រជាជាតិខ្មែរ ជាពិសេសគឺលោកបានសង្កត់ធ្ងន់លើការអប់រំបុត្រធីតាខ្មែរឱ្យប្រណិបត្តិប្រព្រឹត្តខ្លួនយ៉ាងណាឱ្យក្លាយជានារីដ៏ប្រសើរឧត្តមមុននឹងក្លាយជាប្រពន្ធ និងជាម្តាយគេទៅអនាគត។ លោកបានទូន្មានឱ្យនារីខ្មែរ ចេះរៀនកិច្ចការវិជ្ជាមេផ្ទះ និងត្រូវរៀបចំកិរិយាមារយាទឱ្យបានសមសួន ពីព្រោះមានតែចរិយាសម្បត្តិនេះហើយដែលជាគុណសម្បត្តិដ៏ល្អប្រពៃថ្លៃថ្លាសម្រាប់ស្ត្រីក្រមុំ។ ជាក់ស្តែងដូចមាននៅក្នុងពាក្យកាព្យបានបញ្ជាក់ថា៖

*. ជានារីតោងរៀនកិច្ចដាក់ទុក ការស៊ីចុកដេកដើរធ្វើអ្វីៗ*

*មើលប្រមាណតាមស្ថានខ្លួនជាស្រី ជាតិស្ត្រីស្រីក្រមុំធំឥរិយា។*[៧១]

ម្យ៉ាងវិញទៀតលោកក៏បានបញ្ជាក់ផងដែរអំពីតួនាទីជាកូនស្រី ត្រូវតែដឹងនូវឧបការគុណរបស់មាតាបិតាដែលលោកខិតខំបីបាច់ថែរក្សា និងចាត់ទុកកូនស្រីជាកំណប់ទ្រព្យដ៏ប្រសើររបស់លោក ហើយពួកគាត់ពិតជាពុំចង់ឃើញកូនស្រីរបស់គាត់ក្លាយទៅជាកូនដែលរមិលគុណ ជាកូនដែលពុំដឹងនូវអនន្តគុណ ឬជាកូនដែលពុំគាប់ប្រសើរនោះឡើយ។ តួយ៉ាងមានសេចក្ដីបញ្ជាក់ថា៖

*- មែនស្រីណាឫស្យាធ្វើទុច្ចរិត ពុំមានគិតគុណលោកចិញ្ចឹម*
*ឃើញម៉ែឪដល់នូវសេចក្ដីក្រ មិនតបតគុណលោកប៉ុនកេសី។[....]*
*- កើតជាស្រីគ្មានអ្វីសងគុណម៉ែ រក្សាតែកេរ្តិ៍លោកឱ្យវរ*
*ស្មើសងគុណដែលលោកពឧទរ ប្រាកដឮមានករខ្ចរខ្ចាយទៅ។*[៧២]

ជាមួយគ្នានេះដែរ លោកក៏បានណែនាំស្ត្រីខ្មែរត្រូវប្រយ័ត្នប្រយែងក្នុងការជ្រើសរើសគូស្រករ គឺត្រូវឱ្យម្ដាយឪពុកដឹងឮ និងចូលរួមចាត់ចែងរៀបចំទុកដាក់ឱ្យផង។ បានសេចក្ដីថា លោកពុំចង់ឱ្យស្ត្រីខ្មែរយកប្ដីដោយចិត្តឯងដោយពុំមានការដឹងឮឬយល់ស្របពីឪពុកម្ដាយទេ ពីព្រោះវានឹងនាំឱ្យអាប់ឱនកិត្តិយសខ្លួនឯងនិងក្រុមគ្រួសារ។ ដូចមានសេចក្ដីបានលើកឡើងនៅក្នុងច្បាប់របស់គាត់ថា៖

*កុំធ្វើក្រៅច្បាប់ស្រីឱ្យក្ដីខុស ស្រឡាញ់ប្រុសក្រៅចិត្តម៉ែឪប្រាណ*

---

[៧១] សុត្តន្តប្រីជាឥន្ទ *សុភាសិតច្បាប់ស្រី* បោះពុម្ពលើកទី៣ ទំព័រ២៣។

[៧២] សុត្តន្តប្រីជាឥន្ទ *សុភាសិតច្បាប់ស្រី* -ដ.ឯ.ម- ទំព័រ ២៦-៣១។

*កាត់ប្រយោជន៍សារលោហិតមិត្តសន្តាន ឱ្យលោកបានទុក្ខទោសក្នុង លោកិយ។*[៧៣]

យើងក៏បានសង្កេតឃើញផងដែរថា លោកបានបញ្ចូលទស្សនៈទំនើបខ្លះៗដែរនៅក្នុងច្បាប់នេះ គឺលោកចង់រំឭកដល់ស្ត្រីខ្មែររៀនសូត្រចាប់យកចំណេះជំនាញណាមួយឱ្យបានចេះច្បាស់លាស់ពិតប្រាកដ ពីព្រោះវាជាមធ្យោបាយដ៏ល្អបំផុត ដើម្បីជួយសម្រាលដល់បន្ទុករបស់ស្វាមីនៅក្នុងរបបរកស៊ីចិញ្ចឹមគ្រួសារនិងកិច្ចការផ្សេងៗទៀត ដើម្បីកុំឱ្យស្វាមីហត់នឿយ មួរម៉ៅក្តៅក្រហាយអាចនឹងឈានទៅដល់ការប្រព្រឹត្តនូវអំពើហិង្សាក្នុងគ្រួសារក៏សឹងមាន។ នៅក្នុងន័យនេះចង់បញ្ជាក់ថា បើកាលណាស្ត្រីឬភរិយាមាននូវចំណេះ ហើយមិនត្រឹមតែអាចជួយសម្រួលដល់ស្វាមីតែម្យ៉ាងប៉ុណ្ណោះទេ តែថែមទាំងអាចរឹតបន្តឹងនូវចំណងសាមគ្គីភាពជាមួយស្វាមីចាប់ដៃគ្នាកសាងនូវសុភមង្គលគ្រួសារថែមទៀត។ ជាក់ស្តែង ដូចមានសេចក្តីបញ្ជាក់ស្រាប់៖

*រៀនវិជ្ជាឱ្យចេះជាគ្រូគេ ទើបទំនេរមិនសូវនឿយឥន្ទ្រិយ*

*ចេះស្មើរៗមិនស្ទាត់ហត់តិមជី ជានារីមិនចេះអ្វីប្តីនឿយឯង។*[៧៤]

សរុបសេចក្តីមកយើងឃើញថា ថ្វីត្បិតតែលោក**ឧកញ៉ាសុត្តន្តប្រីជាឥន្ទ** ទទួលឥទ្ធិពលពីអ្នកប្រាជ្ញជំនាន់មុនៗ ដែលបានអប់រំស្ត្រីខ្មែរទៅតាមបែបបទសីលធម៌នៃលទ្ធិព្រះពុទ្ធសាសនាក៏ពិតមែន ប៉ុន្តែស្នាដៃរបស់លោកចាប់ផ្តើម

---

[៧៣] សុត្តន្តប្រីជាឥន្ទ សុភាសិតច្បាប់ស្រី -ដ.ឯ.ម- ទំព័រ ២៦។

[៧៤] -ដ- ទំព័រ ៦០។

មានលក្ខណៈទំនើបជាងមុនបន្តិច ដោយសារតែសុភាសិតច្បាប់ស្រីរបស់លោក មានទំនោរងាកមករកបរិបទនៃសង្គមខ្មែរច្រើនជាងមុន។ ត្រង់ចំណុចនេះចង់បញ្ជាក់ថា ច្បាប់ស្រីរបស់លោកផ្តោតជាសំខាន់ទៅលើការអប់រំស្ត្រី ទៅតាមស្ថានភាព និងទិដ្ឋភាពនៃសង្គមជាក់ស្តែង ស្របតាមផ្នត់គំនិតរបស់ខ្មែរក្នុងការអប់រំគ្រួសារច្រើនជាងច្បាប់ស្រីរបស់អ្នកប្រាជ្ញកវីមុនៗ។ ប៉ុន្តែគោលបំណងនៃការអប់រំស្ត្រីនេះ គឺពុំមានអ្វីខុសប្លែកគ្នាប៉ុន្មានទេ ពីព្រោះទាំងអ្នកប្រាជ្ញជំនាន់មុន រួមទាំងលោកឧកញ៉ា **សុតន្តប្រីជាឥន្ទ** ផង សុទ្ធតែចង់អប់រំស្ត្រីខ្មែរយើងឱ្យក្លាយទៅជាទៅជាកូនដ៏ល្អរបស់ម្តាយឪពុក ជាភរិយាដ៏ល្អរបស់ស្វាមី និងជាម្តាយដ៏ល្អរបស់កូនៗទាំងនៅក្នុងក្រុមគ្រួសារ និងសង្គមជាតិទាំងមូល សមដូចទស្សនៈទំនើបបច្ចុប្បន្ននេះពោលថា«*ស្ត្រីជាមាតានៃពិភពលោក*»។

## ១៣.៥- ច្បាប់ក្រមរបស់អ្នកព្រះឥសូរស្រាអធិរាជ ហៅ ង៉ុយ

ដូចបានរៀបរាប់ខាងលើម្តងរួចមកហើយថា លោកតា **ក្រម ង៉ុយ** ជាកវីឯកមួយរូបដែលមានឈ្មោះល្បីរន្ទឺនៅនាកំឡុងស.វ.ទី២០។ លោកបានខិតខំអប់រំកូនខ្មែរទាំងប្រុសស្រីឱ្យក្លាយទៅជាមនុស្ស និងការរស់នៅប្រកបដោយភាពចុះសម្រុងគ្នានៅក្នុងសង្គម។ ជាពិសេស គឺការសិក្សារៀនសូត្រចាប់យកនូវចំណេះវិជ្ជាការផ្សេងៗ ព្រមទាំងបេររកស៊ីចិញ្ចឹមជីវិតផង គឺកូនខ្មែរទាំងប្រុសស្រីត្រូវសង្វាតស្វះស្វែងប្រឹងប្រែងឱហាតកុំគប្បីធ្វេសប្រហែសឡើយ ដែលប្រការនេះដូចមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ល្បើកថ្មីរបស់លោកថា៖

*បើល្ងង់ឱ្យចេះ រករៀនតម្រិះ រិះរកតម្រាប់*
*ឥន្ទ្រិយឆ្វេងស្តាំ កុំចាំគេប្រាប់ រៀនស្តីរៀនស្តាប់*
*រៀនមើលឱ្យស្តែង។*

*កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង*
*បើក្រឱ្យមាន វិញ្ញាណចេះក្រែង គិតគ្រប់កន្លែង*
*កុំដេកតែក្រ។ (ល្បះទី៤៦-៤៧)*

រីឯការជ្រើសរើសគូស្រករវិញ កវី **ក្រម ង៉ុយ** បានបង្ហាញពីទស្សនៈទំនើបដែលមានលក្ខណៈវិទ្យាសាស្ត្រ (គំនិតរីកចម្រើន) ពីព្រោះលោកបានអប់រំទូន្មានកូនខ្មែរមិនឱ្យជឿលើលេខអត្ត (ក្បួនទស្សន៍ទាយ) ឬក្បួនតម្រាផ្សេងៗដែលនាំឱ្យខាតបង់នូវផលប្រយោជន៍ដោយប្រការណាមួយ។ មិនតែប៉ុណ្ណោះលោកបានផ្ដាំទុកថា *បើកាលណារកប្រពន្ធប្ដីឱ្យរកស្រុកជិត ពីព្រោះវាងាយស្រួលឱ្យពិនិត្យមើលពីពូជពង្សវាតា កិរិយាមារយាទជាដើម។ ប៉ុន្តែបើរកឯស្រុកឆ្ងាយវិញ លោកថាត្រូវឱ្យម្ដាយជួយពិនិត្យពិចារណា មិនត្រូវធ្វើអ្វីតាមតែចិត្តឯង ដោយគ្មានឪពុកម្ដាយដឹងឮនោះទេ។* ប្រការដែលពិសេសនោះគឺលោកបានលើកតម្លៃអំពីសិទ្ធិរបស់ស្ត្រី មានន័យថាស្ត្រីមានសិទ្ធិជ្រើសរើសគូស្រករ ឬមានសិទ្ធិសម្រេចទៅលើជោគវាសនាអនាគតរបស់ខ្លួនដោយខ្លួនឯង។ ប៉ុន្តែត្រូវមានការទទួលយល់ព្រមពីសំណាក់មាតាបិតា ឬឪពុកម្ដាយផងដែរ។ ត្រង់ចំណុចនេះ លោកសាស្ត្រាចារ្យ **ជា សុខម៉េង** បានសរសេរថា «.....*លោក **ភិរម្យង៉ុយ** លោកបានងាកចេញបន្តិចបន្តួចអំពីទស្សនៈនំមិនធំជាងនាឡិ ដែលដក់ជាប់នៅក្នុងផ្នត់គំនិតរបស់ប្រជារាស្ត្រខ្មែរតាំងពីយូរយារណាស់មកហើយ។ លោកយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ គឺជាអនាគតដ៏យូរអង្វែងដែលទាមទារឱ្យសាម៉ីខ្លួនទាំងពីរទទួលដឹងឮ និងទទួលបាននូវសិទ្ធិសម្រេចចិត្ត*

*សម្រាប់ខ្លួនឯងផ្ទាល់*»។[៧៥] ជាក់ស្តែងដូចមានបញ្ជាក់ស្រាប់នៅក្នុងច្បាប់ល្បើកថ្មីរបស់លោកតា **ក្រម ង៉ុយ** ដដែលនេះថា៖

*កូនចៅប្រុសស្រី រកប្រពន្ធប្តី ឱ្យរកស្រុកជិត*
*បើរកស្រុកឆ្ងាយ ឱ្យម្តាយពិនិត្យ ឱ្យត្រឹមត្រូវពិត*
*ពូជពង្សវង្សាវតា។*
*កូនអើយអ្នកចាំ កុំយកខែឆ្នាំ កុំជឿតម្រា*
*ពាក្យក្បួនតម្រាយ កើតពីមនុស្សចារ ពីដូនពីតាចារតាមសម្គាល់។*
*(ល្បះទី៧៨-៧៩)*

## ១៤- ស្ត្រី និងច្បាប់សម័យទំនើប

### ១៤.១- ច្បាប់ជាតិ

ដោយមានការទាមទារសិទ្ធិស្មើភាពគ្នានៅក្នុងសកម្មភាពសង្គមដោយឥតឈប់ឈរ ទើបមានការផ្លាស់ប្តូរនូវផ្នត់គំនិតមួយចំនួនចំពោះសមភាពរវាងបុរសនិងស្ត្រី រួមមាន៖

#### ✍ រដ្ឋធម្មនុញ្ញ

នៅក្នុងមាត្រា៤៥នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា ការរើសអើងគ្រប់ប្រភេទត្រូវបានបំបាត់ចោល។ ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់។ បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ។ អាពាហ៍ពិពាហ៍ ត្រូវធ្វើតាម

[៧៥] ជា សុកម៉េង *តួនាទីស្ត្រីខ្មែរតាមរយៈប្រវត្តិសាស្ត្រ និង អក្សរសិល្ប៍* ទស្សនាវដ្តីសង្គមសាស្ត្រ-មនុស្សសាស្ត្រ ឆ្នាំ២០០៤ ទំព័រ៤។

លក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ។

✍ **ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ**

នៅត្រង់ផ្នែកទី៤នៃច្បាប់ស្តីពីសិទ្ធិនិងករណីកិច្ចរបស់សហព័ទ្ធ ត្រង់មាត្រា២៩៖ *ក្នុងគ្រួសារប្តីប្រពន្ធត្រូវមានភាពស្មើគ្នាលើគ្រប់ទស្សនៈ។* មាត្រា៣០ចែងថា៖ *ប្តីប្រពន្ធមានករណីកិច្ចស្រឡាញ់គ្នាទៅវិញទៅមក គោរពគ្នាទៅវិញទៅមក ថែរក្សាគ្នានិងជួយគ្នាទៅវិញទៅមក ដើម្បីឈានទៅកាន់វឌ្ឍនភាពព្រម ទាំងកសាងគ្រួសារមួយមានសាមគ្គីភាព និងប្រកបដោយសុភមង្គល។*

✍ **ច្បាប់ស្តីពីឯកពន្ធភាព (១២មាត្រា)**

*មាត្រា៤៖* ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្រ្តីមានប្តីពីរ។ ត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព បុរសឬស្រ្តីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត។

*អ្នកសមគំនិតត្រូវមានទោសដូចគ្នា។*

***មាត្រា៩៖*** ជនណាដែលប្រព្រឹត្តិល្មើសនឹងមាត្រា៤នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ដល់១(មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី២០០.០០០(ពីររយពាន់)រៀល ដល់១.០០០.០០០(មួយលាន)រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ។

*មាត្រា៣៥០ នៃក្រមព្រហ្មទណ្ឌ ៖* បទទ្វេពន្ធភាព។

ដូច្នេះតាមរយៈច្បាប់នេះយើងឃើញថា ទាំងបុរសទាំងស្រ្តីបើមានកការផិតក្បត់ដោយទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត តែមិនទាន់រលាយ

ចំណងអាពាហ៍ពិពាហ៍ចាស់នៅឡើយ ជននោះនឹងត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់ ដូចមានចែងក្នុងមាត្រាទី៩។

## ១៤.២- ច្បាប់អន្តរជាតិ

បើនិយាយពីច្បាប់អន្តរជាតិ អង្គការសហប្រជាជាតិបានគាំទ្រចំពោះសិទ្ធិទាំងឡាយរបស់ស្ត្រី ដែលមានចែងនៅក្នុង**ច្បាប់ធម្មនុញ្ញ**របស់ខ្លួន។ រាល់សេចក្តីសម្រេចទាំងឡាយនៃអង្គការសហប្រជាជាតិត្រូវបានប្រកាសនៅក្នុង**មាត្រា១**នៃធម្មនុញ្ញរបស់ខ្លួន គឺដើម្បីឱ្យសម្រេចនូវគោលបំណងនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្តីពីការបង្កើននិងការលើកទឹកចិត្តឱ្យមាននូវការគោរពសិទ្ធិមនុស្សដែលជាមូលដ្ឋានគ្រឹះនៃសេរីភាពសម្រាប់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងអំពីឋានៈ ពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ។

ក្នុងគ្រាដំបូង ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម បានបង្កើនបេសកម្មរបស់ខ្លួនលើមុខតំណែងរបស់ស្ត្រីដូចមានក្នុងគោលនយោបាយសំខាន់ៗរបស់សកលលោក ដែលបានបង្កើតរូបរាងឡើងឧទ្ទិសទាំងស្រុងទៅលើសមភាពភេទ និងការបោះជំហានទៅមុខរបស់ស្ត្រី។ ក្នុងចំណោមសមិទ្ធិដំបូងបំផុតនោះគឺការសម្រេចឱ្យបាននូវការធានាលើភេទ ដែលជាភាសាមួយគ្មានដែនកំណត់នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពី ***ការប្រកាសជាសកលនៃសិទ្ធិមនុស្ស***។ ដែនកំណត់នៃការប្រកាសបានអនុម័តដោយសភាប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដោយបានអះអាងថា *មនុស្សជាតិទាំងឡាយដែលកើតមកមានសេរីភាព សមភាពក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិដែលមនុស្សគ្រប់រូបត្រូវបានគេផ្តល់សិទ្ធិសេរីភាព ដែលត្រូវបានកំណត់ជាលើកទី៤នៅក្នុងការប្រកាសនេះ*

*ដោយគ្មានការបែងចែកប្រភេទដូចជា ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា កំណើត ឬឋានៈតួនាទីអ្វីឡើយ។*

នៅពេលដែលចលនាស្ត្រីនិយមអន្តរជាតិបានចាប់ផ្តើមកើននូវកម្លាំងជំរុញទឹកចិត្ត នាកំឡុងទសវត្សរ៍ឆ្នាំ១៩៧០ សភាប្រជាតិបានប្រកាសថា ឆ្នាំ១៩៧៥ ជាឆ្នាំនៃទិវានារីអន្តរជាតិ ហើយសន្និសិទពិភពលោកដំបូងស្តីពីស្ត្រីត្រូវបានរៀបចំឡើង នៅក្នុងទីក្រុងម៉ិចសិចកូ។ ការជំរុញលើសន្និសិទបានប្រកាសជាបន្តបន្ទាប់ពីឆ្នាំ១៩៧៦ដល់១៩៨៥ ដែលជាទសវត្សរ៍នៃ **អ.ស.ប** សម្រាប់ស្ត្រី និងបានបង្កើតឡើងមូលនិធិស្ម័គ្រចិត្តសម្រាប់ទសវត្សរ៍នេះដែរ។

នៅឆ្នាំ១៩៧៩ សភាជាតិបានអនុម័តពិធីសារចំពោះរាល់ទម្រង់រើសអើងស្ត្រី ដែលតែងតែបរិយាយជាសេចក្តីព្រាងច្បាប់អន្តរជាតិសម្រាប់ស្ត្រី។ នៅក្នុងមាត្រាចំនួន៣០របស់អង្គការនេះ សន្និបាទបានកំណត់យ៉ាងជាក់ច្បាស់នូវការរើសអើងប្រឆាំងនឹងស្ត្រី ហើយក៏បានកំណត់នូវរបៀបវារៈសម្រាប់សកម្មភាពថ្នាក់ជាតិដើម្បីបញ្ចប់នូវការរើសអើង។ សន្និបាទនេះបានកំណត់ថាវប្បធម៌ប្រពៃណីជាកម្លាំងដ៏មានឥទ្ធិពលលើតួនាទីភេទ និងទំនាក់ទំនងគ្រួសារ ហើយវាក៏ជាសន្ធិសញ្ញាដំបូងនៃសិទ្ធិមនុស្សដែលបញ្ជាក់បន្ថែមពីការបង្កើតឡើងវិញនូវសិទ្ធិស្ត្រី។

រយៈពេលប្រាំឆ្នាំក្រោយពីសន្និសិទទីក្រុងម៉ិចសិក មានសន្និសីទពិភពលោកមួយស្តីពីស្ត្រីត្រូវបានប្រារព្ធឡើងជាលើកទី២ នៅទីក្រុង **កូផេនហាជេន** (**Copenhagen**) ក្នុងឆ្នាំ១៩៨០។ លទ្ធផលដែលបានពីកម្មវិធីនេះ ត្រូវបានអំពាវនាវឱ្យរដ្ឋប្រជាជាតិចាត់វិធានការខ្លាំងជាងមុន ដើម្បីធានាបាននូវភាពជា

ម្ចាស់កម្មសិទ្ធិនិងការគ្រប់គ្រងទ្រព្យសម្បត្តិ ព្រមទាំងការធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិស្រ្តីចំពោះមរតក ការឃុំគ្រងកូនចៅ និងការបោះបង់សញ្ជាតិ។

### ១៤.៣- ស្រ្តី និងកុមារទាំងឡាយ

កិច្ចប្រជុំមួយដែលប្រព្រឹត្តទៅនៅក្នុងខែកញ្ញាឆ្នាំ២០១០ ដែលមានគោលដៅឆ្ពោះទៅរកការអភិវឌ្ឍ សហសវត្សដែលមានលោកអគ្គលេខាធិការបានផ្តើមនូវកិច្ចខិតខំជាលក្ខណៈសកលក្នុងការប្រមូលផ្តុំទៅដោយមេដឹកនាំសំខាន់ៗចំនួន៤០នាក់ ដើម្បីធ្វើឱ្យមានភាពជាក់លាក់នូវសំណុំយុទ្ធសាស្រ្តមួយ និងពន្លឿនដំណើរការសុខភាពស្រ្តី និងកុមារ។

នៅឆ្នាំ១៩៨៥ សន្និសីទបានពិនិត្យ និងវាយតម្លៃឡើងវិញនូវការសម្រេចបាននៃទសវត្សរ៍ អង្គការសហប្រជាជាតិចំពោះស្រ្តី សិទ្ធិស្មើគ្នា ការអភិវឌ្ឍ និងសន្តិភាពដែលបានធ្វើការប្រជុំ នៅឯទីក្រុងណៃរ៉ូប៊ី។ វាត្រូវបានគេធ្វើការប្រជុំនៅពេលមួយដែលចលនាសមភាពភេទបានធ្វើចប់សព្វគ្រប់ដោយទទួលស្គាល់ជាទូទៅថា ត្រឹមត្រូវនិងមានអ្នកតំណាងមួយម៉ឺនប្រាំពាន់នាក់នៃអង្គការមិនមែនរដ្ឋាភិបាល(NGOs) បានចូលរួមវេទិកា NGO រួមគ្នាមួយ ដែលមានមនុស្សជាច្រើនបានរៀបរាប់ថា***ជាកំណើតនៃស្រ្តីនិយមសកល*** ដែលប្រព្រឹត្តទៅនៅទីក្រុង ***ម៉ិចសិកកូ*** មិនត្រូវបានគេពិភាក្សាឱ្យបានពេញលេញ ហើយរដ្ឋាភិបាលចំនួន១៥៧ចូលរួមអនុម័តលើយុទ្ធសាស្រ្តនេះ នាទីក្រុង **ណៃរ៉ូប៊ី** ដែលសម្លឹងឆ្ពោះទៅកាន់យុត្តិសាស្រ្តឆ្នាំ២០០០។ វាបានធ្វើឱ្យខូចមូលដ្ឋានមួយ នៅក្នុងការប្រកាសរាល់បញ្ហាទាំងឡាយដែលជាបញ្ហារបស់ស្រ្តី។

លទ្ធផលជាដំបូងនៃសន្និសីទ**ណៃរ៉ូប៊ី**(Nairobi) ត្រូវបានគេដោះដូរទៅនឹងមូលនិធិស្ម័គ្រចិត្តសម្រាប់ទសវត្សរ៍របស់អង្គការសហប្រជាជាតិ ដើម្បីឱ្យ

ស្ត្រីចូលក្នុងមូលនិធិអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(បច្ចុប្បន្នជាផ្នែកមួយនៃ(UN Woman)។

សន្និសីទពិភពលោកលើកទី៤ ផ្តោតលើស្ត្រីបានបោះជំហានឆ្ងាយជាងសន្និសីទក្រុង**ណៃរ៉ូប៊ី** ដែលបានប្រព្រឹត្តទៅនៅក្នុងទីក្រុងប៉េកាំង ក្នុងឆ្នាំ១៩៩៥។ គោលនយោបាយទីក្រុងប៉េកាំងបានអះអាងថា សិទ្ធិស្ត្រី ជាសិទ្ធិមនុស្ស ហើយបានប្តេជ្ញាចិត្តលើសកម្មភាពជាក់លាក់ ដើម្បីធានាការគោរពចំពោះសិទ្ធិទាំងនោះ។ នេះបើយោងទៅតាមការបែងចែកនៃUN ដើម្បីស្ត្រីនៅក្នុងការត្រួតពិនិត្យទៅលើសន្និសីទលើកទី៤របស់ខ្លួនៈ *"ការដោះដូរជាមូលដ្ឋានដែលបានប្រព្រឹត្តទៅក្នុងទីក្រុង**ប៉េកាំង** គឺជាការទទួលស្គាល់ទៅលើភាពចាំបាច់ដើម្បីប្តូរពីការផ្តោតលើស្ត្រី ទៅលើទស្សនៈភេទ ការទទួលស្គាល់រចនាសម្ពន្ធសង្គមទាំងមូលនោះ និងគ្រប់ទំនាក់ទំនងទាំងឡាយរវាងបុរសនិងស្ត្រី ដែលត្រូវបានគេវាយតម្លៃឡើងវិញផងដែរ។ ប៉ុន្តែដោយមានការសើរើរចនាសម្ពន្ធមូលដ្ឋានសង្គមឡើងវិញ និងរដ្ឋធម្មនុញ្ញរបស់វាអាចផ្តល់ឱ្យស្ត្រីទទួលបាននូវអំណាចពេញលេញ ដើម្បីនាំយកនូវតួនាទីដ៏ត្រឹមត្រូវរបស់ពួកគេ ជាដៃគូស្មើភាពជាមួយនឹងបុរសរាល់ទម្រង់នៃជីវិត។ នៅក្នុងការផ្លាស់ប្តូរនេះដែរ តំណាងឱ្យការអះអាងយ៉ាងរឹងមាំដែលសិទ្ធិរបស់ស្ត្រី គឺជាសិទ្ធិរបស់មនុស្សជាតិ ហើយដែលសមភាពភេទគឺជាបញ្ហានៃការព្រួយបារម្ភសកល និងជាផលប្រយោជន៍ទាំអស់គ្នា"*។

ជាលទ្ធផលនៃការប្រកាសនៃកិច្ចប្រជុំសហស្សវត្សរ៍ ដែលប្រព្រឹត្តទៅនាខែកញ្ញា ឆ្នាំ២០០០ ហើយដែលបញ្ហាតួនាទីភេទ ត្រូវបានគេប្រចាប់បញ្ចូលជាគោលបំណងអភិវឌ្ឍសហស្សវត្សរ៍ ជាបន្តបន្ទាប់ហើយដែលមានចែងយ៉ាង

ច្បាស់នៅក្នុងគោលបំណងលេខ៣(បង្កើននូវសមភាពភេទ និងការផ្ដល់អំណាចដល់ស្ត្រី)និងលេខ៥(កាត់បន្ថយ៣ភាគ៤នៃមរណភាពរបស់មាតា)។ បណ្ដាញនៃអង្គការសហប្រជាជាតិនេះ ត្រូវបានគេយកមកធ្វើជាកិច្ចប្រជុំដោយលើកឡើងពីគោលបំណងទាំងនោះ។

## ១៤.៤- ការពង្រីកបណ្ដាញសហប្រជាជាតិ និងការលុបបំបាត់អំពើហិង្សា

នៅខែកក្កដា ឆ្នាំ២០១០ មហាសន្និបាតអង្គការសហប្រជាជាតិបានបោះឆ្នោតជាឯកច្ឆ័ន ដើម្បីបង្កើតនូវស្ថាប័នដាច់ដោយឡែកមួយ ដោយបានសាកល្បងជាមួយនឹងការពន្លឿនដំណើរការឱ្យសម្រេចបាននូវសមភាពភេទ និងការផ្ដល់អំណាចដល់ស្ត្រី។

អង្គភាពថ្មីមួយរបស់អង្គការសហប្រជាជាតិសម្រាប់សមភាពភេទនិងការផ្ដល់នូវអំណាចស្ត្រី ឬស្ត្រីក្នុងអង្គការសហប្រជាជាតិ ដែលបានរួមបញ្ចូលទីភ្នាក់ងារនៃស្ថាប័នពិភពលោកចំនួនពីរ ហើយការិយាល័យមានមូលនិធិអភិវឌ្ឍអង្គការសហប្រជាជាតិ ដើម្បីស្ត្រី(UNIFFM) ជាផ្នែកមួយនៃការអភិវឌ្ឍស្ត្រី ការិយាល័យប្រឹក្សាពិសេសចំពោះបញ្ហាយេនឌ័រ និងវិទ្យាស្ថានស្រាវជ្រាវហ្វឹកហ្វឺនអន្តរជាតិនៃអង្គការសហប្រជាជាតិ ដើម្បីអភិវឌ្ឍស្ត្រី(UN-INSTRAW)។ អង្គការសហប្រជាជាតិទទួលបន្ទុកខាងស្ត្រីបានចាប់ប្រតិបត្តិការនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១១។

ទិដ្ឋភាពដ៏សំខាន់មួយនៃនីតិកាលស្ត្រីក្នុងអង្គការសហប្រជាជាតិ គឺដើម្បីចង្អុលបង្ហាញប្រព័ន្ធដែលបានសម្របសម្រួលចំពោះភេទ(Gender)។ នៅខែមេសាឆ្នាំ២០១២ ផែនការសកម្មភាពពង្រីកប្រព័ន្ធ (UNSWAP) ចំពោះ

សមភាពភេទនិងការផ្តល់អំណាចឱ្យស្ត្រី គឺត្រូវបានគេអនុម័តនៅក្នុងកិច្ចប្រជុំមួយនៃក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិអង្គការសហប្រជាជាតិ សម្រាប់ការសម្របសម្រួល ត្រូវបានគេអនុវត្តដោយឆ្លងកាត់បណ្តាញនៃអង្គការសហប្រជាជាតិទាំងមូល។ សហប្រជាជាតិបានច្របាច់បញ្ចូលទីភ្នាក់ងារនិងការិយាល័យចំនួន៤ នៃអង្គការសហប្រជាជាតិឱ្យទៅជាការិយាល័យតែមួយវិញ។

ចំពោះអំពើហិង្សាលើស្ត្រី ប្រព័ន្ធអង្គការសហប្រជាជាតិ បានបន្តក្នុងការផ្តល់នូវវត្តមានដ៏ពិសេសចំពោះបញ្ហាហិង្សាលើស្ត្រី។ នៅឆ្នាំ១៩៩៣ ដែលក្រុមប្រឹក្សានេះ *ធ្វើការប្រកាសលើការលុបបំបាត់អំពើហិង្សាលើស្ត្រី* បានកំណត់នូវនិយមន័យដ៏ទូលំទូលាយនិងដាក់លាក់មួយនៃអំពើហិង្សាប្រឆាំងស្ត្រីនូវរាល់ទម្រង់របស់វាទាំងអស់។ វាបានតំណាងឱ្យការប្តេជ្ញាចិត្ត ដោយរដ្ឋភាគីក្នុងការគោរពដល់ទំនួលខុសត្រូវ និងការប្តេជ្ញាចិត្តដោយសហគមន៍អន្តរជាតិដ៏ខ្លាំងក្លាដើម្បីលុបបំបាត់នូវអំពើហិង្សាប្រឆាំងស្ត្រី។

នៅឆ្នាំ២០០៧ ប្រធានបទនៃទិវាស្ត្រីអន្តរជាតិគឺ *បានកំពុងបញ្ចប់និទន្ឋណ្ឋភាពចំពោះអំពើហិង្សាប្រឆាំងស្ត្រី។* ហើយនៅថ្ងៃ២៥កុម្ភៈ២០០៨ លោក **បាន គីមូន** បានចាប់ផ្តើមធ្វើ *យុទ្ធនាការរួមជាសកលមួយនៃក្រុមព្រឹក្សាជាន់ខ្ពស់នៃអង្គការសហប្រជាជាតិ ដើម្បីបញ្ចប់អំពើហិង្សាប្រឆាំងនឹងស្ត្រី។* ក្នុងការបើកយុទ្ធនាការសកលជាច្រើនឆ្នាំ គាត់ក៏បានហៅអំពើហិង្សាប្រឆាំងស្ត្រីថាជាបញ្ហាដែលមិនអាចរង់ចាំបាន។ ចំណែកប្រធានបទដែលប្រារព្ធឆ្នាំ២០០៩នេះគឺ *ស្ត្រីនិងបុរសរួមគ្នាដើម្បីបញ្ចប់អំពើហិង្សាប្រឆាំងស្ត្រី និងកុមារី។* ទិវានារីអន្តរជាតិស្តីពីការលុបបំបាត់រាល់អំពើហិង្សាប្រឆាំងស្ត្រី ត្រូវបានប្រារព្ធនៅថ្ងៃ ២៥ វិច្ឆិកា។

## ១៤.៥- ច្បាប់ស្ដីពីសិទ្ធិមនុស្សអន្តរជាតិ

សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ១៩៤៨។ សេចក្តីថ្លែងការណ៍នេះជាអត្ថបទអន្តរជាតិទីមួយដែលប្រើពាក្យ ***សិទ្ធិមនុស្ស*** ហើយវាត្រូវបានអនុម័តដោយចលនាសិទ្ធិមនុស្សអន្តរជាតិ ដោយឱ្យតម្លៃវាជាធម្មនុញ្ញមាន៣០មាត្រា ដែលមានខ្លឹមសារសង្ខេបដូចតទៅ៖

- មាត្រា១ : មនុស្សរាល់រូបមានតម្លៃស្មើគ្នា
- មាត្រា២ : ត្រូវចាត់ទុកមនុស្សគ្រប់រូបឱ្យបានស្មើៗគ្នា
- មាត្រា៣ : សិទ្ធិមានជីវិតរស់នៅ
- មាត្រា៤ : សិទ្ធិការពារមិនឱ្យគេយកទៅធ្វើជាខ្ញុំកញ្ជះ
- មាត្រា៥ : សិទ្ធិមិនឱ្យមានទារុណកម្មមកលើខ្លួន
- មាត្រា៦ : សិទ្ធិឱ្យគេទទួលស្គាល់ខ្លួនជាមនុស្ស
- មាត្រា៧ : សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់
- មាត្រា៨ : សិទ្ធិសុំឱ្យច្បាប់ការពារខ្លួន
- មាត្រា៩ : សិទ្ធិមានសេរីភាព
- មាត្រា១០ : សិទ្ធិឱ្យមានការកាត់ក្តីត្រឹមត្រូវ
- មាត្រា១១ : សិទ្ធិទទួលការកាត់ទោសសមស្របតាមច្បាប់
- មាត្រា១២ : សិទ្ធិការពារជីវភាពឯកជនរបស់ខ្លួន
- មាត្រា១៣ : សិទ្ធិធ្វើដំណើរទៅមកដោយសេរី
- មាត្រា១៤ : សិទ្ធិទៅសុំការជ្រកកោននៅប្រទេសក្រៅ
- មាត្រា១៥ : សិទ្ធិមានសញ្ជាតិមួយ

- មាត្រា១៦ : សិទ្ធិរៀបចំគូស្រករ និងមានគ្រួសារ
- មាត្រា១៧ : សិទ្ធិមានសម្បត្តិកម្មសិទ្ធិ
- មាត្រា១៨ : សិទ្ធិមានជំនឿដោយសេរី
- មាត្រា១៩ : សិទ្ធិនិយាយស្តី និងសម្តែងមតិដោយសេរី
- មាត្រា២០ : សិទ្ធិរួមប្រជុំដោយសេរី
- មាត្រា២១ : សិទ្ធិរួមចំណែកក្នុងសកម្មភាពនយោបាយ
- មាត្រា២២ : សិទ្ធិមាននិរភ័យសង្គម
- មាត្រា២៣ : សិទ្ធិមានការងារធ្វើ
- មាត្រា២៤ : សិទ្ធិមានការសម្រាក និងកម្សាន្តកាយ
- មាត្រា២៥ : សិទ្ធិមានជីវភាពរស់នៅសមរម្យ
- មាត្រា២៦ : សិទ្ធិមានការអប់រំ
- មាត្រា២៧ : សិទ្ធិទទួលផលក្នុងជីវភាពវប្បធម៌ និងរក្សាសិទ្ធិ
- មាត្រា២៨ : សិទ្ធិមានច្បាប់ការពារសិទ្ធិរបស់ខ្លួន
- មាត្រា២៩ : កាតព្វកិច្ចចំពោះសង្គម និងគោរពសិទ្ធិអ្នកដទៃ
- មាត្រា៣០ : កាតព្វកិច្ចការពារខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ។

ធម្មនុញ្ញសហប្រជាជាតិក៏មានចែងផងដែរថា ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងការទទួលស្គាល់សិទ្ធិស្មើគ្នា និងមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ សន្តិភាពក្នុងពិភពលោក។ ធម្មនុញ្ញនេះតម្រូវឱ្យរដ្ឋនានាមាននូវកាតព្វកិច្ចលើកស្ទួយការគោរពជាសកល និងការប្រតិបត្តិនូវសិទ្ធិ និងសេរីភាពរបស់មនុស្ស។

## ១៥- ការអប់រំឥរិយាបថ

ការអប់រំឥរិយាបថ គឺជាការឱ្យដឹង ឱ្យស្គាល់ និងឱ្យយល់ច្បាស់ពីខ្លួនឯង ថាខ្លួនកំពុងធ្វើអ្វី និងបាននឹងកំពុងត្រៀមធ្វើអ្វីខ្លះចំពោះខ្លួននាពេលអនាគត? ការអប់រំឥរិយាបថនឹងធ្វើឱ្យមនុស្សស្គាល់ពីអតីតកាល និងអាចដោះស្រាយរឿងរ៉ាវពីអតីតកាលឱ្យជ្រះស្រឡះពីក្នុងចិត្ត ដើម្បីកសាងខ្លួនឱ្យបានល្អនាពេលបច្ចុប្បន្ន។ **ហេតុអ្វីបានជាត្រូវការអប់រំកែប្រែឥរិយាបថ?** ការអប់រំឥរិយាបថជាកត្តាជួយធ្វើឱ្យយើងបានទទួលនូវការអប់រំកាន់តែច្រើននិងទទួលបាននូវអត្ថប្រយោជន៍ពីការអប់រំឥរិយាបថ។ ជាចាំបាច់សម្រាប់មនុស្សគួរតែមានការអប់រំឥរិយាបថ ដើម្បីឱ្យខ្លួនឯងស្គាល់ខ្លួនឯងកាន់តែច្បាស់ថែមទៀត។ នៅពេលដែលមនុស្សម្នាក់មិនទាន់យល់ច្បាស់ពីអ្វីដែលខ្លួនឯងត្រូវការ ថាខ្លួនឯងកំពុងធ្វើអ្វី បុគ្គលម្នាក់នោះមានបញ្ហាដ៏ស្មុគស្មាញដែលមិនអាចដោះស្រាយបាន ដោយសារតែមិនទាន់ស្គាល់ច្បាស់ពីខ្លួនឯង និងមិនដឹងពីដំណោះស្រាយដ៏ល្អ។ ការអប់រំឥរិយាបថនឹងធ្វើឱ្យបុគ្គលនោះបានដឹងពីអ្វីសំខាន់ដែលខ្លួនមាន ហើយដឹងពីអ្វីដែលខ្លួនមិនដឹង ដើម្បីឱ្យបុរស-ស្ត្រីបានចេះ ហើយអាចទៅធ្វើការទំនាក់ទំនងជាមួយអ្នកដទៃបាន។

ការដែលមនុស្សបានទទួលនូវការអប់រំសីលឥរិយាបថដ៏ល្អហើយ ពួកគេនឹងក្លាយជាមនុស្សដែលចេះប្រើប្រាស់សមត្ថភាពដែលខ្លួនមាន យល់ច្បាស់ពីតម្លៃនៃជីវិត អាចដោះស្រាយនូវរាល់បញ្ហាទាំងឡាយដែលអាចឱ្យខ្លួនទទួលបាននូវសុភមង្គល និងចេះរៀបចំដំណើរជីវិតខ្លួនឯង។ រាល់ទង្វើដែលបានប្រព្រឹត្តសុទ្ធតែជាអំពើគប្បី និងចេះបែងចែកអ្វីដែលល្អនិងអាក្រក់ ហើយអ្វីដែលសំខាន់បំផុតនោះ គឺនឹងអាចទទួលបានភាពជោគជ័យក្នុងឆាកជីវិត។

ដើម្បីទទួលបានការអប់រំឥរិយាបថមួយដ៏ល្អ គឺអាចធ្វើឡើងដោយចាប់ផ្ដើមពីចំណេះដឹង ឬសតិបញ្ញាដែលខ្លួនមានដោយបង្រៀនខ្លួនឯងឱ្យចេះសង្កេតមើលពីអ្វីៗដែលជាអំពើល្អនៅជុំវិញខ្លួន និងបានមកពីការបង្ហាត់បន្ថែមពីអ្នកដទៃសម្រាប់ខ្លួន។ មួយវិញទៀតការអប់រំឥរិយាបថ ក៏ជាប្រយោជន៍មួយសម្រាប់សុខភាពផ្លូវចិត្តផងដែរ ព្រោះវានឹងធ្វើឱ្យគេមានអារម្មណ៍ស្ងប់ ឬចេះសង្រួមចិត្តឱ្យនឹងន ស្គាល់ពីខ្លួនឯង តស៊ូលំបាកជាមួយបញ្ហាដែលកំពុងប្រឈមមុខ និងឱ្យតម្លៃជីវិតមិនគិតពីអ្វីដែលជាអំពើអគតិដូចជាការធ្វើអត្តឃាតជាដើម។

ឥរិយាបថទាំងបួនដែលមនុស្សតែងតែប្រព្រឹត្តិប្រចាំថ្ងៃមាន ដេក ដើរ ឈរ អង្គុយ។ បើទោះបីជាត្រង់ចំណុចខ្លះកវីបានលើកឡើងលម្អិត ហើយចំណុចខ្លះមិនបានលំអិតច្បាស់ក៏ដោយ ក៏វាមានទំនាក់ទំនងរួចជាស្រេចទៅហើយក្នុងឥរិយាបថទាំងនេះ។

## ១៥.១- ឥរិយាបថក្នុងការដេក

នៅក្នុងចំណុចនេះកវី **ម៉ឺន ម៉ៃ** ក៏បានបង្ហាញនូវឥរិយាបថក្នុងការដេកដែលស្ត្រីគ្រប់រូបគួរតែប្រណិប័តន៍ ពីព្រោះវាជាឥរិយាបថមួយដែលជួយឱ្យស្ត្រីបានប្រកបទៅដោយឥរិយាដ៏ប្រពៃនៅក្នុងគ្រួសារ ក្នុងសង្គម និងក៏បានបង្ហាញពីប្រពៃណីរបស់ជាតិខ្លួនផងដែរ។ ឥរិយាបថក្នុងការដេកជាគំរូដ៏ល្អមួយសម្រាប់ស្ត្រីទូទៅទាំងស្ត្រីមានស្វាមី និងមិនមានស្វាមី ពីព្រោះថា ស្ត្រីបើកាលណាដេកផ្តេសផ្តាសវានឹងធ្វើឱ្យស្ត្រីនោះបាត់តម្លៃ ដែលនាំទៅរកការរិះគន់មិនតិចពីញាតិមិត្ត និងសង្គម។ ខាងក្រោមនេះជាខ្លឹមសារដែលចែងជាកំណាព្យបកស្រាយពីការដេក៖

*ស្រីមួយដេកដាក់កាយា ប្រះប្រែអាត្មា ឱ្យខ្នងទៅប្តី។*
*ទុកស្មើពស់ក្រោយអប្រិយ ឡើងផ្ទះឥតបី ឥតបើគណនា។*
*ចង្រៃកាចក្រៃពុំជា នឹងព្រាត់ប្រាស់គ្នា ពុំបានវែងឆ្ងាយ។*

## ១៥.២- ឥរិយាបថក្នុងការដើរ

ការដើរ គឺជាចំណុចមួយដែលមនុស្សគ្រប់រូបគួរតែប្រកាន់ខ្ជាប់មិនថាតែមនុស្សស្រី ឬប្រុសទេ ព្រោះថាវាជាឥរិយាបថល្អមួយក្នុងសង្គម ដែលអាចជួយបុគ្គលនោះឱ្យមានគេស្រឡាញ់រាប់អានចូលចិត្ត ដោយសារតែការចេះដឹងពីការទាបខ្ពស់ សុជីវធម៌ក្នុងទីសាធារណៈ(មិនសំដៅលើការកោតខ្លាចបុគ្គលណាម្នាក់ទេ តែវាជាការគោរពគ្នា)។

វាជាសីលធម៌មួយជួយបង្ហាញផ្លូវដល់ស្ត្រី ក្នុងការប្រើប្រាស់ឥរិយាឱ្យបានល្អសមតាមប្រពៃណីជាតិ និងសមជាស្ត្រីមានលក្ខិណា ព្រមទាំងជួយលើកមុខមាត់ដល់គ្រួសារ និងសង្គមផង។ ថ្វីត្បិតតែឥឡូវសីលធម៌ ទាំងអស់នេះស្ទើរតែបាត់បង់ទៅហើយក្តី តែក៏មានមនុស្សមួយចំនួននៅរក្សាឥរិយាបថដែលជាប្រពៃណីមួយនេះដែរ ជាពិសេសអ្នកដែលមានឪពុកម្តាយយាយតា ដែលមានការចេះដឹងច្រើនចំពោះរឿងនេះ និងអ្នកដែលបានសិក្សាចេះដឹងជ្រៅជ្រះ។ ដូចមានជាឧទាហរណ៍ក្នុងច្បាប់ស្រីនេះលើកឡើងថា៖

*ស្រីមួយដើរទៅផាត់ដាយ ឮលាន់ស្ទើរឆ្ងាយ ប្រថពីសន្ធឹក។*
*សំពត់ដាច់ដាចមិននឹក ដើរឮគគឹក ស្មើសូរន្ទះ។*
*ញុំញ៉ើដំណើររះ ដាក់ជើងឡើងផ្ទះ គគ្រាំគគ្រេង។*
*កក្រើកផ្ទះទាំងបីល្វែង ដូចកល់គេសែង របស់ចេញទៅ។*

នេះបញ្ជាក់ឱ្យឃើញថា ស្ត្រីគួរតែមានសីលធម៌ល្អក្នុងការរស់នៅ របៀបរបបច្បាប់ទម្លាប់នៅក្នុងគ្រួសារ មិនត្រូវដើរដូចគេទន្ទ្រាំ ដែលខុសនឹងសីលធម៌ក្នុងការរស់នៅ មុននឹងឈានជំហានត្រូវចេះថ្នមជើង ពោលគឺធ្វើយ៉ាងណាមិនឱ្យរំខានគេ។

## ១៥.៣- ឥរិយាបថក្នុងការនិយាយស្តី

ជាការពិតណាស់ឥរិយាបថមួយនេះ ក៏ជាចំណុចមួយដ៏ល្អដែរ ដែលស្ត្រីមិនគួរមើលរំលង ព្រោះថាវាជាក្បួនមួយជួយលើកតម្លៃដល់ស្ត្រីក្នុងគ្រួសារ សង្គម និងកេរ្តិ៍ឈ្មោះរបស់ស្ត្រីផង។ ការនិយាយជាទម្លាប់ដ៏ល្អមួយសម្រាប់ស្ត្រី ប្រសិនបើស្ត្រីចេះរៀបចំពាក្យសម្តីឱ្យបានល្អ មានសុជីវធម៌ក្នុងការនិយាយស្តីនោះ ទោះបីជាស្ត្រីនោះមានរូបសម្បត្តិមិនសូវជាល្អដូចស្រីដទៃក៏ដោយ ក៏វាអាចជួយលើកតម្លៃដល់ស្ត្រីនោះៗបានមួយកម្រិតដែរ តែប្រសិនបើស្ត្រីនោះសោតជាអ្នកមានរូបសម្រស់ស្អាតផូរផង់ផងនោះ វាក៏នឹងរឹតតែធ្វើឱ្យស្ត្រីនោះមានភាពវិសេសវិសាលថែមទៀត។ ដូចមានឃ្លាបញ្ជាក់ថា៖

*ទោះនឹងនិយាយស្រដី ការកេរ្តិ៍ជាស្រី កុំស្តីឡេះឡោះ។*
*ថាលេងដូចក្មេងព្រ៉េះព្រោះ ឃើញប្រុសកម្លោះ សសៀរចូលជិត។*
*សើចច្រៀងបញ្ឆៀងមិនគិត ប្រុសព្រើលបានចិត្ត ទាហានដោយសារ។*
*ហៅស្រីអប្រិយឥតការ ឥតមានឥរិយា មារយាទក្នុងខ្លួន។*
*សើរ៉ើពុំធ្វើនឹងនួន ស្រដីមិនមូន មិនមានអៀនអន់។*
*ឃើញគេបៀតបែរគេយគន់ សើចសួរចំអន់ ចំអកឱ្យប្រុស។*

ត្រង់នេះស្ត្រីគួរតែប្រុងប្រយ័ត្នខ្លួន និងត្រូវចេះគិតពិចារណាឱ្យបានវែងឆ្ងាយ មិនត្រូវចិត្តងាយ អាចឆាប់ចាញ់បោកមនុស្សប្រុសដោយសារតែអំពើ

របស់ខ្លួន។ មុននឹងជឿលើអ្នកណាម្នាក់ ត្រូវចេះសាកសួរប្រឹក្សាពីមនុស្សដែលមានចំណេះដឹងជ្រៅជ្រះឬអ្នកណាម្នាក់ ដែលដឹងពីស្ថានភាពបានច្បាស់លាស់ និងត្រូវចេះ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ជាស្ត្រីភេទ សក្តិសមជានារីភេទ។

ចំណុចមួយទៀតក៏បានហាមប្រាមដល់ស្ត្រីផងដែរ មិនឱ្យសើចឮពេក នាំឱ្យផ្អើលគេផ្អើលឯងដែលលោកចាត់ទុកថាជាចង្រៃ។

ស្រីមួយសើចលេងកក្អាកក្អាយ ឮលេចចម្ងាយ រំលងផ្ទះបី។
ស្មើសត្វចចាតបក្សី ចូលភូមិផងក្តី ចង្រៃក្តាត់ណា។

### ១៥.៤- ឥរិយាបថក្នុងការហូបចុក

កវីក៏បានបង្ហាញពីឥរិយាបថ ក្នុងការហូបចុកឱ្យបានត្រឹមត្រូវផងដែរ ត្បិតអីក្នុងការហូបចុកខ្មែរ យើងមានការប្រកាន់ណាស់ ជាពិសេសនារីត្រូវមានទម្លាប់ល្អក្នុងការហូបចុកនេះតែម្តង។ ឥរិយាបថក្នុងការហូបចុក គឺជាការគោរពដឹងគុណទៅដល់ព្រះមេរុដែលបានផ្តល់ជាផ្លែផ្កា ស្រូវអង្ករដល់មនុស្សលោក។ ដូច្នេះហើយបានជាខ្មែរយើង ពេលបរិភោគបាយម្តងៗគេតែងតែក្រាលកន្ទេលបត់ជើង(បច្ចុប្បន្ននៅសល់តិចតួចណាស់) តែបើព្រះសង្ឃអាចបត់ភ្នែនបាន ព្រោះគេយល់ថា ព្រះសង្ឃជាអ្នកមានសីល។

សរុបមកអំពីជាតិសព្ទនៃពាក្យស្ត្រី ប្រវត្តិនៃស្ត្រីនៅក្នុងពិភពលោក ការអប់រំដើម្បីទាមទារនូវសិទ្ធិសេរីភាព ការបណ្តុះបណ្តាលអំពីជំនាញវិជ្ជាជីវៈ ការសិក្សាអប់រំដើម្បីឱ្យស្ត្រីក្លាយជាចលករនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ និងជាអ្នកផ្តល់កំណើតដល់មនុស្សជំនាន់ក្រោយដ៏សំខាន់ក្នុងចូលរួមអភិវឌ្ឍមនុស្ស និងសង្គមនាពេលអនាគត។ ឆ្លងតាមប្រវត្តិសាស្ត្រខ្មែរ(សង្គម វប្បធម៌

នយោបាយ ប្រពៃណី ទំនៀម) បានបញ្ជាក់ថា ស្ត្រីខ្មែរមានគុណសម្បត្តិធំធេង ដែលគួរឱ្យស្ងប់ស្ងែងជាច្រើនដូចជា៖

. **ស្ត្រីខ្មែរជាអ្នកជំនួញដ៏ឆ្លាតវៃ** ស្ត្រីខ្មែរភាគមិនថា ចាស់ក្មេងនោះទេ មិនសូវទុកពេលទំនេរ ឥតប្រយោជន៍ឡើយ។ ក្រៅពីភារៈថែរក្សាទ្រព្យសម្បត្តិ និងអប់រំកូនចៅ បើទោះណាជាមានការមមាញឹកយ៉ាងណាក៏ដោយ ក៏ស្ត្រីនៅឆ្លៀតពេលរកស៊ីលក់ដូរ នៅផ្ទះជួយបន្ថែម ប្រាក់ចំណូលស្វាមីផងដែរ។ ស្ត្រីខ្លះលក់គ្រឿងទេស ខ្លះលក់នំចំណី ខ្លះធ្វើការងារសិប្បកម្ម។ល។

. **ស្ត្រីខ្មែរជាភរិយាដ៏ល្អរបស់ស្វាមី** ក្រៅពីការថែទាំទ្រព្យសម្បត្តិនិងកូនចៅ ស្ត្រីខ្មែរនៅមានភារៈយកចិត្តទុកដាក់ចំពោះប្តីថែមទៀតផង។ ស្ត្រីខ្មែរតែងតែដើរតួនាទីជាអ្នកប្រឹក្សាយោបល់របស់ប្តី ជាអ្នកលើកទឹកចិត្តប្តីនៅគ្រប់កាលៈទេសៈទាំងអស់ ជាពិសេសពេលដែលប្តី មានជួបឧបសគ្គក្នុងមុខរបរ។ ពេលខ្លះស្ត្រីហ៊ានទាំងចូលរួមអារកាត់ ក្នុងមុខរបរប្តីថែមទៀតផង។

. **ស្ត្រីខ្មែរជាមាតាដ៏ល្អរបស់កូន៖** ពេលឪពុកទៅធ្វើការ នៅឯក្រៅបាត់មានតែម្តាយទេដែលនៅជិតកូន ដឹងចិត្តកូន និងចេះជួយអប់រំ ឧបត្ថម្ភ និងលើកទឹកចិត្តកូនគ្រប់បែបយ៉ាង ដើម្បីឱ្យកូនបានក្លាយជាមនុស្សល្អ និងទទួលបានជោគជ័យនៅក្នុងសង្គម។

. **ស្ត្រីខ្មែរជាអ្នកប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌របស់ព្រះពុទ្ធសាសនា** ស្ត្រីខ្មែរភាគច្រើនតែមានចិត្តជ្រះថ្លានៅក្នុងការដាក់ទាន ការជួយសង្គ្រោះអ្នកដទៃឱ្យបានសុខ។ ស្ត្រីខ្មែរច្រើនតែមានព្រហ្មវិហារធម៌ចំពោះកូនស្វាមី ក៏ដូចជាអ្នកដទៃ។ ស្ត្រីខ្មែរជាទូទៅតែងគោរពបូជាព្រះពុទ្ធសាសនា ធ្វើ

បុណ្យរាប់បាត រក្សាសីល ធ្វើល្អ ចេះជួយគ្នាតាមរយៈការផ្តល់ក្តីស្រឡាញ់ ក្តីមេត្តាបានយ៉ាងខ្ជាប់ខ្ជួន។

. **ស្ត្រីខ្មែរជាកងជីវពលដ៏ក្លាហានរបស់ជាតិ** ស្ថិតក្នុងស្ថានភាពប្រទេសកើតសង្គ្រាម ស្ត្រីខ្មែរតែងស្ម័គ្រចិត្តជួយរ៉ាប់រងឧបត្ថម្ភស្បៀងអាហារ នានាជូនដល់សមរភូមិមុខ ស្ត្រីខ្លះចូលខ្លួនក្នុងការធ្វើជាទាហាន ដើម្បីវាយខ្មាំងសត្រូវឈ្លានពានឱ្យខ្ចាត់ខ្ចាយ។ ដូចជាសម័យលង្វែកនិងឧដុង្គជាដើម ស្ត្រីខ្មែរនាសម័យនោះ សុខចិត្តកាត់សក់ខ្លីធ្វើជាបុរសបន្លំភ្នែកសត្រូវ វាយទ័ពសៀមឱ្យខ្ចាត់ខ្ចាយ។ បើទោះបីជាបុរសត្រូវបានពួកសត្រូវសម្លាប់ចោលច្រើនយ៉ាងណាក៏ដោយ ក៏ស្ត្រីខ្មែរមិនមានការរួញរាក្នុងការការពារជាតិឡើយ។

. **ស្ត្រីខ្មែរជាអ្នកទាមទារសេរីភាពដ៏សកម្មរបស់ជាតិ** ស្ថិតក្នុងស្ថានភាពជួបនូវវិបត្តិសង្គមឬរឿងអយុត្តិធម៌ក្នុងសង្គម ស្ត្រីខ្មែរតែងតែចេញមុខតវ៉ាជារឿយៗ ដើម្បីទាមទារឱ្យបាននូវយុត្តិធម៌សង្គម។

. **ស្ត្រីខ្មែរជាក្តីសង្ឃឹមរបស់បុរស** ទីណាដែលមានស្ត្រី គឺទីនោះតែងតែមានក្តីសង្ឃឹម មានស្នាមញញឹម និងភាពជឿជាក់សម្រាប់បុរស ព្រោះថាស្ត្រីខ្មែរគឺជាអ្នកដែលមានសិល្បៈខ្ពស់ ក្នុងការចរចាក៏ដូចជាការលើកទឹកចិត្ត។ ឧទាហរណ៍ ក្រុមហ៊ុនដែលឈានមុខនៅលើទីផ្សារគេច្រើនយកស្ត្រីមកធ្វើជាអ្នកទំនាក់ទំនង ដូចការងារទទួលភ្ញៀវ ការងារលេខាធិការ និងការងារលក់ដូរជាដើម ព្រោះថាស្ត្រីខ្មែរមានសិល្បៈខាងការរៀបចំតុបតែង មានដំណើរទន់ភ្លន់ និងចេះប្រើពាក្យពេចន៍សុភាពរាបសារ ព្រមទាំងមានភាពឈ្លាសវៃ នៅក្នុងទំនាក់ទំនងជាដើម។

. **ស្ត្រីខ្មែរ គឺជាកម្លាំងដ៏មុតស្រួចរបស់សហគមន៍ក៏ដូចជាប្រទេសជាតិ** ស្ត្រីខ្មែរមានចំនួនច្រើនជាងបុរស ជាមនុស្សឧស្សាហ៍ព្យាយាមនៅក្នុងការងារ។ ការងារដែលស្ត្រីខ្មែរធ្វើ មានដូចជាការងារសិល្បៈ កសិកម្ម ឧស្សាហកម្ម សេវាកម្មទេសចរណ៍ ពាណិជ្ជកម្មខ្នាតតូច សេវាអប់រំ សិប្បកម្មជាដើម។ល។ ដែលការងារទាំងអស់នេះសុទ្ធតែអាចផ្តល់កំណើនខ្ពស់ដល់សេដ្ឋកិច្ចជាតិ។

. **ស្ត្រីខ្មែរជាគ្រូបង្រៀនរបស់ជាតិ** ស្ត្រីខ្មែរគឺជាមនុស្សសក្តិសមទី១នៅក្នុងវិស័យអប់រំនៅបឋមសិក្សា។ ការអប់រំមនុស្ស គឺជាកិច្ចការសំខាន់ដែលមិនអាចខ្វះបាន។ ការអប់រំកុមាររឹតតែសំខាន់ណាស់ទៅទៀត វាមិនខុសពីការដាំដើមរុក្ខជាតិឡើយ គឺដើម្បីបានឈើល្អយកទៅប្រើប្រាស់ គេត្រូវតែមានបច្ចេកទេសដាំដើមឈើឱ្យបានល្អតាំងតែពីតូចទៅ។ ការអប់រំកុមារ គឺមានការពឹងពាក់ច្រើនទៅលើស្ត្រី ព្រោះថាស្ត្រីមានភាពទន់ភ្លន់ជាងបុរស មានភាពអត់ធន់ ក្នុងការងារផងទាំងពួង ជាពិសេសជាមួយនឹងក្មេង។

. **ស្ត្រីខ្មែរជាអ្នកឈានមុខគេនៅក្នុងកិច្ចថែរក្សាវប្បធម៌** មិនថាការងារសិប្បកម្ម ការងារសិល្បៈ ចរិយាមារយាទ សំដីសំដៅ ការស្លៀកពាក់។ល។ គឺស្ត្រីមានភាពសកម្មនៅក្នុងការថែរក្សានូវអត្តសញ្ញាណរបស់ជាតិ។ ការហូរចូលនូវវប្បធម៌ពាលានានា មិនអាចមកពង្វក់ឱ្យស្ត្រីខ្មែរភ្លេចអត្តសញ្ញាណជាតិកំណើត ដ៏ល្អផូរផង់របស់ខ្លួនបានឡើយ។ របាំអប្សរា គឺបានក្លាយជាសម្បត្តិបេតិកភណ្ឌអរូបិយភណ្ឌពិភពលោក ក៏ព្រោះតែមានស្ត្រីជាអ្នកចូលរួមការពារ។

តាំងតែពីបុរាណកាលរហូតមកដល់ពេលបច្ចុប្បន្ននេះ ខ្មែរមានស្ត្រីឆ្នើមច្រើនរូបរាប់មិនអស់ដែលបានធ្វើពលិកម្មធំធេង ដើម្បីជាតិមាតុភូមិប្រកបដោយមោទនភាព មានដូចជា៖ ព្រះនាង**សោមា**( លីវយី ) ព្រះនាង**ឥន្ទ្រទេវី**

ម្ចាស់ក្សត្រី **កុសមៈ នារីរ័ត្ន** សម្តេចម៉ែ(**មុនីនាថនរោត្តមសីហនុ**) សម្តេចកិត្តិព្រឹទ្ធបណ្ឌិត(**ប៊ុនរ៉ានី ហ៊ុនសែន**) លោកជំទាវ **ពេជ្រ ចន្ទមុនី ហ៊ុន ម៉ាណែត** សម្តេចសង្ឃហបណ្ឌិត **ម៉ែន សំអន** សម្តេចរដ្ឋសភាធិបតី **ឃួន សុដារី** លោកជំទាវ **អ៊ឹង កន្ថាភាវី** អ្នកស្រី **សិទ្ធ** អ្នកស្រី **កែវ ច័ន្ទបូរណ៍** អ្នកស្រី **ប៉ាល់ វណ្ណារក្ស** អ្នកស្រី **ពេជ្រ សង្វារ៉ាន** អ្នកស្រី **ពុង ឈីវកេក** អ្នកស្រី **អ៊ុំ សុផានី** អ្នកស្រី **រស់ សេរីសុទ្ធា**។ល។

បើក្រឡេកទៅមើលស្រ្តីនៅក្នុងពិភពលោក យើងវិញយើងក៏ឃើញមានស្រ្តីជាច្រើនដែលប្រកបទៅដោយគុណតម្លៃរាប់មិនអស់ដែលយើងម្នាក់ៗ តែងតែស្គាល់គ្រប់ៗគ្នាដូចជា លោកស្រី **អ៊ុងសាន ស៊ូជី** លោកស្រី **អារីយ៉ូ** លោកស្រី **ហ៊ីឡារី គ្លីនតុន** អ្នកស្រី **តេរីសា** លោកស្រី **អ៊ែនជីណាជូលា** លោកស្រី **ម៉ាហ្គារែត ថាច់ផ័រ**។ល។ ដែលលោកទាំងអស់នេះមានបេសកកម្មផ្សេងៗគ្នា ក្នុងបុព្វហេតុសង្គម មនុស្សធម៌ នយោបាយ និងសិល្បៈ។

សរុបមកវិញស្រ្តី គឺពិតជាមានតម្លៃដ៏ធំធេងសម្រាប់សង្គម ប្រទេសជាតិក៏ដូចជាពិភពលោកទាំងមូល។ យើងទាំងអស់គ្នាគួរតែនាំគ្នាលើកស្ទួយតម្លៃស្រ្តីបានខ្ពស់ស្មើនឹងបុរស។ យើងគួរតែយល់ដឹងឱ្យច្បាស់ពីសុខទុក្ខរបស់ស្រ្តី និងចេះផ្តល់ឱកាសឱ្យស្រ្តីមានលទ្ធភាពនៅក្នុងការកសាងពិភពលោកដែលមិនអាចខ្វះបានជាមួយបុរស ជាពិសេសសូមរដ្ឋាភិបាលពង្រឹងការយកចិត្តទុកដាក់បន្ថែមក្នុងលើកកម្ពស់សិទ្ធិស្រ្តី ផ្តល់តម្លៃសង្គមទៅឱ្យស្រ្តីឱ្យបានកាន់តែច្រើន ស្រ្តីអាចធ្វើអ្វីបានច្រើន ដែលមានរឿងខ្លះបុរសមិនអាចធ្វើបាន ប៉ុន្តែបែជាស្រ្តីអាចធ្វើបាន ដូចជាការចាំបីបាច់ថែរក្សាកូនប្រកបដោយទំនួលខុសត្រូវជាដើម។

ពាក់ពន្ធនឹងបញ្ហាទាំងអស់នេះ បច្ចុប្បន្នក្រសួងកិច្ចការនារីបានធ្វើផែនការយុទ្ធសាស្ត្រនារីរតនៈទី៦(២០២៤-២០២៨) ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងបច្ចេកវិទ្យាឌីជីថល បង្កើនសុខុមាលភាពនិងផ្តល់តម្លៃឱ្យស្ត្រី និងក្មេងស្រីបន្ថែមទៀត។ ក្នុងឱកាសនោះ រដ្ឋមន្ត្រីក្រសួងកិច្ចការនារីលោកស្រី **អ៊ឹង កន្ថាផាវី** ថ្លែងថា *ការងារលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី ជាការងារយូរអង្វែង ដែលទាមទារឱ្យមានការចូលរួមពីគ្រប់ដៃគូទាំងអស់ ទាំងស្ថាប័នរដ្ឋ និងឯកជន។* លោកស្រីបន្ថែមថា *ក្រសួងកិច្ចការនារីបានដំណើរការតាក់តែង «ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨» ដើម្បីចូលរួមអនុវត្តតាមការចង្អុលបង្ហាញក្នុងក្របខណ្ឌយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ព្រមទាំងធ្វើឱ្យស៊ីចង្វាក់ជាមួយនឹងក្របខណ្ឌគោលនយោបាយជាតិ និងកម្មវិធីតាមវិស័យ និងការឆ្លើយតបទៅនឹងស្ថានភាព និងការវិវត្តរបស់សង្គម។*

ក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ផ្តោតលើយុទ្ធសាស្ត្រស្នូលមួយ និងយុទ្ធសាស្ត្រសំខាន់ៗចំនួន៦។ យុទ្ធសាស្ត្រស្នូលគឺការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍គ្រប់វិស័យ និងគ្រប់កម្រិតដោយប្រើប្រាស់អភិក្រមបរិវត្តកម្មយេនឌ័រ។ ចំណែកយុទ្ធសាស្ត្រសំខាន់ៗចំនួន៦រួមមាន *ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ការលើកកម្ពស់តម្លៃសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ ការលើកកម្ពស់សុខុមាលភាពស្ត្រីនិងក្មេងស្រី កិច្ចការពារផ្នែកច្បាប់សម្រាប់ស្ត្រីនិងក្មេងស្រី ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចស្ត្រី និងការប្រែប្រួលអាកាសធាតុ។*

សូមបញ្ជាក់ថា ផែនការយុទ្ធសាស្ត្រនារីរតនៈត្រូវបានបង្កើតឡើងជារៀងរាល់៥ឆ្នាំម្តង ដែលលើកដំបូងបង្កើតឡើងនៅឆ្នាំ១៩៩៩។ ដើម្បីឱ្យផែនការនេះកាន់តែមានប្រសិទ្ធភាព ក្រសួងបានរៀបចំការតាមដាន និងការត្រួតពិនិត្យការអនុវត្តតាមរយៈការរៀបចំសន្និបាតប្រចាំឆ្នាំ កិច្ចប្រជុំប្រចាំឆ្នាំនៅតាមអង្គភាពនីមួយៗ តាមមូលដ្ឋាន និងខេត្ត ដើម្បីពិនិត្យមើលលើការអនុវត្ត។

តាមការសង្កេតជាទូទៅ អំពើហិង្សាផ្អែកលើយេនឌ័រ ការរំលោភបំពានផ្លូវភេទទាំងផ្ទាល់ និងតាមប្រព័ន្ធអនឡាញមកលើស្ត្រីនិងកុមារ ព្រមទាំងការបៀតបៀនលើស្ត្រីជាកម្មករនិយោជិត និងស្ត្រីក្នុងវិស័យផ្សេងទៀតនៅតែជាក្តីព្រួយបារម្ភ។ ចំណែកក្រុមជនជាតិដើមភាគតិច ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ស្ត្រីមានពិការភាព ក៏ធ្លាប់ឆ្លងកាត់អំពើហិង្សានៅក្នុងកម្រិតខ្ពស់ ហើយត្រូវប្រឈមនឹងឧបសគ្គដ៏ខ្លាំងក្លាក្នុងការទទួលបានយុត្តិធម៌ និងសំណងប៉ះប៉ូវការខូចខាតផ្សេងៗ។ នេះបើតាមរបាយការណ៍ ស្តីពី ការតាមដានលើការអនុវត្តអនុសញ្ញាស៊ីដាវ(CEDAW) សម្រាប់ប្រទេសកម្ពុជាឆ្នាំ២០២២ ដែលចេញកាលពីថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០២៣។

យុទ្ធសាស្ត្រថ្មីនេះ មានភាពវិជ្ជមានច្រើន ហើយវាអាចជាផ្លូវត្រួសត្រាយនាំស្ត្រីនិងក្មេងស្រីទទួលបានការពង្រឹងសិទ្ធិអំណាចពិតប្រាកដ ប្រសើរជាងមិនមានសារៈសំខាន់ក្នុងការចូលរួមចំណែកគាំពារដល់ស្ត្រី និងកុមារនៅកម្ពុជា ក៏ប៉ុន្តែនិយាមសង្គមដែលនៅតែចាក់ឫសយ៉ាងជ្រៅក្នុងកម្រិតពីតួនាទីយេនឌ័រ ឬទស្សនៈឱ្យតម្លៃស្ត្រីដែលចេះស្តាប់បង្គាប់ អាចនាំឱ្យមានអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅគ្រប់ដំណើរការនៃជីវិត នៅផ្ទះ សហគមន៍ ឬនៅកន្លែងការងារ ក៏ដូចជានៅកន្លែងផ្សេងៗ។ ដូច្នេះយើងគួរសហការគ្នាដោយបង្កើនការយកចិត្ត

ទុកដាក់លើបញ្ហាប្រឈមដែលកំពុងកើតមានចំពោះយេនឌ័រ ដ្បិតថាយេនឌ័រជាកម្លាំងចលករដ៏សំខាន់ ពោលគឺស្ត្រីនិងបុរសជាដៃគូដែលមិនអាចខ្វះបានក្នុងការកសាងសង្គមជាតិក៏ដូចជាក្នុងពិភពលោក៕

# គន្ថនិទ្ទេស

. ក្រុមប្រឹក្សាជាតិភាសាខ្មែរ ***វចនានុក្រមខ្មែរ*** ការផ្សាយរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា បោះពុម្ពលើកទី១ ឆ្នាំ២០២២។
. ក្រសួងអប់រំយុវជននិងកីឡា ***សិក្សាសង្គមថ្នាក់ទី១០*** បោះពុម្ពផ្សាយ ឆ្នាំ២០១៦។
. ក្រសួងកិច្ចការនារី ***យេនឌ័រ និងការអប់រំ*** ឆ្នាំ២០១០។
. ក្រសួងកិច្ចការនារី ***ការបញ្ជ្រាបយេនឌ័រ*** ឆ្នាំ២០១០។
. ខ្លូត ធីតា ***បរិបទប្រវត្តិសាស្ត្រនៃស្ត្រីខ្មែរ*** សិក្ខាសាលា ឆ្នាំ២០១៧។
. ជួន ណាត ***វចនានុក្រមខ្មែរ*** ភាគ១ និងភាគ២
. ញ៉ុក ថែម ***រឿងកុលាបប៉ៃលិន***
. ញ៉ុក ថែម ***ទសជាតក*** (ព្រះវេស្សន្ត)
. ញ៉ុក ថែម ***បញ្ញាសជាតក*** (ក្រុងសុភមិត្ត)
. ឌឹក គាម និង ឡឿក អំ ***ភូមិតិរច្ឆាន*** ភ្នំពេញ ឆ្នាំ១៩៧១។
. ត្រឹង ងា ***វប្បធម៌អរិយធម៌***
. ថាច់ ត្វាន់ ***ប្រវត្តិសាស្ត្រប្រជាជាតិខ្មែរ*** គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ គ.ស.២០១០។
. ធនាគារពិភពលោកសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ ***កម្ពុជា ភាពក្រីក្រអាចកាត់បន្ថយពាក់កណ្ដាលបានទេនាឆ្នាំ២០១៥?*** ភ្នំពេញ ២០០៦។
. ជា សុកម៉េង ***តួនាទីស្ត្រីខ្មែរតាមរយៈប្រវត្តិសាស្ត្រនិងអក្សរសិល្ប៍*** ទស្សនាវដ្ដីសង្គមសាស្ត្រ-មនុស្សសាស្ត្រ ឆ្នាំ២០០៤ ទំព័រ៤។
. ប៊ុតសាវង្ស ***ស្ត្រីក្នុងព្រះពុទ្ធសាសនា*** ទំព័រ ៣២,៤៦ ព.ស.២៥៥១។
. ប៉ុន ចន្ទម៉ុល ***ចរិតខ្មែរ*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៧២។
***. ព្រះត្រៃបិដក*** ភាគ២៩ ភាគ៦៣(វិធុរជាតក)។
. ពុទ្ធសាសនបណ្ឌិត្យ ***ប្រជុំរឿងព្រេងខ្មែរ*** ភាគ១ដល់ភា៩
. ព្រះអង្គឌួង ***ច្បាប់ស្រី*** វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦២។

. ភិក្ខុសោម *រឿងទុំទាវ*

. មីសែលត្រាណេ *សង្គមខ្មែរក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧* គ.ស.២០០៣។

. មៀច ប៉ុណ្ណ **កម្រងឯកសារស្ដីអំពីប្រពៃណីទំនៀមទម្លាប់ខ្មែរ** ភាគ៤ គ.ស.២០១២។

. រាជបណ្ឌិត្យសភាកម្ពុជា ***ទស្សនវិជ្ជាខ្មែរសម័យអង្គរ*** គ.ស. ២០០៨។

. សុត្តន្តប្រីជាឥន្ទ ***សុភាសិតច្បាប់ស្រី*** បោះពុម្ពលើកទី៣។

. សេរីវុធ Learner's Dictionary បោះពុម្ពលើកទី១ គ.ស.១៩៩៧។

. វង្ស អែមសំអាន***សង្គមវិជ្ជាគ្រួសារ*** ឆ្នាំ២០០៩។

. ឡឹក រ៉ាវី ***រឿងជាតិស្ត្រី***

. អង្គឌួង *កាកី*

. វេបសាយនានា

. https://www.srpostnews.com/article/42981

. https://rhac.org.kh/km

. https://www.bing.com/search

. https://khmer.voanews.com/

# ឧបសម្ព័ន្ធទី១

## ព្រះរាជក្រឹត្យ

នស/រកត/០៨២៣/១៩៨១

**ស្ដីពី**

**ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា**

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៧៧២ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១** : បញ្ចប់តំណែងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានតែងតាំងសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា និងតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ដែលមានសមាសភាព ដូចតទៅ៖

**I-នាយករដ្ឋមន្ត្រី**

ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត**

**II-ឧបនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម នេត សាវឿន
២- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន
៣- ឯកឧត្តម ស៊ុន ចាន់ថុល
៤- ឯកឧត្តម ហង់ជួន ណារ៉ុន
៥- ឯកឧត្តម សាយ សំអាល់
៦- ឯកឧត្តម ស សុខា
៧- ឯកឧត្តម ទៀ សីហា
៨- ឯកឧត្តម កើត រិទ្ធ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៩- ឯកឧត្តម សុខ ចិន្តាសោភា
១០-ឯកឧត្តម វង្សី វិស្សុត

**III-ទេសរដ្ឋមន្ត្រី**

១- ឯកឧត្តម គន់ គីម (ទទួលបន្ទុកបេសកកម្មពិសេស)
២- ឯកឧត្តម ហូ សិទ្ធី (ទទួលបន្ទុកបេសកកម្មពិសេស)
៣- ឯកឧត្តម អ៊ុក រ៉ាប៊ុន (ទទួលបន្ទុកបេសកកម្មពិសេស)
៤- ឯកឧត្តម ឱម យ៉ិនទៀង (ទទួលបន្ទុកបេសកកម្មពិសេស)
៥- ឯកឧត្តម អៀង ម៉ូលី (ទទួលបន្ទុកបេសកកម្មពិសេស)
៦- ឯកឧត្តម ថោង ខុន (ទទួលបន្ទុកបេសកកម្មពិសេស)
៧- ឯកឧត្តម ពេជ សោភ័ន (ទទួលបន្ទុកបេសកកម្មពិសេស)
៨- ឯកឧត្តម ព្រុំ សុខា (ទទួលបន្ទុកបេសកកម្មពិសេស)
៩- ឯកឧត្តម សក់ សេដ្ឋា (ទទួលបន្ទុកបេសកកម្មពិសេស)
១០-ឯកឧត្តម អូស្មាន ហាស្សាន់ (ទទួលបន្ទុកបេសកកម្មពិសេស)
១១-ឯកឧត្តម អ៊ី ឈាន (ទទួលបន្ទុកបេសកកម្មពិសេស)
១២-ឯកឧត្តម អ៊ុក ប្រាជ្ញា (ទទួលបន្ទុកបេសកកម្មពិសេស)
១៣-ឯកឧត្តម អ៊ុច បូរិទ្ធ (ទទួលបន្ទុកបេសកកម្មពិសេស)
១៤-ឯកឧត្តម ស្វាយ ស៊ីថា (ទទួលបន្ទុកបេសកកម្មពិសេស)
១៥-ឯកឧត្តម ផៃ ស៊ីផាន (ទទួលបន្ទុកបេសកកម្មពិសេស)
១៦-ឯកឧត្តម លី ធុជ (ទទួលបន្ទុកបេសកកម្មពិសេស)
១៧-ឯកឧត្តម ឆែម គាតរិទ្ធី (ទទួលបន្ទុកបេសកកម្មពិសេស)
១៨-ឯកឧត្តម ឈៀង យ៉ាណារ៉ា (ទទួលបន្ទុកបេសកកម្មពិសេស)
១៩-ឯកឧត្តម សុក ស៊ីផាន់ណា (ទទួលបន្ទុកបេសកកម្មពិសេស)
២០-ឯកឧត្តម កែវ រ៉េមី (ទទួលបន្ទុកបេសកកម្មពិសេស)
២១-ឯកឧត្តម គី តិច (ទទួលបន្ទុកបេសកកម្មពិសេស)

**IV-រដ្ឋមន្ត្រី**

១- ឯកឧត្តម វង្សី វិស្សុត រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
២- ឯកឧត្តម ស សុខា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
៣- ឯកឧត្តម ទៀ សីហា រដ្ឋមន្ត្រីក្រសួងការពារជាតិ
៤- ឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
៥- ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៦- ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៧- ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- លោកជំទាវ ចម និម្មល — រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
៩- ឯកឧត្តម ហែម វណ្ណឌី — រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
១០-ឯកឧត្តម កែវ រតនៈ — រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល
១១-ឯកឧត្តម ប៊ិន ត្រឈៃ — រដ្ឋមន្ត្រីក្រសួងផែនការ
១២-ឯកឧត្តម ហង់ជួន ណារ៉ុន — រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
១៣-ឯកឧត្តម ជា សុមេធី — រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
១៤-ឯកឧត្តម សាយ សំអាល់ — រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១៥-ឯកឧត្តម អ៊ាង សុផល្លែត — រដ្ឋមន្ត្រីក្រសួងបរិស្ថាន
១៦-ឯកឧត្តម ថោ ជេដ្ឋា — រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
១៧-ឯកឧត្តម នេត្រ ភក្ត្រា — រដ្ឋមន្ត្រីក្រសួងព័ត៌មាន
១៨-ឯកឧត្តម កើត រិទ្ធ — រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
១៩-ឯកឧត្តម ហួត ហាក់ — រដ្ឋមន្ត្រីក្រសួងអធិការកិច្ច
២០-ឯកឧត្តម ជា វ៉ាន់ដេត — រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
២១-ឯកឧត្តម ឈាង រ៉ា — រដ្ឋមន្ត្រីក្រសួងសុខាភិបាល
២២-ឯកឧត្តម ប៉េង ពោធិ៍នា — រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
២៣-លោកជំទាវ ភឿង សកុណា — រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
២៤-ឯកឧត្តម សុខ សូកេន — រដ្ឋមន្ត្រីក្រសួងទេសចរណ៍
២៥-ឯកឧត្តម ចាយ បូរិន — រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា
២៦-លោកជំទាវ អ៊ឹង កន្ថាផាវី — រដ្ឋមន្ត្រីក្រសួងកិច្ចការនារី
២៧-ឯកឧត្តម ហេង សួរ — រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
២៨-ឯកឧត្តម ហ៊ុន ម៉ានី — រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
២៩-ឯកឧត្តម ម៉ៅ ហាវណ្ណាល់ — រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
៣០-ឯកឧត្តម ឡាំ ជា — រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

**មាត្រា២** : ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

[illegible]

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣*

# ប្រវត្តិរូបសង្ខេប



## ១- ប្រវត្តិផ្ទាល់ខ្លួន៖

នាមត្រកូលនិងនាមខ្លួន **ជា វណ្ណី** (CHEA Vanny) កើតថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅក្រុងភ្នំពេញ ដែលមានលោកឪពុកនាម **ជា ម៉ៅ** និងអ្នកម្ដាយនាម **ផាត់ វណ្ណា** មានបងប្អូន៦នាក់ បងស្រីនាម **ជា វណ្ណៈ** ប្អូនស្រីនាម **ជា វណ្ណី** និងប្អូនប្រុស **ជា សុផាន់ណារ៉ា ជា ធារិទ្ធ ជា វិសារ័ត្ន ជា វិរៈ**។ រៀបការនៅឆ្នាំ២០០១ ស្វាមីមាននាម **ទុយ យូឃីម** និងមានកូន២នាក់ កូនស្រីនាម **ទុយ ទេពវនោថ** និងកូនប្រុសនាម **ទុយ ទិព្វធរណិន្ទ**។ បច្ចុប្បន្នជាប្រធាននាយកដ្ឋាន ធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា។

## ២- ប្រវត្តិការសិក្សា៖

ឆ្នាំ២០០៩-២០១៣ សិក្សាថ្នាក់បណ្ឌិតផ្នែកអក្សរសិល្ប៍ នៅរាជបណ្ឌិត្យកម្ពុជា។ ឆ្នាំ២០០០-២០០២ សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកអក្សរសិល្ប៍ នៅរាជបណ្ឌិត្យសភាកម្ពុជា។ ឆ្នាំ១៩៩៧-១៩៩៨ សិក្សានៅមហាវិទ្យាល័យគរុកោសល្យ ផ្នែកអក្សរសាស្ត្រខ្មែរ។ ឆ្នាំ១៩៩៣-១៩៩៧ សិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកអក្សរសាស្ត្រខ្មែរ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ឆ្នាំ១៩៨៩-១៩៩២ សិក្សានៅវិទ្យាល័យឥន្ទ្រទេវី។ ឆ្នាំ១៩៨៦-១៩៨៩ សិក្សានៅអនុវិទ្យាល័យទួលគោក និងឆ្នាំ១៩៨២-១៩៨៦ សិក្សានៅសាលាបឋមសិក្សាវត្តនាគវ័ន្ត។

## ៣- ប្រវត្តិការងារ៖

ឆ្នាំ១៩៩៤-១៩៩៦ ប្រធានការិយាល័យបុគ្គលិកនៃមជ្ឈមណ្ឌលវប្បធម៌ខ្មែរ។ ឆ្នាំ១៩៩៨-២០០១ ជាគ្រូបង្រៀននៅវិទ្យាល័យជាស៊ីមព្រែកអញ្ចាញ។ ឆ្នាំ២០០១-

២០១៨ ជាមន្ត្រីស្រាវជ្រាវនៃរាជបណ្ឌិត្យសភាកម្ពុជា បម្រើការនៅវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។ ឆ្នាំ២០១៨ ប្រធានផ្នែកធម្មសាស្ត្រនិងចរិយាសាស្ត្រនៅវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ៣។ ២០២៤-២០២៩ ទីប្រឹក្សាមជ្ឈមណ្ឌលស្រាវជ្រាវកម្ពុជា នៃសាកលវិទ្យាល័យជីវជាំង ខេត្តជាំងស៊ុ ប្រទេសចិន។

## ៤-ស្នាដៃស្រាវជ្រាវនិងចងក្រង៖

ឆ្នាំ២០០២ស្នាដៃសារណាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់«**រឿងរាមកេរ្តិ៍ក្នុងវប្បធម៌ខ្មែរ**»។ ឆ្នាំ២០០៤ស្នាដៃ«**អន្លោគ្រាមសួយ**»។ ឆ្នាំ២០០៦ស្នាដៃ«**អន្លោគ្រាមព័រ**»។ឆ្នាំ២០០៧ ស្នាដៃ «**រឿងព្រេងនិទានជនជាតិភាគតិច**»។ ឆ្នាំ២០០៨ ស្នាដៃ «**អក្សរសិល្ប៍ខេត្តកណ្តាល**»។ ឆ្នាំ២០១០ ស្នាដៃ«**ការអប់រំមិនផ្លូវការរបស់ជនជាតិដើមភាគតិចគ្រឹងនិងទំពួន**»។ ឆ្នាំ២០១១ ស្នាដៃ«**ព្រហ្មញ្ញសាសនានៅក្នុងសង្គមខ្មែរ**»។ ឆ្នាំ២០១៣ ស្នាដៃនិក្ខេបបទថ្នាក់បណ្ឌិត«**រឿងរាមកេរ្តិ៍ក្នុងសង្គមខ្មែរ**»។ ឆ្នាំ២០១៥ ស្នាដៃ « Women's Right and Role in Khmer Folktale Literature»។ ឆ្នាំ២០១៦ ស្នាដៃ «**ក្បួនតែងកំណាព្យខ្មែរ**» និង«**អក្សរសិល្ប៍ប្រជាប្រិយខ្មែរ**»។ ឆ្នាំ២០១៧ ស្នាដៃ «**អក្សរសិល្ប៍សម័យមុនអង្គរនិងអង្គរ**» និង«**អក្សរសិល្ប៍សម័យក្រោយអង្គរ**»។ ឆ្នាំ២០១៨ ស្នាដៃ «**អក្សរសិល្ប៍បស្ចិមប្រទេស**» និង «**អក្សរសិល្ប៍អំណែតអណ្តូងនិយមនិងតថនិយម**»។ ឆ្នាំ២០១៩ ស្នាដៃ«**កាព្យប្រវត្តិពង្សក្សត្រខ្មែរ**»។ ឆ្នាំ២០២១ «**កាព្យប្រវត្តិអក្សរសិល្ប៍ខ្មែរ**»។ ឆ្នាំ២០២២ ស្នាដៃ «**តម្លៃអប់រំបណ្តុះធម្មចរិយា**» ។ ឆ្នាំ២០២៣ ស្នាដៃ «**អរិយធម៌ខ្មែរ**»។ ឆ្នាំ២០២៤ ស្នាដៃនេះ «**បច្ចុប្បន្នភាពនៃយេនឌ័រនិងតួនាទីយេនឌ័រនៅកម្ពុជា**»។

## ៥- សញ្ញាបត្រដែលបានទទួល៖

ឆ្នាំ១៩៩២ បានទទួលសញ្ញាបត្រមធ្យមទុតិយភូមិ។ ឆ្នាំ១៩៩៧ បានទទួលសញ្ញាបត្របរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ នៅសាកលភូមិន្ទភ្នំពេញ។ ឆ្នាំ១៩៩៨ បាន

ទទួលសញ្ញាបត្រគ្រូមធ្យមសិក្សាទុតិយភូមិ បរិញ្ញា+១ អក្សរសាស្ត្រខ្មែរ នៅវិទ្យាស្ថានជាតិអប់រំ។ ឆ្នាំ២០០២ បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកអក្សរសិល្ប៍នៅរាជបណ្ឌិត្យសភាកម្ពុជា និងឆ្នាំ២០១៣បានទទួលសញ្ញាបត្របណ្ឌិតផ្នែកអក្សរសិល្ប៍នៅរាជបណ្ឌិត្យសភាកម្ពុជា។

## ៦- កិត្តិយសដែលបានទទួលៈ

ខែមេសា ឆ្នាំ២០០៩ បានទទួលមេដាយការងារថ្នាក់ «**សំរិទ្ធ**»។ ខែមីនា ឆ្នាំ ២០១១ បានទទួលមេដាយការងារថ្នាក់«**ប្រាក់**»។ ខែធ្នូ ឆ្នាំ២០១២ បានទទួលមេដាយការងារថ្នាក់«**មាស**»។ ឆ្នាំ២០១៨ ត្រូវបានរាជរដ្ឋាភិបាលតែងតាំងជាប្រធានផ្នែកធម្មសាស្ត្រនិងចរិយាសាស្ត្រ វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើប្រធាននាយកដ្ឋាន។ ឆ្នាំ២០១៨ ទទួលបានគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់**ធិបឌិន្ទ** ពីរាជរដ្ឋាភិបាល។ ខែមីនា ឆ្នាំ ២០២០ បានទទួលពានរង្វាន់ក្នុង វិស័យអប់រំ " Outstanding International Education Award " នាទីក្រុងបាងកក ប្រទេសថៃ។ ខែកក្កដា ឆ្នាំ២០២៤ ទទួលបានគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ពីរាជរដ្ឋាភិបាល។ ខែកក្កដា ឆ្នាំ ២០២៤ ទទួលបានការតែងតាំងជាទីប្រឹក្សាមជ្ឈមណ្ឌលស្រាវជ្រាវកម្ពុជានៃសាកលវិទ្យាល័យជីជាំង ខេត្តជាំងស៊ី ប្រទេសចិន។